# ហេតុអ្វីបានជាវៀតណាមឈ្លានពានកម្ពុជា

និពន្ធដោយៈ ស្ទីហ្វិន ហ្សេ ម៉ូរីស

ប្រែសម្រួលដោយៈ នួន សុខវ៉ាង

## វប្បធម៌នយោបាយ និង មូលហេតុនៃសង្គ្រាម









# វាចាអ្នករៀបរៀង

ដោយយល់ឃើញថា សៀវភៅឈ្មោះ " **ហេតុអ្វីបានជាវៀតណាមឈ្លានពានកម្ពុជា** " របស់លោក ស្ទីហ្វិន ម៉ូរីស មានប្រយោជន៍សំខាន់សម្រាប់កូនចៅខ្មែរជំនាន់នេះនិងជំនាន់ក្រោយ ដើម្បីដឹងនិងយល់អំពីកលល្បិចរបស់យួន ក្នុងការវាតទីនិងពង្រីកអនុត្តរភាពរបស់ខ្លួនមកលើអធិបតេយ្យរបស់ខ្មែរ ខ្ញុំបានឆ្លៀតពេលប្រែសម្រួលភាគខ្លះៗដែលទាក់ទិនពីរឿងខ្មែរនិងយួន ក្នុងគោលបំណងផ្សព្វផ្សាយជាតុពិតនៃប្រវត្តិសាស្ត្រឱ្យបានជ្រួតជ្រាបក្នុងមជ្ឈដ្ឋាននៃប្រជាពលរដ្ឋខ្មែរទូទៅ ។ សៀវភៅនេះនឹងជំរាបលោកអ្នក ថាតើថ្ងៃ ៧មករា១៩៧៩ ជាថ្ងៃអ្វី ? តើជាថ្ងៃដែល **បរទេសស្រោចស្រង់ជីវិតខ្មែរដោយចេតនា** ឬជាថ្ងៃដែល **បរទេសឈ្លានពានខ្មែរដោយចេតនា** ? ខ្ញុំសូមអភ័យទោសអំពីសំណាក់អស់លោកអ្នកអានផងដែរ បើសិនជាមានការថ្គាំថ្គងក្នុងសំនួនវោហារឃ្លោងឃ្លា ។ ខ្ញុំនឹងរង់ចាំទទួលជានិច្ចនូវគ្រប់ការទិទៀនស្ថាបនាទាំងឡាយដែលអាចកើតមានឡើងដោយថាហេតុ ។

ខ្ញុំសូមថ្លែងអំណរគុណជាអតិបរមាចំពោះលោក **ហ្វ្រេងគ្លីន លី** ( Franklin Ly) ដែលបានបរិច្ចាគធនធានរបស់លោកក្នុងការជួយបោះពុម្ពចម្លងសៀវភៅនេះ ។ សូមលោកនិងក្រុមគ្រួសារបានសម្រេចនូវបំណង**ល្អ**គ្រប់យ៉ាងក្នុងជីវិតរបស់លោក ៕

ដោយការរាប់អានដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

នួន សុខវ៉ាង

# មាតិការឿង


១- ឧទ្ទិសកថា

២- វាចាអ្នករៀបរៀង

៣- ពាក្យបំព្រួញ ទំព័រ២

៤- ជំពូកមួយ: ឫសគល់នៃជម្លោះ ទំព័រ៣

៥- ជំពូកពីរ: ការងើបឡើងជាសាធារណៈ និងការធ្លាក់ចុះ ជាសម្ងាត់នៃយុទ្ធសាមគ្គីភាពយួននិងខ្មែរកុម្មុយនិស្តៈ ១៩៧០-១៩៧៥ ទំព័រ២៧

៦- ជំពូកបី: នយោបាយការបរទេសរបស់កម្ពុជាប្រជាធិបតេយ្យៈ ១៩៧៥-១៩៧៨ ទំព័រ៥០

៧- ជំពូកបួន: ការបែកបាក់យុទ្ធសាមគ្គីភាពនៅឥណ្ឌូចិន ទំព័រ៦៨

៨- ជំពូកប្រាំ: យុទ្ធសាស្ត្របែកផ្លូវគ្នារបស់សូវៀតនិងវៀតណាម ចំពោះកម្ពុជា ទំព័រ៩៦

៩- ជំពូកប្រាំមួយ: ផលវិបាកនៃការឈ្លានពានរបស់វៀតណាម ទំព័រ១០៨

១០- កំណត់សម្គាល់ ទំព័រ១២១

# ហេតុអ្វីបានជាវៀតណាមឈ្លានពានកម្ពុជា

និពន្ធដោយ ស្ទីហ្វិន ជេ ម៉ូរីស

ប្រែសម្រួលដោយ គួន សុខវ៉ាង

# Why Vietnam Invaded Cambodia

Stephen J. Morris

Political Culture
And
The Causes Of war

វប្បធម៌នយោបាយ

និង

មូលហេតុនៃសង្គ្រាម

## ពាក្យបំព្រួញ

| | |
|---|---|
| ១_ក.ក.វ.ត. | ការិយាល័យ កណ្ដាលសំរាប់ វៀតណាមខាង ត្បូង |
| ២_ក.ប. | កម្ពុជា ប្រជាធិបតេយ្យ |
| ៣_ ក.អ. | កុម្មុយនិស្ត អន្តរជាតិ |
| ៤_ កុម. | កុម្មុយនិស្ត |
| ៥_ខ.ក. | ខ្មែរ ក្រហម |
| ៦_ខ.វ. | ខ្មែរ វៀតមិញ |
| ៧_ប.ក.ក. | បក្ស កុម្មុយនិស្ត កម្ពុជា |
| ៨_ប.ក.ថ. | បក្ស កុម្មុយនិស្ត ថៃ |
| ៩_ប.ក.វ. | បក្ស កុម្មុយនិស្ត វៀតណាម |
| ១០_ប.ក.ស.ស. | បក្ស កុម្មុយនិស្ត សហភាព សូវៀត |
| ១១_ប.ក.ឥ. | បក្ស កុម្មុយនិស្ត ឥណ្ឌូចិន |
| ១២_ប.ព. | ប៉ុល ពត |
| ១៣_វ.ក. | វៀត កុង |
| ១៤_វ.ជ. | វៀតណាមខាង ជើង |
| ១៥_វ.ត. | វៀតណាមខាង ត្បូង |
| ១៦_វ.ម. | វៀតមិញ |
| ១៧_ស.ប.ច | សាធារណរដ្ឋ ប្រជាមានិត ចិន |
| ១៨_ស.ប.ប.ក. | សាធារណរដ្ឋ ប្រជាមានិត ប្រជាធិបតេយ្យ កូរ៉េ |
| ១៩_ស.រ.អ. | សហ រដ្ឋ អាមេរិក |
| ២០_ស.ស. | សហភាព សូវៀត |
| ២១_ស.ស.វ. | សាធារណរដ្ឋ សង្គមនិយម វៀតណាម |
| ២៣_ស.ស.ស.ស. | សាធារណរដ្ឋ សង្គមនិយម សហភាព សូវៀត |

# ជំពូកមួយ

## ១_ឫសគល់នៃជម្លោះ

## យួនកុម្មុយនិស្តនិងខ្មែរ,១៩៣០_១៩៧០

ក្នុងរយៈពេលជាង៥ទសវត្ស វៀតណាមកុម្មុយនិស្តបានធ្វើការឃោសនាប្រកបដោយជោគជ័យ អំពីប្រវត្តិ-សាស្ត្ររបស់ជាតិគេ ថាជានិមិត្តរូបដ៏យូរលង់មួយនៃរឿងនិទាននៅក្នុងគម្ពីគ្រិស្តសាសនារបស់ ដេវីឌ ច្បាំងនឹងយក្ស បរទេស (ហ្គោលីយ៉ាត) ចិន បារាំង និងអាមេរិកាំង ។ ទោះជារឿងនិទាននេះពិតយ៉ាងណាក៏ដោយ ការណ៍ពិតវាបានយ៉ាងច្រើនណាស់ត្រឹមតែពាក់កណ្តាលប៉ុណ្ណោះ ។ គេបានលាក់នូវការពិតមួយផ្នែកធំនៃប្រវត្តិសាស្ត្រវៀតណាម គឺការដែលថាមវន្តអារ្យធម៌ (អារ្យធម៌ដែលមានថាមពល) នៃជនចំណាកស្រុកពីប្រទេសចិនដែលបានធ្វើដំណើរជានិរន្តទៅទិសខាងត្បូងនិងទិសខាងលិច ដើម្បីច្បាំងដណ្តើមយកប្រទេសជិតខាងតូចតាចនិងទន់ខ្សោយ ហើយនិងបានបំផ្លិចបំផ្លាញនូវវប្បធម៌របស់គេនៅពេលដែលខ្លួនធ្វើនិគមកិច្ចទៅលើប្រទេសទាំងនោះ ។

## ២_នយោបាយក្រៅប្រទេសបែបបុរាណរបស់វៀតណាមចំពោះកម្ពុជា:

អារ្យធម៌វៀតណាមបានចាប់ផ្តើមនៅដីសណ្តទន្លេក្រហមនៃប្រទេសវៀតណាមសព្វថ្ងៃ កាលពីកន្លះសហស្សវត្សមុនគ.ស. ។ ការរីកសាយនៃអារ្យធម៌វៀតណាម ដំបូងឡើយគឺការប៉ះទង្គិចគ្នាជាមួយជនជាតិចាមកាន់ព្រាហ្មណ៍សាសនានៃអាណាចក្រចម្ប៉ា ដែលលូតលាស់ចម្រើនហើយដែលសព្វថ្ងៃគេហៅវៀតណាមកណ្តាល ។ ក្រោយពីសង្គ្រាមក្តៅគគុកពាក់សតវត្ស ជាមួយរាជវង្សយួនភាគខាងជើង ប្រទេសចម្ប៉ាបានត្រូវបាត់បង់មួយផ្នែកធំនៅក្នុងពាក់កណ្តាលទីពីរនៃសតវត្សទី១៥ ។ ជនជាតិចាមដែលនៅសេសសល់ ទីបំផុតត្រូវគេសម្លាប់រង្គាល រត់ខ្ចាត់ខ្ចាយចោលស្រុកនៅចុងសតវត្សទី១៧ ។ រាជវង្សចាម ព្រមទាំងជនភៀសខ្លួនចាម៥០០០នាក់បានរត់ទៅជ្រកកោននៅប្រទេសកម្ពុជាក្នុងឆ្នាំ១៦៩២ ។ សព្វថ្ងៃ មាននៅសល់ជនជាតិចាមខ្លះដែរនៅវៀតណាម តែនៅឆ្នាំ១៩៦០ ចំនួនមនុស្សមានតែ២៨,០០០នាក់ប៉ុណ្ណោះ បើប្រៀបធៀបនឹង៣០,០០០គ្រួសារ នៅសតវត្សទី១១ ។

ខ្មែរ ដែលជាក្រុមជាតិពន្ធធំជាងគេ ហើយដែលមានប្រទេសនិងប្រជាជនជាម្ចាស់ទឹកដី គឺជាមុខព្រួញទីពីរដែលអារ្យធម៌ដ៏ល្បីល្បាញបានត្រូវបំផ្លិចបំផ្លាញក្រោមកណ្តាប់ដៃយួន ។ អារ្យធម៌ខ្មែរសម័យអង្គរបានរីកឡើងខ្ពស់ត្រដែតដល់កំពូលនៅសតវត្សទី១៣ ។ តែអារ្យធម៌នេះក៏ត្រូវបានធ្លាក់ចុះមកវិញក្នុងសតវត្សជាបន្តបន្ទាប់ មួយផ្នែកធំតាមរយៈសង្គ្រាមដែលជាស្នាដៃរបស់សៀម ។ ទឹកន្លែងសព្វថ្ងៃដែលគេហៅវៀតណាមខាងត្បូង ជាទឹកដីដែលខ្មែរធ្លាប់រស់នៅ មុនការមកដល់នៃជនជាតិវៀតណាមក្នុងសតវត្សទី១៧ ។ ប៉ុន្តែ នយោបាយបុរាណភាព

ទឹកដីបានត្រូវកាត់ផ្តាច់ម្តងបន្តិចៗទៅឱ្យអធិរាជវៀតណាម ។ មកដល់ចុងសតវត្សទី១៨ ទឹកដីខ្មែរចេះតែរួញទៅៗ។

វប្បធម៌ និងស្ថាប័នជាច្រើនរបស់វៀតណាម គឺជាលទ្ធផលដ៏សម្បើមលើសលប់ ដែលគេបានរៀនក្បួនពីចិន ។ វៀតណាមបានអនុវត្តទស្សនសាកលរបស់ចិន ។ ឧទាហរណ៍: អធិរាជវៀតណាមជាអ្នកទទួលរាជសម្បត្តិពីព្រះអាទិទេព ។ ដូច្នេះ បរទេសត្រូវតែខ្លបខ្លាចអំណាចខ្លួន ។ យោងតាមគំរូស្តេចចិន បានតម្រូវឱ្យស្តេចយួនបង្កើតនូវប្រព័ន្ធទំនាក់ទំនងជាអន្តរជាតិមួយ ដើម្បីផ្តោតលើ **ការយកប្រទេសជនទៃដាក់ជាចំណុះ** ។ ប្រទេសជិតខាងរបស់វៀតណាមត្រូវតែបញ្ជូន"បេសកជន និងសួយសាអាករទៅថ្វាយអធិរាជយួនតាមកំណត់ ដើម្បីថ្លែងនូវការដឹងគុណដែលជាទំនៀមទម្លាប់របស់គេ" ។

ស្តេចយួនធ្វើតម្រាប់តាមចិននេះ គឺដើម្បីតាំងខ្លួនជាចៅហ្វាយនៃអ្នកជិតខាងរបស់គេ ។ ឧទាហរណ៍: វៀតណាមបានចាត់ទុកអារ្យធម៌ខ្មែរថាជា "មនុស្សព្រៃទល់ដែន" ជាពាក្យដែលចិនប្រើសម្រាប់សម្គាល់ជនជាតិភាគតិចមិនមែនចិន នៅក្នុងសម័យសន្តតិវង្សជិន ។ ប្រទេសជាតិខ្មែរបានត្រូវគេហៅថា "ប្រទេសនៃពួកមនុស្សព្រៃលើ" (the country of the upper barbarians)។

តែទោះយ៉ាងណាក៏ដោយ ការប៉ុនប៉ងរបស់ស្តេចយួនក្នុងការចម្លងយកមេរៀនពីចិននេះ បានត្រូវរាំងស្ទះដោយភាពជាក់ស្តែងផ្នែកភូមិសាស្ត្រ: ចិនជាប្រជាជាតិដ៏ធំមួយដែលឥទ្ធិពលវប្បធម៌និងសេដ្ឋកិច្ចគ្មានប្រទេសជិតខាងណា នៅអាស៊ីខាងកើតនិងអាស៊ីអគ្នេយ៍ អាចប្រកួតជាមួយបានឡើយ ។ ផ្ទុយទៅវិញ វៀតណាមជាប្រទេសមួយដែលមានឥទ្ធិពលមធ្យមនៅក្នុងតំបន់ ហើយដែលកម្លាំងក៏ប្រហាក់ប្រហែលគ្នានឹងគូរប្រកួតជិតខាងរបស់គេដែរ ជាអាទិ៍ គឺ សៀមនិងភូមា ។ ហេតុនេះ ទស្សនៈជាថានានុក្រមនៃនយោបាយអន្តរជាតិដោយចិន និងវៀតណាមបានផ្តល់នូវភាពប្រាកដនិយមដែលទាក់ទងនឹងឥទ្ធិពលចិននៅក្នុងតំបន់ ប៉ុន្តែគ្មានន័យអ្វីទេចំពោះមធ្យោបាយរបស់វៀតណាមទៅលើអ្នកជិតខាងជាច្រើនរបស់គេ ហើយចេះតែបន្តប្រកួតប្រជែងដោយអ្នកជិតខាងខ្លាំងមួយទៀត គឺសៀម ។ នៅពាក់កណ្តាលទីមួយនៃសតវត្សទី១៩ អ្នកជិតខាងដែលយួនចាត់ទុកថាជាចំណុះរបស់គេនោះ គឺមានតែរាជវាំងហ្លួងព្រះបាងនិងវៀងចាន់ *(ទីក្រុងទាំងពីរស្ថិតនៅក្នុងប្រទេសលាវសព្វថ្ងៃ)* និងរាជវាំងភ្នំពេញ*(សព្វថ្ងៃជារាជធានីនៃប្រទេសកម្ពុជា)* តែប៉ុណ្ណោះ ។

អធិរាជយួនបានចាប់ជ្រៀតជ្រែកចូលនយោបាយផ្ទៃក្នុងរបស់កម្ពុជាយូរអង្វែងមកហើយ គឺតាំងពីមុនប្រទេសវៀតណាមរួមចូលគ្នាក្នុងឆ្នាំ១៨០២ម្ល៉េះ ។ ជារឿយៗ នៅក្នុងកំលុងសតវត្សទី១៨ វៀតណាមតែងតែឆ្លើយតបទៅនឹងការហៅរកជំនួយ (ជំនួយយោធា) ពីស្តេចខ្មែរដែលដណ្តើមរាជ្យគ្នា ដោយស្តេចខ្មែរម្នាងទៀតរក់

ទៅពឹងសៀម ។ តែជាទូទៅ អធិរាជយួនចូលចិត្តគ្រប់គ្រងដោយប្រយោល ។

នៅដើមសតវត្សទី១៩ ក្រោយពីបានលេបយកទឹកដីភាគខាងត្បូងនៃកម្ពុជាមួយផ្នែកធំបានហើយ វៀត-ណាមបានបង្កើនភារកិច្ចរបស់គេជាលំដាប់លំដោយ នៅក្នុងប្រទេសដ៏រាវស្តួចដែលជាអ្នកជិតខាងរបស់ខ្លួន ។ នៅឆ្នាំ១៨១៣ ក្រោយពីបានចូលរួមក្នុងការលើក អ្នកអង្គចន្ទ (ព្រះបាទអង្គចន្ទ) ឲ្យឡើងសោយរាជ្យ យួនបានធ្វើជាអាណាព្យាបាលលើកម្ពុជា ។ ប៉ុន្តែ ក្រោយពីអ្នកអង្គចន្ទសុគតទៅនៅឆ្នាំ១៨៣៤ អធិរាជយួនក្រុងហ្វេបានយកកម្ពុជាទាំងមូលធ្វើជាខេត្តរបស់ខ្លួន ។ ឯពួកអណិកជនចិន ដែលធ្វើអន្តោប្រវេសន៍ចូលមកវៀតណាម ត្រូវអ្នកដឹកនាំយួនក្រោយៗមកទៀតបញ្ចុះបញ្ចូលឲ្យមករស់នៅកម្ពុជា ។

នៅក្រោមអាណានិគមរបស់ខ្លួននាកំលុងឆ្នាំ១៨៣០ យួនបានបង្ខិតបង្ខំខ្មែរឲ្យទទួលយកវប្បធម៌របស់គេ ។ មិនត្រឹមតែបានបញ្ជូនអ្នករដ្ឋការរបស់គេមកស្រុកខ្មែរប៉ុណ្ណោះទេ តែគេថែមទាំងបានព្យាយាមប្តូរសម្លៀកបំពាក់ ភាសា និងកសិកម្មរបស់ខ្មែរទៀតផង ។ យួនសង្ឃឹមទៀតថា គេនឹងអាចបញ្ចូលសាសនាមហាយានរបស់ចិន_យួនមកក្នុងសាសនាថេរវាទរបស់ខ្មែរ ។ ខ្មែរភាគច្រើនយល់ឃើញថា វប្បធម៌ចក្រពត្តិយួនមានភាពក្រអឺតក្រអោងជាងចក្រពត្តិសៀម ។ ហេតុនេះហើយ បានជាអធិរាជយួនបានចាត់ទុកខ្លួនគេថាជាសត្រូវស្លូពូជរបស់ខ្មែររហូតមកទល់សព្វថ្ងៃនេះ ។

## ៣_នយោបាយក្រៅប្រទេសបែបបុរាណរបស់ខ្មែរចំពោះវៀតណាមៈ

ជិតពីរសតវត្ស មុនពួកអាណានិគមបារាំងមកដល់នៅពាក់កណ្តាលសតវត្សទី១៩ ទំនាក់ទំនងរបស់ខ្មែរជាមួយវៀតណាម គឺគ្មានអ្វីក្រៅពីស្តេចខ្មែរឈ្លោះដណ្តើមរាជ្យគ្នា ហើយរត់ទៅរកយួនឲ្យជួយតែប៉ុណ្ណោះឡើយ ។ ជារឿយៗ ស្តេចខ្មែរតែងតែអំពាវនាវរកជំនួយទ័ពពីអធិរាជក្រុងហ្វេ ដើម្បីកម្ចាត់គូរប្រជែងរបស់ខ្លួន ។ ពួកម៉ាឡេចាម និងសៀមបានត្រូវភាគីខ្មែរឯទៀតហៅរក ដើម្បីជាជំនួយក្នុងគោលបំណងដូចគ្នា ។ ប៉ុន្តែនៅដើមសតវត្សទី១៨ សៀមនិងយួនបានក្លាយជាកត្តាចម្បងនៃជម្លោះផ្ទៃក្នុងរបស់ខ្មែរ ។ នៅសតវត្សទី១៨ កម្ពុជាធ្លាក់ខ្លួនជាប្រទេសចំណុះគេ ដែលអ្នកដឹកនាំតែងរត់រកការគាំពារពីសៀម ឬពីយួនជានិច្ច ។ ស្តេចនៃប្រទេសទាំងពីរនេះតែងបានលាភសក្ការៈ តាមបែបសម្បទានពីស្តេចខ្មែរវិញនូវទឹកដីខ្មែរដ៏ធំសម្បើម ។ ប្រទេសជិតខាងដ៏ធំទាំងពីរនេះក៏បានតម្រូវផងដែរឲ្យខ្មែរបន្តធ្វើជាអ្នកនៅក្រោមបង្គាប់របស់ខ្លួន តាមរយៈសួយសារអាករជាសម្ភារៈ និងសួយសារអាករជានិមិត្តរូប ។

រហូតមកដល់ដើមសតវត្សទី១៩ ទើបវៀតណាមបានរួបរួមគ្នា ។ ការរួមគ្នារបស់វៀតណាមបានបង្កើត

នូវកម្លាំងដ៏ខ្លាំងលើសលប់មួយក្នុងការគំរាមកំហែងឧត្តរជីវិត *(ការគង់វង្សជីវិត)* របស់កម្ពុជា ។

ពេញមួយសតវត្សទី១៩ ទំនាក់ទំនងរបស់ខ្មែរជាមួយយួនបានឆ្លងកាត់នូវព្រឹត្តិការណ៍ជាច្រើន ។ ចាប់ពីឆ្នាំ ១៧៩៤ដល់១៨០៦ ក្នុងពេលដែលយួនកំពុងជាប់ដៃធ្វើសង្គ្រាមស៊ីវិល កម្ពុជាស្ថិតនៅក្រោមឥទ្ធិពលស្តេចសៀម ។ ពីឆ្នាំ១៨០៦ដល់១៨១៤ ជាលើកទីមួយហើយដែលខ្មែរស្ថិតនៅក្រោមអាណាព្យាបាលភាពរបស់សៀមនិងយួន ។ ពីឆ្នាំ១៨១៤ដល់១៨៣០ អាណាព្យាបាលភាពរបស់យួនមានសារៈសំខាន់ណាស់ ។ ក្រោយឆ្នាំ១៨៣០ ឥទ្ធិពលវៀតណាមកើនខ្លាំងឡើង បណ្តាលឲ្យមានការទាមទារផ្តាច់ទឹកដីខ្មែរជាច្រើននៅចន្លោះឆ្នាំ១៨៣៥ និង១៨៤៥ ។ កម្ពុជាបាត់បង់ឯករាជ្យ ស្ថិតក្រៀមស្រពោនរហូតធ្លាក់ខ្លួនជា **ប្រទេសអាណាព្យាបាល** (a protectorate) នៃអ្នកជិតខាងទិសខាងកើតរបស់ខ្លួន ។

នៅក្នុងដំណាក់កាលនោះ ការងើបបះបោររបស់របស់របស់ប្រជាជនប្រឆាំងនឹងសៀម ហើយជាពិសេសប្រឆាំងនឹងយួនក៏កើតមានឡើង ។ យូរៗម្តង តែងមានការប្រឈមមុខគ្នាតាមផ្លូវទ័ពពីអ្នកជិតខាងណាមួយ ជាមួយនឹងកងកម្លាំងទ័ពខ្មែរនៅក្នុងទឹកដីដែលគេដណ្តើមយក ។ ប៉ុន្តែ គេមិនដែលឃើញមានការវាយប្រយុទ្ធណាមួយដែលបង្ហាញថាខ្មែរចង់បានប្រទេសជិតខាងរបស់គេឡើយ ។ មេដឹកនាំខ្មែរ ជាពិសេសស្តេចខ្មែរ មិនដែលបានតតាំងជា-មួយអ្នកជិតខាងខ្លួនទាំងពីរនៅពេលតែមួយម្តងណាឡើយ ។ ជានិច្ចកាល ជ័យជំនះទៅលើសត្រូវម្ខាង តែងតែតម្រូវឲ្យមានអនុសញ្ញាពីសត្រូវម្ខាងទៀត បើសិនជំនួយរបស់គេជាជំនួយលាក់មុខ ។ ហេតុនេះ បើទោះជាមេដឹកនាំខ្មែរអាចត្រូវជាអ្នកទទួលកំហុសចំពោះប្រសិទ្ធិភាពនៃសម្ពន្ធមិត្តរបស់គេក៏ដោយ ពួកគេគ្រាន់តែជាអ្នកប្រដេញតាមនយោបាយប្រឈមមុខខាងផ្នែកយោធាជាមួយនឹងអ្នកជិតខាងណាដែលមានឥទ្ធិពលខ្លាំងជាងប៉ុណ្ណោះ តាមរយៈតក្កវិជ្ជា *(ភាពសមហេតុសមផល)* នៃការថ្លឹងថ្លែងកម្លាំងរបស់សម្ពន្ធមិត្ត ។ ទង្វើនេះមិនត្រឹមត្រូវទេ តែគេត្រូវទទួលស្គាល់ថា ការណ៍ពិតវាត្រូវតែអញ្ចឹង ។

## ៤-វៀតណាមកុម្មុយនិស្តនិងវប្បធមបដិវត្តកុម្មុយនិស្តអន្តរជាតិ

មហិច្ឆតារបស់យួនកុម.នៅលាវនិងកម្ពុជា មិនត្រឹមតែជាលទ្ធផលនៃនយោបាយវប្បធម៌ជាប្រពៃណី និងបែបផែនចិត្តគំនិតរបស់គេប៉ុណ្ណោះទេ ។ លើសពីនោះទៅទៀត ការលោភលន់នេះបានត្រូវបញ្ជាក់ដោយទស្សនៈថ្មីៗរបស់កុម្មុយនិស្តអន្តរជាតិ *(ក.អ.)* ដែលត្រួតត្រាដោយសហភាពសូវៀត ហើយដែលនៅក្នុងនោះមាន ង្វៀនអាយកុក ឬហូជីមិញ *(ស្ថាបនិកនៃចលនាយួនកុម្មុយនិស្ត)* ជាមន្ត្រីយ៉ាងសកម្មម្នាក់ផង ។

ង្វៀនអាយកុកជាសមាជិកស្ថាបនិកម្នាក់នៃបក្សកុម្មុយនិស្តបារាំង ដែលបានបែកចេញពីបក្សសង្គមនិយម

បារាំងនៅឆ្នាំ១៩២០ ពីរឿងមិនស្មោះត្រង់នឹងក.អ. ។ នៅឆ្នាំ១៩២៣ គាត់បានចាកចេញពីប្រទេសបារាំងដោយលួចលាក់ តាមការអញ្ជើញរបស់ថ្នាក់ដឹកនាំក.អ. ដើម្បីចូលរួមក្នុងការហ្វឹកហ្វឺនដ៏ខ្លីមួយនៅការិយាល័យផ្នែកបូព៌ានៃក.អ. ។ គាត់បានសិក្សានៅមហាវិទ្យាល័យ **ជនគោកយ៉ាកទិសបូព៌** នៅទីក្រុងម៉ូស្គូ ហើយទទួលបន្ទុកធ្វើកិច្ចការជាមួយការិយាល័យ ក.អ.នៅប្រទេសចិន ។ យ៉ាងហោចណាស់ក៏១៦ឆ្នាំដែរ គឺគិតពីខែកក្កដា១៩២៣ ដល់ខែកក្កដា១៩៣៩ ដែលង្វៀនអាយកុកបានចូលរួមយ៉ាងសកម្មជាមន្ត្រីនៅក្នុងក.អ. បំពេញការងារនៅសហភាពសូវៀត អឺរ៉ុបខាងលិច ចិន ហុងកុង សៀម និងម៉ាឡេស៊ី ។ ប្រទេសវៀតណាមនិងប្រទេសជុំវិញទៀតនៃ **ឥណ្ឌូចិនបារាំង** មិនមែនជាចំណុចនយោបាយសំខាន់តែមួយគត់របស់គាត់ទេ បើទោះជាផ្នែកខ្លះនៃភារកិច្ចរបស់គាត់មានខ្លឹមសារសម្រាប់ខ្លួនគាត់ក៏ដោយ ។

ប៉ុន្មានឆ្នាំថ្មីៗនេះ យួនកុម.បានចាប់ផ្តើមបើកទំព័រថ្មី ចូលរួមអបអរសាទរជាមួយក.អ. ។ នៅឆ្នាំ១៩៨៤ ទិន្នានុប្បវត្តិប្រចាំខែរបស់វៀតណាមបានមួយសរសេរថា:

> **"ក.អ.បានផ្តល់ការណែនាំដល់បដិវត្តន៍ឥណ្ឌូចិន តាមការប៉ាន់ប្រមាណនៃស្ថានការណ៍អន្តរជាតិនិងការសម្រេចជាទូទៅលើមាតិកានយោបាយ និងអង្គការនៃប្រជាជននៅក្រោមអាណានិគម ក្នុងការតស៊ូប្រឆាំងនឹងចក្រពត្តិនិយម និងតាមរយៈការប៉ាន់ប្រមាណនិងសេចក្តីសម្រេចដ៏ច្បាស់លាស់ចំពោះស្ថានការណ៍នៅឥណ្ឌូចិន" ។**

គំនិតចង់ធ្វើសហព័ន្ធរបស់ប្រជាជនអស់ក្តីសង្ឃឹមដែលបារាំងហៅថាឥណ្ឌូចិន បានហូរចេញមកពីគំនិតក.អ. ដែលមានលំនាំដូចអនាគតសាធារណរដ្ឋសូវៀតនៅជុំវិញពិភពលោក ក្រោយពីបដិវត្តកុម្មុយនិស្តដណ្តើមបានអំណាច ។ ឆ្នាំ១៩២០ ឡេនីនបានសរសេរថា:

> **"សហព័ន្ធជាបែបផែនផ្លាស់ប្តូរមួយទៅរកឯកភាពពេញលេញនៃវណ្ណៈកម្មករនៃប្រជាជាតិផ្សេងៗគ្នា ។ ការអាចធ្វើសហព័ន្ធបាន បានត្រូវបង្ហាញឲ្យឃើញរួចទៅហើយនៅក្នុងការអនុវត្តន៍ ទាំងផ្នែកទំនាក់ទំនងរវាងសាធារណរដ្ឋសង្គមនិយមសហភាពសូវៀតរុស្ស៊ី (ស.ស.ស.ស.រ.) និងសាធារណរដ្ឋសូវៀតឯទៀត ហើយនិងទាំងផ្នែកទំនាក់ទំនងនៅក្នុងស.ស.ស.ស.រ. ចំពោះប្រជាជាតិទាំងឡាយដែលតាំងតែពីដើមមកមិនដែលស្គាល់ឋានៈជារដ្ឋពេញលេញ ឬរដ្ឋស្វយ័តឡើយ... ។ ហេតុនេះ ក.អ.មានភារកិច្ចក្នុងការបន្តអភិវឌ្ឍ សិក្សា និងសាកល្បងតាមការពិសោធន៍សហព័ន្ធថ្មីនេះ ដែលឈរនៅលើមូលដ្ឋាននៃ ប្រព័ន្ធសូវៀត និងចលនាសូវៀត" ។**

យោងតាមការនិពន្ធន៍ជាហូរហែរបស់ក.អ. មុនការឈានដល់ "អំណាចផ្តាច់ការវណ្ណៈអធនពិភពលោក" អនាគតប្លុកកុម្មុយនិស្តជាបណ្តាញមួយដែលប្រមូលផ្តុំរដ្ឋនីមួយៗ បញ្ចូលទៅក្នុង"សហភាពនៃសហព័ន្ធ" ។ នៅក្នុងលិខិតមួយ *(ដែលមានលក្ខណៈជាឪពុកនិយាយទៅរកកូន)* គណៈកម្មាធិការកណ្តាលបក្សកុម្ម.ចិនបានសរសេរទៅគណៈកម្មាធិការកណ្តាលបក្សកុម.ឥណ្ឌូចិននៅខែមេសា១៩៣៤ ដោយបានបញ្ជាក់យ៉ាងច្បាស់លាស់ថា:

> **"សមមិត្តទាំងឡាយត្រូវដើរតាមមាគ៌ារបស់យើង និងមាគ៌ារបស់សហភាពសូវៀត ។ គឺជាមាគ៌ាដ៏ជាក់លាក់មួយដែលមិនបរាជ័យ និងបានបង្ហាញផ្លូវទៅរកជ័យជំនះ... ។ កាន់ដៃគ្នាជាមួយបក្សកុម្មុយនិស្តបារាំង ជាមួយបក្សកុម្មុយនិស្តចិន ជប៉ុន ឥណ្ឌា និងឥណ្ឌូណេស៊ី ពួកម៉ាក់_ឡេនីននៅឥណ្ឌូចិននឹងបំបះបំបោរប្រជាជនដែលត្រូវគេជិះជាន់ ឲ្យងើបឡើងប្រឆាំងនឹងចក្រពត្តិនិយមលុះត្រាតែបានជោគជ័យ ។ របាំងរវាងតួមិនតាំងចិន (ក.អ.ចិន) និងឥណ្ឌូចិនបារាំងនឹងមិនអាចបំបែកប្រជាជនយើងបានឡើយ, សូវៀតឥណ្ឌូចិន និងសូវៀតចិននឹងរួមគ្នាជាមួយនឹងសហព័ន្ធពិភពលោកនៃសាធារណរដ្ឋសូវៀត ។ "**

ទ្រឹស្តីរបស់ក.អ.បានស្នើរឲ្យធ្វើ**សាកលភាវូបនីយកម្ម**តាមការពិសោធន៍របស់សូវៀត ។ ក្នុងករណីឥណ្ឌូចិននេះមានន័យថា ដោយហេតុវៀតណាមមានប្រជាជនច្រើនលើសលប់ វៀតណាមជាអ្នកដើរតួ ធ្វើខ្មែរនិងលាវឲ្យទៅជាសហព័ន្ធឥណ្ឌូចិន ដូចរុស្ស៊ីយកប្រទេសជិតខាងរបស់ខ្លួនធ្វើសហភាពសូវៀតដូច្នោះដែរ ។ ចំពោះរឿងនេះ ពួកសូវៀតរុស្ស៊ីចេះតែថាឲ្យរួចពីមាត់ប៉ុណ្ណោះ អំពីគំនិតដែលខ្លួនចង់រកសិទ្ធិឲ្យប្រជាជាតិតូចតាច ក្នុងការកំណត់វាសនាខ្លួនដោយឯង។ ប៉ុន្តែ គ្រប់ការប៉ុនប៉ងដោយរដ្ឋាភិបាលរបស់សាធារណរដ្ឋសូវៀតទាំងឡាយក្នុងការរកសិទ្ធិនោះតែងតែបានជួបប្រទះជានិច្ចនូវការគាបសង្កត់យ៉ាងខ្លាំងក្លា ។

## ៥_បក្សកុម្មុយនិស្តឥណ្ឌូចិននៅលាវនិងនៅកម្ពុជា:១៩៣០_៤៥

នៅក្រោមឥទ្ធិពលក.អ. មេដឹកនាំយួនកុម.បានដៅទុកយ៉ាងត្រឹមត្រូវទៅលើនយោបាយអនាគតរបស់លាវនិងខ្មែរ តាំងពីបក្សរបស់គេចាប់កកើតឡើងម្ល៉េះ ។ មុនដំបូង មានបក្សកុម.មួយនៅប្រទេសបារាំងបានប្រកាសថាជាបក្សឯករាជ្យ ។ តែមួយខែក្រោយមក បក្សនេះក៏បានក្លាយខ្លួនជាសមាជិកជំនិតរបស់ក.អ. ។អាយកុកបានបំភ្លេចចោលនូវពិធីការគណៈកម្មាធិការប្រតិបត្តិរបស់ក.អ. ចុះថ្ងៃ២៨វិច្ឆិកា១៩២៩ ដែលបានអំពាវនាវដល់គ្រប់បក្សទាំងអស់ឲ្យចូលរួមគ្នាជាមួយ **បក្សកុម្មុយនិស្តឥណ្ឌូចិន** *(ប.ក.ឥ.)* ។ ចុងឆ្នាំ១៩៣០ ក្រោយពីក.អ.បានសើរើឡើងវិញអំពីបញ្ហាឈ្មោះបក្ស គេក៏បានចេញបញ្ជាឲ្យប្តូរឈ្មោះកុម្មុយនិស្តអន្តរជាតិឲ្យទៅជា**បក្សកុម្មុយនិស្តឥណ្ឌូចិន វិញ**។

ក.អ.បានពន្យល់ថា ឈ្មោះបក្សគឺជា "ចំណុចទាក់ទាញក្រុមកុម្មុយនិស្តទាំងអស់នៅឥណ្ឌូចិន ដូចជាបក្សនៃពួកវណ្ណៈអធនទាំងអស់នៅវៀតណាម កម្ពុជា លាវ ។ល។ " ម្យ៉ាងទៀត មិនត្រឹមតែមានឯកភាពខាងផ្នែកភូមិសាស្ត្រ សេដ្ឋកិច្ច និងនយោបាយប៉ុណ្ណោះទេ តែជាទូទៅ យើងត្រូវការនូវឯកភាពក្នុងការតស៊ូ នូវឯកភាពក្នុងទិសដៅសម្រាប់វណ្ណៈអធនទាំងអស់នៅឥណ្ឌូចិន ដើម្បីប្រឆាំងគ្រប់កម្លាំងប្រតិកិរិយានៅឥណ្ឌូចិន ដើម្បីប្រឆាំងនឹងនយោបាយបែងចែករបស់ចក្រពត្តិនិយមបារាំង ។

សម័យប្រជុំពេញអង្គមួយនៃគណៈកម្មាធិការបណ្ដោះអាសន្នប.ក.វ. បានប្រព្រឹត្តទៅនៅខែតុលា១៩៣០ ។ ស្របទៅតាមដំណោះស្រាយរបស់ក.អ. ឈ្មោះបក្សបានត្រូវប្តូរទៅជាបក្សកុម្មុយនិស្តឥណ្ឌូចិន ។

តាមការណ៍ពិត កាលនោះមិនទាន់មានចលនាបដិវត្តត្រឹមត្រូវនៅកម្ពុជានិងលាវនៅឡើយទេ ។ ឯសមាជិកស្ថាបនិកចំនួន២១១នាក់ មិនមាននរណាម្នាក់ពីកម្ពុជាឬពីលាវឡើយ ។ ដោយឡែក យោងតាមការវិភាគរបស់យួនកុម.នៅពេលថ្មីៗនេះបានបញ្ជាក់ថាៈ " កម្មវិធីនយោបាយរបស់បក្សឆ្នាំ១៩៣០ បានធ្វើផែនការណ៍សម្រាប់បដិវត្តន៍នៃប្រទេសនីមួយៗ ។ ចន្ទៈរបស់ក.អ.បានចែងយ៉ាងច្បាស់ថាៈការរំដោះឱ្យរួចជា **អ្នកជា** នៃប្រជាជាតិទាំងបីនៅឥណ្ឌូចិនបារាំង មិនអាចធ្វើបានដោយប្រទេសនីមួយៗតែម្នាក់ឯងឡើយ តែត្រូវប្រព្រឹត្តទៅក្រោមព្យាបាលភាពរបស់យួនកុម. ។ មុនសង្គ្រាមលោកលើកទីពីរ គំនិតទាំងនេះគ្រាន់តែជាការចាំទ្បានតែប៉ុណ្ណោះ ដោយហេតុថានៅលាវនិងកម្ពុជា បដិវត្តន៍មិនអាចកើតមានបានឡើយ ។ ប៉ុន្តែ យើងបានផ្តល់ដល់វៀតណាមនូវលទ្ធិស្របច្បាប់មួយ ហើយនិងគម្រោងគំនិតដល់ពួកគេ និងទស្សនៈវិស័យនយោបាយរបស់យើងដែលអាចធ្វើឱ្យចេញរូបរាងឡើងជាយថាហេតុ ។ "

ក្នុងកំលុងឆ្នាំ១៩៣០ ប.ក.ឥ.បានរវល់ជាប់ដៃក្នុងការប្រយុទ្ធតស៊ូដ៏ខ្លាំងក្លាជាមួយនឹងគូប្រកួតនយោបាយនៅវៀតណាម ។ ប.ក.ឥ.មិនដែលមានលទ្ធភាពគ្រប់សង្កត់លើចលនាប្រឆាំងបារាំងឡើយ រហូតមកដល់ក្រោយសង្គ្រាមលោកលើកទីពីរ ។ មុនសង្គ្រាមលោកលើកទីពីរ ប.ក.ឥ.ជាចលនាប្រឆាំងនឹងពួកអាណានិគមមួយក្នុងចំណោមចលនាជាច្រើន ។ នៅខែមេសា១៩៣៨ ចលនានេះមានសមាជិកជិតពីរពាន់នាក់ដែលភាគច្រើន ច្រើនតែប្រព្រឹត្តមិនស្របច្បាប់ ។ ប៉ុន្តែ ចលនាកុម្មុយនិស្តនេះមានជំហរគ្រាន់បើជាងក្រុមកុម្មុយនិស្តនៅលាវនិងកម្ពុជា។

មុនសង្គ្រាមលោកលើកទីពីរ មិនសូវមានចលនាកុម្មុយនិស្តទេនៅក្នុងប្រទេសជិតខាងទាំងពីរនេះ ។ ឯកសារសម្ងាត់ផ្ទៃក្នុងរបស់ ប.ក.ឥ.បានបង្ហាញថា នៅក្នុងអង្គការបក្ស មានភាគច្រើនជាជនជាតិភាគតិចចិននិងយួន ។ ឧទាហរណ៍ៈ តាមលិខិតឆ្លើយឆ្លងជាមួយក្រុងម៉ូស្គូ ខែកញ្ញា១៩៣០ ង្វៀនអាយកុកបានបញ្ជាក់ថាៈ

“នៅស្រុកខ្មែរមានសមាជិកបក្ស១២៤នាក់ ដែលនៅក្នុងនោះ ១២០នាក់ជាជនជាតិចិន និង៤នាក់ជាជាតិអណ្ណាម (យួន) ។ សហជីពការងារមានជាតិពន្ធចិនចំនួន៣០០នាក់ ”។ នៅឆ្នាំ១៩៣៤ មន្ត្រីនៃក.អ.បានកវ៉ាថា:“នៅកម្ពុជា និងលាវ ជនម្ចាស់ស្រុកចាំបាច់ត្រូវតែចូលរួមជាមួយអង្គការបក្ស ។ ”

ខែមីនា១៩៣៥ នៅពេលដែលបារាំងចាប់ធ្វើការបោសសម្អាតពួកកុម្មុយនិស្តជាបន្តបន្ទាប់ នៅកម្ពុជាមានសមាជិកបក្ស៩នាក់, គ្មានចលនាយុវជនកុម្មុយនិស្តទេ, សហភាពពាណិជ្ជកម្មមានសមាជិក៤នាក់, និងសហភាពកសិករមានសមាជិក៥០នាក់ស្ថិតនៅក្រោមបញ្ជារបស់ប.ក.ឥ. ។ នៅប្រទេសលាវ ដែលប្រជាជនមានតែមួយភាគបីនៃប្រជាជនខ្មែរ ប.ក.ឥ.មានសមាជិក៣២នាក់, ចលនាយុវជនមាន២៥នាក់, សហភាពពាណិជ្ជកម្មមាន៥៥នាក់, និងសម្ព័ន្ធប្រឆាំងចក្រពត្តិមានសមាជិក៦៩នាក់ ។ មួយឆ្នាំក្រោយមក នៅខែកក្កដា១៩៣៦ សមាជិកភាពរបស់បក្សនៅប្រទេសលាវបានធ្លាក់មកនៅ២៨ ចំណែកឯនៅប្រទេសខ្មែរវិញ មានបក្សកុម្មុយនិស្តមួយក្រុមតូចដែលកាត់ផ្តាច់ពីបក្សកុម្មុយនិស្តវៀតណាម ។ នៅខែមេសា១៩៣៨ បក្សខ្មែរដែលជាសាខារបស់ប.ក.ឥ.មានសមាជិក១៦នាក់ដែលទាំងអស់គ្នាសុទ្ធតែជាចិន និងមានសមាជិក១០០នាក់នៅក្នុងសហភាពពាណិជ្ជកម្ម ។

យោងតាមសមាជិកភាពដែលបង្ហាញពីភាពទន់ខ្សោយរបស់ប.ក.ឥ.នៅកម្ពុជានិងនៅលាវ យើងត្រូវបញ្ជាក់បន្ថែមនូវព្រឹត្តិការណ៍មួយចំនួនទៀត ។ **ទីមួយ** នៅពាក់កណ្តាលឆ្នាំ១៩៣០ រចនាសម្ព័ន្ធរបស់ប.ក.ឥ.ទូទាំងវៀតណាមបានចុះទន់ខ្សោយ បណ្តាលមកពីការគាបសង្កត់របស់បារាំង ។ ឆ្នាំ១៩៣៥ នៅអណ្ណាម (វៀតណាមកណ្តាល) និងនៅតុងកឹង(វៀតណាមខាងជើង) ចលនាប.ក.ឥ.ស្ទើរតែមិនមានសោះ ។ ឧទាហរណ៍ ទីក្រុងហាណូយមានសមាជិកបក្សតែ៣០នាក់ប៉ុណ្ណោះ ។ **ទីពីរ** ដោយសារភាពទន់ខ្សោយរបស់អង្គការប.ក.ឥ.នៅកម្ពុជានិងលាវ អង្គការនេះត្រូវតែបង្ហាញនូវភាពម៉ឺងម៉ាត់ ។ មុនសមាជបក្សខែមីនា១៩៣៥ អង្គការបក្សពីកម្ពុជា កូសាំងស៊ីននិងអណ្ណាមខាងត្បូងបានត្រូវបញ្ចូលគ្នាឱ្យនៅក្រោមការដឹកនាំរបស់អង្គការកូសាំងស៊ីនដ៏ខ្លាំងមួយ ។ នៅក្នុងសមាជបក្សឆ្នាំ១៩៣៥ មានគណៈប្រតិភូ១៣មកចូលរួម ដែលនៅក្នុងនោះមានៈ ១តំណាងប្រទេសលាវ ៣តំណាងអង្គការរួមរបស់កូសាំងស៊ីន អណ្ណាមខាងត្បូង និងកម្ពុជាផង ។ តាមការណ៍ពិត ឥណ្ឌូចិនទាំងមូលគឺជាគោលដៅនយោបាយ និងភូមិសាស្ត្ររបស់ ប.ក.ឥ. ។

នៅឆ្នាំ១៩៤០ ប.ក.ឥ.បានពន្យុះឱ្យមានការងើបបះបោរប្រឆាំងនឹងអំណាចអាណានិគមបារាំង ។ ប៉ុន្តែការបះបោរនៅឆ្នាំ១៩៣០_៣១ បានជួបប្រទះនូវការគាបសង្កត់ជាខ្លាំង ។ បក្សត្រូវបែកខ្ចាត់ខ្ចាយ ។ មេដឹកនាំ

និងកម្មាភិបាលជាន់ខ្ពស់ខ្លះទៀតបានលាក់ខ្លួនបំពួនអាត្មាដោយសុខស្រួលនៅប្រទេសចិន ក្នុងតំបន់ដែលគ្រប់គ្រងដោយកងទ័ពក្រហមរបស់ម៉ៅ ។ ដល់ឆ្នាំ១៩៤១ ពួកនេះត្រូវត្រឡប់មកវៀតណាមវិញ ។

នៅក្នុងការបះបោរមិនបានសម្រេចជាបន្តបន្ទាប់នាឆ្នាំ១៩៤០ កាតព្វកិច្ចចម្បងរបស់ប.ក.ឥ.គឺត្រូវរៀបចំជាថ្មីឡើងវិញនូវចលនានយោបាយដ៏ត្រឹមត្រូវមួយនៅវៀតណាម ។ ខែឧសភា១៩៤១ អាយកុកបានបង្កើតបក្ស **វៀតណាមដុកឡាប់ដុងមិញហូយ** (សម្ព័ន្ធឯករាជ្យវៀតណាម) ឬវៀតមិញ នៅក្រោយរបាំង **អង្គការស្នេហាជាតិមិនមែនកុម្មុយនិស្ត** ដែលដឹកនាំដោយកម្មាភិបាលប.ក.ឥ. ។ គោលបំណងគឺប្រមូលកម្លាំងប្រជាជនប្រើ ដើម្បីប.ក.ឥ.ដណ្ដើមយកអំណាច ។ ក្រោយមក ដើម្បីបិទបាំងផែនការកុម្មុយនិស្តអន្តរជាតិរបស់ខ្លួន ង្វៀនអាយកុកបានដាក់របាសុនាមខ្លួនឯងថា **ហូជីមិញ** ។ បើទោះជាឈ្មោះហូជីមិញមិនសូវបានស្គាល់ពីសំណាក់ជនជាតិវៀត-ណាមភាគច្រើនមុនឆ្នាំ១៩៤៥ក៏ដោយ ក៏គាត់បានបង្កើតរួចទៅហើយនូវអង្គការនយោបាយតូចមួយដែលបើកប្រតិ-បត្តិការនៅតំបន់មូលដ្ឋានដាច់ស្រយាល ។

រដ្ឋប្រហាររបស់ជប៉ុន ទម្លាក់របបអាណានិគមទីក្រុងវីស៊ីនៃប្រទេសបារាំង នៅខែមីនា១៩៤៥ គឺជាសញ្ញាផ្លូវចិត្តដ៏សំខាន់មួយនៅលាវ និងកម្ពុជាក៏ដូចជានៅវៀតណាមដែរ ។ រដ្ឋប្រហារនេះបានដកហូតមកវិញនូវការព្រឹទ្ធិស៊ុះសាយពីមុនមក ដែលថាបារាំងជាជនជាតិមួយមិនដែលចាញ់អ្នកណាសោះ ។ ហេតុនេះហើយ បានជានៅពេលជប៉ុនចុះចាញ់នៅខែសីហា១៩៤៥ ចលនាទាំងឡាយនៅក្នុងតំបន់បានស្ទុះងើបឡើងដើម្បីបំពេញកន្លែងចន្លោះប្រហោង ។ ការងើបតស៊ូដ៏មហិមានេះបានត្រូវគេហៅថា **"បដិវត្តន៍ខែសីហា"** (បដិវត្តន៍យកគំរូតាមលទ្ធិម៉ាក់-ឡេនីន) ដែលបានផ្ដល់នូវកិត្យានុភាពយ៉ាងសម្បើមដល់ពួកវៀតមិញរបស់ប្រធាន **ហូ** នៅទូទាំងវៀតណាម ។ ប៉ុន្តែការខំប្រឹងប្រែងចរចាទាមទារឯករាជ្យពីបារាំងរបស់ហូជីមិញអស់រយៈពេល១៥ខែ មិនបានជោគជ័យឡើយ ។ សង្គ្រាមក៏បានផ្ទុះឡើងនៅខែធ្នូ ១៩៤៦ ។

ក្រោយសង្គ្រាមលោកលើកទីពីរ លទ្ធិកុម្មុយនិស្តនៅតែមានឥទ្ធិពលទៅលើក្រុមតស៊ូប្រឆាំងរដ្ឋការអាណា-និគមបារាំងនៅលាវនិងកម្ពុជា តាមមាគ៌ាដឹកនាំរបស់វៀតណាម ។ ក្រោយការផ្ទុះសង្គ្រាមរវាងពួកវៀតមិញនិងបារាំង កិច្ចប្រតិបត្តិការសឹករបស់វៀតមិញភាគច្រើនត្រូវបានប្រព្រឹត្តទៅនៅក្នុងប្រទេសវៀតណាមខ្លួនឯង ។ ប៉ុន្តែនៅលាវនិងកម្ពុជា គេបានឃើញពួកវៀតមិញជាមួយនឹងមូលដ្ឋានទ័ពសំខាន់ៗជាច្រើន បានបន្តសកម្មភាពជាហូរហែអស់រយៈពេល៣០ឆ្នាំ ។

## ៦_កិច្ចប្រតិបត្តិការនៃបក្សកុម្មុយនិស្តឥណ្ឌូចិននៅកម្ពុជា១៩៤៦_៥៤៖

ក្នុងឆ្នាំ១៩៤៦ នៅកម្ពុជាក៏មានចលនាតស៊ូប្រឆាំងនឹងបារាំងដូចនៅវៀតណាមដែរ ។ ចលនានេះត្រូវបានគេស្គាល់ថា **ចលនាខ្មែរឥស្សរៈ** ។ ខ្មែរឥស្សរៈមានច្រើនក្រុម ដែលមួយចំនួនតូចស្ថិតនៅក្រោមឥទ្ធិពលវៀតមិញ ។ បើទោះជាវល់ជាប់ដៃប្រយុទ្ធតស៊ូនឹងអាណានិគមបារាំងក៏ដោយ ក៏ប្រជាជនខ្មែរនៅតែព្យាយាមទប់ទល់ជាមួយឥទ្ធិពលយួនជានិច្ច ។ ការទន្ទ្រានវាតទីកាត់យកទឹកដីខ្មែរក្នុងអតីតកាល នៅតែដក់ជាប់ជានិច្ចក្នុងសម្បជ្ជញ្ញៈជាតិនៃជនខ្មែរគ្រប់រូប ។

សេចក្តីសម្រេចចិត្តរបស់បារាំងជាច្រើនបានធ្វើឲ្យប្រជាជនខ្មែររីតតែចង់អាឃាតជាមួយយួនកាន់តែខ្លាំងឡើង ។ ក្រោយពីយកបានឥណ្ឌូចិនទាំងមូលក្នុងពាក់កណ្តាលទីពីរនៃសតវត្សរ៍ទី១៩ រដ្ឋការបារាំងបានគូសបន្ទាត់ព្រំដែនសាជាថ្មីរវាងខ្មែរនិងយួន ។ នៅព្រំប្រទល់ខាងលិចវិញ ខេត្តខ្មែរជាច្រើនដែលត្រូវសៀមកាន់កាប់ បានត្រូវប្រគល់មកឲ្យខ្មែរវិញ ។ ប៉ុន្តែនៅផ្នែកខាងកើតប្រទេសវិញក្នុងចន្លោះឆ្នាំ១៨៧០_១៩១៤ រដ្ឋការអាណានិគមបានកាត់ដីខ្មែរមួយភាគធំបញ្ចូលទៅក្នុងអង្គភាពរបស់ខ្លួន ដែលក្រោយមកបានក្លាយជាកម្មសិទ្ធិរបស់យួន ។ ក្នុងករណីខ្លះ ដូចជាខេត្តតាយនិញរបស់យួនសព្វថ្ងៃ តំបន់នេះធ្លាប់មានប្រជាជនខ្មែររស់នៅកុះករក្រោមរដ្ឋអំណាចរបស់ខ្មែរ ។ ការកាត់ទឹកដីនេះត្រូវបានទទួលស្គាល់ជាហូរហែតាមរយៈសន្ធិសញ្ញាជាច្រើន ដែលចុះហត្ថលេខាដោយបារាំង ដោយគ្មានការយល់ព្រមពីស្តេចខ្មែរឡើយ ។ តំបន់ព្រៃនគរនិងតំបន់ដីសន្ទទន្លេមេគង្គភាគខាងត្បូងនៃប្រទេសកម្ពុជា បានត្រូវបារាំងដាក់បញ្ចូលទៅក្នុងអង្គភាពអាណានិគមរបស់ខ្លួនដោយដាក់ឈ្មោះថា **កូសាំងស៊ីន** ។ **ការកាត់ទឹកដីកូសាំងស៊ីនឲ្យទៅយួន បានត្រូវធ្វើឡើងជាផ្លូវការដោយបារាំង** ក្នុងកិច្ចព្រមព្រៀងឆកសមុទ្រអាឡុង (ប្រទេសវៀតណាម) **នៅថ្ងៃទី៥មិថុនា១៩៤៨** ។ លើសពីនេះទៅទៀត ដូចជានៅក្នុងប្រទេសលាវដែរ ជនជាតិយួនបានវិលចូលមកក្នុងប្រទេសខ្មែរវិញ ធ្វើជាអ្នករដ្ឋការក្នុងរបបអាណានិគមក្រោមកិច្ចការពាររបស់បារាំង ។ បារាំងបានជួយយួនឲ្យបានធ្វើជាកម្មករក្នុងចំការកៅស៊ូ និងក្នុងផ្នែកសេវាផ្សេងៗ ។ ជនជាតិយួនចូលមកស្រុកខ្មែរក្នុងឋានៈជាអន្តោប្រវេសន្ត ក្តោបក្តាប់មួយភាគធំនៃពាណិជ្ជកម្មរបស់ប្រទេសជាមួយជនជាតិចិន ។ នៅពេលចប់សង្គ្រាមលោកលើកទីពីរ ជាដំបូង ទីក្រុងភ្នំពេញមិនមែនជាទីក្រុងខ្មែរទេ ។ តាមការប៉ាន់ស្មានជាផ្លូវការនៅឆ្នាំ១៩៤៦ ក្នុងចំណោមប្រជាជន១១០ពាន់នាក់ មានជនជាតិចិនជាង៣០ពាន់នាក់ និងជិត៣០ពាន់នាក់ទៀតជាជនជាតិឥណ្ឌូចិន ដែលនៅក្នុងនោះភាគច្រើនលើសលប់ជាជនជាតិយួន ។ នៅតាមជនបទ របៀបរស់នៅនៃក្រុមអន្តោប្រវេសន្តទាំងនោះបានបង្ហាញនូវភាពខុសប្លែកគ្នារវាងចិននិងយួន។ចិន ដែលភាគច្រើនជាបុរស ចូលចិត្តរៀប

ការជាមួយស្ត្រីខ្មែរ ។ ចំណែកឯយួនវិញ ចូលមកជាទ្រង់ទ្រាយគ្រួសារ រស់នៅតាមប្រពៃណីរបស់ខ្លួនដោយឡែកប្លែកពីខ្មែរ ។

ដោយយោលទៅលើមូលហេតុទាំងនេះ បើទោះជាស្ថិតនៅក្រោមអំណាចអាណានិគមបារាំងក៏ដោយ ការប្រឆាំងនឹងបារាំងរបស់ប្រជាជនខ្មែរ ក៏ប្រែជាការប្រឆាំងនឹងយួនទៅវិញ ដោយគេយល់ឃើញថាអ្នកដែលជញ្ជក់ឈាមខ្មែរពិតប្រាកដគឺយួន ។ ទាំងនេះបញ្ជាក់ឲ្យឃើញថា សកម្មភាពនយោបាយរបស់យួនកុម្មុយនិស្តនៅក្នុងសង្គមខ្មែរមិនត្រឹមគ្រាន់តែមានការពិបាកប៉ុណ្ណោះទេ តែជារឿយៗសកម្មភាពនោះត្រូវអនុវត្តតាមរយៈអ្នកដែលមានឈាមជ័រជាខ្មែរកាត់យួន ។ ឧទាហរណ៍: សមាជិកជាន់ខ្ពស់នៃបក្សកុម្មុយនិស្តឥណ្ឌូចិនពីររូបធ្វើការនៅស្រុកខ្មែរដែលជាខ្មែរកាត់យួនគឺ **សៀវ_ហេង** និង **ស៊ឺង_ង៉ុកមិញ** ។

នៅឆ្នាំ១៩៤៦ កស្តុតាងបានបញ្ជាក់ថាមានកងប្រដាប់អាវុធនៅក្នុងស្រុកខ្មែរដែលត្រួតត្រាដោយបក្សកុម្មុយនិស្តឥណ្ឌូចិន(ប.ក.ឥ.) ។ កងឯកភាពវៀតមិញមួយកងតាំងនៅក្នុងខេត្តបាត់ដំបង ភាគខាងលិចនៃប្រទេសកម្ពុជា ។ តាមសេចក្តីរាយការណ៍នៃក្រុមស៊ើបការណ៍សម្ងាត់បារាំងក្នុងខែសីហា១៩៤៦ ពួកវៀតមិញបានប្រមូលយួនស្ទើរតែទាំងអស់ក្នុងខេត្តបាត់ដំបង ដោយបង្កើតជាកងប្រដាប់អាវុធមួយកងឯកភាព មានគ្នាពីររយនាក់បំពាក់ដោយអាវុធដែលបានពីជប៉ុន ។ ពួកវៀតមិញមានគ្នាតិចមែន តែមានគ្រឿងអាវុធច្រើនជាងពួកខ្មែរឥស្សរៈមិនមែនកុម្មុយនិស្តដែលជួយគាំទ្រដោយសៀម ។ គណៈកម្មាធិការបដិវត្តបានត្រូវបង្កើតឡើងនៅចុងឆ្នាំ១៩៤៦ នៅតាមខេត្តដែលជាប់នឹងវៀតណាមខាងត្បូង ជាអាទិ៍ខេត្តតាកែវ ព្រៃវែង និងភាគខាងត្បូងនៃខេត្តកណ្តាល ។ គណៈកម្មាធិការនេះ ក្រោយមកត្រូវបានបញ្ចូលទៅក្នុងអង្គការរណសិរ្សមួយ ដែលទទួលស្គាល់ជាផ្លូវការដោយពួកវៀត-មិញនៅខែមីនា១៩៤៧ មានឈ្មោះជាភាសាយួនថា"លានដួនវៀតគាវ គូកុកកាវមាន" គឺ **សម្ពន្ធនៃអន្តោប្រវេសន៍យួននៅកម្ពុជាដើម្បីសង្គ្រោះជាតិ ។**

នៅចុងឆ្នាំ១៩៤៧ គណៈកម្មាធិការរំដោះប្រជាជនអគ្នេយ៍ទិសនៃកម្ពុជាបានត្រូវបង្កើតឡើង ដើម្បីបំផុសចលនាបដិវត្តន៍ក្នុងសង្គមខ្មែរ ។ គណៈកម្មាធិការរំដោះខ្មែរស្សេរៈបានត្រូវបង្កើតឡើងនៅចុងឆ្នាំ១៩៤៨ដើម្បីចាត់ចែងសកម្មភាពផ្នែកនយោបាយយោធារបស់ខ្មែរ ។ ការបំផុសបំផុលនិងអង្គការកម្មករចំការកៅស៊ូនៅភាគខាងកើតប្រទេសស្ថិតនៅក្រោមការទទួលរ៉ាប់រងរបស់ពួកវៀតមិញ ។ កម្មករចំការកៅស៊ូភាគច្រើនលើសលប់ជាអា-ណិកជនយួន ។ ការត្រួតត្រានៃស្នងការយួនមកលើខ្មែរឥស្សរៈ បណ្តាលឲ្យមានភាពតានតឹងរវាងខ្មែរឥស្សរៈនិងពួកវៀតមិញ ។

រហូតមកដល់ចុងឆ្នាំ១៩៤៨ ក៏គេនៅមិនទាន់ឃើញមានបក្សកុម្មុយនិស្តនៅកម្ពុជាឬលាវនៅឡើយ ។ នៅក្នុងសេចក្តីថ្លែងការណ៍មួយរបស់គណៈកម្មាធិការប្រតិបត្តិកណ្តាលនៃប.ក.ឥ.នៅដើមឆ្នាំ១៩៤៩ យួនបានអំពាវនាវឲ្យបង្កើតបក្សកុម្មុយនិស្ត ។ សេចក្តីថ្លែងការណ៍នោះបានបញ្ជាក់ថា ការជ្រើសរើសសមាជិកថ្មីសម្រាប់បក្សនៅក្នុងស្រុកខ្មែរមិនមានលក្ខណៈតឹងតែងទេ ប៉ុន្តែបន្ទាប់ពីអង្គការបានត្រូវបង្កើតហើយ គេត្រូវព្យាយាមបណ្តុះស្មារតី និងអប់រំអ្នកទាំងនោះដើម្បីឈានឡើងទៅកាន់កំរិតនយោបាយ ។

នៅឆ្នាំ១៩៤៩ ពួកយួនកុម្មុយនិស្តបានបង្កើតគណៈកម្មាធិការស្ថាបសួងមតិមួយ ដើម្បីបង្កើតគណៈបក្សបដិវត្តប្រជាជនកម្ពុជា ។ លោក **ប៊ែរណា ហ្វូល** និយាយថា សមាជិកនៃគណៈកម្មាធិការនេះត្រូវបានជ្រើសសម្រាំងយ៉ាងហ្មត់ចត់ក្នុងចំណោមជនជាតិយួនដែលមានការពិសោធន៍ដ៏ជ្រៅជ្រះក្នុងបញ្ហាខ្មែរ ។ ក្រោយពីបង្កើតគណៈកម្មាធិការនោះបន្តិចមក កងឯកភាពប្រដាប់អាវុធពិសេសរបស់យួនដែលមានឈ្មោះថា **កងទ័ពវៀតណាមជួយកម្ពុជា** បានត្រូវបង្កើតឡើងដើម្បីប្រតិបត្តិការនយោបាយរបស់យួនកុម្មុយនិស្តនៅក្នុងប្រទេសកម្ពុជា ។ ទីបញ្ជាការប្រតិបត្តិយោធានិងនយោបាយរបស់វៀតមិញនៅវៀតណាមខាងត្បូង ក៏ត្រូវបានផ្ទេរមកតាំងនៅក្នុងខេត្តព្រៃវែងនៃកម្ពុជាវិញ ។ នៅទីនោះ បណ្តាញនៃគណៈកម្មាធិការហ្វ៊ីកហ្វឺនមួយបានត្រូវរៀបចំឡើងក្នុងឆ្នាំ១៩៥០ ដែលជាថ្មីម្តងទៀត សមាជិកនៃអង្គការនេះសុទ្ធតែជាអាណិកជនជាតិយួន ។

នៅខែមីនា១៩៥០ កិច្ចប្រជុំមួយនៃមេដឹកនាំវៀតមិញ និងមេដឹកនាំខ្មែរឥស្សរៈបានប្រព្រឹត្តទៅនៅហាទាងវៀតណាមខាងត្បូង ក្រោមវត្តមានរបស់មេកុម្មុយនិស្តយួន **ឡេ_ឌឹកថូ** ។ នៅទីនោះ **ង្វៀន ថាញ់សឹង** ប្រធានគណៈកម្មការកិច្ចការបរទេសវៀតណាមខាងត្បូងរបស់វៀតមិញបាននិយាយថា **"អន្តោប្រវេសន្តយួននៅកម្ពុជាមានភារកិច្ចដ៏សំខាន់ដែលអាចជាកម្លាំងមូលទាញមួយ ឆ្ពោះទៅរកការចាប់ផ្តើមនៃចលនាបដិវត្តន៍នៅកម្ពុជា"** ។ នៅចុងសុន្ទរកថា **សឹង**ហាក់ដូចជាបានថ្លែងឲ្យដឹងថា ថ្វីបើបក្សវណ្ណៈអធន (ប.ក.ឥ.) អាចដឹកនាំចលនាបានក៏ដោយក៏អ្នកនៅក្នុងបក្សភាគច្រើនជាជនជាតិវៀតណាម ហើយចលនានេះក៏នៅតែមិនបានចាក់ឫសជ្រៅទៅក្នុងសង្គមខ្មែរឡើយ ។ ប៉ុន្តែភារកិច្ចរបស់ ប.ក.ឥ.មានសារៈសំខាន់ណាស់ដោយហេតុថា "កម្ពុជាស្ថិតនៅលើក្តារអុកឥណ្ឌូចិន បដិវត្តន៍ខ្មែរត្រូវតែដាក់នៅក្រោមការដឹកនាំរបស់ **វណ្ណៈអធនឥណ្ឌូចិន។"**

ខែមេសា១៩៥០ មានការបើកអង្គប្រជុំមួយរវាងមេដឹកនាំវៀតមិញនិងខ្មែរឥស្សរៈ ដែលគេឲ្យឈ្មោះថា **សមាជជាតិទីមួយនៃខ្មែរតស៊ូ** ។ ក្នុងអង្គប្រជុំនោះ រណសិរ្សរួបរួមខ្មែរឥស្សរៈមួយនិងគណៈកម្មាធិការកណ្តាលបណ្តោះអាសន្នដើម្បីរំដោះប្រជាពលរដ្ឋខ្មែរមួយបានត្រូវបង្កើតឡើង ដឹកនាំដោយ **សឹង ង៉ុកមិញ** របស់ ប.ក.ឥ.

និងក្រោមការត្រួតពិនិត្យរបស់សមាជិកប.ក.ឥ. ។

ការទំប្រឹងប្រែងបង្កើតនូវអង្គការផ្សេងៗជាច្រើននោះ គឺជាការត្រួសត្រាយផ្លូវឆ្ពោះទៅរកការកកើតនៃគណៈបក្សនយោបាយខ្មែរថ្មីមួយក្រោមការត្រួតត្រារបស់យួន ។ ខែកុម្ភៈ១៩៥១ ប.ក.ឥ.បានលិចឡើងម្តងទៀតជាផ្លូវការក្រោមឈ្មោះថ្មីថា **ឡាវដុង ឬបក្សពលករវៀតណាម** ។ ថ្វីបើឈ្មោះថ្មីនេះចង់ណែនាំឱ្យដឹងថា យួនមិនចង់ដាក់ឥទ្ធិពលទៅលើចលនាបដិវត្តផ្សេងទៀតនៅក្នុងឥណ្ឌូចិនក៏ដោយ គេក៏បានប្រកាសនៅក្នុងពេលជាមួយគ្នានោះផងដែរនូវការបង្កើត **បក្សជាបងប្អូនពីរថ្មីទៀត** គឺបក្សឯករាជ្យលាវមួយ ដែលសមាជិកភាគច្រើនជាយួន និង ***បក្សប្រជាជនបដិវត្តកម្ពុជា***មួយ ។ គណៈបក្សថ្មីរបស់ខ្មែរនេះមិនត្រឹមតែបង្កើតឡើងដោយបក្សឡាវដុងប៉ុណ្ណោះទេ សូម្បីតែឈ្មោះនិងលក្ខន្តិកៈផ្សេងៗទៀតក៏ត្រូវបកប្រែពីភាសាយួនមកជាភាសាខ្មែរដែរ ។ គណៈបក្សថ្មីរបស់ខ្មែរនេះស្ថិតនៅក្រោមឥទ្ធិពលរបស់យួន ។ **ក្នុងកំលុងឆ្នាំ១៩៥១ ពួកយួនកុម្មុយនិស្តតែងនិយាយជារឿយៗអំពីគំនិតចង់ធ្វើសហព័ន្ធរវាងប្រទេសទាំងបី គឺវៀតណាម កម្ពុជានិងលាវ និងការបង្រួបបង្រួមជាយថាហេតុនៃបក្សបដិវត្តរបស់ប្រទេសទាំងបី ។**

យោងតាមក្រសួងស៊ើបការណ៍សម្ងាត់បារាំងនៅពេលនោះ រហូតមកដល់ខែសីហា១៩៥១ មានខ្មែរតែមួយចំនួនតូចប៉ុណ្ណោះដែលចូលរួមក្នុងបក្ស ។ តាមស្ថិតិរបស់ **បក្សកុម្មុយនិស្តកម្ពុជា** (ប.ក.ក.) ដែលផ្សាយជាសម្ងាត់នៅដើមឆ្នាំ១៩៧០បានឱ្យដឹងថា: ពួកខ្មែរកុម្មុយនិស្តដំបូងកើតនៅឆ្នាំ១៩៥១ មានគ្នាប្រហែលសែសិបនាក់ ហ្វឹកហ្វឺនដោយ ប.ក.ឥ., ដប់នាក់ដោយបក្សកុម្មុយនិស្តបារាំង, និងបីឬបួននាក់ដោយបក្សកុម្មុយនិស្តថៃ ។ បើទោះជាមានការណែនាំត្រឹមត្រូវពីគណៈកម្មាធិការកណ្តាលនៅពេលនោះឱ្យកែតម្រង់ស្ថានភាពនោះក៏ដោយ បារាំងបានកត់សម្គាល់ថា: "ការជ្រើសរើស និងការបង្កើតកម្មាភិបាលខ្មែរមានការលំបាក, បេក្ខជនបង្ហាញនូវការមិនសូវយល់ដឹង មិនអើពើ និងគ្មានវិន័យ "។ តែទោះយ៉ាងណាក៏ដោយ មេដឹកនាំវៀតមិញនៅតែព្យាយាមបន្តការជ្រើសរើស និងហ្វឹកហ្វឺនខ្មែរមួយចំនួនទៀត ។ មុនដំបូង ជនជម្រើស (អ្នកដែលត្រូវគេជ្រើសរើស) ត្រូវគេបញ្ជូនឱ្យទៅហាត់នៅវៀតណាមខាងត្បូង។ តែក្រោយមក នៅខែមិថុនា១៩៥២ គេបានសម្រេចឱ្យបង្កើតក្នុងតំបន់នីមួយៗនៃប្រទេសកម្ពុជា នូវសាលានយោបាយយោធាមួយដឹកនាំដោយយួន និងគណៈកម្មាធិការមួយទៀតរបស់ទីប្រឹក្សាយួន ។ ក្នុងរយៈពេលបីឆ្នាំជាបន្តបន្ទាប់ កម្មាភិបាលយួនបានខំបន្តជ្រើសរើសអាណិកជនខ្មែរ ដើម្បីបញ្ចូលទៅក្នុងអង្គការនយោបាយនិងយោធាដែលត្រួតត្រាដោយយួន ។ គេមិនសូវបានជោគជ័យប៉ុន្មានទេក្នុងការប្រជុំប្រជានេះ ។ ឧទាហរណ៍: ខែមីនា១៩៥២ (ដោយផ្អែកទៅលើឯកសារសំខាន់របស់វៀតមិញ និងអ្នកឱ្យការណ៍ដែលគេចាប់បាន)

ការិយាល័យចលនានៅភ្នំពេញមានបុគ្គលិកអចិន្ត្រៃយ៍ចំនួនសាមសិបបួននាក់ ដែលក្នុងនោះប្រាំពីរនាក់ជាជនជាតិយួន, បីនាក់ជាចិន, និងខ្មែរតែបួននាក់ប៉ុណ្ណោះ ។

សម្បទាននយោបាយដល់រាជរដ្ឋាភិបាលរបស់មហាក្សត្រនរោត្តម សីហនុ រួមនឹងកិត្យានុភាពនយោបាយផ្ទាល់ខ្លួនរបស់ព្រះអង្គផង បានធ្វើឱ្យកងទ័ពកសិករប្រឆាំងបារាំងនៅកម្ពុជា មានការពិបាកជាងនៅវៀតណាម ។ ប៉ុន្តែអមិត្តភាពដ៏ជ្រាលជ្រៅរវាងខ្មែរនិងយួនបានធ្វើឱ្យឃើញច្បាស់ថា បក្សគ្រប់គ្រងដោយវៀតណាម និងរណសិរ្សប្រឆាំងអាណានិគមរបស់គេតែងបានទទួលការគាំទ្រពីប្រជាជនតិចតួចប៉ុណ្ណោះនៅក្នុងកម្ពុជា ។

តម្រូវទៅតាមកិច្ចព្រមព្រៀងហ្សឺណែវ ដែលចុះហត្ថលេខាដោយបារាំងនិងវៀតមិញនៅឆ្នាំ១៩៥៤ កងកម្លាំងកុម្មុយនិស្តយួនទាំងអស់ត្រូវដកថយពីកម្ពុជា ។ រាជរដ្ឋាភិបាលរបស់សម្តេចសីហនុត្រូវបានទទួលឯករាជ្យពេញលេញ និងការទទួលស្គាល់ជាអន្តរជាតិនៅខែវិច្ឆិកា១៩៥៣ ។ **ជាមួយនឹងការដកថយរបស់យួន ខ្មែរកុម្មុយនិស្តប្រហែលប្រាំពាន់នាក់ក៏ទៅជាមួយដែរ** ដែលនៅក្នុងនោះមានកម្មាភិបាល កងទ័ព និងក្រុមគ្រួសាររបស់គេ ដែលគេតែងហៅថា"ខ្មែរវៀតមិញ" ។ ខ្មែរទាំងនេះត្រូវបានទទួលការហ្វឹកហាត់បន្ថែមទៀតនៅហាណូយ **រង់ចាំឱកាសល្អដែលប្រវត្តិសាស្ត្រហុចឲ្យ ។**

## ៧_ដើមកំណើតនៃខ្មែរក្រហម

ការដកថយទៅហាណូយក្នុងឆ្នាំ១៩៥៤នៃខ្មែរវៀតមិញចំនួនពាក់កណ្តាល ធ្វើឱ្យខ្មែរពច្វង (ខ្មែរវៀតមិញ) ដែលនៅសេសសល់ស្ថិតនៅក្នុងភាពគ្មានអ្នកគ្រប់គ្រង ។ គណៈបក្សរណសិរ្សមួយឈ្មោះ **បក្សប្រជាជន** បានត្រូវបង្កើតឡើងដើម្បីប្រើជាផ្លូវការខាងផ្នែកនយោបាយ នៅពេលដែលបក្សកុម្មុយនិស្តមិនទាន់ប្រតិបត្តិការជាសម្ងាត់ ។ នៅក្នុងការបោះឆ្នោតសាកលឆ្នាំ១៩៥៥ បក្សប្រជាជន ដែលមាននិន្នាការទៅខាងយួន បានតែជិត៣០ពាន់សម្លេង ឯបក្សសង្គមរាស្ត្រនិយមរបស់សម្តេចសីហនុបានជាង៦៣០ពាន់សម្លេង ។

បក្សនយោបាយខ្មែរពច្វងដែលគ្មានមេកើយត្រឹមត្រូវនេះ បានត្រូវដាក់បំពេញមកវិញយ៉ាងចាប់រហ័សដោយពួកបញ្ញវន្តកុម្មុយនិស្តក្មេងៗមួយក្រុមដែលទើបវិលត្រឡប់មកពីស្រុកបារាំងនៅកំលុងឆ្នាំ១៩៥០ ។ ក្នុងចំណោមបញ្ញវន្តទាំងនោះមានជាអាទិ៍ **ខៀវសំផន, ហ៊ូនិម, និងហ៊ូយន់** ដែលបានទទួលសញ្ញាប័ត្រខ្ពង់ខ្ពស់ ។ ចំណែកអ្នកឯទៀតដូចជា **សាឡុត_ស (ប៉ុលពត)** មិនបានរៀនចប់សព្វគ្រប់ទេ ។ ប៉ុន្តែ ដោយហេតុថានិស្សិតទាំងនោះមិនត្រូវបានគេណែនាំឱ្យចូលក្រុមម៉ាក់និយម (Maxism) នៅប្រទេសបារាំង ពួកគេក៏បាននាំគ្នាចូលរៀននៅសាកលវិទ្យាល័យប្រជាប្រិយ៍មួយដែលគ្រប់គ្រងដោយបក្សកុម្មុយនិស្តបារាំង ។

យោងតាមមិត្តភក្តិនៃក្រុមខ្មែរជ្រុលនិយមទាំងនោះបានឲ្យដឹងថា កាលនៅប្រទេសបារាំងពួកនេះមិនមាន អរិភាពអ្វីជាមួយពួកវៀតណាមទេ។ ផ្ទុយទៅវិញ ពួកគេមានទំនាក់ទំនងល្អជាមួយពួកនិស្សិតយួននៅ ម៉ុងពែលីយេ (Montpellier) ហើយថែមទាំងទិទៀនខ្មែរណាដែលហៅពួកវៀតណាមថា **យួន** ទៀតផង ព្រោះថាពាក្យនេះ ជាពាក្យមើលងាយ ។

នៅឆ្នាំ១៩៥៣ ប៉ុលពត និងនិស្សិតមូលរ៉ាឌីវ (Radical student) ជំនាន់ទី១បានវិលត្រឡប់មកស្រុក ខ្មែរវិញ ហើយបានចូលរួមជាមួយក្រុមខ្មែរឥស្សរៈដែលមានសឹងផ្ទឹកមិញជាមេ ក្រោមបញ្ជាការរបស់យួន ។ ដោយ ហេតុថាសម័យនោះ **បដិវត្តខ្មែរនិន្នាការយួន**ទើបនឹងចាប់បដិសន្ធិ គេយល់ថា **តម្លៃរបស់បដិវត្ត** មានសារៈសំខាន់ ជាង **តម្លៃរបស់ប្រពៃណី** ក្នុងការអប់រំកិរិយាបទពួកខ្មែរក្រហមឲ្យប្រព្រឹត្តចំពោះវៀតណាម ។

វាជាការមិនត្រឹមត្រូវទេបើយើងដាក់កំហុសច្រើនហួសពេកទៅលើបារាំងថាបានបង្កបង្កើតក្រុមខ្មែរក្រហម ព្រោះថា **នួនជានិងតាម៉ុក** មិនដែលបានទៅស្រុកបារាំងផងនោះ ។ និស្សិតក្រហមដែលបានវិលមកពីស្រុកបារាំង វិញមានឥទ្ធិពលយ៉ាងសំខាន់នៅទីក្រុងភ្នំពេញ ដោយខ្លះបានក្លាយជាគ្រូបង្រៀននៅតាមសាលាឯកជន នាចុងឆ្នាំ ១៩៥០ ។ ចូងតាមការបង្រៀន គ្រូទាំងនោះបានច្បៀតដាក់ឥទ្ធិពលរបស់គេទៅលើយុវសិស្សមួយចំនួនដែលសិស្ស ខ្លះថែមទាំងបានរត់ចូលព្រៃជាមួយគេផង ។ អ្នកមូលរ៉ាឌីវ (Radicalist) ខ្លះដែលធ្វើការក្នុងរដ្ឋាភិបាលភ្នំពេញ ក៏បានលួចឧបត្ថម្ភបណ្តាញកុម្មុយនិស្តលួចលាក់ក្នុងទីក្រុងផងដែរ នៅពេលដែលក្រុមរបស់គេតាមជនបទកំពុងត្រូវ បែកខ្ចាត់ខ្ចាយ ។ ការអន្តរាយនេះបណ្តាលមកពីអំពើក្បត់របស់មេក្រុមកុម្មុយនិស្តឈ្មោះ **សៀវហេង** ដែលបានរាយ ការណ៍ប្រាប់រដ្ឋាភិបាល ។ ដោយមានមូលដ្ឋានប្រតិបត្តិការរបស់គេនៅក្នុងក្រុងភ្នំពេញនេះហើយ បានជាពួកបញ្ញវន្ត ក្រហមពីស្រុកបារាំងអាចមានលទ្ធភាពកាន់កិច្ចការសំខាន់ៗក្នុងបក្សបដិវត្តប្រជាជនខ្មែរ នៅឆ្នាំ១៩៦០ ។

ក្នុងឆ្នាំនោះ ឈ្មោះបក្សក៏ត្រូវបានផ្លាស់ទៅជា **បក្សពលករកម្ពុជា** វិញដើម្បីឲ្យស៊ីគ្នានឹង **បក្សពលករវៀតណាម** ។ កិច្ចប្រជុំបក្សឆ្នាំ១៩៦០ បានត្រូវគេទទួលអបអរថាជាថ្ងៃកំណើតនៃ **បក្សកុម្មុយនិស្តកម្ពុជា (ប.ក.ក.)** បើទោះជាបក្សនេះបានត្រូវគេសន្មត់ឈ្មោះនៅឆ្នាំ១៩៦៦ក៏ដោយ ។ គួរកត់សម្គាល់ផងដែរថា ឆ្នាំ១៩៦០បានត្រូវ ក្លាយជាកាលបរិច្ឆេទផ្លូវការរបស់បក្សក្នុងកំឡុងឆ្នាំ១៩៧៧ ។ តាមរយៈជនផ្តាច់ខ្លួនខ្លះបានឲ្យដឹងថា បក្សនេះបាន ត្រូវបង្កើតតាំងពីឆ្នាំ១៩៥១ម្ល៉េះ ។ សភាពខុសគ្នារវាងថ្ងៃកំណើតបក្សនេះមានសារៈសំខាន់ណាស់ ដោយខ្មែរ ក្រហមចង់បញ្ជាក់អះអាងអំពីភាពឯករាជ្យរបស់ខ្លួនចេញពីបក្សកុម្មុយនិស្តយួន ។

នៅឆ្នាំ១៩៦៣ ប៉ុលពតបានត្រូវតែងតាំងជាអគ្គលេខាធិការបក្ស ។ ក្នុងឆ្នាំជាមួយគ្នានោះដែរ ភាគច្រើន

នៃសមាជិកគណៈកម្មការកណ្ដាលនៃបក្សកុម្មុយនិស្តកម្ពុជា(ប.ក.ក.) ក្រោមសម្ពាធនៃនគរបាលរបស់សម្ដេចសីហនុ បានរត់ចេញពីភ្នំពេញទៅនៅជនបទ ។ ក្នុងចំណោមអ្នកគេចខ្លួនទាំងនោះមានប៉ុលពត អៀងសារី សុនសេន និងនួនជា ។ (ចំណែកវរជនឯទៀត មានខៀវសំផន ហ៊ូនឹម និងហ៊ូយន់ នៅធ្វើការជាមួយរដ្ឋាភិបាលដើម្បីតស៊ូនយោបាយស្របច្បាប់) ។ នៅខាងក្នុងផ្ទៃប្រទេស សមាជិកនៃប.ក.ក.បានចាប់ផ្ដើមចាត់តាំងអង្គការប្រជាជនតាមជនបទ ដើម្បីបង្កើតចលនាទ័ពព្រៃបះបោរ ប្រឆាំងនឹងរដ្ឋាភិបាលរបស់សម្ដេចសីហនុ ។ មូលដ្ឋានស្នូលរបស់គេនៅពេលនោះគឺជនជាតិភាគតិចតំបន់ព្រៃភ្នំនៅទិសឦសាន និងនិរតី ។ ពួកអ្នកភ្នំ ឬខ្មែរលើទាំងនេះមានការក្រវក្រោធជាយូរមកហើយជាមួយនឹងការវាយឫកខ្ពស់របស់ពួកខ្មែរកណ្ដាលទៅលើពួកគេ ។ ក្នុងពេលធ្វើសង្គ្រាមឆ្នាំ ១៩៧០_៧៥ ជាមួយសាធារណរដ្ឋ **លន់ណុល** ខ្មែរក្រហមបានជ្រើសរើសប្រជាជនចុងកាត់មាត់ញកដែលមិនចេះអក្សរមួយចំនួនធំនៃខេត្តកំពតនិងខេត្តកំពង់ឆ្នាំង និងពីតំបន់ភ្នំនៅជិតប៉ៃលិន ។ ការរស់នៅឆ្ងាយដាច់ស្រយាលពីសង្គមដែលមានអារ្យធម៌ គឺជាប្រភពសំខាន់មួយក្នុងការគាំទ្រផែនការបដិវត្តវណ្ណៈបញ្ច្រាសរបស់ពួកខ្មែរក្រហម ។

បុ៉ន្តែគួរកត់សំគាល់ថា ជំហានដំបូងនៃអង្គការនយោបាយរបស់ខ្មែរក្រហម បានត្រូវស្ថិតនៅក្រោមការឧបត្ថម្ភរបស់កងទ័ពយួនកុម្មុនិស្ត ដែលតាំងពីឆ្នាំ១៩៦៥មក គេបានប្រើភូមិភាគបូព៌ានៃកម្ពុជាជាទីជម្រក កន្លែងសំរាក និងកន្លែងដុកស្បៀង ។ កាលនោះ មិនមានភស្តុតាងណាមួយបញ្ជាក់ថាយួនកុម្មុយនិស្តនិងខ្មែរក្រហមមានទំនាស់ជាចំហជាមួយគ្នាទេ ។ គេក៏មិនអាចនឹងជឿជង់បានទេ ថាកងទ័ពខ្មែរក្រហមមួយក្ដាប់តូចអាចធ្វើអ្វីកើតនៅក្នុងកាលៈទេសៈបែបនោះឡើយ ហើយក៏គ្មានភស្តុតាងណាប្រាប់ថា មេដឹកនាំខ្មែរក្រហមមានការភិតភ័យនឹងយួននៅពេលនោះដែរ ។ បើសិនជាខ្មែរក្រហមខ្លាចយួន គេអាចដកថយទៅកន្លែងឆ្ងាយៗក្នុងប្រទេសដូចជាតំបន់ពាយព្យដែលជាកន្លែងគ្មានកងទ័ពយួន ។

ផ្ទុយទៅវិញ មានភស្តុតាងច្បាស់លាស់ដែលនិយាយថា ប៉ុលពតនិងបក្សពួកនៅតែស្រុះស្រួលជាមួយវៀតណាមជានិច្ចក្នុងកំលុងឆ្នាំ១៩៦០ ។ ឧទាហរណ៍ៈ នៅខែកក្កដាឆ្នាំ១៩៦៥ ប៉ុលពតបានធ្វើទស្សនកិច្ចនៅទីក្រុងហាណូយ ដើម្បីពិភាក្សាជាមួយការិយាល័យនយោបាយបក្សកុម្មុយនិស្តវៀតណាម ក្នុងការធ្វើចលនាកុម្មុយនិស្តកម្ពុជាឲ្យឯករាជ្យ ។ បើទោះជាមានភាពខុសគ្នាក្នុងទស្សនវិស័យនិងអាទិភាពនយោបាយក៏ដោយ ក៏មគ្គុទេសក៍ខ្មែរនិងវៀតណាមបានពិភាក្សាគ្នាក្នុងនាមជាសមមិត្តដែរ ។ ខែវិច្ឆិកា១៩៦៩ ប៉ុលពតបានទៅហាណូយម្ដងទៀតដើម្បីពិភាក្សាពីរឿងនយោបាយ ។ កាលនោះ កំហឹងចងអាឃាតជាមួយយួនមិនទាន់លេចចេញជារូបរាងនៅឡើយទេ ។ ចំពោះពួកមគ្គុទេសក៍ខ្មែរក្រហម ក្នុងទសវត្សរ៍១៩៦០ គេនៅតែយល់ឃើញថា **តម្លៃបដិវត្ត** មានសារៈសំខាន់ជាង

**តម្លៃប្រពៃណី** *របស់ជាតិពន្ធ(អ្នកព្រៃភ្នំ) ក្នុងអតីតកាល (ភាពប្រទូស) ជាមួយវៀតណាម ។*

គេមិនបានដឹងពិតប្រាកដថា តើខ្មែរក្រហមជាប់ចិត្តស្រឡាញ់លទ្ធិម៉ៅនិយមតាំងពីកាលណាទេ ។ យួនកុម្មុយនិស្តបានពោលអះអាងថា ប៉ុលពតនិងអៀងសារី បានគោរពបូជានិងកោតសរសើរគំនិតម៉ៅ តាំងពីគាត់នៅស្រុកបារាំងម្ល៉េះ ។ យួនបានបញ្ជាក់ទៀតថា ប៉ុលពតបានជួបម៉ៅសេទុងដំបូងនៅឆ្នាំ១៩៦០ ។ ប៉ុន្តែសម្តេចសីហនុបានអះអាងថា ទាល់តែវិលត្រឡប់មកស្រុកខ្មែរវិញហើយទេ ទើបពួកខ្មែរកុម្មុយនិស្តបានទទួលឥទ្ធិពលម៉ៅតាមរយៈស្ថានទូតចិននៅភ្នំពេញ ។ សម្តេចសីហនុបានបន្ថែមទៀតថា ពួកនេះខ្លះបានទាំងធ្វើទស្សនកិច្ចជាសម្ងាត់ទៅប្រទេសចិនក្នុងកំលុងឆ្នាំ៥០និង៦០ទៀតផង ។ ការអះអាងនេះមិនត្រឹមត្រូវទេ ។

មនោគមន៍វិជ្ជាម៉ៅហាក់ដូចជាបានជ្រួតជ្រាបបន្តិចម្តងៗដល់ពួកខ្មែរក្រហម ។ ហើយយួនកុម្មុយនិស្តខ្លួនឯងក៏មានភារកិច្ចផ្ទាល់ក្នុងការជួយផ្សព្វផ្សាយមនោគមន៍វិជ្ជានេះដែរ ដោយហេតុថាខ្លួនស្ថិតនៅក្រោមឥទ្ធិពលចិនកុម្មុយនិស្តក្នុងរវាងឆ្នាំ១៩៥០_៥៦ និងឆ្នាំ១៩៦៥_៦៦ នៅពេលដែលយួនកុម្មុយនិស្តកំពុងតែមានឥទ្ធពលខ្លាំងទៅលើខ្មែរក្រហម ។ ប៉ុលពតបានធ្វើដំណើរជាលើកដំបូងទៅប្រទេសចិន ពីចុងឆ្នាំ១៩៦៥ដល់ដើមឆ្នាំ១៩៦៦ ។ កម្មវិធីនយោបាយរបស់ប.ក.ក.នៅដើមឆ្នាំ១៩៦០ ដែលប៉ុលពតបានបង្ហាញដល់វៀតណាមនៅខែមិថុនាឆ្នាំ១៩៦៥ មិនមានអ្វីទាក់ទងនឹងលទ្ធិម៉ៅទេ ។ តែនៅក្នុងលិខិតមួយដែលគាត់ផ្ញើទៅបក្សកុម្មុយនិស្តចិនឆ្នាំ៦៧ទើបមាន ។ ទស្សនកិច្ចរបស់ប៉ុលពតនៅប្រទេសចិនក្នុងឆ្នាំ១៩៦៥_៦៦ និង១៩៧០ មិនបានបញ្ចូលឥទ្ធិពលមនោគមន៍វិជ្ជាម៉ៅទៅលើពួកខ្មែរក្រហមទេ ប៉ុន្តែវាទំនងជាឥទ្ធិពលនេះបានជ្រួតជ្រាបយ៉ាងជ្រាលជ្រៅរួចទៅហើយ ។

## ៨_នយោបាយរបស់សម្តេចសីហនុចំពោះវៀតណាម៖

សម្តេចសីហនុមានការព្រួយបារម្ភចំពោះមហិច្ឆតារបស់យួន ដូចប្រជាពលរដ្ឋខ្មែរធ្លាប់មានកាលពីដើមសតវត្សទី១៩ដូចនោះដែរ ។ នៅខែមករា១៩៦៣ សម្តេចបានសរសេរថា:

> **"ទោះជាឈ្មោះយ៉ាឡុងក្តី ហូជីមិញក្តី ង៉ោឌិញយាមក្តី គ្មានយួនណាមួយដេកលក់ដោយសុខស្រួលទេ បើគេមិនបានរុញកម្ពុជាឲ្យដល់ការរលាយរលត់ ដោយយកខ្មែរធ្វើជាកញ្ចះជាមុនទេនោះ ។"**

ជិតម្ភៃឆ្នាំក្រោយមក ព្រះអង្គថ្លែងម្តងទៀតថា:

> **"ប្រជារាស្ត្រខ្មែរមានមូលហេតុត្រឹមត្រូវក្នុងការស្អប់យួន ។ អ្នកជិតខាងយើងទិសខាងកើត ជាច្រើនសតវត្សកន្លងមកបានលេបទឹកដីរបស់ខ្មែរ យកធ្វើជាអាណានិគមរបស់ខ្លួន ដោយទុកឲ្យខ្មែរធ្វើការជ្រើសរើសរវាង ការចុះចូលនិងការភៀសខ្លួនចេញ ។"**

សម្ដេចសីហនុបានទទួលស្គាល់ថា ប្រជារាស្ត្រខ្មែរជាច្រើនស្អប់យួនណាស់ រហូតដល់មានអ្នកខ្លះយល់សប្តិឃើញដល់ការដណ្តើមយកទឹកដីដែលបាត់បង់មកវិញផង ។ ប៉ុន្តែសម្ដេចប្រើមធ្យោបាយជៀសៈ

**"ក្នុងទំនាក់ទំនងរបស់ខ្ញុំជាមួយវៀតណាម ខ្ញុំតែងតែប្រកាន់ខ្ជាប់នូវគំរិយាបទអ្នកប្រាកដនិយម ។ ទេវតាបានចារទុកមក ឲ្យយួនធ្វើជាអ្នកជិតខាងយើងជាអមតៈ។ នៅឆ្នាំ១៩៦០ យួនខាងជើងនិងយួនខាងត្បូងមានគ្នាជិតហាសិបលាននាក់ ច្រើនជាងខ្មែរប្រាំបីដង ។ ទោះជាក្រហមក្ដី ឬខៀវក្ដី យួនជាអ្នកជិតខាងដ៏គ្រោះថ្នាក់ធំមួយដែលខ្ញុំត្រូវតែប្រយ័តប្រយែងជាទីបំផុត ។"**

យុទ្ធសាស្ត្រសំខាន់ទីពីររបស់សម្ដេចសីហនុគឺថា សហរដ្ឋអាមេរិកមិនអាចនៅអាស៊ីអគ្នេយ៍ជារៀងរហូតបានទេ គឺមានតែមហាអំណាចកុម្មុយនិស្តប៉ុណ្ណោះ ។ ដូចនេះ លោកយល់ថាត្រូវតែសម្របសម្រួលជាមួយចិន និងវៀតណាមខាងជើង ។

ក្នុងពេលឡើងកាន់អំណាចដំបូង សម្ដេចសីហនុបានប្រកាន់យកនយោបាយអព្យាក្រឹតរវាងលោកខាងកើតនិងលោកខាងលិចដែលត្រូវបានប្រកាសជាផ្លូវការនៅថ្ងៃ២៣ធ្នូ១៩៥៤ ដោយនាយករដ្ឋមន្ត្រីប៉ែនទុត ។ សម្ដេចសីហនុបានឈោងចាប់យកនយោបាយនេះ នៅក្នុងសន្និសិទនៃប្រទេសមិនចូលបក្សសម្ព័ន្ធ នៅបានឌុង នាឆ្នាំ១៩៥៥ ។ មធ្យោបាយមួយទៀតរបស់ទ្រង់ដែរគឺការប្រកែកមិនព្រមទទួលសេចក្ដីស្នើរបស់សហរដ្ឋអាមេរិក ដើម្បីឲ្យចូលរួមក្នុង អង្គការសន្ធិសញ្ញាអាស៊ីអគ្នេយ៍ (SEATO) នៅឆ្នាំ១៩៥៦ ។

នៅក្នុងស្ថានការជាបន្តបន្ទាប់នៃកិច្ចព្រមព្រៀងក្រុងហ្សឺណែវ ខែមិថុនា១៩៦២ ដែលប្រទេសមហាអំណាចភាគច្រើនបានប្រកាសឲ្យប្រទេសលាវនៅជាអព្យាក្រឹត សម្ដេចសីហនុជឿប្រាកដថា លាវច្បាស់ជាគេចមិនរួចពីកុម្មុយនិស្តឡើយ ។ ទ្រង់ក៏មានការព្រួយបារម្ភដែរថាជោគវាសនានេះពិតជានឹងកើតមានដល់ប្រទេសរបស់ព្រះអង្គ ជាពិសេសបើសិនជាសង្គ្រាមនៅលាវត្រូវរាលដាលចូលមកកម្ពុជា ។ ដោយមិនចាប់អារម្មណ៍ទៅលើការគ្មានដំណោះស្រាយរបស់សហរដ្ឋអាមេរិកចំពោះវាសនាប្រទេសលាវ សម្ដេចសីហនុបានសម្រេចថា សន្តិសុខនៃប្រទេសរបស់ទ្រង់អាចនឹងត្រូវបានការពារយ៉ាងប្រសើរ ដោយការងាកទៅរកប្លុកកុម្មុយនិស្ត ជាពិសេសគឺប្រទេសចិន ។ សីហនុសង្ឃឹមថា មិត្តភាពជាមួយចិនអាចធានាបានដល់ប្រទេសរបស់ព្រះអង្គប្រឆាំងនឹងមហិច្ឆតារបស់យួនខាងជើង ។ គាត់បានដឹងរួចហើយថាយួនខាងជើងបានប្រើផ្លូវលំ ហូជីមិញនៅក្នុងទឹកដីខ្មែរ ដើម្បីជាផ្លូវដឹកស្បៀងទៅធ្វើចម្បាំងនៅយួនខាងត្បូង ។ នៅដើមឆ្នាំ១៩៦០ នយោបាយការបរទេសរបស់សីហនុក៏រឹតតែមានឥទ្ធិពលខ្លាំងឡើង ដោយសារកំហឹងរបស់ទ្រង់ទល់នឹងនយោបាយជាសត្រូវរបស់ ស.រ.អ. និងរដ្ឋាភិបាលថៃនិងយួន

ខាងត្បូងដែលមានទិន្នាការទៅរក ស.រ.អ. ។ ពួកទ័ពព្រៃខ្មែរសេរីដែលសម្តេចសីហនុជឿថាគាំទ្រដោយ **សេអ៊ីអា** *(ក្រុមស៊ើបការសម្ងាត់អាមេរិកាំង)* ហើយដែលដឹកនាំដោយ **សឺង-ង៉ុកថាញ់** *(គូប្រជែងនយោបាយដ៏យូរអង្វែងរបស់សីហនុ)* បានធ្វើការផ្សាយតាមរលកធាតុអាកាស នូវការឃោសនាប្រឆាំងនឹងសីហនុពីប្រទេសថៃ និងពីវៀត-ណាមខាងត្បូង ។ នៅខែសីហា១៩៦៣ សីហនុបានផ្តាច់ទំនាក់ទំនងទូតជាមួយយួនខាងត្បូង ។ ខែវិច្ឆិកាឆ្នាំដដែល ទ្រង់បានកាត់កម្មវិធីជំនួយយោធាស.រ.អ.ក្នុងប្រទេសកម្ពុជា ។ ខែធ្នូ១៩៦៣ សីហនុបានចុះហត្ថលេខាជាលើកដំ-បូងលើកិច្ចព្រមព្រៀងជំនួយយោធាជាមួយប្រទេសចិន ។ ថ្ងៃទី៣ឧសភា១៩៦៥ សីហនុផ្តាច់ទូតជាមួយ ស.រ.អ. ។

ចាប់ពីឆ្នាំ១៩៦៥មក ចិន រុស្ស៊ី និងឆេកូត្រូវបានអនុញ្ញាតឱ្យប្រើកំពង់ផែក្រុងសីហនុ ដើម្បីផ្គត់ផ្គង់ស្បៀង ឱ្យទ័ពយួនខាងត្បូង និងយួនខាងជើង ហើយពួកវៀតកុងក៏បានត្រូវអនុញ្ញាតឱ្យប្រើខេត្តខាងកើតនៃប្រទេសកម្ពុជា ដើម្បីជាជំរក ក្នុងការប្រយុទ្ធទល់នឹង“ចក្រពត្តិអាមេរិក” ។ សីហនុបានបន្តភ្ជាប់ចំណងមិត្តភាពជាមួយសាធារណ-រដ្ឋប្រជាមានិតចិន ហើយចិនបានទទួលស្គាល់នូវតម្លៃក្នុងការដែលបានសីហនុធ្វើជាសម្ពន្ធមិត្ត ។ ខែតុលា១៩៦៥ ចិនបានយាងសម្តេចសីហនុទៅប៉េកាំង ដើម្បីចូលរួមជាភ្ញៀវកិត្តិយសក្នុងថ្ងៃបុណ្យជាតិ ។

តាំងពីឆ្នាំ១៩៦៦ដល់១៩៦៧ សីហនុបានចេញសេចក្តីថ្លែងការណ៍គាំទ្រជំហររបស់ទីក្រុងហាណូយចំពោះស្ថានភាពមុនកិច្ចចរចា និងការទទួលស្គាល់ជាផ្លូវការនូវ **រណសិរ្សរំដោះជាតិវៀតណាមខាងត្បូងក្រោមបញ្ជារបស់ទីក្រុងហាណូយ** ថាជាតំណាងតែមួយគត់របស់ប្រជាជនវៀតណាមខាងត្បូង ។ ឧទាហរណ៍: តាមវិទ្យុហាណូយ ក្នុងខែមីនា១៩៦៧ សម្តេចសីហនុបានផ្ញើសារមួយទៅលេខាធិការដ្ឋាននៃសន្និសិទត្រៃទ្វីប (Tricontinental Conference) នៅទីក្រុងហាវ៉ាណា ដោយ “ថ្កោលទោសយ៉ាងចាស់ដៃចំពោះសង្គ្រាមឈ្លានពានរបស់ ស.រ.អ. នៅវៀតណាមនិងបានប្រកាសថា កម្ពុជាគាំទ្រយ៉ាងពេញទំហឹងចំពោះការតស៊ូរបស់ប្រជាជនវៀតណាម ប្រឆាំងនឹងការឈ្លានពានរបស់ស.រ.អ. និងចំពោះការសង្គ្រោះជាតិ ។” ខែមេសា១៩៦៦ សីហនុបានតម្លើងឋានៈនៃ **កាប្តូរបេសកកម្មរបស់សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម** *(វៀតណាមខាងជើង ឬ ស.ប.វ.)* ដែលបានធ្វើឡើងកាលពីខែកក្កដា១៩៦២ ឱ្យទៅជា**តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ។**

**ថ្ងៃ៨មិថុនា ១៩៦៧** ស.ប.វ.បានចេញសេចក្តីថ្លែងការណ៍មួយ:"**ទទួលស្គាល់ និងទទួលរ៉ាប់រងគោរពបូរណភាពទឹកដីកម្ពុជាក្នុងព្រំដែនសព្វថ្ងៃរបស់ខ្លួន"** ។ បន្ទាប់ពីសេចក្តីថ្លែងការណ៍នោះបន្តិចមក គឺមួយអាទិត្យក្រោយពីសេចក្តីថ្លែងការណ៍ស្រដៀងគ្នាមួយធ្វើដោយគណៈកម្មការកណ្តាលនៃ ***រណសិរ្សរំដោះជាតិវៀតណាមខាងត្បូង*** *(រ.រ.ជ.វ.ត.)* សីហនុបានផ្ញើសារទៅ **ង្វៀន ហ៊ូថូ** ប្រធានគណៈកម្មាធិការកណ្តាលនៃគណៈកម្មាធិការប្រតិបត្តិ

អចិន្ត្រៃយ៍ (Presidium) រ.រ.ជ.វ.គ. និងមួយទៀតទៅ **ផាំវ៉ាន់ដុង** នាយករដ្ឋមន្ត្រីនៃស.ប.វ. ដើម្បីស្នើសុំតម្លើងទំនាក់ទំនងទូតរវាងអង្គភាពនយោបាយ និងរាជរដ្ឋាភិបាលកម្ពុជា ។ បន្ទាប់មកទៀត នៅថ្ងៃ២៤មិថុនា១៩៦៧ សេចក្តីជូនដំណឹងជាផ្លូវការមួយនៅហាណូយបានប្រកាសពីទំនាក់ទំនងផ្លូវទូតរវាងស.ប.វ. និងកម្ពុជា ។ ពេលនេះ នយោបាយការបរទេសរបស់សីហនុបានងាកយ៉ាងខ្លាំងទៅរកវៀតណាមខាងជើង ។

## ៩_វៀតណាមខាងជើងទាស់នឹងខ្មែរក្រហមដោយសារសីហនុ

យួនកុម្មុយនិស្តមានអាកប្បកិរិយាប្លែកគួរឲ្យកត់សំគាល់រវាងរដ្ឋាភិបាលសីហនុ និងពួកខ្មែរក្រហម ។ នៅពេលមានកិច្ចព្រមព្រៀងក្រុងហ្សឺណែវ១៩៥៤ យួនបានទទួលស្គាល់ភាពទន់ខ្សោយរបស់ខ្លួននៅកម្ពុជាដែលជាហេតុធ្វើឲ្យគេសុខចិត្តដកទ័ពចេញពីប្រទេសនេះ ។ ការព្រួយបារម្ភជាបន្ទាន់របស់យួនកុម្មុយនិស្តគឺការត្រួតត្រាទាំងស្រុងលើវៀតណាមខាងត្បូង ។ ចំណែកកម្ពុជា គេគ្រាន់តែទុកជាឈ្នាន់សម្រាប់ជាន់ដើម្បីសម្រេចគោលដៅនេះសិន។

ផ្ទុយទៅវិញ ពួកមេដឹកនាំប.ក.ក. ក្រោមសម្ពាធរបស់ប៉ូលិសនិងទាហានសីហនុ បានប្រឆាំងនឹង"របបសក្តិភូមិ"របស់ទ្រង់ដ៏ខ្លាំងក្លាដែលគេពិបាកនឹងបង្ក្រាប ។ ចាប់ពីឆ្នាំ១៩៦០ដល់៦៧ ពួកគេបានសម្របសម្រួលជា_មួយយុទ្ធសាស្ត្រយួន ដោយបានធ្វើការតស៊ូនយោបាយ(មិនមែនតស៊ូដោយអាវុធ) ជាមួយរាជរដ្ឋាភិបាលកម្ពុជា ។ ប៉ុន្តែនៅឆ្នាំ១៩៦៧ គេបានមើលឃើញថា សីហនុបានប្រឆាំងនឹងសកម្មភាពស្របច្បាប់របស់ពួកគេ ។ ក្នុងឆ្នាំនោះ ពួកគេក៏បានប្រុងប្រៀបរៀបចំបង្កើតកងទ័ពព្រៃ ដើម្បីបះបោរប្រឆាំងនឹងរដ្ឋាភិបាល។

ខែមេសា១៩៦៧ ចលាចលមួយបានផ្ទុះឡើងនៅតំបន់សំឡូត ខេត្តបាត់ដំបង ភាគខាងលិចកម្ពុជា។ អំពើអយុត្តិធម៌ទៅលើអ្នកស្រុកបានបណ្តាលឲ្យមានកុប្បកម្មមួយ ដែលត្រូវបានបង្ក្រាបយ៉ាងឥតរួញរាពីរដ្ឋាភិបាល ។ ខ្មែរក្រហមឥតបានទាក់ទិននៅក្នុងឧទ្ទាមកម្មនេះទេ តែទោះជាយ៉ាងណាក៏ដោយ ពួកអ្នកបដិវត្តក្រោយៗបានយកព្រឹត្តិការណ៍នេះជាដើមទុន ដើម្បីបំផុសសកម្មភាពបែបនេះនៅទីកន្លែងផ្សេងទៀត ។ ខែមករា១៩៦៨ ប.ក.ក. បានដឹកនាំការបះបោរមួយប្រឆាំងនឹងរដ្ឋាភិបាល ដោយរួមកម្លាំងជាមួយជនជាតិភាគតិចខ្មែរលើ នៅភាគឦសានប្រទេស ។ គេបានប្តូរផ្តាច់ថានឹងរំលំរដ្ឋាភិបាលឲ្យបានក្នុងរយៈពេលតិចជាងពីរឆ្នាំ ។ នៅដើមឆ្នាំ១៩៧០ ប.ក.ក. មានទ័ពព្រៃហ្វឹកហ្វឺនរាប់ពាន់នាក់ ប្រតិបត្តិការនៅតំបន់ផ្សេងៗគ្នាក្នុងប្រទេស ដែលភាគច្រើនបានតាំងទីនៅភាគឦសាន មុំខេត្តរតនគិរីនិងមណ្ឌលគិរី នៅជិតផ្លូវលំហូជីមិញ ហើយដែលគេចាត់ថាជាខែលការពាររបស់ទ័ពព្រៃយួនកុម្មុយនិស្ត។

បើទោះជាគេដណ្តើមបានអាវុធជាច្រើនពីកងទ័ពរដ្ឋាភិបាលក៏ដោយ ក៏ពួកខ្មែរក្រហមតែងបានជំនួយតិចតួចខ្លះដែរពីយួនកុម្មុយនិស្ត ។ តែគេមិនបានទទួលនូវជំនួយគ្រប់បែបយ៉ាងដែលគេចង់បាននោះទេ ។ យោងតាមអតីតកម្មាភិបាលយួនកុម្មុយនិស្តម្នាក់ ខ្មែរក្រហមបានសុំគ្រឿងអាវុធពីយួនដើម្បីធ្វើការបះបោរជាទូទៅមួយប្រឆាំងនឹងរដ្ឋាភិបាលសីហនុ ។ យួនប្រកែកដោយហេតុថា ទ័ពខ្មែរក្រហមនៅខ្សោយពេក គ្មានប្រជាប្រិយភាពក្នុងស្រទាប់ប្រជាជន ហើយគេអាចត្រូវកម្ទេចភ្លាមមួយរំពេចបើសិនគេហ៊ានងើបប្រឆាំង ។ សំខាន់ជាងទៅទៀតប្រហែលជាយួនយល់ឃើញថា រដ្ឋាភិបាលសីហនុមានអត្ថប្រយោជន៍ដល់ទ័ពព្រៃយួនក្នុងការដែលរដ្ឋាភិបាលនេះអនុញ្ញាតឱ្យពួកគេប្រើទឹកដីខ្មែរដើម្បីវាយវៀតណាមខាងត្បូង ។ ដោយមើលឃើញថាជំនួយរបស់យួនមានព្រំដែនមេដឹកនាំខ្មែរក្រហមភាគច្រើនយល់ឃើញថា ទីក្រុងហាណូយបានបោះបង់ពួកគេចោលហើយ ។

## ១០_ការប្តូរនយោបាយរបស់សីហនុចំពោះវៀតណាមខាងជើង

ដោយថាហេតុ ឥរិយាបទរបស់សម្តេចសីហនុចំពោះយួនកុម្មុយនិស្តប្រែប្រួលទៅតាមនយោបាយក្នុងស្រុក ។ សមាជិករដ្ឋាភិបាលខ្មែរជាច្រើន និងកងទ័ពមានការក្រេវក្រោធកាន់តែខ្លាំងឡើង ចំពោះការឈ្លានពានទឹកដីជាបន្តបន្ទាប់ពីពួកយួន ។ តាមសម្តេចសីហនុ ថានាយទាហានជាច្រើនទឹងសម្បានឹងទ្រង់ជាខ្លាំង ក្នុងការដែលទ្រង់បានផ្តាច់ទំនាក់ទំនងជាមួយស.រ.អ.ជាពិសេសជំនួយយោធា ។ ពួកនាយទាហាននិងវរៈជនជាច្រើនផ្សេងទៀត ដូចជាទ្រង់សិរិមតៈ ដែលត្រូវជាបងប្អូនជីដូនមួយរបស់ទ្រង់ជាដើម ចង់ឱ្យខ្មែរមានការជិតស្និទ្ធកាន់តែខ្លាំងជាមួយស.រ.អ.ដើម្បីរួមគ្នាវាយយួនកុម្មុយនិស្ត ។ សីហនុខ្លួនឯងមិនចង់ប្រឆាំងនឹងយួនកុម្មុយនិស្តទេ តែទ្រង់ក៏ចង់ឱ្យមានការឆ្លើយតបចំពោះការគាបសង្កត់នេះដែរ ។

នៅចុងឆ្នាំ១៩៦៧ សម្តេចបានងាកទៅរកជំហរអព្យាក្រឹតពិតប្រាកដមួយរវាងស.រ.អ.និងវៀតណាមខាងជើង ។ ទ្រង់បានមានប្រតិកម្មខ្លះៗចំពោះព្រឹត្តិការណ៍បះបោរនៅបាត់ដំបងដែលមានខ្មែរក្រហមនៅពីក្រោយ ដែលទ្រង់យល់ច្រឡំថាជាឧបករណ៍របស់ចិន ឬមួយជារបស់យួន ។ ទ្រង់ក៏មានប្រតិកម្មដែរចំពោះសកម្មភាពរបស់ពួកអ្នកនយោបាយ "ស្របច្បាប់" ខ្មែរក្រហម **ហ៊ូ_យន់ ហ៊ូ_និម និងខៀវ_សំផន** ដែលបានផ្សព្វផ្សាយមនោគមន៍វិជ្ជាម៉ៅប្រឆាំងនឹងរដ្ឋាភិបាល តាមរយៈសមាគមមិត្តភាពខ្មែរ_ចិន ។ ប៉ុន្តែទ្រង់ក៏បានមានប្រតិកម្មផងដែរចំពោះការលេចឡើងជាសាធារណៈ នូវសក្តីភាពដ៏ខ្លាំងក្លានៃទីជំរករបស់យួនកុម្មុយនិស្តនៅលើទឹកដីខ្មែរ ។ នៅថ្ងៃ៩វិច្ឆិកា១៩៦៧ អ្នកកាសែតបរទេសបានរកឃើញជំរំវៀតកុងដែលគេបោះបង់ចោល ស្ថិតនៅចម្ងាយជាង៦គ.ម.ពីព្រំប្រទល់ ក្នុងទឹកដីខ្មែរ ។ ថ្ងៃ៤ធ្នូ១៩៦៧ ស.រ.អ.បានចេញសេចក្តីប្រឆាំងមួយចំពោះកម្ពុជា បញ្ជាក់អំពីការ

ព្រួយបារម្ភនៃការប្រើទឹកដីខ្មែរដោយយួនខាងជើង និងវៀតកុង ។ នៅចុងខែធ្នូ ស.រ.អ.បានចាប់ផ្តើមធ្វើការឃោសនាផ្លូវទូតមួយ ដើម្បីសុំការគាំទ្រជាអន្តរជាតិ សំរាប់ពង្រឹងការត្រួតពិនិត្យអន្តរជាតិទៅលើអព្យាក្រឹតភាពរបស់កម្ពុជា ។

នៅក្នុងសម្ភាសមួយជាមួយអ្នកសារពត៌មានអាមេរិកាំង **(ស្ទែនលី ការណូវ)** សីហនុបានបញ្ជាក់ថា : ទ្រង់នឹងមិនធ្វើអ្វីទាំងអស់ បើ ស.រ.អ.វាយប្រហារទៅលើមូលដ្ឋានយួនកុម្មុយនិស្តនៅក្នុងតំបន់ដាច់ស្រយាលនៃប្រទេស ។ ទ្រង់អាចនឹងវាយបកតបវិញ ដោយទំនងជាហៅរកជំនួយពីចិន ពីកូរ៉េខាងជើង ឬពីគុបា បើសិនជាជនរងគ្រោះជាជនជាតិខ្មែរ ឬជាជនជាតិយួនស្របច្បាប់នៅកម្ពុជា ។ សារដដែលនេះក៏ត្រូវបានបញ្ជាក់ឡើងវិញម្តងទៀតចំពោះតំណាងរដ្ឋាភិបាលស.រ.អ.ចេស្ទ័រ បាវលេស (Chester Bowles) នៅភ្នំពេញ ក្នុងខែមករា ១៩៦៨ ។

ក្នុងឆ្នាំ១៩៦៨ សីហនុបានថ្កោលទោសខ្មែរក្រហមជាសាធារណៈថាចង់"បើកទ្វារកម្ពុជាឲ្យចៅហ្វាយវៀត-មិញរបស់គេចូល" ។ ឆ្នាំ១៩៦៩ សីហនុបានចាប់ផ្តើមទិតៀនជាចំហចំពោះសកម្មភាពរបស់យួនខាងជើង និងវៀតកុងនៅក្នុងទឹកដីខ្មែរ ។ ក្នុងសន្និសិទកាសែតមួយនៅភ្នំពេញ ថ្ងៃ១៧ ឧសភា ទ្រង់បានបញ្ជាក់ថា:

> **"ខ្ញុំមានការសោកស្តាយដោយមិត្តវៀតកុង និងវៀតមិញរបស់យើង ដែលបានប្រកាសថា គោរពអព្យា-ក្រិតភាព ឯករាជ្យភាព និងបូរណភាពទឹកដីក្នុងព្រំប្រទល់របស់ខ្លួន ហើយនិងបានទទួលស្គាល់ព្រំប្រទល់នេះ ក៏បានជួយហ្វឹកហ្វឺនពួកខ្មែរក្រហមផងដែរ ។"**

នៅខែឧសភា សីហនុបានភ្ជាប់ទំនាក់ទំនងទូតជាមួយស.រ.អ.ឡើងវិញ ។ ប៉ុន្តែនៅខែបន្ទាប់មក ទ្រង់បានតម្លើងឋានៈតំណាងរណសិរ្សរំដោះជាតិវៀតណាមខាងត្បូងឲ្យស្មើនឹងថ្នាក់ទូត ។ រដ្ឋាភិបាលរបស់ទ្រង់តែងដាក់សម្ពាធជានិច្ចទៅលើទ្រង់ឲ្យកង់ទ័ពយួនដកចេញទាំងអស់ពីទឹកដីខ្មែរ ។ ការដាក់សម្ពាធនេះបាននាំមកដល់ទ្រង់នូវដំណើរស្លាប់រស់មួយទៅបរទេស ក្នុងលេសថាទៅព្យាបាលរោគនៅបារីស ក្នុងខែមករា១៩៧០ ។

ថ្ងៃ៨ និង១១មីនា បាតុកម្មហិង្សាមួយប្រឆាំងនឹងយួនកុម្មុយនិស្ត និងយួនស៊ីវិលដែលរស់នៅស្រុកខ្មែរបានផ្ទុះឡើងនៅខេត្តស្វាយរៀង ។ ថ្ងៃ១១មីនា មានបាតុកម្មដ៏ធំមួយប្រឆាំងនឹងយួនវៀតកុង នៅក្នុងទីក្រុងភ្នំពេញ ។ ស្ថានទូតវៀតណាមខាងជើង និងស្ថានទូតរដ្ឋាភិបាលបដិវត្តបណ្តោះអាសន្នវៀតណាមខាងត្បូង រួមទាំងការិយា-ល័យនៃទីភ្នាក់ងារសារពត៌មានវៀតណាមផងបានត្រូវលួចប្លន់ និងបំផ្លិចបំផ្លាញ ។ អ្នកឆ្លើយឆ្លងពត៌មានជាច្រើនបានអះអាងថា បាតុកម្មនេះត្រូវបានផ្តួចផ្តើមឡើងដោយរដ្ឋាភិបាល ។

សម្តេចសីហនុបានចាកចេញពីបារីសទៅម៉ូស្គូនិងប៉េកាំងនៅថ្ងៃ១៣មីនា១៩៧០ មិនត្រឹមតែដើម្បីរកជំនួយ

ឲ្យកម្ពុជាប៉ុណ្ណោះទេ តែគឺដើម្បីព្យាយាមបញ្ចុះបញ្ចូលចៅហ្វាយរបស់ហាណូយ ឲ្យដាក់ឥទ្ធិពលលើកូនដីងរបស់គេថែមទៀតផង ។ ក្រោយមក សីហនុបានបញ្ជាក់ថា សម្ពើរបស់ទ្រង់ឲ្យគាបសង្កត់ហាណូយនោះបានត្រូវទាត់ចោលដោយមេដឹកនាំសូវៀត។

នៅថ្ងៃដែលសីហនុទៅដល់ម៉ូស្គូ រដ្ឋាភិបាលខ្មែរដឹកនាំដោយនាយករដ្ឋមន្ត្រីលន់ណុលបានសុំឲ្យសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម និងរដ្ឋាភិបាលបដិវត្តបណ្ដោះអាសន្នវៀតណាមខាងត្បូងដកទ័ពចេញពីដីខ្មែរ នៅព្រលឹមថ្ងៃ១៥មីនា ។ ថ្ងៃ១៨មីនា១៩៧០ នៅពេលដែលសម្ដេចសីហនុកំពុងនៅទីក្រុងម៉ូស្គូនៅឡើយ លន់ណុលបានដឹកនាំរដ្ឋប្រហារដោយឥតបង្ហូរឈាមមួយ ។ កម្ពុជាបានមកដល់ភាពប្រឈមមុខគ្នាមួយជាមួយយួនកុម្មុយនិស្តដែលនឹងផ្ទុះឡើងក្នុងពេលដ៏ខ្លី ។ ឥរិយាបទរបស់យួនកុម្មុយនិស្តចំពោះកម្ពុជា និងជាពិសេសចំពោះចលនាខ្មែរកុម្មុយនិស្ត បានចុះបញ្ចាំងនូវឥរិយាបទជាប្រពៃណីរបស់យួន ចំពោះអ្នកជិតខាងទិសខាងលិចរបស់គេ ។ ផ្នត់គំនិតរបស់យួនកុម្មុយនិស្តបានត្រូវអប់រំខ្លះៗរួចទៅហើយនៅឆ្នាំ១៩៣០ តាមបញ្ជារបស់កុម្មុយនិស្តអន្តរជាតិ(Comintern) ឲ្យបង្កើតជារដ្ឋសហព័ន្ធមួយគ្រប់គ្រងដោយបក្សកុម្មុយនិស្តឥណ្ឌូចិន (I.C.P.) ។ បញ្ជារបស់កុម្មុយនិស្តអន្តរជាតិ *(ក.អ.)* នៅពេលនោះមានសារៈសំខាន់ណាស់ ដោយហេតុថាវាបានផ្ដល់នូវភាពស្របច្បាប់មួយក៏រិតនៃនយោបាយម៉ាក់ស៊ីស្ត៍ តាមរយៈគំនិត"វណ្ណៈអធនអន្តរជាតិ" ស្របតាមមហិច្ឆតាដ៏ច្បាស់ក្រឡែតរបស់**ចក្រពត្តយួន**តែប៉ុណ្ណោះ ។ នៅពេលដែលបទបញ្ជាបានត្រូវដាក់ចេញ ពិភពកុម្មុយនិស្តជាផ្ទាំងថ្មមួយដ៏ធំ រីឯការរីកសាយភូមិសាស្ត្រនៃឥទ្ធិពលរបស់យួនកុម្មុយនិស្តអាចពិពណ៌នាប្រាប់សមមិត្ត *(សមាជិកបក្សកុម្មុយនិស្ត)* ឯទៀតថាគ្រាន់តែជាការរីកសាយនៃ**ប្លុកសង្គមនិយម**តែប៉ុណ្ណោះ ។

ប៉ុន្តែក្រោយឆ្នាំ១៩៦០ ជាមួយនិងការបាក់បែកសាមគ្គីគ្នាយ៉ាងចាប់ហ័សនៅក្នុង "បក្សសង្គមនិយម" ការប្រកាន់យកនូវ**នយោបាយជាតិដោយខ្លួនឯង**បានផុះចេញឡើងជាទស្សនៈស្របច្បាប់ថ្មីមួយក្នុងការវាយតម្លៃទំនាក់ទំនងនយោបាយរវាងប្រទេសដែលប្រកាន់មនោគមន៍វិជ្ជាម៉ាក់_ឡេនីននិងចលនាបដិវត្តនានា ។ ការបង់ទាក់យកប្រទេសយូហ្គោស្លាវីរបស់គ្រុចចូវ ដោយការពិភាក្សាគ្នាអំពី "មាគ៌ាផ្សេងៗឆ្ពោះទៅរកសង្គមនិយម"បានចាប់ផ្ដើមស្អុយរលួយ ។ ការទទឹងរឹងរុះរបស់ចិនជាមួយសូវៀតក្រោយឆ្នាំ១៩៦០ ជាគំរូទីពីរផ្ដល់ដល់ពួកគេ ។ ក្នុងករណីពិសេសនៅឥណ្ឌូចិន ព្រឹត្តិការណ៍នេះបានឲ្យជាគំរូដល់ខ្មែរកុម្មុយនិស្ត ។ ជាលទ្ធផល ទ្រឹស្តីរបស់**ក.អ.** ដែលយួនកុម.បានចិញ្ចឹមទុកក្នុងចិត្តជាយូរមកហើយនោះ ក៏លែងបានត្រូវគេយកមកអនុវត្តតាមមនោគមន៍វិជ្ជាដដែលក្នុងពិភពកុម្មុយនិស្តទៀតហើយ ។ មហិច្ឆតារបស់យួនកុម.ចំពោះកម្ពុជានិងប.ក.ក. នឹងមិនអាចទទួលបានដោយស្វ័យប្រវត្តិឡើយ។

នៅឆ្នាំ១៩៧៥ ដោយមានការវិវត្តន៍នៅក្នុងលោកកុម្មុយនិស្ត ទស្សនៈសហព័ន្ធឥណ្ឌូចិនអាចនឹងជំនួស ដោយការប្រកាសដ៏ត្រឹមត្រូវរបស់យួនកុម.ជាមួយនឹងគំនិត "ទំនាក់ទំនងពិសេស" រវាងយួននិងអ្នកជិតខាង (ខ្មែរ និងលាវ) ។ ប៉ុន្តែ ការផ្លាស់ប្តូរក្នុងភាសានិយាយ ក្នុងទស្សនៈនយោបាយ និងអាកប្បកិរិយាឥតលាក់លាមចេះតែមានជាបន្ត ។ យើងនឹងឃើញថា វាគ្មានអ្វីប្រែប្រួលជាដុំកំភួនឡើយនៅក្នុង**អសមភាពអំណាច** *(អំណាចមិនស្មើគ្នា)* នៃប្រជាជាតិនៅឥណ្ឌូចិន *(អសមភាពមួយដែល ក.អ.បានធ្វើឲ្យស្របច្បាប់តាំងពីដើមទីមក)* ។

នយោបាយរបស់មេដឹកនាំខ្មែរ *(សម្តេចសីហនុ)* ចំពោះយួនដែលបែកគ្នាជាបណ្តោះអាសន្ននេះ ប្រព្រឹត្តទៅដដែលៗតាមរបៀបរបស់មេដឹកនាំខ្មែរពីអតីតកាល តាំងពីមុនពេលដែលប្រទេសត្រូវបានធ្លាក់ក្រោមអាណានិគមរបស់បារាំងម៉្លេះ ។ **ទ្រង់មិនចង់ក្លាយជាអ្នកប្រឆាំងជាមួយអ្នកខ្លាំងនៅទិសខាងកើត គឺយួនខាងជើងនិងយួនខាងត្បូងឡើយ** ។ ព្រមពេលជាមួយគ្នានោះដែរ **ទ្រង់បានស្វែងរកការធានាការពារពីបរទេសយួន** ។ ដំបូង ទ្រង់អនុវត្តនយោបាយអព្យាក្រឹតរវាងលោកខាងកើតនិងលោកខាងលិច ។ បន្ទាប់មក នៅឆ្នាំ១៩៦៣ ពេលដែលទ្រង់ដឹងថាអំណាចរបស់ទ្រង់ត្រូវបានប្រចាំងដោយរដ្ឋាភិបាលយួនខាងត្បូងដែលគាំទ្រដោយស.រ.អា. ទ្រង់បានងាកទៅចាប់ដៃចិននិងយួនខាងជើង ។ ក្នុងឆ្នាំ១៩៦៧ នៅពេលដែលមានសម្ពាធមនោគមវិជ្ជានិងគំនិតជាតិនិយមដ៏ឆ្អិនក្តៅរបស់ចិនក្នុងសម័យ ***បដិវត្តវប្បធម៌*** ទ្រង់បានត្រឡប់ក្រោយងាកមកអព្យាក្រឹតភាពវិញ ។ ទ្រង់បានបញ្ជាក់ដោយខ្លួនឯងថា នេះគឺជា **វិធីដោះស្រាយប្រាកដនិយម**មួយរបស់នយោបាយ ។ ជាចុងក្រោយ សម្ពាធនៃនយោបាយក្នុងស្រុក ជាពិសេស ការមិនសប្បាយចិត្តនៃវរជននយោបាយរបស់ទ្រង់បានជំរុញសម្តេចសីហនុឲ្យងាកទៅរកលោកខាងលិចវិញនៅឆ្នាំ១៩៦៩_៧០ ហើយដែលបាននាំទៅដល់ការដកអំណាចពីទ្រង់ក្នុងទីបំផុត ។

គួរកត់សំគាល់ថា នៅស្រុកខ្មែរមាន **សិល្បៈនៃការដឹកនាំប្រទេសបែបបុរាណ**មួយដែលគេប្រើសំរាប់ការពារជាតិទល់នឹងប្រទេសខ្លាំងនៅជិតខាង ដោយប្រើកលល្បិចនិងនយោបាយបត់បែន ដើម្បីឲ្យមានតុល្យការនៅក្នុងសម្ពន្ធភាព ។ នយោបាយក្រៅប្រទេសរបស់សម្តេចសីហនុភាគខ្លះបានដើរតាម **នយោបាយបែបបុរាណ** នេះឯង។

ភាពប្រាកដនិយមរបស់សីហនុ មានភាពផ្ទុយស្រឡះពីគោលការណ៍នយោបាយការបរទេសរបស់ពួកខ្មែរក្រហមដែលដណ្តើមបានអំណាចនៅឆ្នាំ១៩៧៥ ។ ប៉ុន្តែសញ្ញាជឿនលឿនជាបន្តបន្ទាប់នៃការដឹកនាំនយោបាយការបរទេសបែប **មិនបុរាណ** មួយ បានត្រូវគេរកឃើញនៅក្នុងការប្រព្រឹត្តិរបស់ពួកខ្មែរក្រហមចំពោះសម្ពន្ធមិត្តរបស់គេ នាពេលធ្វើកុប្បកម្មពីឆ្នាំ១៩៧០ដល់១៩៧៥ គឺតាំងពីមុនពេលដែលគេដណ្តើមបានអំណាចម៉្លេះ ។

♥

# ជំពូកពីរ

## ១_ការងើបឡើងជាសាធារណៈនិងការធ្លាក់ចុះជាសម្ងាត់នៃ"យុទ្ធសាមគ្គីភាព" យួននិងខ្មែរកុម្មុយនិស្ត:១៩៧០_៧៥:

មុនរដ្ឋប្រហារលន់_ណុល ខែមីនា១៩៧០ ការធ្វើឱ្យបានសម្រេចនូវអនុត្តរភាពលើកម្ពុជាហាក់ដូចជានៅតែស្ថិតក្នុងការពិចារណាដ៏យូរអង្វែងមួយសម្រាប់យួនកុម. ។ គោលដៅរយៈពេលខ្លីរបស់គេគឺការយកជ័យជំនះលើ ស.រ.អ. និងយួនខាងត្បូង ។ ចំពោះយួនខាងជើង កម្ពុជាគឺជាបញ្ហាភូមិសាស្ត្រនយោបាយមួយដ៏មានសារៈសំខាន់ក្នុងការប្រយុទ្ធដើម្បីរំដោះវៀតណាមខាងត្បូង ។ រហូតមកទល់នឹងខែមីនា១៩៧០ វាជាចំណោទមួយដែលមេដឹកនាំហាណូយបានខិតខំលៃលកទាល់តែបានជោគជ័យយ៉ាងប្រសើរក្នុងផ្នែកយោធា ។ ដរាបណាសីហនុនៅកាន់អំណាច ហើយនៅតែអនុញ្ញាតឱ្យទ័ពយួនកុម.ប្រើប្រាស់ទឹកដីខ្មែរជាជំរកនិងជាផ្លូវផ្គត់ផ្គង់ពស្តុភា ដរាបនោះហាណូយគ្មានរឿងអ្វីនឹងត្រូវផ្គួលរំលំទ្រង់ឡើយ ។ ផ្ទុយទៅវិញ ស្ថិរភាពរបស់សីហនុ (ឬយ៉ាងហោចណាស់ស្ថិរភាពនៃនយោ_បាយរបស់ទ្រង់ចំពោះហាណូយ ព្រៃនគរ និងវ៉ាស៊ីងតុន) គឺជាយុទ្ធសាស្ត្រចាំបាច់ក្នុងរយៈពេលខ្លីសម្រាប់យួនកុម. ។

ខ្មែរក្រហមមានទស្សនៈផ្ទុយស្រឡះពីសម្តេចសីហនុ ។ គេមានបំណងចង់រំលាយ"របបសក្តិភូមិ"របស់ទ្រង់ ហើយដាក់ជំនួសវិញដោយរបបផ្តាច់ការរបស់គេ ។ ដោយទោរទន់ទៅតាមភាពរឹងរុះរបស់ម៉ៅ_សេទុងជាមួយនឹងអំណាចសូវៀត ពួកអ្នកបដិវត្តខ្មែរទាំងនេះបានមានបំណងទទួលយកនូវជំនួយនយោបាយ និងយោធារយៈពេលខ្លីពីយួន ។ ប៉ុន្តែពួកគេបានប្រានចោលទាំងស្រុងនូវអនិស្សរភាព (ភាពពឹងពាក់គេ) ទៅលើជំនួយមាគ៌ានយោបាយ និងយោធាពីយួនកុម.ក្នុងការសម្រេចគោលដៅបដិវត្តរបស់គេ ។

នៅដើមឆ្នាំ១៩៧០ មេដឹកនាំហាណូយមិនបានដឹងពីវិសមានចិត្ត (ការស្អប់ខ្ពើម) របស់ខ្មែរក្រហមចំពោះពួកគេទេ គេគ្រាន់តែដឹងថា ខ្មែរក្រហមមិនស្ថិតនៅក្រោមបញ្ជាផ្ទាល់របស់គេប៉ុណ្ណោះ ។ ប៉ុន្តែបើផ្អែកទៅលើស្ថានការណ៍សឹកនិងនយោបាយនៅឥណ្ឌូចិននាពេលនោះ ទីក្រុងហាណូយគ្មានអ្វីគួរឱ្យឆ្ងល់ទេថា ភាពមិនស្មើគ្នាដោយអន្លើៗខ្លះអាចនឹងត្រូវកែតម្រូវបានដោយវិធីប្រើងប្រែង និងវិធីបង្ហាញភស្តុតាង: ការគំរាមកំហែង ឬការសំ_ដែងឥទ្ធិពលយោធាជាយថាហេតុពីសំណាក់កងទ័ពវៀតកុង និងការបញ្ជូនភ្នាក់ងារនយោបាយដែលស្មោះត្រង់នឹងទីក្រុងហាណូយ (ខ្មែរវៀតមិញ) នៅក្នុងស្ថានការណ៍ជាបន្តបន្ទាប់ ។

រដ្ឋប្រហារឥតបង្ហូរឈាមដោយរដ្ឋាភិបាលសីហនុខ្លួនឯង បានរើរុះសាជាថ្មីនូវសម្ពន្ធភាពនយោបាយរបស់ឥណ្ឌូចិន ។ រដ្ឋប្រហារក៏បានស្រាយចំណងព្រឹត្តិការណ៍នយោបាយនិងយោធាផងដែរ ដែលគួប្រកួត ទោះកុម្មុយ_

និស្កត្តីមិនមែនកុម្មុយនិស្កត្តីមិនអាចទោះទាយបាន ឬក្តោបក្តាប់បាន ។ ប៉ុន្តែវាក៏បានបង្ហាញឲ្យឃើញផងដែរ ចំពោះអ្នកដែលយកចិត្តទុកដាក់លើទស្សនវិស័យដ៏ចម្លែករបស់ខ្មែរក្រហម ជាពិសេសការលះបង់ការខំប្រឹងប្រែងទាំងឡាយដែលទាក់ទងនឹងភាពទន់ខ្សោយរបស់គេក្នុងវិស័យនយោបាយ និងវិស័យយោធា ។

ព្រឹត្តិការណ៍ឆ្នាំ១៩៧០_៧៥ បណ្តាលឲ្យមានសង្គ្រាមឥណ្ឌូចិនលើកទីបី ដែលសង្គ្រាមនេះបានចាប់កំណើតតាំងពីមុនចប់សង្គ្រាមឥណ្ឌូចិនលើកទីពីរម្ល៉េះ ។

## ២_កុប្បកម្មក្រោមបរិបាលកិច្ច (កិច្ចឧបត្ថម្ភ) របស់ហាណូយ ខែមេសា១៩៧០_មីនា១៩៧២:

រដ្ឋប្រហាររបស់លន់_ណុលហាក់ដូចជាបានធ្វើឲ្យគេឯងគ្រប់គ្នាមានការភ្ញាក់ផ្អើល ដោយក្នុងនោះមានទាំងស.រ.អ.ផងដែរ ។ តាមសេចក្តីសន្និដ្ឋានរបស់ **វិល្លាម សវគ្រុស**(William Shawcross) ក្រោយពីបានពិនិត្យឯក_សាររបស់រដ្ឋាភិបាល បានមកពីផ្នែកពត៌មានសេរីរបស់ស.រ.អ. បានបញ្ជាក់ថា "គ្មានការជាប់ជំពាក់វាកវីនផ្ទាល់របស់ស.រ.អ.ទេនៅពេលមុនរដ្ឋប្រហារ ។"

ការដាក់សីហនុជំនួសដោយរបបមួយដែលចង់កំចាត់យួនកុម.រចេញពីដីខ្មែរ បានផ្លាស់ប្តូរទំនាក់ទំនងនយោ_បាយរវាងយួនកុម. និងខ្មែរក្រហម ។ ហាណូយត្រូវការដីរករបស់ខ្លួននៅក្នុងដីខ្មែរ ដើម្បីធ្វើសង្គ្រាមប្រឆាំងស.រ.អ. និងវៀតណាមខាងត្បូង ។ មន្ត្រីជាន់ខ្ពស់យួនកុម.**ហួង_អាញ់** បានថ្លែងបញ្ជាក់នៅក្នុងសេចក្តីរាយការណ៍សម្ងាត់មួយ នាសម័យប្រជុំពេញអង្គរបស់គណៈកម្មាធិការកណ្តាលបក្ស ប្រាំបួនខែក្រោយរដ្ឋប្រហារថា:

> **"យើងត្រូវតែមានការប្រុងប្រយ័ត្នខ្ពស់ចំពោះកម្ពុជា ដោយហេតុថាជោគជ័យរបស់យើងនៅវៀតណាមខាងត្បូង និងពឹងផ្អែកទាំងស្រុងថា តើយើងនឹងប្រតិបត្តិការមានប្រសិទ្ធិភាពយ៉ាងណានៅកម្ពុជា. . . បញ្ហាកម្ពុជាសំខាន់ណាស់ ។ ដើម្បីឲ្យដំណោះស្រាយមានជោគជ័យ យើងត្រូវរៀបចំទ័ពឲ្យបានប្រសើរនៅទីនោះ ហើយនឹងផ្តល់ជំនួយសម្ភារៈដល់កងកម្លាំងស្នេហាជាតិក្នុងស្រុកផង "។**

ក្រោយរដ្ឋប្រហារខែមីនា១៩៧០ ហាណូយបានចូលរួមក្នុងរយៈពេលខ្លីជាមួយខ្មែរក្រហម ដើម្បីរំលំរដ្ឋា_ភិបាលកម្ពុជា។ បន្តិចក្រោយមក មានការបញ្ជាក់ឲ្យឃើញថា ការសម្របឡើងវិញខាងផ្នែកនយោបាយសឹកថ្នាក់ទូតជាការចាំបាច់ ។ នៅថ្ងៃ២១មីនា រដ្ឋាភិបាលយួនខាងជើងបានថ្កោលទោសរដ្ឋប្រហារលន់_ណុល ថាជាស្នាដៃរបស់ស.រ.អ.ហើយបានសន្យានូវការគាំទ្រភ្លាមៗរបស់ខ្លួនចំពោះសម្តេចសីហនុ ដែលនឹងត្រូវតែងតាំងជាមេគ្គទេសក៍ក្នុងរដ្ឋាភិបាលចំរុះមួយ ។

ថ្ងៃ២៦ឧសភា សីហនុបានត្រូវទទួលជាភ្ញៀវផ្លូវការរបស់វៀតណាមខាងជើង ។ អង្គការនយោបាយចំរុះដែលមានសីហនុជា មគ្គុទេសក៏តែងតាំង បានត្រូវគេស្គាល់ជាទូទៅថា **ហ្វ៊ុង** (FUNK) ជាភាសាបារាំង ដែលមានន័យថា"រណសិរ្សរួបរួមជាតិកម្ពុជា" ។ រដ្ឋាភិបាលឡប់ឡែដែលតំណាងប្រជាជននៅតំបន់គ្រប់គ្រងដោយហ្វ៊ុង មានឈ្មោះជាអក្សរកាត់ថា **គ្រុង** (រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា) មានសមាជិកភាគច្រើននៅទីក្រុងប៉េកាំង ។ នយោ_បាយសម្របសម្រួលក៏បានបញ្ជាក់ឲ្យឃើញភ្លាមៗផងដែរនៅលើវិស័យយោធា ។ នៅចុងខែមីនា កងទ័ពយួនខាងជើងនិងយួនវៀតកុងបានបើកការវាយប្រហារទៅលើកងទ័ពនិងទីប្រជុំជនរបស់សាធារណរដ្ឋខ្មែរ ។ នៅពេលជាមួយគ្នានោះដែរ ពួកខ្មែរវៀតមិញប្រហែលមួយពាន់នាក់ដែល បានទទួលការហ្វឹកហាត់នៅហាណូយ ក៏ត្រូវបានលបជ្រៀតចូលមកប្រទេសកម្ពុជាវិញ ។ ភារកិច្ចរបស់គេគឺមកជួយត្រួតត្រាមើលតំបន់ដែលទ័ពវៀតកុងដណ្តើមយកបាន ។ ថ្ងៃ៣០មេសា១៩៧០ គឺប្រាំមួយសប្តាហ៍គត់ក្រោយរដ្ឋប្រហារ កងទ័ពស.រ.អ.និងយួនខាងត្បូងបានបើកការវាយលុកដ៏ធំមួយទៅលើជំរកតាមព្រំដែនក្នុងទឹកដីខ្មែរ ។ យួនកុម. ដោយដឹងថានឹងមានការវាយលុកក៏នាំគ្នាដកទ័ពថយចេញមុនអស់ ។ បើទោះជាទ័ពយួនកុម.បានច្បាំងជាមួយកងទ័ពរដ្ឋាភិបាលថ្មីអស់រយៈពេលជាច្រើនសប្តាហ៍រួចមកហើយក៏ដោយ ក៏បាតុកម្មប្រជារាស្ត្រអាមេរិកាំង និងសេចក្តីជំទាស់របស់សភា ស.រ.អ.បានច្រានចោលជាមុនរួចទៅហើយ នូវគ្រប់សេចក្តីស្នើទាំងឡាយ ចំពោះកិច្ចបន្តប្រតិបត្តិការសឹកដេញតាមទ័ពយួនកុម.នៅក្នុងកម្ពុជា ។ ដូចនេះ ពីរខែក្រោយមក នៅពេលកងទ័ពអាមេរិកាំងដកថយចេញពីតំបន់ព្រំដែនពួកគេបានបោសសំអាតដោយជោគជ័យ នូវមូលដ្ឋានទ័ពជាច្រើនដែលបានគំរាមកំហែងតំបន់ដីសណ្តទន្លេមេគង្គនៃវៀតណាមខាងត្បូង ។ ប៉ុន្តែជាទូទៅ គេពិបាកនឹងកំចាត់កងទ័ពកុម្មុយនិស្ត ដែលស្ថិតនៅក្នុងទឹកដីកម្ពុជាណាស់ ។ ក្នុងការប្រយុទ្ធបួនខែដំបូង ទ័ពវៀតកុងបានត្រួតត្រាទឹកដីខ្មែរពាក់កណ្តាលទៅហើយ ។ បើទោះជាមានការទម្លាក់គ្រាប់បែកឥតឈប់ឈរ ពីកងទ័ពអាមេរិកាំងយ៉ាងណាក៏ដោយ ក៏ពួកទាហានជើងចាស់ក្បាលរឹងរបស់យួនខាងជើងនៅតែមានជំហរល្អដដែល ក្នុងការប្រយុទ្ធតទល់ជាមួយកងទ័ពដ៏មានចិត្តអង់អាចក្លាហានរបស់សាធារណរដ្ឋខ្មែរ ដែលខ្សត់ខ្សោយខាងការហ្វឹកហាត់និងខាងគ្រឿងអាវុធ ។

ក្នុងរយៈពេលពីរឆ្នាំបន្ទាប់នៃការប្រយុទ្ធនៅកម្ពុជា ហាណូយជាអ្នកកំណត់លទ្ធផលនៃព្រឹត្តិការណ៍យោធា ។ ចុងឆ្នាំ១៩៧០ យួនខាងជើងមានទាហានបួនកងពលនៅកម្ពុជា ជាមួយកងទ័ពប្រមាណ១០ពាន់នាក់សម្រាប់ច្បាំងនឹងកងទ័ពសាធារណរដ្ឋខ្មែរ ខ្លះទៀតទុកសម្រាប់ការពារផ្លូវលំ ហូ_ជីមិញ ដែលជាផ្លូវផ្គត់ផ្គង់ស្បៀងទៅសមរភូមិនៅវៀតណាមខាងត្បូង ។ កងទ័ពវៀតកុងខ្លះត្រូវគេបញ្ជូនមកពីប្រទេសលាវ ក្រោយពីអាមេរិកាំងវាយលុកស្រុកខ្មែរ។

ហាណូយមានផែនការបញ្ជូនទ័ពមកស្រុកខ្មែរទៀត ដើម្បីបន្ថែមទ័ពយួនកុម.ឲ្យគ្រប់៣០ពាន់នាក់ ។ ហាណូយក៏បានសង្ឃឹមទុកជាមុនផងដែរថា ការជ្រើសរើសយកអន្តោគ្រាមខ្មែរថែមទៀតអាចនឹងធ្វើឲ្យកងទ័ពកើនឡើងដល់១៤០ពាន់នាក់ ដែលជាចំនួនមួយគ្រប់គ្រាន់សម្រាប់កម្ទេចទាហាន **លន់_ណុល**" ដែលមានគ្នាប្រហែល ១០០ពាន់នាក់ប៉ុណ្ណោះ ។ "តាមពិត រហូតមកទល់ពេលជិតចប់សង្គ្រាមទៅហើយ ក៏គេមិនអាចយល់បានអំពីគោលបំណងនៃការរើសទ័ពខ្មែរ ដែលនៅពេលនោះហាណូយបានបាត់បង់អំណាចទៅលើការបះបោរ ។

វាជាការពិតជាក់ស្តែង ទាំងខាងយួមកុម. ទាំងខាងខ្មែរក្រហម ថានៅពេលសង្គ្រាមចាប់ផ្តើម ពួកខ្មែរក្រហមមិនអាចយកភ្នំពេញដោយម្នាក់ឯងបានទេ ។ ដូចនេះ បើចង់ឲ្យកម្ពុជាមានរដ្ឋាភិបាលកុម្មុយនិស្ត កងទ័ពយួនខាងជើងនិងយួនវៀតកុងត្រូវតែដើរតួ ។ ប៉ុន្តែបើទោះជាធាតុពិតនៃទិសដៅយោធាបានផ្តល់ឲ្យហើយក៏ដោយ ក៏ឥរិយាបទនយោបាយរបស់យួនកុម.ចំពោះខ្មែរក្រហម នៅតែស្ថិតក្នុងការតាំងខ្លួនជាចៅហ្វាយគេរហូត ។ នៅខែមេសា១៩៧០ ឯកសារយួនកុម.មួយបានពន្យល់ថា:

**"បើទោះជាបដិវត្តន៍កម្ពុជាត្រូវបានគេទទួលអបអរសាទរក៏ដោយ ក៏បដិវត្តន៍នេះនៅខ្វះសមត្ថភាពនៅឡើយ ។ យើងបានជួយគេទាន់ពេល ហើយបានផ្តល់ដល់គេនូវជំនួយរហ័សទាន់ចិត្ត ។ យើងបានជួយរៀបចំជាប្រព័ន្ធនូវលទ្ធិរបស់គេ បានបង្ហាញមាគ៌ានយោបាយបង្កើតអង្គការ ហើយនិងបានរៀបផែនការសំរាប់អនុវត្តឲ្យដល់ពួកគេ ។ ពួកគេបានយល់ស្របទាំងស្រុងនូវអ្វីៗទាំងអស់ដែលយើងបានស្នើរ ។ យើងគួរបង្ហាញនូវការចង្អៀតចិត្តក្នុងទំនាក់ទំនងរបស់យើង និងប្រាប់ឲ្យគេដឹងខ្លួនថា ពួកគេរស់ដោយសារយើង ។ ជំនួយរបស់យើងនេះគឺជាផ្នែកមួយនៃភាតព្វកិច្ចអន្តរជាតិ ។ ម្យ៉ាងទៀត កម្ពុជាជាឆាកល្ខោនរបស់យើង ។ បដិវត្តន៍កម្ពុជានៅខ្សោយហើយអង្គការរបស់គេនៅធូររលុង ។ យើងត្រូវតែរឹតបន្តឹង" ។**

នៅក្នុងអង្គប្រជុំសម្ងាត់មួយនៅហាណូយ យួនកុម.បានដាក់បញ្ចូលទៅក្នុងនយោបាយបក្សរបស់គេនូវផែនការដ៏ជាក់លាក់មួយគឺ"ត្រូវពង្រឹងមូលដ្ឋានបដិវត្តនៅកម្ពុជា និងដឹកនាំប្រទេសនេះឆ្ពោះទៅរកសង្គមនិយម"។ ថ្វីបើមានការខកចិត្តនឹងសមត្ថភាពទូទៅរបស់ខ្មែរក្រហមក៏ដោយ ក៏យួននៅតែមានសុទិដ្ឋិនិយមចំពោះសេចក្តីសង្ឃឹមនៃជ័យជំនះនៅកម្ពុជា ដូចក្នុងឯកសារកុម្មុយនិស្តមួយដែលគេចាប់បានបញ្ជាក់ថា: "បដិវត្តន៍កម្ពុជាកំពុងស្ថិតក្នុងដំណាក់ការថ្មីមួយ ។ ចេញពីរបបអព្យាក្រឹត**រេវា** ឥឡូវកម្ពុជាអាចដើរតាមនយោបាយមួយដែល **មិនរេវា** ។ ពេលណាខ្មាំងត្រូវបរាជ័យ កម្ពុជានឹងក្លាយទៅជាប្រទេសប្រជាធិបតេយ្យនិងឯករាជ្យ ហើយនឹងធ្វើដំណើរឆ្ពោះទៅរកសង្គមនិយម" ។ នេះបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ថា បើទោះជាយួនកុម.មានកង្វល់ធំចំពោះស្ថានភាពយោធា

នៅវៀតណាមខាងត្បូងក៏ដោយ ក៏នៅមានទិសដៅនយោបាយសំខាន់ៗផ្សេងទៀតដែរ ដែលជាប់ទាក់ទិន ។ នៅក្នុងរបាយការណ៍មួយផ្ញើទៅម៉ូស្គូ ក្នុងខែឧសភា១៩៧១ ឯកអគ្គរដ្ឋទូតសូវៀតប្រចាំវៀតណាមខាងជើងបានបញ្ជាក់ថា: **"សមមិត្តវៀតណាម" ក្នុងឆ្នាំកន្លងទៅ "បានលើកឡើងដោយប្រុងប្រយ័ត" អំពីបញ្ហា "សហភាពសង្គមនិយមឥណ្ឌូចិន"** ។ ឯកអគ្គរដ្ឋទូតបានកត់សំគាល់ថា: "នេះគឺជាសំនួរដ៏ស្មុកស្មាញសម្បើមមួយ" ប៉ុន្តែគាត់បានបន្តទៀតថា បញ្ហានេះគេអាចប្រើបាន"ក្នុងផលប្រយោជន៍ទូទៅរបស់សង្គមនិយម" ។ ស្របពេលជាមួយគ្នានោះដែរ សូវៀតក៏បានទទួលស្គាល់នូវបំណោទ**អត្តទត្តភាព** និង**ការតាំងខ្លួនជាចៅហ្វាយ** របស់យួនទៅលើប្រទេសតូចតាចនៅឥណ្ឌូចិន ។ ក្នុងរបាយការណ៍របស់គាត់ ទូតសូវៀតបានកត់សំគាល់ថា ហាណូយគឺជាមណ្ឌលសម្របសម្រួលសកម្មភាពនៃ "រណសិរ្សរំដោះរបស់វៀតណាម លាវ និងកម្ពុជា" ហើយបានទទួលស្គាល់ថា លាវនិងខ្មែរបានព្រមទទួលយកនិងពឹងផ្អែកទៅលើការដឹកនាំរបស់យួន ។ តែគាត់ក៏បានព្រួយបារម្ភផងដែរចំពោះវិធីដោះស្រាយរបស់យួនទៅនឹងទំនាក់ទំនងនេះ:

> **"យ៉ាងណាក៏ដោយ ជួនកាលមនោគមវិជ្ជាជាតិនិយមតូចចង្អៀតរបស់សមមិត្តវៀតណាមចំពោះដំណោះស្រាយនៃចំណោទឥណ្ឌូចិនវាជាក់ស្តែងពេក ហើយនិងការប៉ុនប៉ងដែលគួរឲ្យកត់សំគាល់ដោយសមមិត្តយួនលើបញ្ហាដាក់លាវនិងកម្ពុជាឲ្យនៅក្រោមបង្គាប់សំរាប់ផលប្រយោជន៍យួន បានហុចជាលទ្ធផលមកវិញគឺការលាក់ចាំងនូវកំហឹងរបស់មិត្តលាវនិងមិត្តខ្មែរ "។**

ស្ថានទូតសូវៀតបានទទួលស្គាល់រួចទៅហើយនូវគ្រាប់ពូជនៃបញ្ហា ដែលនឹងអាចក្លាយទៅជារឿងធំៗគ្នានៅក្នុងតំបន់អស់រយៈពេលជិតពីរទសវត្ស ។ ឧបសគ្គតែមួយគត់ក្នុងគោលដៅរយៈពេលវែងដែលហាណូយមើលឃើញនៅពេលនោះ មិនមែនខ្មែរក្រហមទេ តែគឺ ស.រ.អ.នេះឯង ។

## ៣-ខ្មែរក្រហមទាស់នឹងចិនហើយនិងវៀតណាមខាងជើងដោយសារសីហនុ:

នៅចន្លោះខែមេសា ១៩៧០និងខែមីនា១៩៧២ កងកម្លាំងយួនក្រហមនិងខ្មែរក្រហម ក្រោយពីដណ្តើមយកបានតំបន់ណាមួយហើយ តែងតែរៀបចំរដ្ឋបាលនយោបាយគ្រប់គ្រងដោយហ្វុង និងក្រោមការតែងតាំងរបស់គ្រុងនៃសម្តេចសីហនុ ដែលមានរដ្ឋាភិបាលនិរទេសនៅទីក្រុងប៉េកាំង ។ ក្នុងការឃោសនាដំបូង របស់ហ្វុង គេបានយកឈ្មោះសីហនុមកប្រើដើម្បីយកផលចំណេញក្នុងការប្រមូលកម្លាំងបះបោរ ។ ក្នុងខិត្តប័ណ្ណជាភាសាខ្មែរមួយ ដែលគេចែកចាយនៅពាក់កណ្តាលឆ្នាំ១៩៧០ បានពន្យល់ថា:

**"បងប្អូនរួមជាតិជាទីស្នេហា!**

**ប្រជាជនយើងបានទទួលសន្តិភាពជិត១៥ឆ្នាំហើយ ដែលនៅក្នុងរយៈពេលនោះ ប្រទេសជាអ្នកជិតខាងយើងបានទទួលរងទុក្ខវេទនាមិនចេះចប់ដោយសារសង្គ្រាមដែលនាំមកដោយចក្រពត្តិអាមេរិកនិងខ្ញុំបំរើ ។ ប្រទេសកម្ពុជាជាប្រទេសសន្តិភាពនិងចំរើនល្អតលាស់ដែលធ្លាប់តែជាកោះសន្តិភាពនៃឥណ្ឌូចិន ។ សន្តិភាព វឌ្ឍនភាព និងសុខុមាលភាពនេះបានមកដោយសារការដឹកនាំរបស់សម្តេចនរោត្តមសីហនុ ។ ប៉ុន្តែនៅពេលនេះ កម្ពុជាបានជួបនូវគ្រោះថ្នាក់បណ្តាលមកពីការទម្លាក់សម្តេចសីហនុពីប្រមុខរដ្ឋដោយបនលន់ណុល ស៊ិរិមតៈ និងចេងហេង ដែលជាកញ្ចះដាច់ថ្លៃរបស់ចក្រពត្តិអាមេរិក ។ បងប្អូនជាទីស្នេហា! ពេលនេះប្រជាជនកម្ពុជាបានក្រោកឡើងហើយតាមសេចក្តីអំពាវនាវរបស់សម្តេចព្រះប្រមុខរដ្ឋ "។**

សេចក្តីដៅបញ្ជាក់អំពីភារកិច្ចដឹកនាំរបស់សីហនុនៅក្នុងចលនាបះបោរមានសារៈសំខាន់ណាស់នៅក្នុងឆ្នាំដំបូងនៃសង្គ្រាម និងបានឆ្លុះបញ្ចាំងឥទ្ធិពលរបស់យួនខាងជើងទៅលើការឃោសនារបស់ក្រុមបះបោរខ្មែរ ។ យោងតាមកម្មាភិបាលវៀតកុងផ្តាច់ខ្លួនម្នាក់បានឲ្យដឹងថា ខ្មែរក្រហមយកសីហនុមកប្រើ ដែលពួកគេប្រចាំងនឹងទ្រង់បីឆ្នាំមកហើយនោះ គឺជាការប៉ុនប៉ងដោយចេតនារបស់យួនខាងជើង ដើម្បីបង្កើតការពិបាកដល់ពួកខ្មែរក្រហម ។ របាយការណ៍របស់ជនរត់ចោលជួរនេះ មានកន្លែងខ្លះបានត្រូវបញ្ជាក់បន្ថែមដោយឯកសារជាតឹកតាងថា ក្នុងរយៈពេលមួយឆ្នាំដែលអំណាចយួនចុះអន់ថយនៅថ្នាក់កងឯកភាព ភាកិច្ចរបស់សីហនុក៏ត្រូវបានកាត់បន្ថយដោយពួកខ្មែរកុម.ដែរ ។ ឧទាហរណ៍: ចុល្លលិខិត (លិខិតខ្លី។) មួយរបស់ហ្វុងនៅថ្ងៃ១៩មីនា១៩៧១ ដែលត្រូវគេចែកចាយនៅថ្ងៃបុណ្យខួបទីមួយនៃការបង្កើតរណសិរ្ស បានទូន្មានដល់កម្មាភិបាលទាំងឡាយថា:

**"សម្តេចសីហនុ លោកត្រូវគេស្គាល់ថាជាប្រធានរណសិរ្សរួមជាតិកម្ពុជា ។ យើងមិនបាច់តាំងរូបរបស់ព្រះអង្គទេ...។ សេចក្តីសម្រេចទាំងឡាយបានមកដោយកងទ័ពប្រជាជនយើង មិនមែនបានមកដោយសម្តេចសីហនុទេ ។ យើងមិនគួរបដិសេធទាំងស្រុងនូវវិភាគទានរបស់លោកឡើយ ប៉ុន្តែយើងគួរពន្យល់ប្រជាជនដោយវិធីប៉ិនប្រសប់ថា ជោគជ័យនេះមិនមែនបានមកដោយសារសីហនុទេ គឺបានមកដោយសារបក្សរបស់យើង "។**

សីហនុនឹកឃើញឧប្បត្តិហេតុមួយកាលនៅប៉េកាំង ប្រហែលជាក្នុងឆ្នាំ១៩៧០ ដែលផ្តល់នូវភស្តុតាងបន្ថែមអំពីការឃ្លាតគ្នាជាមូលដ្ឋានរវាងយួននិងចិនមួយផ្នែក ហើយនិងមួយផ្នែកទៀត ក្នុងការដែលខ្មែរក្រហមយកឈ្មោះនិងប្រជាប្រិយភាពរបស់សីហនុមកប្រើជាឧបករណ៍នយោបាយនៅកម្ពុជា:

> **"ថ្ងៃមួយ រដ្ឋាភិបាលហាណូយបានផ្ញើសារមួយមកខ្ញុំ សុំឲ្យខ្ញុំធ្វើលក្ខណៈសញ្ញា (បារាំងថា insigne) ពីរបែបៈ បែបទីមួយមានដាក់រូបខ្ញុំ ឯបែបទីពីរដាក់ព្រះរាជវរលញ្ឆករ (ត្រា) របស់ត្រូង ។ យោងតាម "មិត្តវៀតណាមខាងជើងរបស់ខ្ញុំ" ប្រជាជនខ្មែរនៅស្រឡាញ់សីហនុនិងរាជានិយមណាស់... ។ ដើម្បីទាក់ទាញពួកគេឲ្យជួយគាំទ្រមូលហេតុដ៏ត្រឹមត្រូវរបស់យើង និងដើម្បីជំរុញពួកគេឲ្យចូលរួមជាមួយកងទ័ពហ្វ៊ុង ជាការល្អយើងគួរចែករូបសញ្ញាទាំងនោះដល់ពួកគេ ។ រដ្ឋាភិបាលចិនមិនបានយល់ទាស់ទេនៅពេលបានដំណឹងនេះពីខ្ញុំ ។ គេក៏បានបញ្ជាឲ្យផ្ញើរូបសញ្ញានោះរាប់ពាន់ភ្លាម ចេញពីរោងចក្រដ៏ប្រណីតមួយ ។ នៅពេលផ្ញើរូបសញ្ញានោះទៅហាណូយ ដើម្បីបញ្ជូនបន្តទៅកម្ពុជា លោកអៀងសារី ជួនម៉ុម ។ល។ បានបង្កើតឧបសគ្គ ។ ពួកខ្មែរកុម.ក្មេងៗដែលទើបមកពីសហភាពសូវៀត ឆេកូស្លូវ៉ាគី អាល្លឺម៉ង់ខាងកើត បារាំង ។ល។ បានថ្កោលទោសយ៉ាងខ្លាំងក្លាចំពោះសីហនុ និងរបបរាជានិយមខ្មែរ ដែលជារបបស្របច្បាប់ ដែលពួកខ្មែរក្រហមបានឆ្លៀតចំរាញ់យកប្រយោជន៍ផ្ទាល់ខ្លួនដោយឥតអៀនខ្មាស់ ...។ រូបសញ្ញាមិនត្រូវបានគេផ្ញើមកកម្ពុជាទេ តែផ្ទុយទៅវិញត្រូវគេបោះចោលក្នុងធុងសំរាម "។**

មានពេលមួយ ក្នុងរវាងពាក់កណ្តាលឆ្នាំ១៩៧១ ដោយមេខ្មែរក្រហមចាប់ផ្តើមរឹតបន្តឹងការត្រួតត្រារបស់គេនៅក្នុងហ្វ៊ុង គេក៏ចាប់ដកពួកអ្នកសីហនុនិយមបណ្តើៗពីតំបន់ដែលគេកាន់កាប់ ។ ព្រឹត្តិការណ៍នេះបានកើតឡើងព្រមគ្នាជាមួយនឹងដំណើរ **អច្ចន្តិភាវូបនីយកម្ម** *(ការធ្វើឲ្យមានការប្រែប្រួលដ៏ចាប់រហ័ស)* នៃរបបបដិវត្តនៅក្នុងតំបន់ហ្វ៊ុងកាន់កាប់ ។ ពីរឆ្នាំក្រោយមក ខ្មែរក្រហមចាប់ផ្តើមធ្វើការឃោសនាយ៉ាងធំដើម្បីដកសេចក្តីទុកចិត្តពីសម្តេចសីហនុនៅចំពោះមុខប្រជាជនខ្មែរ ។

តែផ្ទុយទៅវិញ យួនកុម.នៅតែបន្តជួយគាំទ្រភារកិច្ចនយោបាយដល់សម្តេចសីហនុ ។ នេះមិនមែនមានន័យថា ហាណូយចង់បានសីហនុមកកាន់អំណាចវិញទេ ។ **ហែងរី គីស៊ិនជ័រ** បានសង្កេតឃើញនូវអាកប្បកិរិយាអាក្រក់ និងការតាំងខ្លួនធ្វើចៅហ្វាយរបស់ **ឡេ-ឌឹកថូ** (អ្នកដឹកនាំការការិយាល័យនយោបាយនៃប្រទេសនៅឥណ្ឌូ-ចិន *របស់ទីក្រុងហាណូយ )* ចំពោះសម្តេច ។ តាមសំដីលោក **គីស៊ិនជ័រ** ថា នៅក្នុងទស្សនកិច្ចរបស់សម្តេចពេលថ្មីៗនេះនាទីក្រុងហាណូយ **ឡេឌឹកថូ**បាននិយាយចំអកឲ្យសីហនុ និងនិយាយអំពីការចូលចិត្តគ្រឿងប្រណីតឥតប្រយោជន៍របស់សម្តេច ។ **ឡេឌឹកថូ**ក៏បានបង្ហាញដល់ **គីស៊ិនជ័រ** ដែរនូវខ្សែភាពយន្តឯកសារមួយ ស្តីអំពីទស្សនកិច្ចរបស់សីហនុ នៅតំបន់កាន់កាប់ដោយខ្មែរក្រហមក្នុងប្រទេសកម្ពុជា ។ រដ្ឋមន្ត្រីការបរទេស ស.រ.អ.បានឃើញយ៉ាងច្បាស់នូវ "ការទាក់ទិនរបស់សម្តេចជាមួយនឹងការកស៊ីប្តូរផ្តាច់របស់ខ្មែរក្រហម" ។ **គីស៊ិនជ័រ** បានបន្ថែម

ទៀតថា: **"ចំណងធំរបស់ឡុនណុលក្នុងការយកសីហនុមកប្រើ គឺជាមធ្យោបាយមួយសម្រាប់ធ្វើឲ្យខូចទឹកចិត្ត និងធ្វើឲ្យអន្ទរាយដល់រដ្ឋាភិបាលលន់ណុល"** ។

សភាពខុសគ្នានៃ **ការប្រើសីហនុ** របស់យួនកុម. និងខ្មែរកុម.មានមូលហេតុសំខាន់ពីរយ៉ាង ។ **ទីមួយ** គឺបង្ហាញឲ្យឃើញនយោបាយស្មុកស្មាញប្រទាក់ក្រឡារបស់យួន បញ្ជាក់អំពីការយល់ច្បាស់របស់គេចំពោះផ្នត់គំនិតរបស់ប្រជាជនខ្មែរ និងមធ្យោបាយអត់ធ្មត់និងប្រយ័តប្រយែងរបស់យួន ក្នុងការយកខ្មែរប្រើ ដើម្បីផលប្រយោជន៍របស់គេ ។ ឥរិយាបទដែលបានគន់គូរទុករបស់មេដឹកនាំហាណូយនេះ បានត្រូវគេកត់ចំណាំឃើញជាពិសេសនៅពេលដែលសីហនុមានទំនាក់ទំនងជិតស្និតជាមួយនឹងចិន ដែលយើងនឹងពិភាក្សានៅពេលក្រោយ ។

មូលហេតុ**ទីពីរ** គឺឆ្លុះបញ្ចាំងនូវការខ្វះនយោបាយស៊ីជម្រៅរបស់ពួកខ្មែរក្រហម ។ នៅក្នុងគោលបំណងចង់បន្ថយការកិច្ចនយោបាយរបស់សីហនុ ជាទូទៅពួកខ្មែរក្រហមខ្វះការអត់ធ្មត់ជាមួយយុទ្ធសាស្ត្ររបស់ហ្វ៊ុង ។ ពួកគេបានយកមធ្យោបាយដែលឡេនីនហៅថា **អ្នកនិយមឆ្វេងក្មេងខ្ចី** មកប្រើក្នុងការឈោងចាប់យកអំណាច ។ ពួកគេមានការរារែកក្នុងការសម្របសម្រួលនយោបាយ បើទោះជាបណ្តោះអាសន្នក្តី ដែលជាយុទ្ធសាស្ត្រសំរាប់ដណ្តើមអំណាច ។

## ៤_ឧបករណ៍របស់ហាណូយសម្រាប់ត្រួតពិនិត្យកុម្មុយនិស្តកម្ម:

យួនកុម.បានចាប់អនុវត្ត **ឧបករណ៍នយោបាយ** ពីរដើម្បីត្រួតពិនិត្យលើកុម្មុយនិស្តកម្មនៅកម្ពុជា: **ខ្មែរវៀតមិញ** គឺខ្មែរកុម.ដែលបានហ្វឹកហ្វឺននៅយួនខាងជើងតាំងពីឆ្នាំ១៩៥៤ និង **គណៈកម្មាធិការសមគ្គីការ** ដែលបានបង្កើតឡើងក្រោយរដ្ឋប្រហារលន់ណុលភ្លាម ។ ឧបករណ៍នយោបាយទាំងពីរនេះ ពឹងផ្អែកទៅលើវត្តមានរបស់កងឯកភាពយោធាយួនខាងជើង និងរណសិរ្សរំដោះជាតិយួនខាងត្បូងឬវៀតកុងនៅកម្ពុជា ។ បើទោះជាយ៉ាងនេះក៏ដោយក៏កិច្ចការការជ្រើសរើសរើសនេះ នៅមិនទាន់គ្រប់គ្រាន់សម្រាប់កិច្ចការដែលនឹងកើតឡើងនៅក្នុងផ្លូវនយោបាយឡើយ ។

ពួកបះបោរខ្មែរមាននិន្នាការនយោបាយបីក្រុមផ្សេងគ្នា: ពួកសីហនុនិយម ពួកខ្មែរវៀតមិញ និងពួកខ្មែរក្រហម ។ កម្មាភិបាលនិងយោធាខ្លះរបស់ហ្វ៊ុងជាអ្នករាជានិយមរបស់សម្តេចសីហនុ (ខ្មែររំដោះ) ។ ប៉ុន្តែអ្នកសីហនុនិយមមិនដែលមានអំណាចពិតប្រាកដទេ ។ អំណាចនយោបាយនៅក្នុងហ្វ៊ុងស្ថិតក្នុងកណ្តាប់ដៃពួកខ្មែរកុម. ។ តែទោះជាយ៉ាងណា គ្មានពួកខ្មែរវៀតមិញណាម្នាក់បានកាន់អំណាចទេ នៅក្នុងចំណោមខ្មែរកុម.ទាំងនោះ ។ តំណែងខ្ពស់ៗខាងនយោបាយនិងយោធានៅក្នុងហ្វ៊ុងនិងក្នុងកងទ័ព ត្រូវបានកាន់កាប់ដោយពួកអ្នកនិយមម៉ៅ ដែលប.ក.ក.តាំងខ្លួនគេថាជាសមាជិកនៃអង្គការបដិវត្ត និងដែលសម្តេចសីហនុឲ្យឈ្មោះថា ខ្មែរក្រហម។

ពួកខ្មែរវៀតមិញមិនដែលបានទទួលតំណែងជាថ្នាក់ដឹកនាំនៅក្នុងអង្គការបដិវត្តកម្ពុជាទេ សូម្បីកាលពីនៅក្នុងឆ្នាំ១៩៧០និង១៩៧១ ដែលពួកគេកាន់កាប់កិច្ចការរដ្ឋពីថ្នាក់ភូមិដល់ថ្នាក់តំបន់ (ដែលស្ថិតក្រោមយួនត្រួតត្រា) ក៏ដោយ ។ មានភស្តុតាងដូចជាកម្មាភិបាលយោធាខ្មែរវៀតមិញខ្លះបានត្រូវគេបន្ថយឋានន្តរសក្តិដែលខ្លួនធ្លាប់មាននៅវៀតណាមខាងជើង ។ នៅពេលណាមួយ ពួកគេរួមទាំងកម្មាភិបាលនយោបាយនឹងត្រូវកំចាត់ចោលដោយពួកប៉ុលពត ។ ហេតុនេះហើយបានជានៅពេលឡើងកាន់អំណាច ប៉ុលពតនិងក្រុមរបស់គាត់បានរក្សាទុកបក្ស និងរចនាសម្ព័ន្ធយោធាឲ្យនៅឯករាជ្យពីវៀតណាម ។ **វិធីប្រើរនុកក្នុង** របស់ហាណូយដើម្បីត្រួតត្រាបដិវត្តរបស់ខ្មែរកុម.បានត្រូវទទួលការវាយបកវិញ ។

ក្រោយពេលទម្លាក់សីហនុភ្លាម យួនកុម.បានបង្កើតគណៈកម្មាធិការសម្ពន្ធការដើម្បីចាត់ចែងទំនាក់ទំនងរវាងយួនខាងជើងនិងទ័ពវៀតកុងមួយផ្នែក និងមួយផ្នែកទៀតជាមួយខ្មែរកុម. ។ គណៈកម្មាធិការសម្ពន្ធការមានភារកិច្ចចំបងធំពីរ ។ **ទីមួយ ផ្តល់ដំណឹងដល់ខ្មែរកុម.អំពីគោលការណ៍នយោបាយរបស់ប.ក.វ.** (បក្សកុម្មុយនិស្តវៀតណាម) ជាពិសេស ថាតើវៀតណាមគិតយ៉ាងម៉េចក្នុងការតស៊ូប្រឆាំងនឹងស.រ.អ. ។ ភារកិច្ចធំមួយទៀតដែរគឺជួយខ្មែរក្នុងការផ្តល់អ្នកជំនាញការផ្នែកយោធា ផ្នែកសេដ្ឋកិច្ច ផ្នែកសន្តិសុខ និងផ្នែកពេទ្យ ។ **ទីពីរ ជាភារកិច្ចលាក់មុខ គឺមានមុខងារក្នុងការជួយដោះស្រាយជម្លោះរវាងទ័ពខ្មែរក្រហមនិងយួនកុម.** ។ គណៈកម្មាធិការសម្ពន្ធការមានឈ្មោះមួយទៀតថា គណៈកម្មាធិការក្រុមប្រឹក្សា ។

## ៥_ការប្រឈមមុខដាក់គ្នាជាលើកដំបូងរវាងទ័ពយួនកុម.និងខ្មែរកុម.

ក្នុងរយៈពេលពីរឆ្នាំក្រោយរដ្ឋប្រហាររលំលុល ថ្វីបើហាណូយមានការប្រុងប្រយ័ត្នក្នុងការដឹកនាំក្រុមខ្មែរបះបោរក៏ដោយ ក៏នៅតែមានការប៉ះទង្គិចគ្នាជារឿយៗរវាងយួនកុម.និងខ្មែរក្រហមនៅពេលដែលទ័ពព្រៃខ្មែរកើនចំនួនច្រើនឡើងយ៉ាងឆាប់រហ័ស ។ សូម្បីតែមុនឆ្នាំ១៩៧០ ក៏មេដឹកនាំកំពូលប.ក.ក.បានសន្និដ្ឋានដែរថា **យួនមិនមែនជាសម្ពន្ធមិត្តគួរជាទីទុកចិត្តបានឡើយ** ។ ពេលដែលប.ក.ក.បានសម្រេចថាងើបបះបោរប្រឆាំងនឹងរដ្ឋាភិបាលសីហនុក្នុងឆ្នាំ១៩៦៨ យួនកុម.បានប្រកែកមិនគាំទ្រ ។ ប៉ុន្តែបើទោះជារដ្ឋប្រហាររលំលុលឆ្នាំ១៩៧០បានប្តូរទិសនយោបាយរបស់ហាណូយនៅកម្ពុជា ដើម្បីឲ្យយួននិងខ្មែរកុម.មានសត្រូវរួមក៏ដោយ ក៏ភាពលេចឡើងធ្លោនៃចំណង់ត្រួតត្រារបស់ហាណូយទៅលើក្រុមខ្មែរបះបោរ ហាក់ដូចជាបានធ្វើឲ្យមេដឹកនាំប.ក.ក.ងាកបែរទៅប្រឆាំងនឹងយួនកុម.វិញ ។ នៅក្នុងសម័យប្រជុំសភាបក្ស ខែកញ្ញា១៩៧១ **មេប.ក.ក.បានតាំងចិត្តថា យួនជា"សត្រូវជំធំ"** យូរអង្វែងរបស់កម្ពុជា ។ សេចក្តីសម្រេចចិត្តមួយក៏បានធ្វើឡើងដើម្បីដេញទ័ពនិងកម្មាភិបាលយួនកុម.ចេញ ។

បើគិតទៅតាម **សនិទានភាព** (ភាពសមហេតុសមផល) នៃសេចក្តីសម្រេចចិត្តរបស់ប.ក.ក.នេះ គេគួរកត់សំគាល់ថា នៅពេលនោះកងទ័ពរដ្ឋាភិបាលលន់ណុលមានចំនួនច្រើនជាងទ័ពកុម្មុយនិស្តនៅស្រុកខ្មែរ ហើយដែលបីភាគបួននៃទ័ពកុម្មុយនិស្តទាំងនោះជាជនជាតិយួន ។

សំខាន់ជាងនេះទៅទៀត គឺថាកាលណោះយួនកុម.មិនទាន់បានជ្រួតជ្រាបពីនយោបាយរបស់ប.ក.ក.នៅឡើយទេ ។ ឯកសារមួយរបស់យួនវៀតកុងដែលបានផ្សាយដល់គ្រប់កងឯកភាពយួនកុម.ប្រតិបត្តិការក្នុងកម្ពុជានៅខែតុលា១៩៧១ បានធ្វើឲ្យមានការប្រុងប្រយ័ត្នចំពោះជម្លោះរវាង"កងកម្លាំងជាមិត្ត និងកងកម្លាំងរបស់យើង" ។ ឯកសារនោះនិយាយអំពីតម្រូវការ ដើម្បីកែលម្អនូវ"គុណវិបត្តិទាំងឡាយដែលប៉ះពាល់ដល់មិត្តភាពនៃបក្ស និងប្រទេសទាំងពីរ" ។ ប៉ុន្តែឯកសារនោះមិនបានដៅបញ្ជាក់ថា ជម្លោះនោះជាចេតនានយោបាយរបស់មេដឹកនាំខ្មែរក្រហមទេ និងបានសុំឲ្យមានការសម្រុះសម្រួលអាកប្បកិរិយាពីខាងភាគីកម្មាភិបាលនិងកងទ័ពយួនៈ

**"តើយើងដោះស្រាយទំនាស់ដែលតែងកើតមានឡើងជារឿយៗរវាងភាគីទាំងពីរនេះឲ្យបានត្រឹមត្រូវដោយរបៀបណា ? ជាមួយនឹងកម្លាំងប្រយុទ្ធដ៏ធំមួយដែលប្រតិបត្តិការនៅក្នុងសាធារណរដ្ឋខ្មែរ ការប៉ះទង្គិចគ្នានៃភាគីទាំងសងខាងគឺជាការមួយដែលគេចមិនផុត ។ ប្រជាជនទាំងពីរមានភាពខុសប្លែកគ្នាមួយ ។ យើងត្រូវខំធ្វើការប្រឹងប្រែងជាវិជ្ជមាន ដើម្បីកាត់បន្ថយនិងដោះស្រាយនូវទំនាស់នេះឲ្យបានសមស្របដោយគេមានការព្រួយបារម្ភចំពោះបក្សទាំងពីរ និងប្រជាជននៃប្រទេសទាំងពីរ ។**

**យើងត្រូវរក្សាភាពស្ងប់ស្ងៀមនិងភាពមិនលំអៀង ដើម្បីពិនិត្យមើលឲ្យបានត្រឹមត្រូវថាតើវិបត្តិនោះបណ្តាលមកពីខាងយើង ពីខាងខ្មែរ ឬពីខាងសត្រូវ ។ យើងត្រូវយល់ថា ការទទួលខុសត្រូវនៃបក្សរបស់យើង គឺដើម្បីរឹតចំណងសាមគ្គីភាពរវាងបក្សខ្មែរនិងបក្សវៀតណាមដើម្បីផ្ចាញ់សត្រូវរួម ។"**

មួយខែបន្ទាប់ពីសេចក្តីសម្រេចបណ្តេញរបស់មេប.ក.ក.មក កុំថាឡើយដល់ទៅយួនកុម. សូម្បីតែមេខ្មែរបះបោរខ្លះក៏មិនបានដឹងពីរឿងនេះផង ។ នៅដើមឆ្នាំ១៩៧២ ក្នុងពេលដែលកងឯកភាពធំៗជាច្រើនរបស់យួនខាងជើងបានដកចេញដោយស្ម័គ្រចិត្តពីកម្ពុជាដើម្បីវាយលុកវៀតណាមខាងត្បូង កម្មាភិបាលខ្លះនៃហ្វ៊ុងក៏ត្រូវបានបញ្ជាមិនឲ្យទាក់ទងនឹងយួនដែរ ។ សារាចរមួយចេញពីគណៈកម្មាធិការហ្វ៊ុងតំបន់២៥ (ក្នុងខេត្តកណ្តាល) បានដាក់បញ្ជាថាៈ

**"នៅពេលដែលគេលិខិតធ្វើដំណើររបស់កម្មាភិបាលឬយោធាយួន កម្មាភិបាលយោធាកងឆ្អក់ឬកងឈ្លបខ្មែរត្រូវបង្ហាញនូវស្មារតីអន្តរជាតិនិយម គោរពគ្នាទៅវិញទៅមកក្នុងន័យជាសមភាព ហើយលើកលែងនូវ**

**ការខុសឆ្គងបន្តិចបន្តួច និងភាពមិនគប្បីពីអ្នកដំណើរ ។ ចំពោះកម្មាភិបាល ឬយោធាវៀតណាម ប្រតិបត្តិការក្នុងតំបន់២៥ដែលធ្វើដំណើរគ្មានសំបុត្រស្នាម ត្រូវបញ្ជូនទៅកន្លែងដើមវិញ ។ តែបើអ្នកដំណើរឥតសំបុត្រស្នាមមកពីក្រៅតំបន់២៥ អ្នកនោះត្រូវឃត់ទុកដើម្បីសួរចម្លើយ ។ ក្នុងករណីនេះ ជនឃាត់ខ្លួនគួរតែត្រូវទទួលបាននូវការគួរសមរាក់ទាក់ ។ អាកប្បកិរិយាមិនល្អ ដូចជាការអួតអាង ការគំរាមកំហែង ឬការសងសឹកជាដើមត្រូវតែចៀសវាង ។"**

ទោះជាយ៉ាងណាក៏ដោយ ខ្មែរក្រហមជាច្រើនកងឯកភាពបានចាប់ជីវិត និងធ្វើឃាតកម្មពួកកម្មាភិបាលវៀតកុងរួចទៅហើយនៅចុងឆ្នាំ១៩៧១ ។ មេខ្មែរកុម.ខ្លះ (ទំនងជាខ្មែរវៀតមិញដែលមិនត្រូវបានចូលក្នុងប.ក.ក.របស់ប៉ុលពត) បានពន្យល់ហេតុការណ៍ដល់សម្ពន្ធមិត្តយួនរបស់គេ ថាជាការជ្រៀតជ្រែករបស់ភ្នាក់ងារខ្មាំង ។ ឧទាហរណ៍: សំបុត្រមួយពីលេខាធិការបក្សថ្នាក់តំបន់ផ្ញើទៅប្រធានសម្ពន្ធការវៀតណាម បានបញ្ជាក់យ៉ាងនេះ:

**"សមមិត្ត បាហាយ ជាទីគោរព!**

**ដោយមានសហការយ៉ាងជិតស្និទរវាងបក្សកុម្មុយនិស្តនៃប្រទេសទាំងពីរ កងកម្លាំងបដិវត្តខ្មែរបានរំដោះទឹកដីកម្ពុជាពាក់កណ្តាលហើយ ។ ប៉ុន្តែក្រៅពីការបានសម្រេចខាងផ្នែកយោធា ការប៉ះទង្គិចគ្នារវាងខ្មែរ និងកងឯកភាពជាមិត្តបានរីករាលដាលឡើងដែលជាហេតុបណ្តាលឲ្យកម្មាភិបាលនិងយោធាវៀតណាមមួយចំនួនស្លាប់ ជាពិសេសចាប់តាំងពីដើមឆ្នាំ១៩៧១មកទល់នឹងពេលនេះ ។ គេក៏ទើបតែនឹងដឹងពីឫសគល់នៃឧប្បត្តិហេតុនៅពេលថ្មីៗនេះដែរ នៅពេលដែលយើងបានរកឃើញថា អនត្តការ (ការបំផ្លិចបំផ្លាញដោយចេតនា) របស់ខ្មាំងបានបង្កប់នៅក្នុងកងឯកភាពជាមិត្ត និងទីភ្នាក់ងារជាច្រើនដើម្បីធ្វើអនត្តការនិងដើម្បីឲ្យមានការបាក់បែកគ្នារវាងមិត្តនិងមិត្ត ។"**

មេខ្មែរក្រហមបានពិពណ៌នាអំពីហេតុការណ៍ជាក់ស្តែង ដែលបានកើតឡើងក្នុងឃាតកម្មរបស់"សមមិត្តវៀតណាម"ក្នុងពេលកន្លងទៅ ។ ពួកគេក៏បានអះអាងដែរថា: "ក្នុងករណីបែបនេះ យើងខ្ញុំក៏បានបញ្ជាជាបន្ទាន់ដែរ ឲ្យកងកម្លាំងរបស់យើងចាប់ខ្លួនជនដៃដល់យកទៅប្រហារជីវិតចោលហើយ" ។ ប៉ុន្តែនៅមានសញ្ញាជាច្រើនទៀតដែលបញ្ជាក់ពី **ភាពមិនលេងសើច** របស់ពួកខ្មែរក្រហមចំពោះបញ្ហានេះ:

**"ខ្ញុំសូមពន្យល់ប្រាប់មិត្តថា បើមានហេតុការណ៍បែបនេះកើតឡើង គួរតែមិត្តរាយការណ៍មកអង្គបញ្ជាការរបស់យើងដើម្បីដោះស្រាយបញ្ហា មិត្តមិនគប្បីនៅស្ងៀមចាំសងសឹកឡើយ ។ ធ្វើបែបនេះនាំឲ្យតែបែកបាក់គ្នាប៉ុណ្ណោះ ។ ខ្ញុំយល់ថាជាការមិនសមស្របសោះក្នុងការដែលមិត្តបញ្ជាកងកម្លាំងរបស់ខ្លួនឲ្យមកប្រឆាំង**

**និងកងកម្លាំងយើងដែលបណ្ដាលឲ្យអន់ថយដល់អធិបតេយ្យភាពរបស់យើង ។ ទីបំផុត ដើម្បីរក្សាមិត្តភាពរវាងខ្មែរនិងវៀតណាម ខ្ញុំសុំស្នើរដល់មិត្តឲ្យរាយការណ៍មកខ្ញុំនូវគ្រប់ឧប្បត្តិហេតុដែលកើតមានឡើង ។ ខ្ញុំប្ដេជ្ញាថានឹងដាក់ទណ្ឌកម្មជាទម្ងន់ដល់អ្នកធ្វើខុស ។"**

## ៦_ការវែងគំនិតគ្នាលើយុទ្ធសាស្ត្រចរចាចំពោះរឿងវៀតណាមៈ

ថ្វីបើវាមិនមែនជាមូលហេតុនៃការដួលរលំរបស់គេក៏ដោយ សភាពខុសគ្នារវាងខ្មែរក្រហមនិងវៀតណាមចំពោះកិច្ចចរចាប្រកបដោយយុទ្ធសាស្ត្រនយោបាយ បានលេចចេញជារូបរាងឡើងគួរឲ្យចាប់អារម្មណ៍នៅទីបញ្ចប់នៃកិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីស ក្នុងខែតុលា១៩៧២ ។ យួនកុម.ចង់ឲ្យខ្មែរក្រហមដើរតាមគំរូរបស់គេនិងចង់ឲ្យចរចាជាមួយស.រ.អ.និងសាធារណរដ្ឋខ្មែរ ។ នៅឆ្នាំ១៩៧៣ ប្រទេសចិនដែលមេខ្មែរក្រហមចាត់ទុកថាជាមិត្ត ក៏ចូលចិត្តចង់ឲ្យមានកិច្ចចរចាគ្នានេះដែរ ។ ប៉ុន្តែ ខ្មែរក្រហមបានជំទាស់គ្រប់ការប៉ុនប៉ងទាំងឡាយដែលជាការផ្ដើមគំនិតរបស់យួននិងចិន ។ ឥរិយាបថរបស់ពួកខ្មែរក្រហម ដូចខៀវសំផននិងហ៊ូនិមបានបញ្ជាក់ គឺថាគ្មានការចរចានិងគ្មានការឈប់បាញ់គ្នានៅនឹងកន្លែងឡើយ គឺមានតែការប្រយុទ្ធដល់ទីបំផុតតែប៉ុណ្ណោះ ។

ប៉ុន្តែសីហនុ ក្រោមឥទ្ធិពលជូអេនឡាយនិងផាំវ៉ាន់ដុង ទំនងជាមិនចូលរួមជាមួយនឹងការទាត់ចោលយ៉ាងដាច់អហង្ការរបស់ពួកខ្មែរក្រហមស្ដីពីកិច្ចចរចានិងការសម្រុះសម្រួលគ្នានេះឡើយ ។ បន្ទាប់ពីការចុះហត្ថលេខាស្ដីពីកិច្ចព្រមព្រៀងសន្តិភាពវៀតណាមនៅទីក្រុងប៉ារីសក្នុងខែមករា១៩៧៣មក សីហនុបានធ្វើទស្សនកិច្ចនៅវៀតណាមខាងជើង ក្នុងនាមជាភាគីប្រតិភូដែលចូលរួមដោយមេខ្មែរក្រហម **អៀងសារី** និង**គាត់ឆុន**ផងដែរ ។នៅក្នុងពិធីជប់លាងថ្ងៃត្រង់មួយ នាទីក្រុងហាណូយថ្ងៃ៣០មករា១៩៧៣ សីហនុបានប្រកាសថានយោបាយរបស់ហ្វ៊ុងដែលមានរូបទ្រង់ជាប្រធាន បានត្រូវកែប្រែដោយជាប់ទាក់ទិនទៅនឹងកិច្ចព្រមព្រៀងឈប់បាញ់គ្នានៅវៀតណាម ។ យោងតាមអ្នកថ្លែងពត៌មាននៃទីភ្នាក់ងារសារព័ត៌មានបារាំង (AFP) ពីរនាក់នៅពេលជប់លាងនោះ សម្ដេចសីហនុបានបញ្ជាក់ថា នយោបាយថ្មីរបស់ទ្រង់គឺ: "ការបើកផ្លូវទៅរកកិច្ចចរចាជាមួយស.រ.អ. ការកាត់បន្ថយនូវសកម្មភាពយោធារបស់ក្រុមតស៊ូខ្មែរ និងផ្ដល់ការលើកលែងទោសជាទូទៅនៅកម្ពុជា" ។

សីហនុក៏បានបញ្ជាក់បន្ថែមទៀតដែរថា "បើស.រ.អ.ចង់លេងល្បែងមិត្តភាពជាមួយកម្ពុជាដែលជាប្រទេសឯករាជ្យនិងមិនចូលបក្សសម្ពន្ធនោះយើង នឹងអាចមានលទ្ធភាពឈោងទៅដល់ការសម្រុះសម្រួលមួយដ៏ចាប់រហ័សជាមួយរដ្ឋាភិបាលទីក្រុងវ៉ាស៊ីងតុន" ។ ប៉ុន្តែ សីហនុបានបន្ថែមថា: "លន់_ណុលនិងបនក្បត់របស់គេត្រូវតែដកថយ (ចូលនិវត្តន៍) បើសិនជាមានការព្រមព្រៀងបែបនោះ" ។ ជាទីបញ្ចប់ហើយសំខាន់បំផុត សីហនុបានទាមទារថា

នយោបាយថ្មីរបស់ទ្រង់បានត្រូវទទួលការគាំទ្រពេញបន្ទុកពីនាយករដ្ឋមន្ត្រីទីមួយចិន **ជូអេនឡាយ** និងពីនាយករដ្ឋ-មន្ត្រីទីមួយវៀតណាមខាងជើង **ផាំវ៉ាន់ដុង** ។ ប៉ុន្តែនយោបាយថ្មីនោះមិនត្រូវបានយល់ព្រមដោយមេខ្មែរក្រហមនៅក្នុងស្រុកឡើយ ។ នៅពេលក្រោយបន្តិចមកអង្គការដឹកនាំខ្មែរក្រហមហាក់ដូចជាបានឆ្លើយថា **ទេ** ។ នៅថ្ងៃ១កុម្ភៈ វៀតណាមខាងជើងបានបញ្ជាក់ជាសាធារណៈ ថាគេនៅជាប់ជាមួយនឹងសកម្មភាពរបស់មិនសម្របសម្រួលជាមួយរណសិរ្សរួបរួមជាតិកម្ពុជាដែលប្រកាសឡើងដោយសីហនុនៅខែមីនា១៩៧០ ។

ពួកខ្មែរក្រហមបានប្រានចោលនូវការគាំទ្ររបស់សីហនុ ចំពោះមាគ៌ានយោបាយឆ្ពោះទៅរកអំណាចដែលជាការជួយទៅនឹងបំណងរបស់វៀតណាមខាងជើងនិងចិន ។ នៅក្នុងសៀវភៅខ្មៅដែលបានចេញផ្សាយនៅខែកញ្ញា១៩៧៨ ដើម្បីបង្ហាញនូវជម្លោះរបស់គេជាមួយយួន ខ្មែរក្រហមបានអះអាងថា ពួកយួនបានខំរុញច្រានពួកគេនៅពេញឆ្នាំ១៩៧២ ហើយជាពិសេសនៅខែមករា១៩៧៣ ដើម្បីឱ្យពួកគេចរចាលើកិច្ចព្រមព្រៀងសន្តិភាពនៅកម្ពុជា ។ យើងនឹងឃើញថា វៀតណាមមានមូលហេតុសមរម្យក្នុងការចង់ឱ្យមានកិច្ចចរចានៅកម្ពុជា ។

ការមិនចុះសម្រុងគ្នា ម្យ៉ាងរវាងខ្មែរក្រហម និងម្យ៉ាងទៀតរវាងវៀតណាមខាងជើងនិងចិនស្តីពីយុទ្ធសាស្ត្រនៃកិច្ចចរចា មិនបានពន្យល់អំពីយុទ្ធសាស្ត្រយោធាដ៏ចម្លែករបស់ខ្មែរក្រហមនៅពាក់កណ្តាលឆ្នាំ១៩៧៣ទេ ។ ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងប៉ារីស ស្តីពីវៀតណាមនៅខែមករា១៩៧៣ បានបង្វែរការទម្លាក់គ្រាប់បែករបស់ស.រ.អ.ភាគច្រើនមកលើកម្ពុជាវិញ ។ នៅថ្ងៃ៣០មិថុនា ប្រធានាធិបតីនៃស.រ.អ.បានត្រូវបង្ខំដោយការគាបសង្កត់ពីសភាអាមេរិកាំងឱ្យចុះហត្ថលេខាលើច្បាប់មួយ ស្តីពីការបញ្ឈប់ប្រតិបត្តិការសឹករបស់អាមេរិកាំងនៅឥណ្ឌូចិននៅថ្ងៃ១៥ សីហា ។ នេះបានសេចក្តីថា ការទម្លាក់គ្រាប់បែករបស់អាមេរិកាំងត្រូវបញ្ចប់នៅថ្ងៃនោះឯង ។ ផ្ទុយទៅវិញ ខ្មែរក្រហមមិនបានរង់ចាំដល់ថ្ងៃកំណត់១៥សីហានោះទេ ពួកគេបែរជាបើកការវាយលុកដ៏ធំមួយសំរុកទៅលើទីក្រុងភ្នំពេញនៅខែកក្កដា ក្រោមការទម្លាក់គ្រាប់បែកដូចទឹកភ្លៀងពីស.រ.អ. ។

មិនមែនតែការវាយលុករបស់ខ្មែរក្រហមទទួលបរាជ័យប៉ុណ្ណោះទេ គឺវាបានទាំងបណ្តាលឱ្យមានការបាត់បង់ហិនហោចដ៏ធំធេងថែមទៀត ។ ហេតុអ្វីបានជាប.ក.ក.មិនពន្យាការវាយលុករហូតដល់ថ្ងៃ១៥សីហា ? កស្តុគាង់បានបញ្ជាក់ថា ពួកគេបានដាក់បញ្ជាដល់មេទ័ពរបស់គេថា ត្រូវវាយយកភ្នំពេញឱ្យបានមុនខែសីហា ដើម្បី"បញ្ជាក់ដល់ពិភពលោកថាពួកគេអាចផ្តួលរំលំ ស.រ.អ.បាន" ។ នេះចង់ផ្តល់មតិថា ការសម្រេចចិត្តរបស់ខ្មែរក្រហមគឺមិនមែនធ្វើឡើងតាមភាព **សមហេតុផល** ខាងផ្នែកកម្លាំងយោធាទេ តែគឺធ្វើឡើងតាមជំនឿផ្តាច់មុខនៃមនោគមន៍វិជ្ជាដែលគេស្រមៃថាជាគុណសម្បត្តិរបស់ខ្មែរកុម្មុយនិស្ត និងថាជាការប៉ិនប្រសប់របស់គេដើម្បីបង្អាប់មុខប.ក.វ. ។ បើ

ដូច្នោះមែន ការផ្តល់មតិនេះបានបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ក្រឡែតនូវបំណងនៃសេចក្តីសម្រេចបណ្តេញកងទ័ព និងទីប្រឹក្សាយួនចេញនៅខែកញ្ញា១៩៧១ ។

## ៧_ការឃោសនារបស់ខ្មែរក្រហមដើម្បីបណ្តេញវៀតណាមៈ

នៅពេលដែលសេចក្តីសម្រេចចិត្តរបស់ថ្នាក់លើនៃប.ក.ក. ក្នុងការបណ្តេញយួនចេញពីកម្ពុជាត្រូវបានដាក់ឲ្យអនុវត្តនៅឆ្នាំ១៩៧២មក វិធានការដែលគេប្រើជារឿយៗ គឺគេឲ្យកម្មាភិបាលនៃប.ក.ក.នៅក្នុងស្រុក (ឧទាហរណ៍ដូចជាពួកអ្នកដែលមិនបានទៅហ្វឹកហាត់នៅហាណូយ ) ជាពិសេសកម្មាភិបាលថ្នាក់ភូមិភាគឬថ្នាក់តំបន់បើកកិច្ចចរចាជាមួយកងទ័ពឬកម្មាភិបាលបក្សរបស់យួន សុំឲ្យពួកគេថយចេញពីកម្ពុជា ។ បើយួនមិនព្រមចេញ បាតុកម្មប្រជាជនមួយនឹងត្រូវរៀបចំឡើងដោយកម្មាភិបាលក្នុងស្រុកដើម្បីប្រឆាំងនឹងពួកគេ ។ បើធ្វើប៉ុណ្ណេះហើយយួនមិនព្រមចេញទៀត គេនឹងដេញដោយអាវុធម្តង ។ ការប្រយុទ្ធគ្នាតែងកើតឡើងជារឿយៗនៅចុងឆ្នាំ ១៩៧២ និងពាក់កណ្តាលឆ្នាំ១៩៧៣ ។

ចាប់ពីចុងឆ្នាំ១៩៧១រហូតដល់ឆ្នាំ១៩៧៤ ប៉ុលពតបានធ្វើការបោសសំអាតជាសម្ងាត់មួយទៅលើពួក ខ.វ.ម. ។ គេមិនដែលបានប្រកាសជាសាធារណៈទេអំពីរឿងនេះ ។ ជនរងគ្រោះត្រូវគេបោកបញ្ឆោតថា ទៅប្រជុំ ទៅរៀនសូត្រ ឬទៅចូលរួមក្នុងពិធីបុណ្យ រួចហើយត្រូវគេសម្លាប់ចោលដោយស្ងាត់ៗ ។ ភារកិច្ចចាប់ចងនិងកម្ទេចពួកខ.វ.ម.ត្រូវទទួលបន្ទុកដោយនគរបាល (សន្តិសុខ) ដែលជាសាខាមួយរបស់ប.ក.ក. ។

ថ្វីបើការបោសសំអាតពួកខ.វ.ម.បានប្រព្រឹត្តទៅដោយលាក់មុខក៏ដោយ ក៏អាកប្បកិរិយារបស់ពួកខ្មែរក្រហមបានសំដែងចេញរួចទៅហើយចំពោះក្រុមខ្មែររបះបោរឯទៀត ។ តាមសំដីអ៊ិកសារិន ខ្មែរមិនមែនកុម្មុយនិស្តម្នាក់ ដែលបានចូលព្រៃជាមួយខ្មែរក្រហមក្នុងឆ្នាំ១៩៧២បាននិយាយថា:

> **"ចំពោះវៀតណាមខាងជើង ប.ក.ក.មានសហប្រតិបត្តិការជិតស្និទ្ធល្អណាស់ តែគេចូលចិត្តចិនក្រហមច្រើនជាង ។ ការមិនទុកចិត្តយួនខាងជើងតែងតែមាន គ្រាន់តែគេមិនសំដែងចេញប៉ុណ្ណោះ ។ ហ៊ូយន់បាននិយាយថា ប.ក.ក.បានដឹងមុនរួចអស់ហើយ ហើយក៏បានប្រុងប្រៀបចំពោះគ្រោះថ្នាក់ពីពួកវ.ក.និងយួនខាងជើង ។ ប.ក.ក.មាននិន្នាការទៅខាងចិនក្រហមច្រើនជាង ។ គេឃើញចិនមានការគាំទ្រមិនប្រែប្រួល, មានប្រសិទ្ធិភាព និងមិនគិតផលប្រយោជន៍ ។ គេយកគំរូតាមចិនក្នុងការដឹកនាំ ។ គេគួរកត់សំគាល់ដែរថា កម្មាភិបាលជាន់ខ្ពស់នៃបក្សជាច្រើនសុទ្ធតែជាអ្នកសង្គមនិយមនិន្នាការចិន ។ បក្សក៏មើលឃើញផងដែរថា ប្រទេសចិនជាកូនជញ្ជីងសំរាប់ទប់ទល់នឹងគ្រោះថ្នាក់វៀតណាម" ។**

ភាពទទួលខុសត្រូវម៉ឺងម៉ាត់របស់ខ្មែរក្រហមមានប្រសិទ្ធិភាពណាស់កាលពីដំបូងទី ។ មេដឹកនាំយួនមិនបានដឹងភ្លាមៗទេ អំពីអរិភាពនៃការដឹកនាំរបស់ប.ក.ក.នៃប៉ុលពត ។ នៅខែវិច្ឆិកា១៩៧១ គណៈប្រតិភូហ៊ុងមួយក្រុមបានត្រូវបានរៀបចំទទួលដោយលេខាធិកាបក្ស ឡេយទន់ នៅទីក្រុងហាណូយ ។ ឡេយទន់បានសំដែងនូវការសប្បាយរីករាយជាខ្លាំងចំពោះជ័យជំនះនៃកងទ័ពហ៊ុង ។ នៅក្នុងពិធីជប់លាងជាផ្លូវការ តំណាងគណៈប្រតិភូ (អៀងសារី) បានថ្លែងបញ្ជាក់ថាៈ"បក្សទាំងពីរមានទស្សនៈនិងគោលជំហរដូចគ្នាបេះបិទក្នុងការដឹកនាំសង្គ្រាម" ។

យោងតាមអតីតៈមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលបដិវត្តបណ្តោះអាសន្នរបស់វៀតកុងម្នាក់បានឲ្យដឹងថា ទាល់តែមកដល់ឆ្នាំ១៩៧២ហើយទេ ទើបមេប.ក.វ.បានដឹងអំពីបដិបក្ខភាព (ភាពប្រឆាំងជំទាស់) ដ៏ជ្រាលជ្រៅដែលកប់នៅក្នុងថ្នាក់ដឹកនាំជាន់ខ្ពស់របស់ប.ក.ក. ។ ហេតុនេះហើយបានជាចាប់តាំងពីក្រោយពេលដែលកងទ័ពយួនកុម.បាកចេញពីកម្ពុជាដើម្បីចូលរួមក្នុងការវាយលុកវៀតណាមខាងត្បូងនៅរដូវចូលឆ្នាំ មេដឹកនាំប.ក.ក.យល់ថាជាឱកាសល្អ ដើម្បីច្រៀតវំខាននិងកម្ទេចកងឯកភាពយោធានិងគណៈកម្មាធិការសម្ពន្ធការវៀតណាមដែលនៅសេសសល់ ។

ថ្វីបើគ្មានកស្តុតាងជាក់លាក់ក៏ដោយ កងទ័ពខ្មែរក្រហមពិតជាបានកើនឡើងយ៉ាងសន្ធឹកនៅឆ្នាំ១៩៧២ ។ ក្រសួងសម្ងាត់នៃសាធារណរដ្ឋខ្មែរ នៅចុងឆ្នាំ១៩៧០បានឲ្យដឹងថា កងទ័ពហ៊ុងមានចំនួនពី១២ពាន់ទៅ១៥ពាន់នាក់ ។ ក្នុងខែវិច្ឆិកា១៩៧១ ចំនួននេះឡើងដល់ពី១៨ពាន់ទៅ២៥ពាន់នាក់ ។ ខែឧសភា១៩៧២ កងទ័ពហ៊ុងមានចំនួនពី៣៥ពាន់ទៅ៤០ពាន់នាក់ ហើយចេះតែកើនឡើងថែមទៀតនៅឆ្នាំ១៩៧៣ ។

ជាមួយនឹងកិច្ចចុះហត្ថលេខាព្រមព្រៀងសន្តិភាពក្រុងប៉ារីសនៅខែមករា១៩៧៣ កងឯកភាពសំខាន់ៗភាគច្រើនរបស់យួនកុម.ក៏ត្រូវបានដកថយចេញពីកម្ពុជាស្ទើរតែគ្រប់ទីកន្លែង ។ យោងតាមស្ថានទូតស.រ.អ.នៅទីក្រុងភ្នំពេញ នៅស្រុកខ្មែរមានទ័ពយួនកុម.៤២ពាន់នាក់ ប៉ុន្តែក្នុងចំនួននេះ ៣៥ពាន់នាក់មានភារកិច្ចជាអ្នកផ្គត់ផ្គង់ស្បៀងពីហាណូយទៅវៀតណាមខាងត្បូង ។ ចំណែក៧ពាន់នាក់ទៀត ពាក់កណ្តាលជាអ្នកជួយខ្មែរក្រហម ។

ការដកថយរបស់វៀតណាម បានធ្វើឲ្យកងទ័ពបដិវត្តនៃកម្ពុជាប្រជាធិបតេយ្យរបស់ប៉ុលពតក្លាយជាកត្តាយោធាដ៏លើសលប់ប្រឆាំងនឹងពួកសាធារណរដ្ឋខ្មែរ ។ នៅក្នុងពេលនោះ រដ្ឋាភិបាលហ៊ុងត្រូវបានយួនខាងជើងនិងវៀតកុងចាត់ទុកថាជារដ្ឋាភិបាលឯករាជ្យ ។ កងទ័ពនិងកម្មាភិបាលរបស់យួនកុម.ដែលចង់ធ្វើដំណើរឆ្លងកាត់តំបន់ខ្មែរក្រហម ឬចង់ទៅទិញអង្ករពីប្រជាជនក្នុងតំបន់នេះ ត្រូវសុំសំបុត្រអនុញ្ញាតពីហ៊ុង ។ ដោយមើលឃើញថាកាន់តែមានការពិបាកច្រើនឡើងៗនៅក្នុងការទាក់ទងគ្នា យួនខាងជើងនិងយួនវៀតកុងបានបង្កើតក្រុមមួយឈ្មោះ

“ប្រតិបត្តិការ **ក**” (K-Operation) ដែលមានពលទាហានមួយចំនួនតូចសំរាប់ការពារកងឯកភាពគណៈកម្មាធិការសម្ពន្ធការ ។ តែដោយហេតុមានសម្ពាធកាន់តែខ្លាំងពីខ្មែរក្រហម ក្រុមការពារដែលមានគ្នាតិចតួចនេះក៏បានរើទីតាំងទៅនៅជិតព្រំប្រទល់វៀតណាមខាងត្បូងវិញ ។ តាមសំដីយួនកុម.ផ្តាច់ខ្លួនម្នាក់ នៅដើមឆ្នាំ១៩៧៤ យោធានិងកម្មាភិបាលនៃកងឯកភាពមួយបានត្រូវបង្ខំឲ្យដកថយចូលស៊ីប់ទៅក្នុងវៀតណាមខាងត្បូង ហើយនៅពេលដែលគេដកថយទៅនោះ គេក៏ត្រូវបានធ្លាក់ចូលក្នុងការពួនស្ទាក់វាយរបស់ពួកខ្មែរក្រហម ។

សកម្មភាពនយោបាយឯទៀតៗរបស់យួនកុម.ក៏ត្រូវស្ថិតនៅក្រោមសម្ពាធដ៏ធំធេងដែរ ។ **សមាគមមិត្តនៃអ្នកស្នេហាជាតិវៀតណាម** ដែលមានទីលំនៅក្នុងស្រុកខ្មែរ ជាអង្គការមួយរៀបចំឡើងនិងគ្រប់គ្រងដោយការិយាល័យកណ្តាលសំរាប់វៀតណាមខាងត្បូង (ក.ក.វ.ត.) របស់ទីក្រុងហាណូយ ក្នុងគោលបំណងគាំពារពួកវៀតកុងដែលត្រូតត្រាពួកយួននៅស្រុកខ្មែរ ហើយនឹងបញ្ចុះបញ្ចូលយួននៅស្រុកខ្មែរឲ្យជួយផ្គត់ផ្គង់ពួកវៀតកុង ។ ដោយសង្គ្រាមនៅកម្ពុជាចេះតែអូសបន្លាយទៅ និងដោយអំណាចរបស់ខ្មែរក្រហមកាន់តែរឹងមាំទៅ **សមាគមនេះបានខំប្រឹងប្រែងជាខ្លាំងក្នុងការលើកទឹកចិត្តពួកយួនក្នុងស្រុកខ្មែរឲ្យខំតស៊ូអត់ធ្មត់ជាមួយនឹងអាជ្ញាធរខ្មែរក្រហម ហើយនិងសុំពួកគេកុំឲ្យវិលទៅនៅវៀតណាមខាងត្បូងវិញ** ។ នេះជាសញ្ញាមួយដែលបញ្ជាក់ថា **យួនកុម.ចង់ឲ្យមានមូលដ្ឋានសង្គមរបស់គេសំរាប់ទំនាក់ទំនងនយោបាយនាពេលអនាគតនៅកម្ពុជា** ។ ប៉ុន្តែ ការខំប្រឹងប្រែងនេះមិនសូវបានផ្លែផ្កាទេ ។ សមាគមបានបង្ហាញនូវអសមត្ថភាពរបស់ខ្លួន នៅចំពោះមុខច្បាប់ដ៏ឃោរឃៅរបស់ខ្មែរក្រហមប្រឆាំងនឹងយួន ។ នៅដើមឆ្នាំ១៩៧៣ កងឯកភាពយោធាដែលសមាគមបានបង្កើតឡើងដើម្បីការពារជនជាតិយួនបានត្រូវរំលាយតាមការទទូចសុំរបស់ខ្មែរក្រហម ។ នៅក្នុងពេលជាមួយគ្នានោះដែរ ខ្មែរក្រហមបានបង្ខំប្រជាជនវៀតណាមឲ្យចេញពីតំបន់ដីទំនាប ទៅតាំងទីលំនៅថ្មីនៅក្នុងតំបន់ព្រៃភ្នំ ដោយគេយកលេសថាដើម្បីការពារអ្នកទាំងនោះទល់នឹងកងទ័ពរដ្ឋាភិបាលខ្មែរ ។ ប៉ុន្តែ ពួកវៀតណាមដែលត្រូវគេបង្ខំឲ្យបោះបង់ចោលផ្ទះសម្បែង និងអស់លទ្ធភាពក្នុងការរកចំណូលដែលបានពី**របរ**នេសាទ និងពាណិជ្ជកម្មដែលបណ្តាលមកពីការប្តូរទីលំនៅបានចាត់ទុកថា នេះជាមធ្យោបាយមួយដែលខ្មែរក្រហមចក់ប្លន់ទ្រព្យសម្បត្តិ និងកេងយកប្រយោជន៍ពីកម្លាំងពលកម្មរបស់គេ ហើយខ្មែរក្រហមមកវិញនឹងសមាគមវៀតកុង ថាខកខានមិនបានការពារជនជាតិយួនពីការធ្វើទុក្ខបុកម្នេញរបស់ពួកខ្មែរក្រហមទៅវិញ ។

នៅសម័យនោះ ក្រោយការចុះហត្ថលេខាលើកិច្ចព្រមព្រៀងប៉ារីស ការបោសសំអាតខ្មែរកុម.ដែលសង្ស័យថាមាននិន្នាការយួនបានចាប់បន្តធ្វើទៅទៀត ។

## ៨_ប្រតិកម្មដោយអត់ធ្មត់របស់ហាណូយចំពោះការវាយប្រហាររបស់ខ្មែរក្រហម៖

នៅខែកុម្ភៈ១៩៧៣ មេដឹកនាំយួនកុម.ដឹងថាបាតុកម្មនិងការវាយប្រហារដោយអាវុធទៅលើកងកម្លាំងរបស់គេគឺជាការប្រព្រឹត្តិដោយចេតនា ហើយឥឡូវនេះខ្មែរក្រហមបានឃុបឃិតរួមគំនិតគ្នាដើម្បីដណ្តើមយកគ្រឿងអាវុធនិងសម្ភារៈពីយួនកុម. និងបណ្តេញពួកគេចេញពីកម្ពុជាទៀត ។

ប៉ុន្តែទីបញ្ជាការវៀតណាមនៃតំបន់សឹកលេខ១៥០ (ភូមិភាគបូព៌ា) ស្ថិតនៅក្រោមបង្គាប់ក.ក.វ.ត.បានបញ្ជាទ័ពនិងភ្នាក់ងាររបស់គេ ឲ្យចៀសវាងការប៉ះទង្គិចគ្នាជាមួយនឹងខ្មែរក្រហម និងត្រូវចេះអត់ធ្មត់ជាមួយពួកគេផង ។ យួនវៀតកុងតំបន់សឹកលេខ១៥០ មានការខឹងសម្បាចំពោះវិធានការនេះ ហើយបានស្នើថា: បើមិនវាយបកទៅពួកខ្មែរក្រហមវិញទេ គួរដកថយទៅវៀតណាមខាងត្បូងវិញទៅ ។

ប៉ុន្តែតាមរបាយការណ៍របស់កម្មាភិបាលយួនផ្តាច់ខ្លួនម្នាក់នៅពាក់កណ្តាលឆ្នាំ១៩៧៣ គណៈកម្មការ ក.ក.វ.ត.បានចេញបញ្ជាមួយមានសេចក្តីដូចតទៅ:

**"បើខ្មែរក្រហមចង់ឈ្លានពានទីតាំងយើង ចង់សម្លាប់កងទ័ពយើង យើងត្រូវតដៃវិញក្នុងលក្ខណៈការពារខ្លួន តែយើងមិនត្រូវបាញ់គេមុនទេ ។ យើងគ្រាន់តែកំញើញៗបានហើយ ។ ធ្វើយ៉ាងណាឲ្យមានការខូចខាតតិចតួចបំផុត" ។**

ហេតុអ្វីបានជាមេដឹកនាំហាណូយប្រព្រឹត្តយ៉ាងនេះ ចំពោះសម្ពន្ធមិត្តដែលមានចិត្តមិនស្មោះត្រង់ដូច្នេះ ? មកដល់ពាក់កណ្តាលឆ្នាំ១៩៧៣ មានតែទ័ពវៀតណាមខាងជើងនិងវៀតកុង២០០០ឬ៣០០០នាក់ប៉ុណ្ណោះរួមជា_មួយកម្មាភិបាលនយោបាយ២០០០នាក់ដែលនៅបន្តធ្វើសង្គ្រាមនៅកម្ពុជា (បើទោះជាទ័ពចន្លោះពី១៨ពាន់ទៅ២៧ពាន់ថែមទៀតនៅការពារផ្លូវលំ ហូជីមិញក៏ដោយ) ។ ចំពោះវិវាទជាមួយខ្មែរក្រហម យួនកុម.មានការគន់គូរល្អិតល្អន់ណាស់ ។ គេគិតថា បើដកទ័ពពីវ.ខ.ជ.និងពីវ.ខ.ត.មកតទល់ជាមួយខ្មែរក្រហម រដ្ឋាភិបាលព្រៃនគរដែលជាសត្រូវសំខាន់ជាងគេអាចនឹងឆ្លៀតពេលពង្រឹងជំហរយោធា ។ ម្យ៉ាងទៀត បើយើងធ្វើការតប_ត ដែលជាការកំញើញគំរាមនោះ វាក៏ជាកត្តាមួយដែលធ្វើឲ្យពួកខ្មែរក្រហមចុះទន់ខ្សោយបាក់ទឹកចិត្ត ហើយដែលជាហេតុនាំឲ្យរដ្ឋាភិបាលភ្នំពេញរបស់លន់ណុលរឹតតែមានកម្លាំងឡើងថែមទៀត ។ មេដឹកនាំហាណូយត្រូវយល់ថា ការទន់ខ្សោយនៃសាមគ្គីភាពបដិវត្ត មិនថាអ្នកណាជាអ្នកទទួលខុសត្រូវទេ វាបានត្រឹមតែផ្តល់ប្រយោជន៍ទៅឲ្យសត្រូវសំខាន់របស់ប.ក.វ.តែប៉ុណ្ណោះ ហើយថែមទាំងបង្កើតនូវការលំបាកដ៏ធំធេងដល់ហាណូយក្នុងការសម្រេចគោលដៅចម្បងគឺការវាយយកវ.ខ.ត.ទៀតផង ។ ឯរឿងខ្មែរក្រហមទុកមួយអន្លើសិន ចាំយកវ.ខ.ត.បាន សឹមគិតគូជា

ក្រោយ ។ តែទោះក្នុងករណីណាក៏ដោយ ក្នុងរយៈពេលខ្លី មេដឹកនាំហាណូយនៅមានសន្លឹកបៀច្រើនទៀតទុកសម្រាប់លេងជាមួយខ្មែរក្រហម ជាអាទិ៍គឺការបិទខ្ទប់ជំនួយពីចិន ។

ខ្មែរក្រហមពឹងផ្អែកទាំងស្រុងលើវ.ខ.ជ. ក្នុងការទទួលជំនួយយោធា និងសេដ្ឋកិច្ចពីចិន តាមរយៈផ្លូវលំហូជីមិញ ។ រដ្ឋាភិបាលយួនកុម.ជាអ្នកសម្រេចក្នុងការចែកជំនួយទៅឱ្យទ័ពព្រៃខ្មែរ ។ ខែកញ្ញា១៩៧៣ សីហនុបានប្រាប់ទីភ្នាក់ងារពត៌មានបារាំង (AKP) នៅទីក្រុងប៉េកាំងថា ក្រោយកិច្ចព្រមព្រៀងបារីស ហាណូយបានផ្តាច់ជំនួយគ្រឿងអាវុធទៅឱ្យខ្មែរក្រហម ។ ការផ្តាច់ជំនួយនេះបានបន្តឡើងវិញយ៉ាងចាប់នៅពេលដែលទីក្រុងកំពង់ចាមត្រូវយកបានវិញដោយកងទ័ពរដ្ឋាភិបាលក្នុងខែសីហា_កញ្ញា តែក្រោយមកត្រូវកាត់ផ្តាច់ម្តងទៀត ។ យោងតាមសីហនុការខ្វះគ្រឿងសព្វាវុធ បណ្តាលឱ្យកងទ័ពរំដោះដម្លៀសទីក្រុងកំពង់ចាម ដែលគេវាយយកបានបីភាគបួនទៅហើយនោះ ។ នៅក្នុងសម្ភាសមួយជាមួយទស្សនាវដ្តីសេដ្ឋកិច្ចចុងបូព៌ា (Far Eastern Economic Review) បីខែក្រោយមក សម្តេចសីហនុបានដាក់បន្ទុកជាថ្មីម្តងទៀតទៅលើទីក្រុងហាណូយ ចំពោះកង្វះគ្រឿងសព្វាវុធដល់កងទ័ពរបស់ទ្រង់ ។ ទ្រង់បានពន្យល់អំពីរឿងហេតុរបស់ហាណូយថាៈ

**"សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម (ស.ប.វ.) និងរដ្ឋាភិបាលបដិវត្តបណ្តោះអាសន្នវៀតណាមខាងត្បូងលែងត្រូវការទីក្រុងភ្នំពេញឬកំពង់ផែក្រុងព្រះសីហនុក្នុងការរំដោះជាតិនៅវៀតណាមខាងត្បូងទៀតហើយ ។ ម៉្យាងទៀត រដ្ឋាភិបាលនិកសុន នៃស.រ.អ.គួរតែឲ្យស.ប.វ.និងរដ្ឋាភិបាលបដិវត្តបណ្តោះអាសន្នវៀតណាមខាងត្បូងទទួលខុសត្រូវ និងគួរតែដាក់ទណ្ឌកម្មគ្រប់បែបយ៉ាង បើសិនជាស្ថានការណ៍សឹកប្រែទៅជាមហន្តរាយដល់របបលន់ណុល ។ ជាច្រើនលើកច្រើនសាមកហើយ រដ្ឋាភិបាលស.រ.អ.បានប្រាប់ស.ប.វ.ឲ្យដឹងថា ជំនួយអាមេរិកសម្រាប់កសាងឡើងវិញនឹងត្រូវកាត់ផ្តាច់ រីឯកងទ័ពអាកាសស.រ.អ.អាចនឹងធ្វើអន្តរាគមន៍ឡើងវិញប្រឆាំងនឹងវៀតណាមខាងជើង បើសិនជាស្ថានការណ៍សឹកនៅកម្ពុជាត្រូវប្រែប្រួលយ៉ាងឆាប់រហ័ស ដែលជាគុណប្រយោជន៍ដល់ ត្រង ។"**

គ្មានអ្វីគួរឱ្យចម្ងល់ទេថា វាអាចមានការសមទំនងខ្លះដែរក្នុងការបកស្រាយពន្យល់របស់សីហនុស្តីអំពីឥរិយាបទហាណូយ ។ ប៉ុន្តែ យើងបានឃើញហើយថាយួនកុម.មានមូលហេតុផ្សេងទៀតក្នុងការមិនទទួលអបអរចំពោះជ័យជំនះរបស់ពួកខ្មែរក្រហមនៅភ្នំពេញ ។ មូលហេតុម៉្យាង យើងគួរកត់សំគាល់ថា ក្នុងឆ្នាំ១៩៧៣ វ.ខ.ជ.បានផ្តល់នូវជំនួយយោធាសំខាន់ខ្លះជាអាវុធធុនធ្ងន់ដល់ខ្មែរក្រហមដើម្បីវាយយកទីក្រុងកំពង់ចាមក្នុងខែសីហា_កញ្ញា ។ វ.ខ.ជ.បានជួយដឹកនាំជំនួយពីស្រុកចិន កាត់ទឹកដីវៀតណាមតាមផ្លូវលំ ហូ_ជីមិញ បញ្ជូនទៅឱ្យខ្មែរក្រហមនៅ

ក្នុងកម្ពុជា ។ ឯមេដឹកនាំ គ្រុង ក៏ត្រូវបានគេទទួលជាហូរហែនៅហាណូយ ។ ឧទាហរណ៍: សម្តេចសីហនុបានធ្វើទស្សនៈកិច្ចចំនួនមួយសប្តាហ៍នៅហាណូយនៅចុងខែមករា១៩៧៣ ។ តាមទីភ្នាក់ងារព័តមានហាណូយ ក្នុងឱកាសសម្រេចកិច្ចព្រមព្រៀងបារីសដើម្បីបញ្ចប់សង្គ្រាមនិងរៀបចំសន្តិភាពឡើងវិញនៅវៀតណាម សីហនុបានផ្ញើសារ-ទូរលេខមួយដើម្បីសម្តែងសេចក្តីសរសើរចំពោះមេដឹកនាំវៀតណាម ។

បន្ទាប់ពីទស្សនៈកិច្ចរបស់ទ្រង់នៅតំបន់រំដោះនៃប្រទេសកម្ពុជាក្នុងខែមីនា១៩៧៣ សីហនុបានត្រូវទទួលជាថ្មីម្តងទៀតនៅហាណូយ ដោយម្តងនេះមានការចូលរួមពីបេសកជនពិសេស អៀងសារីផង ។ សុន្ទរកថានៅពេលនោះក៏បានបញ្ជាក់ជាថ្មីម្តងទៀតអំពីមិត្តភាពជាភាតរភាព និងយុទ្ធសាមគ្គីភាពដែលចងភ្ជាប់ប្រជាជាតិវៀត-ណាម កម្ពុជា និងលាវ ។

មេដឹកនាំយួនកុម.ក៏ចេះតែបន្តទទួលគណៈប្រតិភូមេដឹកនាំខ្មែរក្រហមដោយគ្មានវត្តមានសីហនុផងទេ។ ឧទាហរណ៍: ផាំវ៉ាន់ដុងបានទទួលគណៈប្រតិភូហ៊ុំងនៅហាណូយ ដឹកនាំដោយអៀងសារីនៅខែវិច្ឆិកា១៩៧៣ ។ ខែមីនា១៩៧៤ គណៈប្រតិភូមួយទៀតដឹកនាំដោយខៀវសំផននិងអៀងសារីបានត្រូវទទួលស្វាគមន៍នៅហាណូយដោយមេដឹកនាំជាន់ខ្ពស់វៀតណាម ដោយរួមទាំងទ្រៀងជិញ និងឡេឌឹកថូផង ។ គណៈប្រតិភូនេះបានត្រូវទទួលម្តងទៀតនៅហាណូយ ចុងខែឧសភា ក្នុងពេលត្រឡប់មកពីធ្វើទស្សកិច្ចជាអន្តរជាតិមួយ ។ នៅក្នុងសេចក្តីថ្លែងការណ៍រួមគ្នាមួយនៅពេលបញ្ចប់ទស្សនកិច្ច គណៈប្រតិភូខ្មែរក្រហមបានទទួលនូវ "ស្វាគមន៍យ៉ាងកក់ក្តៅជាមួយនឹងការជ្រួតជ្រាបចូលគ្នានៃយុទ្ធសាមគ្គីភាព និងភាតរភាពរវាងប្រជាជនទាំងពីរ" ។ ផាំវ៉ាន់ដុងបានបញ្ជាក់ជាថ្មីម្តងទៀតនូវការគាំទ្ររបស់ប្រជាជនវៀតណាមចំពោះការតស៊ូប្រកបដោយជោគជ័យដ៏ត្រឹមត្រូវ និងច្បាស់លាស់របស់ប្រជាជនកម្ពុជា ។

បើទោះជាសេចក្តីថ្លែងការណ៍ទាំងនោះបានបញ្ជាក់ពីការគាំទ្រ"ប្រជាជននិងប្រជាជន" មិនមែន "បក្សនិងបក្ស"ក៏ដោយ ក៏ទំនាក់ទំនងមើលទៅហាក់ដូចជាធ្វើទាំងបង្ខំ ។ ប៉ុន្តែចំណុចបាក់បែកគ្នានៅឆ្ងាយណាស់ ។ នៅក្នុងកាលៈទេសៈដ៏សមហេតុសមផលមួយ មេខ្មែរក្រហមបានទទួលស្គាល់សេចក្តីត្រូវការនៃទំនាក់ទំនងខ្លះជាមួយហាណូយ បើសិនពួកគេឈ្នះ ។ យួនកុម.នៅមានឥរិយាបទសាំញ៉ាំច្រើនទៀត ។ គេមិនចង់ឲ្យខ្មែរក្រហមបានទទួលនូវជ័យជំនះផ្តាច់ព្រ័ត្រទេ ។ តែគេមិនអាចចូលរួមជាមួយនឹងរដ្ឋាភិបាលលន់ណុលកើត ។ ចំពោះហា-ណូយ លទ្ធផលដ៏ប្រសើរបំផុតគឺការបន្តសង្គ្រាមស៊ីវិលនៅកម្ពុជា ជាមួយនឹងការផ្តល់ជំនួយអោក់អួលម្តងបិទម្តងបើកដល់ខ្មែរក្រហម ។ ហាណូយនៅរង់ចាំទាល់តែគេបានជ័យជំនះនៅវ.ខ.ត.សិន ទើបគេងាកមកគិតគូរពីរឿង

ខ្មែរម្តង ។

ហាណូយមានការខកចិត្ត ។ បើទោះជាគេស្ថិតនៅក្នុងស្ថានភាពជឿនលឿនទៅមុខមួយក្តី គេមិនអាចត្រួតពិនិត្យឲ្យបានល្អិតល្អន់នូវដំណើរប្រវត្តិសាស្ត្រនៅទូទាំងឥណ្ឌូចិនបានឡើយ ។ ខ្មែរក្រហមយកភ្នំពេញបាននៅថ្ងៃ១៧មេសា ហើយពីរសប្តាហ៍ក្រោយ ហាណូយយកព្រៃនគរបានទៀត ។ ខ្មែរក្រហមបានសម្រេចជោគជ័យជាស្ថាពរនៅកម្ពុជា ដោយគ្មានអន្តរាគមន៍ផ្ទាល់ពីកងទ័ពយួនកុម្ម.ទេ ។

# ៩_វាសនារបស់សហភាពឥណ្ឌូចិន:

ដូចយើងបានពិភាក្សាមុននេះបន្តិច មហិច្ឆតាជាប្រពៃណីនៃចក្រពត្តិយួននៅឥណ្ឌូចិនបានផ្តល់ជាគ្រឿងលំអមួយដែលជាកេរ្តិ៍ដំណែលរបស់របបម៉ាក់ស៊ីស្ត_ឡេនីនីស្ត តាមរយៈទស្សនៈនៃសហភាពឥណ្ឌូចិន រៀបចំឡើងយ៉ាងជាក់លាក់ដោយកុម្មុយនិស្តអន្តរជាតិនៅឆ្នាំ១៩៣០ ក្នុងសម័យនៃការបង្កើតប.ក.ឥ. ។ គំនិតចង់ឲ្យមានសហ_ភាពមួយបានចាប់កំណើតឡើងវិញដោយយួនកុម្ម. នៅពេលយួនវៀតមិញច្បាំងនឹងបារាំង ។ តែនៅឆ្នាំ១៩៧០ មេដឹកនាំហាណូយ ថ្វីបើនៅតែគាំទ្រគោលការណ៍សហភាពក៏ដោយ ក៏នៅមានការអល់អែកក្នុងការស្នើរជាសាធារណៈនូវការបង្កើតនយោបាយបែបនេះ ។ នៅឆ្នាំ១៩៧៥ គេបានអនុវត្តនូវយុទ្ធសាស្ត្រដកថយមួយ ។ មានមូលហេតុពីរក្នុងយុទ្ធសាស្ត្រនេះ ៖

- ទីមួយ គឺទំនាក់ទំនងរបស់ហាណូយជាមួយប៉េកាំង ។ ក្នុងនាមជាអ្នកជិតខាងយ៉ាងគ្រាក់និងជាចៅហ្វាយរបស់យួន ចិនតែងតែទាមទារជានិច្ចយកមុខងារជាអ្នកកំណត់វាសនាអនាគតរបស់ឥណ្ឌូចិន ។ ការគាំទ្រយ៉ាងជិតស្និទ្ធ ខាងសម្ភារៈនិងមនោគមន៍វិជ្ជាដល់ពួកបះបោរខ្មែរក្រហម ដូចគ្នានឹងការគាំទ្រសម្តេចសីហនុដែលជាប្រមុខរដ្ឋតែងតាំងនៃក្រុមបះបោរផងនោះ បានបញ្ជាក់អំពីការធានារបស់ចិនចំពោះឯករាជ្យកម្ពុជា ។ ហេតុនេះហើយ (ដូចដែលអគ្គរដ្ឋទូតសូវៀតប្រចាំទីក្រុងហាណូយបានចង្អុលបង្ហាញនៅឆ្នាំ១៩៧១) បានជាសមមិត្តវៀតណាមមិនស្ទុះស្ទាក្នុងការបង្កើតកម្លាំងរំដោះសម្រាប់អ្នកជិតខាង នៅក្នុងក្របខ័ណ្ឌនៃរណសិរ្សតស៊ូរួមមួយ ។ ជាជំនួសមកវិញ វៀតណាមពេញចិត្តនឹងទំនាក់ទំនងរបស់គេជាមួយនឹងមិត្តកម្ពុជានិងមិត្តលាវ ដោយដើរលើមូលដ្ឋានទ្វេបក្ស រួមជាមួយនឹងស្ថានភាពនាំមុខដែល"គេបានសម្រេចដើម្បីកាន់កាប់ចលនារំដោះឥណ្ឌូចិន" ។
- ទីពីរ ការពិតនៅលើគោកគឺថា ហេតុអ្វីបានជានៅឆ្នាំ១៩៧៥ យួនត្រូវបង្ខំចិត្តផ្អាកផែនការឥណ្ឌូចិនទុកមួយអន្លើសិន ? ហាណូយតែងតែយល់ច្បាស់ជានិច្ចថា លទ្ធភាពរបស់គេក្នុងការធ្វើឲ្យបានសម្រេចផែនការសហភាពឥណ្ឌូចិន គឺស៊ីសងនៅលើការកាន់ក្តាប់ស្ថានភាពនយោបាយនិងយោធារបស់គេ នៅក្នុងប្រទេសនីមួយៗ ។

ការបោសសំអាតពួកខ្មែរវៀតមិញនៅដើមឆ្នាំ១៩៧០ ដោយប៉ុលពត បានបន្ថយនូវសេចក្តីសង្ឃឹមរបស់ហាណូយក្នុងការដឹកនាំបដិវត្តកម្ពុជា ។ សញ្ញ័យ (ការច្បាំងដណ្តើមយកបាន) របស់ខ្មែរក្រហមនៅកម្ពុជា ពីរអាទិត្យមុនហាណូយយកបានវៀតណាមខាងត្បូង បានប្រាទបោលនូវអំណះអំណាងសាជាថ្មីរបស់ទីក្រុងហាណូយចំពោះការត្រួតពិនិត្យនយោបាយ តាមមធ្យោបាយអន្តរាគមន៍យោធានៃ"ភាតរភាពវៀតណាម" ដោយយកលេសថា "មកជួយរំដោះកម្ពុជា" ។

ប៉ុន្តែ នេះមិនមែនបានន័យថាហាណូយចង់បោះបង់ចោលទាំងស្រុងនូវគំនិតសហព័ន្ធឥណ្ឌូចិននោះទេ ។ នៅខែកុម្ភៈ១៩៧៣ ទូតសូវៀតប្រចាំវៀតណាមខាងជើងបានបង្ហាញឱ្យឃើញយ៉ាងច្បាស់អំពីគោលបំណងរបស់ហាណូយ:

**"ផែនការឥណ្ឌូចិនរបស់សមមិត្តវៀតណាមគឺ ត្រូវដាក់ជំនួសរបបប្រតិកិរិយានៅព្រៃនគរ វៀងចាន់ និងភ្នំពេញដោយរបបជឿនលឿនមួយ ។ រួចហើយ នៅពេលដែលវៀតណាម លាវ និងកម្ពុជាបានចាប់ធ្វើដំណើរនៅលើផ្លូវសង្គមនិយមហើយ យួននឹងជំរុញឲ្យបង្កើតសហភាពនៃប្រទេសនៅឥណ្ឌូចិន (Federation of the Indochinese Countries) ។ ចរន្តនយោបាយរបស់បក្សពលករវៀតណាមនេះហូរចេញមកពីផែនការរបស់អតីតៈបក្សកុម្មុយនិស្តឥណ្ឌូចិន ។"**

លុះមកដល់ឆ្នាំ១៩៧៥ យួននៅតែសង្ឃឹមថានឹងមានការបះបោរសាជាថ្មីរបស់ក្រុមនិយមយួននៅក្នុងបក្សកុម្មុយនិស្តកម្ពុជា ដើម្បីប្រស់អំណាចរបស់គេឱ្យរស់ឡើងវិញ ។ ប៉ុន្តែសេចក្តីសង្ឃឹមរបស់គេ **គឺជាសំណង់ដែលសង់នៅលើដីខ្សាច់។**

## ១០_សេចក្តីសន្និដ្ឋាន

លទ្ធផលដ៏ក្រចះក្រចង់នៃសង្គ្រាម១៩៧០_៧៥នៅកម្ពុជា មិនមែនជាជម្រើសល្អសម្រាប់គ្រប់ភាគីដែលជាប់ទាក់ទិននៅក្នុងសង្គ្រាមនោះទេ ។ អ្នកដែលពេញចិត្តនឹងលទ្ធផលនោះគឺមានតែខ្មែរក្រហមទេ និងអាចទំនងជាមានពួកជ្រុលនិយម (ដែលគេហៅថា"បនអ្នកលេងបួននាក់") ដែលឡើងកាន់អំណាចបណ្តោះអាសន្ននៅប៉េកាំងពីខែកញ្ញា១៩៧៣ រហូតដល់មរណៈភាពរបស់ម៉ៅសេទុង ក្នុងខែកញ្ញា១៩៧៦នោះផងដែរ ។

យួនកុម.ចង់បានរដ្ឋាភិបាលខ្មែរកុម.មួយស្ថិតនៅក្រោមបញ្ជារបស់គេ ដែលគ្រប់គ្រងដោយភ្នាក់ងាររបស់គេគឺខ្មែរវៀតមិញ ។ ការប៉ុនប៉ងជាបឋមរបស់យួនដើម្បីបានសម្រេចគោលដៅនេះ តាមវិធីបំផ្លាញកម្មេចរដ្ឋាភិបាលខ្មែរនិងការជួយបង្កើតទ័ពព្រៃ មិនអាចប្រព្រឹត្តទៅកើតជាមួយនឹងអន្តរាគមន៍យោធាផ្ទាល់ឡើយ ។ សកម្មភាព

នយោបាយនិងយោធារបស់យួនដែលមានព្រំដែននេះ បានឱ្យលទ្ធផលជាជំនួសវិញដោយការឡើងកាន់អំណាចរបស់ពួកខ្មែរក្រហម ។ យួនកុម.ទើបនឹងបានដឹងអំពីភាពប្រទូសរ៉ាយរបស់ខ្មែរក្រហមចំពោះពួកគេនៅពាក់កណ្តាលឆ្នាំ១៩៧២ប៉ុណ្ណោះ ដែលនៅពេលនោះគេមានលទ្ធភាពតិចតួចដើម្បីស្តារព្រឹត្តិការណ៍ឡើងវិញ ។ គេមិនទាន់ចង់កម្ទេចខ្មែរក្រហមមុន ដែលជាហេតុនាំឱ្យខូចផែនការបម្រុង ក្នុងការច្នងទៅយកវៀតណាមខាងត្បូងឡើយ ។ យួនអាចគ្រាន់តែពន្យឺតដំណើរជ័យជំនះរបស់ខ្មែរក្រហមតែប៉ុណ្ណោះ ក្នុងក្តីសង្ឃឹមថានឹងអាចយកវៀត_ណាមខាងត្បូងបានមុន រួចហើយទើបងាកមកចាត់ការអំពី "ជំនួយភាតរភាព" ដល់សមមិត្តកម្ពុជា ( ដោយយកតាមគំរូសូវៀតនៅអឺរ៉ុបខាងកើត ក្នុងឆ្នាំ១៩៤៤_៤៥) ដើម្បី"ជួយ"ខ្មែរក្រហមឱ្យបានជ័យជំនះផ្តាច់ព្រ័ត្រ។

ប៉ុន្តែហាណូយស្ទាបស្ទង់ស្ថានការណ៍ខុស បណ្តាលមកពីរដ្ឋាភិបាលលន់ណុលរលំមុនកាលកំណត់ ។ ក្រោយជ័យជំនះបានដោយខ្លួនឯងរបស់ពួកខ្មែរក្រហម ដែលអង្គការអន្តរជាតិបានទទួលស្គាល់ ហាណូយបានបង្ខំចិត្តត្រូវរង់ចាំរកវិធីផ្សេងៗទៀត ។

ជាទូទៅ ព្រឹត្តិការណ៍ដែលកើតមានឡើងរវាងឆ្នាំ១៩៧០_៧៥ បានបង្ហាញអំពីភាពខុសគ្នាដូចមេឃនិងដីរវាងទស្សនៈវិស័យរបស់យួនកុម.និងខ្មែរក្រហម ស្តីអំពីឥរិយាបទជាទូទៅរបស់គេចំពោះនយោបាយនិងសង្គ្រាម ជាពិសេសឥរិយាបទចំពោះទំនាក់ទំនងរវាង **មនោគមវិជ្ជានិងគោលដៅ** ។

សូមពិចារណាអំពីទស្សនៈខុសគ្នារវាងយួនកុម.និងខ្មែរក្រហមចំពោះមុខងាររបស់សីហនុនៅក្នុងកុប្បកម្ម ។ យួនកុម.ក៏ដូចជាចិនកុម.ដែរ បានទទួលស្គាល់ប្រជាប្រិយភាពរបស់សីហនុ ហើយយកប្រជាប្រិយភាពនេះមកប្រើដើម្បីសកម្មភាពឃោសនាជ្រើសរើសកងទ័ពបះបោរ ។ ផ្ទុយទៅវិញខ្មែរក្រហមមានការព្រួយបារម្ភចំពោះប្រជា_ប្រិយភាពរបស់សីហនុ ហើយនិងការខ្វះសមត្ថភាពខាងផ្លូវចិត្តសាស្ត្រដើម្បីទាញយកប្រយោជន៍ពីប្រជាប្រិយភាពនោះ ។ ពួកគេបែរជាប៉ុនប៉ងបំផ្លាញការទំប្រឹងប្រែងឃោសនាដែលមានការព្រមព្រៀងពីចិននិងវៀតណាមនោះទៅវិញ ។ ដោយថាហេតុ ខ្មែរក្រហមបានលះបង់ចោលនូវបច្ចេកទេស **បញ្ចុះបញ្ចូល** ដើម្បីប្រមូលទ័ព ហើយគេបែរជាមកប្រើ វិធី **បង្ខិតបង្ខំ** ប្រជាជនវិញ ។

ការដែលចម្លែកជាងនេះទៅទៀតគឺ អាកប្បកិរិយារបស់ខ្មែរក្រហមចំពោះយួនតែម្តង ។ ដូចយើងបានឃើញរួចមកហើយ នៅចន្លោះឆ្នាំ១៩៧០_៧២ ខ្មែរក្រហមពឹងផ្អែកទាំងស្រុងទៅលើយួនកុម.ដែលធ្វើឱ្យកងទ័ពរដ្ឋាភិបាលបរាជ័យ ដើម្បីខ្លួនមានលទ្ធភាពក្នុងការពង្រីកតំបន់រំដោះ ។ លើសពីនេះទៅទៀតពួកគេផ្តេកផ្តួលទាំង

ស្រុងទៅលើសប្បុរសធម៌របស់យួនកុម្មុយនីស្ត។ ក្នុងការជួយនាំអាវុធពីប្រទេសចិនកាត់តាម វ.ខ.ជ.មកកម្ពុជា ។ ថ្វីបើមានហេតុការណ៍ទាំងអស់នេះក៏ដោយ ក៏ខ្មែរក្រហមបានចិញ្ចឹមចិត្តប្រឈមមុខប្រទូសជាមួយសម្ពន្ធមិត្តយួនកុម្មុយនីស្ត.តាំងពីយូរមកហើយ គឺតាំងតែពីមុនពេលគេផ្តួលរំលំរដ្ឋាភិបាលភ្នំពេញដែលគាំទ្រដោយស.រ.អ.រម្ល៉េះ ។ ក្នុងការប្រព្រឹត្តបែបនេះ ខ្មែរក្រហមបានតម្រូវមកលើខ្លួនឯងនូវមាគ៌ាដ៏លំបាក និងមិនច្បាស់លាស់មួយដើម្បីធ្វើដំណើរឈានទៅចាប់យកអំណាចរដ្ឋ ។

ទង្វើនេះស្របគ្នានឹងលក្ខណៈចម្លែកនៃសេចក្តីសម្រេចរបស់មេខ្មែរក្រហម ក្នុងការវាយសម្រុកយកទីក្រុងភ្នំពេញកាលពីពាក់កណ្តាលឆ្នាំ១៩៧៣ ក្រោមការវាយប្រហារដ៏ខ្លាំងក្លាតាមផ្លូវអាកាសពីស.រ.អ. ដែលខ្មែរក្រហមបានចំណាយជីវិតយោធានិងកម្មាភិបាលរាប់ពាន់នាក់ឥតប្រយោជន៍ បើទោះជាបានដឹងថាស.រ.អ.នឹងបញ្ចប់ការទម្លាក់បែកនៅថ្ងៃ១៥សីហាក៏ដោយ ។

អាកប្បកិរិយាទាំងអស់នេះឆ្លុះបញ្ចាំងអំពីទស្សនៈមិនប្រាកដនិយមនៃការដឹកនាំរបស់ខ្មែរក្រហម ទាក់ទងផ្នែកសមត្ថភាព និងភាពទន់ខ្សោយរវាងខ្លួនឯងនិងសត្រូវ ។ម្យ៉ាងទៀត អាកប្បកិរិយានេះបានបញ្ជាក់អំពីភាពរឹងត្អឹងរបស់ខ្មែរក្រហមក្នុងការជ្រើសរើសមធ្យោបាយប្រើដើម្បីសម្រេចគោលដៅ ។ មេខ្មែរក្រហមហាក់ដូចជាខកខានមិនបានញែកឲ្យដាច់គ្នារវាងគោលដៅចាំបាច់ជាអាទិភាព និងគោលដៅបន្ទាប់បន្សំដែលគួរធ្វើបណ្តោះអាសន្នសិន ចាំទុកបង្អើយនៅពេលក្រោយ ។

គំរូនៃទស្សនៈនិងអាកប្បកិរិយាមិនសមហេតុសមផលនេះ ចេះតែប្រព្រឹត្តទៅដដែលៗក្នុងរយៈពេលពីរបីឆ្នាំបន្ទាប់មក ។ ខ្មែរក្រហមនឹងមិនស្តាប់ទេដរាបណាដៃហាណូយនៅជាប់ចំណងនឹងពួកគេ ក្នុងការតស៊ូជាមួយនឹងសត្រូវដ៏ខ្លាំងនៅ វ.ខ.ត.។ តែក្រោយថ្ងៃ៣០មេសា១៩៧៥ ដៃហាណូយត្រូវបានស្រាយពីចំណង ហើយដៃនេះក៏ក្លាយទៅជាដៃដែលមាន **មហិទ្ធិឫទ្ធិយ៉ាងសម្បើម** ។

♥

# ជំពូកបី

## ១_នយោបាយការបរទេសរបស់កម្ពុជាប្រជាធិបតេយ្យ១៩៧៥_៧៨៖

ដើម្បីយល់ច្បាស់អំពីវិវត្តន៍នៃទំនាក់ទំនងរវាងវៀតណាម_កម្ពុជាក្រោយឆ្នាំ១៩៧៥ ជាពិសេសការសម្រេចចិត្តរបស់វៀតណាមក្នុងការឈ្លានពានកម្ពុជា យើងត្រូវពិនិត្យជាដំបូងអំពីទំរង់បែបបទដ៏ទូលំទូលាយនៃនយោបាយក្រៅប្រទេសរបស់ខ្មែរក្រហមសិន ។

ចាប់តាំងពីឡើងកាន់អំណាចនៅឆ្នាំ១៩៧៥មក របបខ្មែរកុម.ដែលគេហៅខ្លួនគេជាផ្លូវការថា កម្ពុជាប្រជាធិបតេយ្យបានសន្មត់រដ្ឋវៀតណាមកុម.ថាជាសត្រូវធំរបស់គេ ។ យោងទៅតាមការសន្មត់នេះ (ការអះអាងនិងផលវិបាកដែលយើងពិនិត្យនៅក្នុងជំពូកក្រោយ) វាគួរតែខ្មែរក្រហមអនុវត្តតាមគំរូដឹកនាំប្រទេសបែបបុរាណដោយរត់ទៅរកជំនួយពីអ្នកជិតខាងម្ខាងទៀតគឺសៀម (ដែលជាសត្រូវប្រវត្តិសាស្ត្ររបស់យួនដែរនោះ) ។ តែខ្មែរក្រហមមិនចង់ធ្វើដូចនោះទេ ។ ផ្ទុយទៅវិញ នៅពេលដែលខ្មែរក្រហមប្រឈមមុខនឹងយួននៅទិសខាងកើត ពួកគេក៏ច្បៀតវាយសៀមនៅទិសខាងលិចដែរ ។

នយោបាយការបរទេសខ្មែរពីឆ្នាំ១៩៧៥ដល់១៩៧៨ មិនមែនសុទ្ធតែទាស់នឹងគេឯងគ្រប់គ្នានោះទេ គឺថាមានទំនាក់ទំនងទូតធម្មតានឹងប្រទេសឯទៀតខ្លះដែរ ។ ប៉ុន្តែទិដ្ឋភាពមិនប្រក្រតីនៃនយោបាយក្រៅប្រទេសរបស់ខ្មែរឥតមានន័យអ្វីទាំងអស់ទាក់ទងនឹងវប្បធម៌នយោបាយបដិវត្តរបស់ខ្មែរក្រហម ។

## ២_វប្បធម៌នយោបាយបដិវត្តនិងនយោបាយខ្មែរក្រហម៖

ក្រោយពីដណ្តើមយកអំណាចបានភ្លាមនៅខែមេសា១៩៧៥ ខ្មែរក្រហមបានចាប់ផ្តើមអនុវត្ត **បដិវត្តន៍ជ្រុលនិយម** និងសាហាវឃោរឃៅជាងប្រទេសកុម្មុយនិស្តឯទៀតដែលមានក្នុងប្រវត្តិសាស្ត្រ ។ ពួកគេបានចាប់បណ្តេញប្រជាជនចេញពីទីក្រុងតូចធំទាំងឡាយនៃកម្ពុជាភ្លាមមួយរំពេច ។ ជនាទុជនក្មេងចាស់ប្រុសស្រីត្រូវគេភ្ជង់កាំភ្លើងបង្ខំឲ្យចាកចេញពីលំនៅដ្ឋាន ធ្វើដំណើរផ្សងព្រេងទៅទីជនបទ ដើម្បីកសាងជីវិតថ្មី ក្នុងឋានៈជាប្រជាជនឈ្លើយសង្គ្រាម ។ ព្រមពេលជាមួយគ្នានោះដែរ ខ្មែរក្រហមប្រមូលខ្មែរទាំងអស់ណាដែលជាពលទាហាន និងមន្ត្រីរដ្ឋការចាស់ៗយកទៅសម្លាប់ចោលទាំងហ្វូងៗ ។ ឯចំណែកអតីតៈនាយទាហាន ព្រមទាំងគ្រួសារនិងកូនតូចតាចផង ក៏ត្រូវគេប្រហារជីវិតបង់ដែរ ។

របបថ្មីបានរំលាយសាសនា កម្ទេចវត្តអារាម និងបង្ខំព្រះសង្ឃឲ្យសឹកចាកសិក្ខាបទ ។ ជនជាតិភាគតិចខ្មែរឥស្លាមត្រូវគេធ្វើទុក្ខបុកម្នេញ បំបែកឲ្យរស់នៅផ្សេងគ្នា បង្ខំឲ្យប្តូរសម្លៀកបំពាក់ និងប្តូររបៀបទទួលទាន ។

មួយឆ្នាំឬពីរឆ្នាំក្រោយមក ខ្មែរកុម.ចាប់ស្រាវជ្រាវរកអ្នកចេះដឹងថ្នាក់វិទ្យាល័យឬថ្នាក់ខ្ពស់ជាងនេះ ។ ពួកបញ្ញវន្តទាំងនេះ តំបន់ខ្លះត្រូវបានគេឃុំឃាំងក្នុងមន្ទីរកសាង តំបន់ខ្លះទៀតត្រូវគេសម្លាប់ចោលផ្តាច់ពូជ ។

សកម្មភាពសេដ្ឋកិច្ចភាគច្រើនបានស្ថិតនៅក្នុងបែបជាកសិកម្មរួម ។ របបបានបំផ្លាញចោលនូវចនាសម្ពន្ធគ្រួសារតាមរយៈការងារនិងការសម្រាក ហើយតម្រូវឱ្យមានការទទួលទានអាហាររួមគ្នា ។ កុមារចាប់ពីប្រាំមួយឆ្នាំឡើងទៅត្រូវបំបែកចេញឱ្យទៅធ្វើការនិងដេកឆ្ងាយពីឪពុកម្តាយ ។ ការរួមភេទមុនរៀបការនិងការផឹកស្រាត្រូវមានទោសប្រហារជីវិត ។ ការចាយលុយត្រូវបំបាត់ចោល ។ កម្ពុជាបានក្លាយទៅជាសង្គមទាសករមួយដែលគ្មានអាហារគ្រប់គ្រាន់ ហើយដែលប្រជាជនធ្វើការពីដប់ទៅដប់បួនម៉ោងក្នុងមួយថ្ងៃ ។

នៅក្នុងការដឹកនាំប្រទេស ខ្មែរក្រហមបានចម្លងយកទាំងស្រុងតាមគំនិតម៉ៅសេទុងនៃប្រទេសចិន ។ យើងគួររំលឹកឡើងវិញនូវការឆ្លើយតបរបស់មេខ្មែរក្រហម នៅពេលមរណៈភាពរបស់ម៉ៅនៅឆ្នាំ១៩៧៦ ។ នៅ ថ្ងៃ១៨ កញ្ញា១៩៧៦ នៅភ្នំពេញមានធ្វើពិធីកាន់ទុក្ខខ្មោចម៉ៅសេទុង ដែលនៅពេលនោះប៉ុលពតបានអាន បសំសកថា *(សេចក្តីថ្លែងទុក្ខនៅពេលមរណៈភាព)* រៀបរាប់អំពីការគាំទ្រទាំងខាងសម្ភារៈនិងទាំងខាងផ្លូវចិត្តរបស់ម៉ៅសេទុងចំពោះបដិវត្តកម្ពុជា ។ នៅក្នុងពិធីជប់លៀងមួយនៅប៉េកាំង ថ្ងៃ២៨កញ្ញា១៩៧៧ ប៉ុលពតបាននិយាយថា **គំនិតម៉ៅជាគំរូនៃមាគ៌ានយោបាយរបស់របបគាត់** ។ សូម្បីតែនៅចុងឆ្នាំ១៩៨៧ក៏ដោយ ក្រោយពេលដែលខ្មែរក្រហមមិនព្រមទទួលស្គាល់កំហុសដែលខ្លួនបានប្រព្រឹត្ត និងក្រោយពេលដែលខ្លួនទម្លាក់ចោលគំនិតម៉ាក់ឡេនីនក្នុងផែនការនាអនាគត ក៏មេខ្មែរក្រហមជាន់ខ្ពស់ អៀងសារី បានប្រកាសជាចំហនូវការកោតស្ញប់ស្ញែងរបស់គាត់ចំពោះម៉ៅ សេទុង ។

កម្មវិធីរបស់ប្រធានម៉ៅដែលមានឥទ្ធិពលខ្លាំងជាងគេទៅលើខ្មែរក្រហមគឺ ជំហានមហាលោតផ្លោះ និងមហាបដិវត្តវប្បធម៌វណ្ណៈអធន ។ សីហនុមានជំនឿថា បដិវត្តវប្បធម៌របស់ម៉ៅមានឥទ្ធិពលពិសេសទៅលើមាគ៌ាដឹកនាំរបស់ខ្មែរក្រហមទាំងស្រុង ។ តួយ៉ាងដូចជាឥទ្ធិពល **មហាលោតផ្លោះ** យើងមានភស្តុតាងរបស់ប.ក.ក. បញ្ជាក់ថាៈ "យើងជឿជាក់ថា យើងអាចកសាងប្រទេសបានយ៉ាងចាប់រហ័ស...ដោយគ្រាន់តែរៀបចំយុទ្ធសាស្ត្រនិងយុទ្ធវិធីណាដែលចាំបាច់ប៉ុណ្ណោះ ហើយវិធីនោះគឺ **កម្មវិធីមហាលោតផ្លោះមហាអស្ចារ្យ**នេះឯង ។ មហាលោតផ្លោះមហាអស្ចារ្យមានន័យជាក់លាក់ច្បាស់លាស់" ។ តាមអត្ថបទដកស្រង់ចេញពីឯកសាររបស់បក្សនេះ យើងឃើញថាខ្មែរក្រហមបានធ្វើហួសគំនិតម៉ៅ ។ យើងក៏បានឃើញផងដែរថា ខ្មែរក្រហមមានបំណងចង់ធ្វើបដិវត្តរបស់ខ្លួនឱ្យបានលើសម៉ៅសេទុងនិងលើសចិនកុម្មុយនិស្តទៅទៀត ។ ដូចក្នុងឯកសាររបស់បក្សមួយទៀតចែងថាៈ "សង្គមនិ-

យមរបស់យើងមានលក្ខណៈពិសេសរបស់វា គឺល្បឿន...បើប្រៀបធៀបនឹងប្រទេសដទៃទៀត យើងមានវិធីសាស្ត្រលឿនជាអតិបរមា" ។

ការជម្លៀសប្រជាជនចេញពីទីក្រុង, ការសម្លាប់អតីតៈអ្នករដ្ឋការ នាយទាហាននិងបញ្ញវ័ន្ត, ការបង្កើតភូមិសហករណ៍ភ្លាមៗ, និងការប្រមាថដោយចំមុខទៅលើសាសនានិងជំនឿបុគ្គល គឺជាការអនុវត្តន៍និងជាការពង្រីកមនោគមន៍វិជ្ជាម៉ៅឲ្យឡើងដល់កំរិតធ្ងន់ផុតលេខ ។ នៅក្នុងន័យនេះ គេគួរសន្និដ្ឋានថា វប្បធម៌នយោបាយខ្មែរក្រហម ជាវប្បធម៌ **ម៉ៅនិយមហួសហេតុ** (Hyper Maoist) ។

នៅក្នុងការកាន់អំណាចពីរឆ្នាំកន្លះដំបូង ខ្មែរក្រហមបានលាក់អត្តសញ្ញាណមិនឲ្យប្រជាជន និងពិភពលោកដឹងថាខ្លួនជាកុម្មុយនិស្ត ។ យុទ្ធសាស្ត្រនយោបាយបោកប្រាស់នេះជាលក្ខណៈនៃចលនាបដិវត្តកុម្មុយនិស្តដែលគេតែងប្រើជារឿយៗមុនពេលគេឡើងកាន់អំណាច ។ ប៉ុន្តែការបន្តប្រើយុទ្ធសាស្ត្រនេះដោយខ្មែរក្រហម ក្រោយពេលដែលខ្លួនយកបានកម្ពុជា បានបង្ហាញឲ្យឃើញយ៉ាងច្បាស់នូវមធ្យោបាយពុតត្បុតច្នុតលីលាមួយសម្រាប់ជីវិតនយោបាយ ។ ឯកសារមជ្ឈឹមបក្សមួយបញ្ជាក់អំពីបញ្ហានេះថាៈ "ស្ថានការណ៍ក្នុងប្រទេសនិងក្រៅប្រទេសមានគ្រប់គ្រាន់ហើយសំរាប់ឲ្យបក្សបង្ហាញមុខ ។ **បក្សជាមិត្ត**ទាំងឡាយបានស្នើឲ្យបក្សយើងបើកមុខ ។ គេឃើញសភាពការណ៍នេះ ជាសភាពការណ៍មួយដែលយើងត្រូវតែចេញមុខ ។ម្យ៉ាងទៀត គេទាំងឡាយត្រូវការជំនួយរបស់យើង ។ "

ត្រង់ពាក្យថា **បក្សជាមិត្ត** ខ្មែរក្រហមទំនងជាដៅទៅលើចិនដីគោកនិងកូរ៉េខាងជើង ។ បើដូច្នោះមែនការដែលគេអះអាងថាមហាអំណាចកុម្មុយនិស្តត្រូវការជំនួយរបស់គេនោះគឺជាការអួតអាងលើកកម្ពស់មួយ **បែបឡប់សតិ** ។ ឯកសារដដែលនោះក៏បានប្រាប់ឲ្យដឹងផងដែរអំពីការព្រួយបារម្ភរបស់មេខ្មែរក្រហមចំពោះសត្រូវលាក់មុខទាំងនោះៈ "ខ្មាំងចង់ឲ្យយើងលេចមុខស្រណុកគេតាមសង្កេតយើង ដើម្បីគេអាចសម្រេចនូវគោលដៅរយៈពេលវែងរបស់គេ ។ "

មិនយូរប៉ុន្មាន នៅថ្ងៃ២៧កញ្ញា១៩៧៧ អង្គការបានប្រកាសថាគឺអង្គការបដិវត្តនេះហើយជាបក្សកុម្មុយនិស្តកម្ពុជា ។ បន្ទាប់ពីបានបង្ហាញមុខប.ក.ក.រួចភ្លាមមក ប៉ុលពតបានធ្វើទស្សនកិច្ចជាផ្លូវការលើកទីមួយទៅប្រទេសចិន និងកូរ៉េខាងជើងដែលបង្ហាញនូវភាពម្ចាស់ការខ្លួនទីពីរខ្លួន ពីខាងភាគីមេដឹកនាំកុម្មុយនិស្តកម្ពុជា ក្នុងក្តីសង្ឃឹមទុកជាមុនដោយឥតសង្ស័យថានឹងចងសម្ពន្ធមិត្តជាមួយនឹងមហាមិត្តអាស៊ីរបស់គេ ។

តាមឯកសារបក្ស នៅពេលនោះពួកខ្មែរកុម.ហាក់ដូចជាមានទំនុកទុកចិត្តទៅលើការក្តាប់អំណាចរបស់

គេ ។ គេទុកចិត្តត្រង់ថា គេបានសម្លាប់ឬដាក់គុកពួកមេខ្មែរក្រហមមួយទិស្តជំនាន់ចាស់អស់ជាច្រើន ហើយនិងបានបំភ័យបំបាក់ស្មារតីប្រជាជនខ្មែររួចទៅហើយ ។ បើទោះជាមានទំនុកចិត្តបែបបន្ទំនេះក្តី ខ្មែរក្រហមបានបង្ហាញឲ្យឃើញនូវការព្រួយបារម្ភពីរទៀតដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក ។

ព្រួយទីមួយ គឺអ្នកជិតខាងនៅខាងលិច និងអ្នកជិតខាងនៅខាងកើត (សៀមនិងយួន) ។ តាមឯកសារមួយចុះខែសីហា១៩៧៦ ប.ព.បានអះអាងថា ពួកអ្នកជិតខាងទាំងនេះបានវាយប្រហារនិងធ្វើទារុណកម្មកម្ពុជា ។ ដូច្នេះ ល្បឿននៃបដិវត្តសង្គមនិយមអាចនឹងធ្វើកម្ពុជាឲ្យខ្លាំងឡើងបានៈ

**"ហេតុអ្វីបានជាយើងត្រូវតែប្រញាប់រូតរះ ? ពីព្រោះខ្មាំងវាយយើងនិងធ្វើទុក្ខបុកម្នេញយើង ។ ពីខាងលិចនិងពីខាងកើត ពួកវាព្យាយាមបុករុករំខានយើង ។ នេះហើយជាកលល្បិចរបស់វា...។ បើយើងមិនរូតរះ បើយើងខ្សោយ អាខ្មាំងទិសខាងលិចវាក៏នឹងប្រមាថយើងដែរ ។ តែបើយើងខ្លាំង ហើយមានសេចក្តីអង់អាចក្លាហានតែ មួយ ពីរ បី ឬបួនឆ្នាំ អាខ្មាំងខាងកើតនិងខាងលិចនឹងមិនអាចធ្វើអ្វីយើងកើតឡើយ។"**

ប.ព.យល់ថា ដើម្បីឈានឡើងសង្គមនិយមឲ្យបានចាប់រហ័ស គេត្រូវសម្លាប់ប្រជាជនរាប់រយពាន់នាក់ត្រូវរំលាយកម្ទេចវប្បធម៌និងស្ថាប័នប្រពៃណី បង្កើតវណ្ណៈទីពីរ គឺប្រជាជនថ្មី ដែលអាចធ្វើឲ្យផ្ទៃក្នុងរបស់កម្ពុជាខ្លាំង អាចទប់ទល់នឹងសត្រូវពីខាងក្រៅបាន ។ ការយល់បែបនេះគឺជួយស្រឡះនឹងភាពប្រាកដនិយម ដែលជាលទ្ធផលនៃវិបល្លាសខាងផ្លូវចិត្ត និងការប៉ាន់ខុសនៃមនោគមន៍វិជ្ជា ។

លើសពីនោះទៅទៀត ប.ព.ពោលថា យួននិងសៀមតែងតែវាយប្រហារនិងធ្វើបាបខ្មែរយ៉ាងសកម្ម ។ការនិយាយថាយួននិងសៀមរករឿងប្រទូសរ៉ាយនោះ មានភស្តុតាងតិចតួចណាស់ដែលបញ្ជាក់រឿងនេះ ។ បើប.ព.ចោទដូច្នោះ ហើយខ្លួនគ្មានការពន្យល់ឲ្យបានក្បោះក្បាយ ការពោលអះអាងរបស់គាត់គឺស្ទើរតែជាការបោកប្រាស់ទាំងស្រុង ។

ជាការពិតហើយ ខ្មែរក្រហមត្រូវតែមានហេតុត្រឹមត្រូវដើម្បីលែងទុកចិត្តមិត្តចាស់ខាងកើតរបស់គេ ។ ដូចយើងបានរៀបរាប់រួចមកហើយថា យួនបានកែប្រែយុទ្ធសាស្ត្រក្នុងការក្តាប់ខ្មែរ ដោយបានបញ្ចូលទៅក្នុង ប.ក.ក.នូវមនុស្សដែលគេបានហ្វឹកហ្វឺននិងបានលាងខួរ ។ ក្នុងករណីប្រទេសកម្ពុជា គឺពួកខ្មែរវ.ម.នេះឯងដែលហាណូយបានចាត់ទុកថាជាភ្នាក់ងាររបស់គេ ។ ដូច្នេះ មេខ្មែរក្រហមត្រូវប្រឈមមុខទល់នឹងការគំរាមកំហែងស្របច្បាប់ពីហាណូយមកលើស្វ័យភាពរបស់ខ្លួន ។តែដោយ ប.ព.និងបក្សពួកដឹងនូវល្បិចនេះមុន គេក៏បានចាត់ឲ្យចាប់

ពួកខ្មែរវ.ម.ក្លាមនៅពេលដែលគេត្រឡប់មកពីហាណូយវិញជាមួយកងទ័ពវ.ខ.ជ.នៅដើមឆ្នាំ១៩៧០ និងម្តងទៀតក្រោយថ្ងៃជ័យជំនះឆ្នាំ១៩៧៥ ។ ប៉ុណ្ណោះហើយ ប.ព.និងដៃដើងនៅតែមិនអស់ចិត្ត ចេះតែសង្ស័យថាភ្នាក់ងារយួនហាណូយនៅពួនលាក់ខ្លួនក្នុងបក្សជានិច្ច ។

ការភ័យព្រួយទីពីរ គឺខ្មាំងផ្ទៃក្នុង ។ ចាប់ពីខែធ្នូ១៩៧៦មក មេដឹកនាំបក្សនិយាយឥតឈប់ឈរអំពីរឿងនេះ ។ ដូចជា: "យើងគួរសួរថា **តើខ្មោចក្បត់បង្កប់នៅក្នុងបក្សអស់ហើយ ឬនៅ** ? បើតាមការសង្កេតរបស់យើងក្នុងរយៈពេលដប់ឆ្នាំចុងក្រោយនេះ ច្បាស់ណាស់ថាខ្មាំងនៅដដែល... ។ ពួកក្បត់នៅតែបន្តសកម្មភាពពីគ្រប់ទិសទី" ។

របាយការណ៍បានបន្តព្រមានថា: "មេរោគលាក់ខ្លួននៅក្នុងបក្សក្នុងសម័យបដិវត្តន៍ប្រជាជននិងប្រជាធិបតេយ្យនាឆ្នាំ១៩៦០និងដើមឆ្នាំ១៩៧០ ។ តែទោះជាយ៉ាងណាក៏ដោយ មាគ៌ាដឹកនាំបក្សទុកចិត្តថា ដោយបដិវត្តន៍សង្គមនិយមមានការចំរើនជឿនលឿន បក្សយើងអាចរកមេរោគចង្រៃឃើញ ហើយយើងនឹងបំផ្លាញវាចោលទៅតាមធម្មជាតិពិតនៃបដិវត្តន៍សង្គមនិយម" ។

ខ្មែរក្រហមបានចាប់ផ្តើមបោសសំអាតផ្ទៃក្នុងនៅចុងឆ្នាំ១៩៧៦និង១៩៧៧ ។ ការបោសសម្អាតទំនងជាចាប់ផ្តើមពីថ្នាក់ដឹកនាំប.ក.ក.ទៅមុន ។ នៅពីរខែដំបូងនៃឆ្នាំ១៩៧៧ ចៅហ្វាយខេត្តភាគខាងលិចបួននាក់ត្រូវគេសម្លាប់ ហើយស្នងការរបស់គេត្រូវចាប់ខ្លួនបញ្ជូនទៅកន្លែងគ្មានដំណឹង ។ បើតាមមន្ត្រីយោធាថៃម្នាក់បានឲ្យដឹងថាការបោសសម្អាតនេះបណ្តាលមកពីការប៉ុនប៉ងធ្វើរដ្ឋប្រហាររបស់ភូមិភាគពាយព្យ ។

ការកាប់សម្លាប់យ៉ាងលឿនរហ័សគួរឲ្យរន្ធត់នេះ បានត្រូវគេកត់ត្រាទុករៀងរាល់ឆ្នាំនៅមន្ទីរសួរចម្លើយនិងធ្វើទារុណកម្មទួលស្លែង ។ ទីនោះ គ្រាន់តែបង្ហាញមួយផ្នែកតូចនៃអំពើកាប់សម្លាប់របស់ខ្មែរក្រហមប៉ុណ្ណោះ ប៉ុន្តែវាក៏បានធ្វើឲ្យឃើញផងដែរនូវទំហំនៃអំពើព្រៃផ្សៃដែលប.ព.បានប្រចាំងនឹងរបបរបស់ខ្លួន ។ ឆ្នាំ១៩៧៥ គុកទួលស្លែងមានអ្នកទោស២០០នាក់, ១៩៧៦មាន២២៥០នាក់, ១៩៧៧មានជាង៦០០០នាក់, និងឆ្នាំ១៩៧៨មានជិត១ម៉ឺននាក់ ។ មនុស្សទាំងនោះត្រូវគេចោទប្រកាន់ថាជាខ្មាំង និងត្រូវគេធ្វើទារុណកម្ម បង្ខំឲ្យឆ្លើយសារភាពជាលាយលក្ខណ៍អក្សរថាខ្លួនបានក្បត់បក្សឬក្បត់ជាតិ ។ ដូចរបបកុម្មុយនិស្តខ្លះ មានសូវៀតរបស់ស្តាលីន និងចិនរបស់ម៉ៅជាដើម ជនរងគ្រោះខ្លះជាមន្ត្រីជាន់ខ្ពស់របស់បក្ស ហើយខ្លះថែមទាំងជាមិត្តផ្ទាល់របស់ប.ព.ទៀតផង ។ ដូចឧទាហរណ៍នៅសហភាពសូវៀតឬនៅចិនដែរ ជនរងគ្រោះទាំងនោះភាគច្រើនសុទ្ធតែឆ្លើយសារភាពតាមការបង្ខិតបង្ខំ ។ ចំណែកនៅឆ្នាំ១៩៧៧ អ្នកទោសសុទ្ធតែត្រូវគេចោទដោយឥតទំនងពីបទថា ជាភ្នាក់ងារយួនឬ

ភ្នាក់ងារ សេអ៊ីអា ។ យោងតាមរបាយការណ៍ក្រសួងសន្តិសុខកម្ពុជាប្រជាធិបតេយ្យ (ក.ប.) ផែនការក្បត់ប្រឆាំងនឹងបដិវត្តន៍កម្ពុជាគឺបណ្តាលមកពីការឃុបឃិតសមគំនិតគ្នារវាងសូវៀត អាមេរិកាំង ថៃ និងវៀតណាម ។

គំរោងផែនការដ៏អស្ចារ្យនេះដែលបានរៀបចំគ្រោងទុកយ៉ាងហ្មត់ចត់ និងសហការគ្នាយ៉ាងជិតស្និទ្ធជាលើកដំបូងដើម្បីបំផ្លាញក.ប. គឺជាឧទាហរណ៍គំរូនៃការកសាង"សហគមន៍ប្រប្លូកប្របល់មួយ" ។

គំនិតនយោបាយការបរទេសរបស់ខ្មែរក្រហម ត្រូវបានទទួលឥទ្ធិពលខ្លះដែរពីភាពក្រពុលមុខនៃមេដឹកនាំរបស់ខ្លួន ។ តែមួយភាគធំត្រូវបានបំពាក់បំប៉នដោយទ្រឹស្តីមនោគមន៍វិជ្ជាត្រឹមត្រូវ ។ ដូចយើងបានឃើញហើយនៅក្នុងនយោបាយក្នុងស្រុក **ផ្នែកអនុវត្ត** ខ្មែរក្រហមបានប្រព្រឹត្តជ្រុលហួសព្រំដែនចំពោះការប្រតិបត្តិមនោគមន៍វិជ្ជាម៉ៅសេទុង ។ ឯ**ផ្នែកទ្រឹស្តីវិញ** ក្នុងនយោបាយក្រៅស្រុក ខ្មែរក្រហមបានឱបក្រសោបយកទស្សនៈមនោគមន៍វិជ្ជាពីររបស់ម៉ៅ ។ **ទីមួយគឺទ្រឹស្តីខ្លួនទីពឹងខ្លួន** ។ ខុសពីអ្នកដឹកនាំមុនៗ វិទ្យុក.ប.ភ្នំពេញបានបញ្ជាក់ថា "គ្មាននរណាមួយរស់នៅយ៉ាងអាម៉ាស់ដោយការសុំទានដូចពួកបនលន់ណុលទេ... ។ ខុសពីពួកក្បត់សាធារណរដ្ឋទាំងស្រុងកម្ពុជាថ្មីឥឡូវនេះមានសមត្ថភាពនឹងឧបត្ថម្ភខ្លួនឯងបាន" ។

ទ្រឹស្តីនេះត្រូវបានគេលើកតម្កើង និងត្រូវបានបញ្ចូលទៅក្នុងឯកសារបក្សទៀតផង:

**"យើងគ្មានជំនួយពីបរទេសខាងផ្នែកឧស្សាហកម្មនិងកសិកម្មទេ...។ និយាយជាទូទៅ ប្រទេសសង្គមនិយមឯទៀតបានទទួលជំនួយបរទេសសន្ធឹកសន្ធាប់ណាស់ក្រោយពេលរំដោះ ។ ពេលនេះ យើងបានជំនួយតិចតួចប៉ុណ្ណោះពីចិន តែមិនជាក្រាស់ក្រែលទេបើប្រៀបធៀបនឹងប្រទេសឯទៀត ។ នេះជានយោបាយបក្សយើង ។ បើយើងដើរសុំទានគេវាបានខ្លះមែន តែវានឹងប៉ះពាល់ដល់មាគ៌ានយោបាយយើង ។"**

**ទ្រឹស្តីទីពីរ**របស់ម៉ៅ គឺជាអាទិភាព **កត្តាជំនឿនៃឆន្ទៈមនុស្ស** និងភាពបរិសុទ្ធនៃមនោគមន៍វិជ្ជា ដើម្បីយកជ័យជំនះលើ **កត្តាសម្ភារៈ** ។ ជាសាធារណៈ ខ្មែរក្រហមនិយាយថា: "មហាជោគជ័យរបស់បដិវត្តន៍កម្ពុជាដែលមានមូលដ្ឋានឈរលើសម្បជញ្ញៈនយោបាយនិងសីលធម៌បដិវត្ត ជាសក្ខីភាពដែលមិនអាចប្រកែកបានថា កត្តាមនុស្ស គឺជា **កត្តាគន្លឹះ** ឯកត្តាសម្ភារៈគ្រាន់តែជា កត្តាបន្ទាប់បន្សំ ប៉ុណ្ណោះ" ។

សារៈសំខាន់នៃកត្តាមនុស្សខាងផ្នែកកម្លាំងនិងជោគជ័យនយោបាយឬយោធា ក៏ត្រូវបានបញ្ជាក់នៅក្នុងឯកសារផ្ទៃក្នុងរបស់បក្សដែរ ។ ដូចជានៅពាក់កណ្តាលឆ្នាំ១៩៧៦ ឯកសារចែងថា: "បញ្ហាកទេសមិនមែនជាកត្តាផ្តាច់ព្រាត់ទេ, កត្តាផ្តាច់ព្រាត់របស់បដិវត្តន៍គឺ *នយោបាយបដិវត្តប្រជាជន និងបដិវត្តវិធីសាស្ត្រ*" ។

ជាថ្មីម្តងទៀត ទិនានុប្បវត្តិរបស់បក្សឈ្មោះ **ទង់បដិវត្ត**ចេញខែមិថុនា១៩៧៦ បានធ្វើវិភាគអំពីការ

គស៊ូជាបន្តរវាងបដិវត្តន៍ និងប្រតិបដិវត្តន៍ (ប្រឆាំងបដិវត្តន៍) ដែលមានសេចក្ដីថាៈ

**"តើខ្លាំងខ្លាំងឬខ្សោយ ? បញ្ហានេះមិនមែននៅលើគេទេ គឺនៅលើយើង ។ បើយើងប្តេជ្ញាជាប្រៀវិធានការដាច់ខាត ខ្លាំងនឹងដកថយ ។ ពួកគេនឹងបែកខ្ញាត់ខ្ញាយ និងត្រូវកម្ទេចជាដុំតូចៗ ។ ពេលណាយើងខ្លាំង ខ្លាំងចុះខ្សោយ ។ ពេលណាយើងខ្សោយ ខ្លាំងខ្លាំងវិញ ។ យើងខ្លាំងមានន័យថា យើងមានទស្សនៈត្រឹមត្រូវ និងអនុវត្តនូវវិធានការនយោបាយនិងយោធាសមស្រប ។"**

## ៣_អនុវត្តន៍គោលការណ៍"ខ្លួនទីពឹងខ្លួន":ការទូតនិងពាណិជ្ជកម្មក្រៅប្រទេស

ក្នុងលំនាំទូទៅនៃទំនាក់ទំនងផ្លូវទូត នយោបាយក្រៅប្រទេសរបស់ក.ប.ហាក់ដូចជាបានអនុវត្ត **ការស្អប់បរទេស**តាមគំរូបដិវត្តន៍វប្បធម៌របស់ម៉ៅ ។ គ្រាន់តែក្រោយពេលគេដណ្ដើមអំណាចបានភ្លាម គេបានបណ្ដេញពួកបញ្ញើមប្រទេសនិងអ្នកការទូតស្ទើរតែគ្រប់ប្រទេសចេញមួយរំពេច ។ មកដល់ដើមឆ្នាំ១៩៧៨ នៅភ្នំពេញមានតែស្ថានទូតចិន កូរ៉េខាងជើង អាល់បានី យូហ្គោស្លាវី លាវ និងអេហ្ស៊ីបប៉ុណ្ណោះ ។ ចំណែកពពួកប្រទេសដែលជាសមាជិកនៃកតិកាសញ្ញា Warsawវិញ មិនត្រូវបានទទួលស្គាល់ដោយរបបថ្មីនេះទេ លើកលែងតែប្រទេសរូម៉ានីមួយប៉ុណ្ណោះ ដោយហេតុថាសហភាពសូវៀតចង់ភ្ជាប់ទំនាក់ទំនងធម្មតាជាមួយក.ប. ។

អ្នកការទូតបរទេសដែលមានទីតាំងនៅភ្នំពេញ ត្រូវស្ថិតនៅក្រោមការឃ្លាំមើលយ៉ាងល្អិតល្អន់ ដោយអនុញ្ញាតឲ្យមានការទាក់ទងគ្នាបន្តិចបន្តួច ហើយនិង **គ្មានការទាក់ទងទាល់តែសោះជាមួយនឹងប្រជាជនខ្មែរ** ។ គេទាំងឡាយរស់នៅក្នុងប្រទេសមួយដែលបិទស្ទើរតែជិតឈឹង ។

ក្នុងរយៈពេលមួយឆ្នាំកន្លះក្រោយពីកាន់អំណាច រដ្ឋាភិបាលក.ប.មិនបានធ្វើពាណិជ្ជកម្មជាមួយបរទេសណាទេ តែអាចជាមានធ្វើជាមួយចិននិងកូរ៉េខាងជើង (បើទោះសេចក្ដីពិស្ដាអំពីរឿងនេះជារឿងសម្ងាត់ក៏ដោយ) ។ ថ្នាក់ដឹកនាំប.ក.ក.យោងទៅលើហេតុនោះថាជា នយោបាយ"ខ្លួនទីពឹងខ្លួន" ។

នៅដើមឆ្នាំ១៩៧៦ មេដឹកនាំខ្មែរក្រហមចាប់ពង្រីកទំនាក់ទំនងផ្លូវទូតជាមួយប្រទេសមិនមែនកុម្មុយនិស្តដែលរីកចំរើនក្នុងពិភពលោក ។ ថ្ងៃ២៣មេសា ភ្ជាប់ជាមួយប្រទេសមិនចូលបក្សសម្ព័ន្ធ ប៉េរូ និងថ្ងៃ២៨មេសាជាមួយនឹងប្រទេសសេរី ម៉ាឡេស៊ី ។ នៅពាក់កណ្ដាលខែឧសភាប្រទេសជាសមាជិកទាំងអស់នៃសមាគមប្រជាជាតិអាស៊ីអគ្នេយ៍ (ASEAN) លើកលែងតែឥណ្ឌូណេស៊ីមួយចេញ បានដាក់ទូតជាមួយក.ប. ។ ការប្រកែករបស់ឥណ្ឌូណេស៊ីប្រហែលបណ្ដាលមកពីប្រទេសនេះមិនទុកចិត្តចិនដែលជាចៅហ្វាយរបស់ខ្មែរក្រហម ។ មូលហេតុដែលសំខាន់ជាងនេះទៅទៀតគឺ ក.ប.គាំទ្រសាធារណរដ្ឋប្រជាធិបតេយ្យទីម័រខាងកើត (EastTimor).

វាជាការច្បាស់ណាស់ដែលថាខ្មែរក្រហមមានបំណងផ្តាច់ប្រជាជនរបស់ខ្លួនឱ្យនៅឆ្ងាយពីពិភពលោក ។ ពួកគេខំខ្នះខ្នែងយ៉ាងអស់សង្ឃឹមរកការទទួលស្គាល់របបរបស់ខ្លួនពីប្រទេសនានា ជាពិសេសប្រទេសតតិយលោក។ បំណងរបស់គេគឺដើម្បីគាំទ្រខាងផ្លូវនយោបាយដែលមានភាពតឹងតែងកាន់តែខ្លាំងឡើងៗនៅក្នុងជម្លោះជាមួយយួន កុម. ថ្វីបើជម្លោះនោះស្ថិតនៅក្នុងភាពបិទបាំងខ្លះក៏ដោយ ។

ថ្ងៃ៣មករា១៩៧៧ ក.ប.បានភ្ជាប់ទូតជាមួយប្រទេសហុល្លង់ (Netherlands) ។ នៅចុងខែមករា គណៈប្រតិភូសេដ្ឋកិច្ចមួយរបស់យូហ្គោស្លាវីបានមកទស្សនាកម្ពុជា ។ ប្រទេសទាំងពីរបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហការគ្នាមួយខាងផ្នែកសេដ្ឋកិច្ចនិងពាណិជ្ជកម្ម ហើយបានប្រកាសថា យូហ្គោស្លាវីនឹងផ្តល់ជំនួយជាគ្រឿងបរិក្ខាកសិកម្មដល់ក.ប.។ ខែកុម្ភៈ រដ្ឋមន្ត្រីក្រសួងការបរទេស អៀងសារី បានដឹកនាំគណៈប្រតិភូមួយទៅប្រទេសភូមា ។ នៅចុងខែនោះគាត់បានទស្សនាប្រទេសម៉ាឡេស៊ី និងបានពិភាក្សាអំពីអនាគតទំនាក់ទំនងសេដ្ឋកិច្ចនៃប្រទេសទាំងពីរផង ។ រដ្ឋមន្ត្រីការបរទេសម៉ាឡេស៊ីបានសន្យាថា នឹងជួយកសាងកម្ពុជាជាថ្មីឡើងវិញ ។

ការផុះឡើងនៃនយោបាយជំនួញក្រៅប្រទេសបានឆ្លុះបញ្ចាំងឱ្យឃើញនូវគម្លាតឆ្ងាយនៃឧត្តមគតិខ្លួនទីពឹងខ្លួន ។ នៅខែតុលា១៩៧៦ រដ្ឋាភិបាលក.ប.បានបង្កើតអគារពាណិជ្ជកម្មមួយនៅហុងកុង ដើម្បីពង្រីកជំនួញក្រៅប្រទេស ។ ទំនិញនាំចូលពីប្រទេសជប៉ុនមាន ដែកថែបប្រហែល១ម៉ឺនតោន វាយនភណ្ឌ យានជំនិះ ផលិតផលគីមី និងគ្រឿងសំណង់ ។ ពីហុងកុង ក.ប.បាននាំចូលទំនិញតម្លៃរាប់លានដុល្លា ជាពិសេសជាតិគីមី វាយនភណ្ឌ ដែកនិងដែកថែបបរិក្ខាពេទ្យនិងថ្នាំពេទ្យ ថ្នាំសត្វឃាត ប្រេងឥន្ធនៈនិងបរិក្ខាដឹកជញ្ជូន ។ ក.ប.ត្រូវគេជឿថាបានសងបំណុលចិន មួយផ្នែកតាមការដឹកស្រូវ (មួយចំនួនដែលគេមិនដឹង) កៅស៊ូ និងម្រេចទៅឱ្យចិន កូរ៉េខាងជើងនិងលាវ ។ ប៉ុន្តែទំនិញនាំចូលពីជប៉ុននិងហុងកុង ត្រូវចិនចេញលុយឱ្យ ទំនងជាប្រាក់២០លានដុល្លាដែលចិនបានឱ្យកាលពីឆ្នាំ១៩៧៥ ។ ពាណិជ្ជកម្មក្រៅប្រទេសនេះបើប្រៀបធៀបទៅមានទំហំតូចហួស ។ ដូច្នេះដោយមានការពឹងផ្អែកមួយភាគទៅលើជំនួយសេដ្ឋកិច្ចចិន និងការនាំចូលនូវគ្រឿងបរិក្ខានិងឱសថ ក.ប.មិនបានអនុវត្តទាំងស្រុងនូវមាគ៌ា **ខ្លួនទីពឹងខ្លួន**ឡើយ ឯសេដ្ឋកិច្ចសោតក៏ជាសេដ្ឋកិច្ចឥតត្រីវិស័យ ។ ម្យ៉ាងទៀត នៅក្នុងចំណងមិត្តភាពខាងផ្លូវទូតក្តីឬខាងសេដ្ឋកិច្ចក្រៅប្រទេសក្តី ក្នុងកំឡុងពេលខ្មែរក្រហមកាន់អំណាចបីឆ្នាំកន្លះ គេមិនដែលឃើញមានស.រ.អ.នៅក្នុងនោះឡើយ ។ ការបើកផ្លូវទៅរកកិច្ចចរចាមួយដោយរដ្ឋាភិបាល **ជីមមីការទើរ** (Jimmy Carter) នៅថ្ងៃ១៤ មីនា១៩៧៧ តាមរយៈការិយាល័យសម្ពន្ធការដែលមានទីតាំងនៅប៉េកាំង បានត្រូវទាត់ចោលដោយរដ្ឋមន្ត្រីការបរទេសរបស់ ក.ប. ។

## ៤_សម្ពន្ធមិត្តកណ្តាលៈចិននិងកូរ៉េខាងជើង

បើទោះជាគេស្រែកប្រកាសអំពីគោលការណ៍"ខ្លួនទីពឹងខ្លួន"ក៏ដោយ ក៏កត្តាគន្លិះនៃនយោបាយការបរទេសរបស់ក.ប.នៅតែជាសម្ពន្ធមិត្តស្អិតរមួតរបស់សាធារណរដ្ឋប្រជាមានិតចិន(ស.ប.ច.)ដដែល ។ ក្នុងសម័យដែលម៉ៅសេទុងនៅរស់នៅឡើយ ប៉ុលពត អៀងសារី និងមេខ្មែរក្រហមជាច្រើនទៀតតែងលួចធ្វើទស្សនកិច្ចដោយស្ងាត់ៗទៅប្រទេសចិន ។ មានតែនៅខែកញ្ញា១៩៧៧ប៉ុណ្ណោះ គឺមួយឆ្នាំក្រោយមរណភាពរបស់ម៉ៅដែលប.ព.បានប្រកាសជាសាធារណៈអំពីទស្សនកិច្ចរបស់ខ្លួននៅស.ច.ប. ។ ទស្សនកិច្ចនេះត្រូវបានធ្វើឡើងមួយថ្ងៃក្រោយការប្រកាសបើកមុខជាសាធារណនៃបក្សកុម្មុយនិស្តកម្ពុជា ។

គណៈប្រតិភូខ្មែរក្រហម ដែលមានប៉ុលពត,អៀងសារី,វនវ៉េត,និងជួនជឿន ត្រូវបានទទួលអបអរដោយនាយករដ្ឋមន្រ្តីនិងប្រធានបក្ស ហួគួហ្វេង ហើយនិងមានការលាងសាយភោជន៍នៅមហាសាលប្រជាជនដែលចូលរួមដោយកូឈ្មួយបក្សកុម្មុយនិស្តចិនបួននាក់ ។ នេះជាកិត្តិយសដ៏អស្ចារ្យមួយសំរាប់ភ្ញៀវបរទេសម្នាក់ ។ មានសេចក្តីរាយការណ៍ថា ប.ព.ក៏ត្រូវបានប្រជាជនចិន១០០ពាន់នាក់ស្រែកជ័យឃោសន៍ទទួលអបអរសាទរនៅពេលធ្វើដំណើរតាមរថយន្តច្លងកាត់ទីលាន **ធានអានមិន** ផងដែរ ។

ក្រោយពេលចប់ទស្សនកិច្ចនៅប្រទេសចិន គណៈប្រតិភូក.ប.បានបន្តដំណើរទៅកូរ៉េខាងជើងដែលពួកគេបានទទួលបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅដែរក្នុងការស្នាក់នៅរយៈពេលប្រាំថ្ងៃ ។ តាមសេចក្តីជូនដំណឹងជាផ្លូវការថាការសន្ទនាគ្នារវាងសមមិត្តគិមអ៊ិលស៊ុង និងសមមិត្តប៉ុលពតបានប្រព្រឹត្តទៅក្នុង"បរិយាកាសយុទ្ធមិត្ត និងទុកចិត្តគ្នា ។ " ក្នុងពិធីបុណ្យដ៏ឱឡារិកមួយ ប.ព.បានទទួលងារជាវីរបុរសនៃ **សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ** (ស.ប.ប.ក.)ដោយមានការចូលរួមពីគិមអ៊ិលស៊ុងនៅព្យុងយ៉ាង ថ្ងៃ៧តុលា ។ ជាការពិតហើយថា រដ្ឋាភិបាលនៃស.ប.ប.ក.ជាមិត្តសំខាន់ទីពីររបស់ក.ប. ។ នៅខែវិច្ឆិកា គណៈប្រតិភូអាកាសចរណ៍ស៊ីវិលនៃស.ប.ប.ក.បានធ្វើទស្សនកិច្ចនៅកម្ពុជា ហើយពិធីការពាណិជ្ជកម្មមួយបានត្រូវចុះហត្ថលេខានៅភ្នំពេញរវាងស.ប.ប.ក.និងក.ប. ។

## ៥_ការបង្កើតរណសិរ្សទីពីរៈកម្ពុជាប្រជាធិបតេយ្យនិងថៃ

ប.ព.មានការព្រួយបារម្ភពីការគំរាមកំហែងរបស់វៀតណាម តែគេពិបាកយល់អំពីអាកប្បកិរិយារបស់ខ្មែរក្រហម (ខ.ក.) ចំពោះប្រទេសថៃ ។ ក្នុងកំឡុងឆ្នាំ១៩៧៧ យោធាខ.ក.បានធ្វើការវាយប្រហារទៅលើភូមិថៃនៅតាមព្រំដែន ។

ចុងខែមករា ទ័ពខ.ក.២០០នាក់បានវាយភូមិថៃបួន ធ្វើឱ្យស្លាប់ជនស៊ីវិលថៃ២៩នាក់ និងប៉ូលីសម្នាក់ ។

ក្រោយមក ខ.ក.បានសារភាពថាបានវាយប្រហារដូច្នោះមែន ដោយហេតុថាភូមិនោះជាដីខ្មែរ មិនមែនដីសៀមទេ ។ ការវាយប្រយុទ្ធរបស់ខ.ក.ទៅលើភូមិថៃតាមព្រំដែនកើតមានពីរដង គឺនៅខែកុម្ភៈនិងខែមេសា ។ ខែមិថុនាទាហានម៉ារីនថៃ៥នាក់ត្រូវសម្លាប់ហើយច្រើននាក់ទៀតបានធ្លាក់ចូលក្នុងការឡោមព័ទ្ធរបស់ខ.ក. ។ ខែកក្កដាក្នុងចម្បាំងមួយជាមួយខ.ក. សៀមបានប្រើរថក្រោះនិងទ័ពអាកាស ។ នៅដើមខែសីហា ទ័ពខ.ក.២០០នាក់បានវាយលុកភូមិថៃមួយ ស្លាប់អ្នកស្រុកអស់៣១នាក់ ។ បន្ទាប់ពីនោះមក នាយករដ្ឋមន្ត្រីថៃបានព្រមានថា ប្រទេសថៃនឹងប្រើសកម្មភាពយោធាប្រចាំងនឹងកម្ពុជាវិញ បើខ.ក.នៅតែបន្តការវាយប្រហារ ។ ខែតុលា ខ.ក.វាយភូមិបីនៅតំបន់អារញ្ញ ។ ថ្ងៃ២វិច្ឆិកា ទ័ពខ.ក.បានបើកការវាយលុកព្រមៗគ្នាទៅលើភូមិថៃជាង១០ទៀតតាមបណ្តោយព្រំដែនប្រវែងជាង៦៤គ.ម. ។

ការបង្ករឿងហេតុទៅលើភូមិថៃនេះ គឺគ្មានន័យអ្វីទាំងអស់ ដោយហេតុថារបបភ្នំពេញកំពុងតែមានបញ្ហាជាមួយយួន ហើយម្យ៉ាងទៀតខ្លួនកំពុងតែរកការគាំទ្រផ្លូវទូតនិងផ្លូវសេដ្ឋកិច្ចពីបណ្តាប្រទេសនានានៅក្នុងសកលលោកផង ។ មេដឹកនាំថៃខ្លះបានអះអាងថា នៅពេលនោះថ្នាក់ដឹកនាំជាន់ខ្ពស់ក.ប.មិនបាននៅពីក្រោយខ្នងការវាយប្រហារទេ ដោយគេជឿថាឧប្បត្តិហេតុនេះកើតឡើងដោយពួកខ.ក.ថ្នាក់ក្រោម ហើយគ្មានការដឹងឮពីមជ្ឈិមបក្សនៅភ្នំពេញឡើយ ។ វិទ្យុភ្នំពេញផ្សាយថា ថៃជាអ្នកផ្តើមគំនិតរករឿង ហើយអំពាវនាវឲ្យធ្វើការដោះស្រាយជម្លោះ ។ នៅថ្ងៃ១៥ធ្នូ កងទ័ពខ.ក.ជាង២០០នាក់ ដោយមានការគាំទ្រពីពួកទ័ពព្រៃកុម.ថៃផង បានវាយប្រហារទៅលើភូមិថៃពីរនៅជាប់ព្រំដែន ស្លាប់ជនជាតិថៃអស់១៦នាក់ ។ រដ្ឋមន្ត្រីការបរទេសថៃបានថ្លែងថា រដ្ឋាភិបាលថៃបានសម្រេចមិនតប_តវិញទេ ពីព្រោះ "ចង់ឲ្យមានបរិយាកាសល្អ" និងមិនចង់ឲ្យប៉ះទង្គិចដល់ការប្រព្រឹត្តិទៅនៃចំណងផ្លូវទូតជាមួយកម្ពុជាឡើយ ។ បើទោះជារដ្ឋាភិបាលថៃប៉ុនប៉ងរកសុខជាមួយគេយ៉ាងណាក៏ដោយ ថ្ងៃបន្ទាប់មក ខ.ក.បានវាយប្រហារបួនលើកទៀតទៅលើភូមិថៃ ។

## ៦_ពង្រីកចំណងមិត្តភាពនៅអាស៊ីអគ្នេយ៍:

ដោយគ្មានដំណោះស្រាយអំពីជម្លោះជាមួយថៃ ខ.ក.ព្យាយាមរឹតចំណងផ្លូវទូតជាមួយប្រទេសដទៃទៀតនៅអាស៊ីអគ្នេយ៍ ។ ចុងខែវិច្ឆិកា១៩៧៧ រដ្ឋាភិបាលក.ប.បានរៀបចំបដិសណ្ឋារកិច្ចចំនួនបីថ្ងៃទទួលប្រធានាធិបតីភូមា ណេវិន, ទស្សនកិច្ចនៃប្រមុខរដ្ឋបរទេសមុនគេបង្អស់នៅក.ប. ។

ថ្ងៃ៣ធ្នូ **ចិន_យ៉ុងតុយ** សមាជិកមជ្ឈិមបក្សកុម្មុយនិស្តចិន បានដឹកនាំគណៈប្រតិភូមួយមកដល់ភ្នំពេញ

ហើយបានត្រូវគេនាំដើរធ្វើទស្សនកិច្ចនៅតាមទីជនបទ ។ គោលដៅនៃទស្សនកិច្ចនេះ គឺចិនចង់ពិភាក្សាអំពីភាពអាក់អន្លលនៃទំនាក់ទំនងមិត្តភាពរបស់ក.ប.ជាមួយអ្នកជិតខាងខ្លួន ។

ថ្ងៃ៦ធ្នូ មុនគណៈប្រតិភូចិនចេញដំណើរ គណៈប្រតិភូម៉ាឡេស៊ីក៏បានមកដល់ភ្នំពេញ ។ ថ្វីបើថៃមានរឿងជាមួយខ.ក. ហើយថៃក៏ជាសមាជិកអាស៊ានដូចម៉ាឡេស៊ីដែរនោះ ម៉ាឡេស៊ីក៏បានផ្តល់នូវជំនួយអភិវឌ្ឍន៍ដល់ក.ប. ហើយក.ប.បានបញ្ជាក់ថាខ្លួននឹងពង្រីកការទាក់ទងសេដ្ឋកិច្ចនិងពាណិជ្ជកម្មជាមួយម៉ាឡេស៊ីវិញដែរ ។

ដោយមានការគាំទ្រយ៉ាងរាក់ទាក់ពីចិននិងកូរ៉េខាងជើង, ចំណងមិត្តភាពជាមួយភូមានិងម៉ាឡេស៊ី, និងផ្លូវជំនួញជាមួយជប៉ុននិងហុងកុង រដ្ឋាភិបាលក.ប.នឹងមិនស្ថិតក្នុងភាពឯកោនៅតំបន់អាស៊ីឡើយ ។ ម្យ៉ាងទៀតកងទ័ពក.ប.នៅតែបន្តបុករុកប្រទេសថៃដែលចង់តែចងមិត្តជាមួយខ្លួន ។

## ៧_ប្រស្នាលាក់មុខៈជម្លោះឥតស្រាករបស់កម្ពុជាប្រជាធិបតេយ្យជាមួយថៃ

ចុងខែធ្នូ១៩៧៧ រាជទូតស៊ុយអែដប្រចាំប្រទេសថៃបានមកធ្វើទស្សនកិច្ចនៅកម្ពុជាចំនួនពីរថ្ងៃ តាមការអញ្ជើញរបស់អ្នកសារពត៌មានថៃ ដើម្បីធ្វើជាអ្នកសម្រុះសម្រួលរវាងថៃនិងកម្ពុជា ។ នៅពាក់កណ្តាលខែមករា ១៩៧៨ ក.ប.បានផ្តាច់ចំណងទូតជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម *(ស.ស.វ.)* ហើយបានបើកការវាយប្រយុទ្ធគ្នាជាមួយវៀតណាមនៅតាមព្រំប្រទល់ខាងកើត ។ ទស្សនាវដ្តី នូវយ៉កថាយម៍ (New York Times) បានរាយការណ៍ថា ប្រទេសថៃមានការចំរើនទៅមុខយ៉ាងសម្បើមក្នុងការបបួលកម្ពុជាឲ្យទៅអង្គុយតុចរចា ។តែការវាយប្រហាររបស់ខ្មែរទៅលើភូមិនិងប៉ុស្តិ៍ការពារថៃចេះតែបន្ត ។ ថ្ងៃ២០មករា១៩៧៨ កងទ័ពថៃបានប្រកាសជាសាធារណៈថា ខ.ក.បានជួយទ័ពព្រៃថៃកុម្មុយនិស្តដោយបានផ្តល់ការហ្វឹកហ្វឺននិងគ្រឿងអាវុធ ហើយថែមទាំងរួមគ្នាវាយប៉ុស្តិ៍ការពារថៃទៀតផង ។

ការប្រកាសឲ្យដឹងនេះមិនបានធ្វើឲ្យទីក្រុងបាងកកភ្ញាក់ផ្អើលឡើយ ។ ចុងខែមករា រដ្ឋមន្ត្រីការបរទេសថៃបានធ្វើទស្សនកិច្ចបួនថ្ងៃនៅភ្នំពេញ ។ នៅក្នុងពិធីជប់លាងមួយ គាត់បានសន្មត់ថាការវាយប្រហាររបស់ខ្មែរគឺជាការវាយប្រហាររបស់ "ភាគីទីបី" មួយដែលគ្មានឈ្មោះ ។ នៅពេលត្រឡប់មកបាងកកវិញ គាត់បានប្រកាសថាថៃនិងកម្ពុជានឹងភ្ជាប់ចំណងមិត្តភាពគ្នាឡើងវិញក្នុងពេលដ៏ឆាប់ដែលអាចធ្វើទៅបាន ។ គាត់ក៏បានបញ្ជាក់ថែមទៀតដែរថា ប្រទេសទាំងពីរបានយល់ព្រមបន្តជាបន្ទាន់នូវទំនាក់ទំនងខាងផ្នែកសេដ្ឋកិច្ចនិងពាណិជ្ជកម្ម ។

កន្លងទៅបានប្រហែលបួនថ្ងៃ ខ.ក.បានវាយប៉ុស្តិ៍ការពារថៃមួយ ហើយបានដុតភូមិអ្នកស្រុក ។ បីថ្ងៃបន្ទាប់ខ្មែរកុម្មុយនិស្តនិងថៃកុម្មុយនិស្តបីរយនាក់រួមគ្នាវាយភូមិថៃមួយ ហើយនៅពេលដកថយ បានកៀរយកប្រជាជនថៃជា

ច្រើនរយនាក់មកស្រុកខ្មែរវិញ ។ ការវាយប្រហារលើកទីពីរទៅលើភូមិដដែលបានកើតឡើងនៅថ្ងៃ១២កុម្ភៈ ។ នៅក្នុងពេលជាមួយគ្នានោះដែរមានសេចក្ដីរាយការណ៍ថា ខ.ក.បានវាយប្រហារទាហានថៃនៅក្នុងខេត្តថៃពីរផ្សេងទៀតជាប់ព្រំដែន ។ ថ្ងៃ១៥កុម្ភៈ ខ.ក.ចាប់បានជនស៊ីវិលថៃ៥០នាក់នៅបុរីរាំមហើយនាំយកមកស្រុកខ្មែរ ។ រដ្ឋមន្ត្រីការបរទេសថៃនៅតែមិនយល់ ថាតើមកពីមូលហេតុអ្វីបានជាការប៉ះទង្គិចគ្នាតាមព្រំដែនមិនចេះចប់សោះ បើទោះជាមានកិច្ចព្រមព្រៀងជាមួយរដ្ឋមន្ត្រីការបរទេសក.ប.ហើយក៏ដោយ ។ លិខិតជាផ្លូវការមួយរបស់ **ឧប្បឌិត** (រដ្ឋមន្ត្រីការបរទេសថៃ) បានផ្ញើទៅអៀងសារីសុំឲ្យជួយបញ្ឈប់ការប្រយុទ្ធគ្នារបស់របស់ ។ បីថ្ងៃក្រោយមក ខ.ក. មានគ្នា១៦នាក់និងទ័ពព្រៃថៃមួយក្រុមបានវាយលុកភូមិថៃមួយទៀត ចាប់បានថៃ៦នាក់ តែ៥នាក់បានរត់រួច ។ ថ្ងៃ២៤កុម្ភៈ រដ្ឋាភិបាលក.ប.បានឆ្លើយតបនឹងលិខិតរបស់ឧប្បឌិតវិញ ដោយបញ្ជាក់ថាឧប្បត្តិហេតុដែលកើតឡើងទាំងប៉ុន្មានគឺបណ្ដាលមកពី"កងទ័ពថៃជាអ្នកបង្ក" ។

ក្នុងការព្យាយាមពន្យល់អំពីអាកប្បកិរិយាអ្នកជិតខាងរបស់ខ្លួន មេដឹកនាំថៃថ្នាក់ខ្ពស់ពីររូបបានប្រកែកមិនព្រមទម្លាក់កំហុសទៅលើថ្នាក់ដឹកនាំក.ប.នៅភ្នំពេញឡើយ ។ នៅថ្ងៃ១៦កុម្ភៈ ឧប្បឌិតបានអះអាងថា គាត់នៅតែមានជំនឿលើភាពស្មោះត្រង់របស់មេ ខ.ក. ជាពិសេសអៀងសារី ។ ឧប្បឌិតពោលថា"ការប្រយុទ្ធគ្នានៅតាមព្រំដែនអាចជាលទ្ធផលនៃកង្វះទំនាក់ទំនងល្អនៅកម្ពុជា ឬអាចជាកង្វះវិន័យនៃមេបញ្ជាការថ្នាក់ក្រោម" ។ ថ្ងៃ៣មីនា នាយករដ្ឋមន្ត្រីថៃ **គ្រៀងសក្ដិ** បានយល់ឃើញថាគឺពួកថៃកុម្មុយនិស្តទេជាអ្នកទទួលខុសត្រូវនៅក្នុងជម្លោះ ឯពួកខ្មែរក្រហមចូលទៅទឹកដីថៃដោយអចេតនាម្ដងម្កាលប៉ុណ្ណោះ ។

ការវាយប្រហារទៅលើភូមិថៃតាមព្រំដែន ដោយរួមទាំងការចាប់ជនស៊ីវិលថៃរាប់រយនាក់មកជាមួយផងបានបន្តប្រព្រឹត្តទៅរហូតដល់ខែមីនា១៩៧៨ ។ ការប្រយុទ្ធមិនមែនកើតឡើងនៅតែមួយកន្លែងទេ គឺមាននៅគ្រប់ខេត្តតាមបណ្ដោយព្រំដែនខ្មែរ_ថៃ ។ តាមការសាកសួរអ្នកដែលរត់រួចបានឲ្យដឹងថា: បក្សកុម្មុយនិស្តថៃ ដោយមានជំនួយពីប.ក.ក. បានចាប់បង្ខំប្រជាជនឲ្យចូលរួមជាមួយទ័ពព្រៃ ដើម្បីច្បាំងជាមួយទ័ពរដ្ឋាភិបាលថៃនៅពេលអនាគត ។ ថ្ងៃ១មេសា១៩៧៨ ខ.ក.បានបាញ់ផ្គក់ជាលើកទីមួយទៅលើទីប្រជុំជនអារញ្ញខាងប្រទេសថៃដោយកាំភ្លើងរ៉ុកកែតរបស់ចិន ។ ថ្ងៃ៩មេសា ថៃកុម្មុយនិស្តនិងខ.ក.បានវាយប្រហារភូមិថៃមួយទៀតនៅខេត្តបុរីរាំម សម្លាប់ប្រជាជន១៧នាក់, ដុតបំផ្លាញផ្ទះ៧០ខ្នង, លួចបានត្រាក់ទ័រមួយនិងឡានច្រូង៤គ្រឿង, ព្រមទាំងទំនិញដែលដាក់លក់នៅទីផ្សារមួយចំនួនទៀត ។ បន្ទាប់ពីការវាយប្រហារនេះមក ទើបនាយរដ្ឋមន្ត្រីថៃបានធ្វើការព្រមានថានឹងមានការវាយតបវិញពីកងទ័ពរដ្ឋាភិបាល ។ នៅចុងខែមេសា មានការវាយប្រហារដោយគ្រាប់បែកដៃនិងរ៉ុកកែត

ទៅលើក្រុងអារញ្ញម្ដងទៀត ។ លើកនេះបានបង្ហាញយ៉ាងច្បាស់ថា ខ.ក.មិនមែនគ្រាន់តែជួយប្រមូលទ័ពឲ្យពួកថៃកុម្មុយនិស្ដប៉ុណ្ណោះទេ តែពួកកុម្មុយនិស្ដថៃផ្ទាល់ខ្លួន ដែលត្រូវគេយកទៅលាងខួរនិងហ្វឹកហ្វឺនក្បួនសឹកក្នុងដីខ្មែរ ថែមទាំងឲ្យដឹងថា បេសកកម្មចម្បងរបស់គេគឺបង្កើត"តំបន់រំដោះ"មួយសម្រាប់ថៃកុម្មុយនិស្ដនៅក្នុងទឹកដីថៃ ។

តើព្រឹត្តិការណ៍ទាំងឡាយនោះកើតឡើងពីពួក ខ.ក.ថ្នាក់ក្រោម ដោយគ្មានការដឹងឮពី ខ.ក.ថ្នាក់លើដូចនាយករដ្ឋមន្ត្រីថៃអះអាងមែនឬ ? មានភស្ដុតាងដែលបញ្ជាក់ពីការផ្លាស់ប្ដូរនយោបាយក្នុងស្រុករបស់ពួកខ្មែរក្រហមដែលគេអនុវត្តក្នុងតំបន់ផ្សេងៗគ្នានៅទូទាំងប្រទេសកម្ពុជា ។ ប៉ុន្តែការផ្លាស់ប្ដូរនេះជា **បញ្ហាកិរិត** វាមិនមែនជា **បញ្ហាប្រភេទ** ឡើយ ។ ការជួយគាំទ្រពួកថៃកុម្មុយនិស្ដគឺជាបញ្ហាប្រភេទនយោបាយ មិនមែនជាបញ្ហាកិរិតនៃការអនុវត្តទេ ។ វាជាការមិនទំនងសោះដែលថា មេបញ្ជាការនៅតាមព្រំដែនអនុវត្តនយោបាយបែបនេះដោយគ្មានការយល់ព្រមពីភ្នំពេញនោះ ។ ជាពិសេស វាជាការមិនគួរឲ្យជឿដែរដែលថា ប៉ុលពតបានបោសសម្អាតពួកមេខ្មែរក្រហមនៅភូមិភាគពាយព្យក្នុងកំលុងឆ្នាំ១៩៧៧ ។

ទីបញ្ចប់មួយហាក់ដូចជាគេចមិនរួច: ដោយនៅពេលជាមួយគ្នារដ្ឋាភិបាល ក.ប.ប្រឈមមុខជាមួយអ្នកខ្លាំងទិសខាងកើតម្យ៉ាង និងម្យ៉ាងទៀត ការជួយឧបត្ថម្ភក្រុមបះបោរប្រចាំងនឹងអ្នកជិតខាងទិសខាងលិចរបស់ខ្លួនផង ។

យើងគួររំលឹកផងដែរនូវសក្ខីភាពនៃឯកសារផ្ទៃក្នុងរបស់ប.ក.ក. ដែល ប.ព.បានប្រាប់បក្សពួកគាត់នៅខែសីហា១៩៧៦ថា "ខ្មាំងវាយប្រហារនិងធ្វើទុក្ខបុកម្នេញយើង" ។ ខ្មាំងគឺ វៀតណាមនៅខាងកើត និងថៃនៅខាងលិច ។ គាត់បានអះអាងថា ពួកខ្មាំងអស់នេះនៅតែព្យាយាម" បុករុកនិងរំខានយើង ។ " គ្មានភស្ដុតាងឯករាជ្យណាមួយបញ្ជាក់ពីអំណះអំណាងនេះឡើយ ។ យើងបានឃើញហើយថា នៅពេលកំពុងនិងក្រោយការវាយប្រហាររបស់ខ្មែរទៅលើថៃក្នុងឆ្នាំ១៩៧៧_៧៨ មេដឹកនាំថៃអសិរីធីនឹងលួងលោមខ្មែរក្រហមទៀតហើយ ។ ដូច្នេះសេចក្ដីបញ្ជាក់ទាំងឡាយបានផ្ដោតទៅលើការឆ្កួតក្រពុលមុខរបស់ប៉ុលពត ។ ការឆ្កួតវង្វេងស្រមើស្រមៃរបស់ប.ព.ចំពោះថៃអាចពន្យល់បានតាមរយៈការវាយប្រហារនៃខ្មែរក្រហម ។

គឺអន្តរាគមន៍របស់ចិននេះហើយដែលមួយភាគបានជួយសម្រួលនយោបាយរបស់ខ.ក. ។ ថៃបានអំពាវនាវមេដឹកនាំខ្មែរដើម្បីចរចារកដំណោះស្រាយ ។ សេចក្ដីស្នើរបស់ថៃនៅតែឥតមានការឆ្លើយតប ទាល់តែចិនចូលធ្វើអន្តរាគមន៍នៅពាក់កណ្ដាលខែមិថុនា១៩៧៨ ។ ជាលទ្ធផល ព្រឹត្តិការណ៍បន្តបន្ទាប់ក៏កើតមានឡើង ដោយអៀងសារីបានទៅដល់ប្រទេសថៃនៅថ្ងៃ១៤កក្កដា១៩៧៨ ។

ទស្សនកិច្ចរបស់អៀងសារីនៅប្រទេសថៃ មិនត្រូវបានប្រកាសជាផ្លូវការទេ ។ តែផ្ទុយទៅវិញនៅក្នុងកិច្ចប្រជុំសាពិតមានមួយ មន្ត្រីការបរទេសរបស់ក.ប.បានថ្កោលទោសយ៉ាងចាស់ដៃចំពោះវៀតណាម ។ សារីបានធ្វើឲ្យម្ចាស់ផ្ទះ (ថៃ) អាម៉ាស់មុខយ៉ាងខ្លាំងដោយហេតុថាថៃបានប្តូរទូតជាមួយវៀតណាមរួចទៅហើយ ហើយថៃកំពុងតែរៀបចំឲ្យមានចំណងទូតជាធម្មតាឡើងវិញជាមួយកម្ពុជា ។

តែទោះជាយ៉ាងណាក៏ដោយ ទស្សនកិច្ចរបស់អៀងសារីបានបង្ហាញនូវការរីកចំរើនខ្លះក្នុងមិត្តភាពរវាងក.ប.និងប្រទេសថៃ ។ មានតែការប៉ះទង្គិចគ្នាតិចតួចប៉ុណ្ណោះរវាងទាហានថៃនិងទ័ពខ.ក. ក្នុងកំលុងខែកក្កដានិងសីហា ។

នៅថ្ងៃ១៤កញ្ញា១៩៧៨ អៀងសារីបានជូនដំណឹងដល់រដ្ឋមន្ត្រីការបរទេសថៃថា កម្ពុជាបានចាត់តាំងរដ្ឋទូតម្នាក់សម្រាប់ទីក្រុងបាងកកហើយ ។ ពីរថ្ងៃក្រោយមក មន្ត្រីក្រសួងការបរទេសថៃបានមកដល់ភ្នំពេញ ដើម្បីរៀបចំបើកស្ថានឯកអគ្គរាជទូតនៃព្រះរាជាណាចក្រថៃ ។ ពួកគេទាំងឡាយបានត្រូវទទួលយ៉ាងរាក់ទាក់ពីអៀងសារី ។ ជម្លោះកំប៉ិកកំប៉ុករវាងប្រទេសទាំងពីរក៏ហាក់ដូចជាបញ្ចប់ទៅដែរ ។

## ៨_ការចែចង់សមាគមអាស៊ាន:

នៅក្នុងស្ថានការណ៍ជាបន្តបន្ទាប់ នៃកិច្ចព្រមព្រៀងសន្តិភាពដោយឥតដាក់លាក់មួយជាមួយប្រទេសថៃ ក.ប.បានចាប់ផ្តើមវាយលុកផ្លូវទូតនៅក្នុងសមាគមនៃប្រទេសអាស៊ាន ។ ក.ប.ត្រូវការនូវការប្រកួតប្រជែងមួយជាមួយវៀតណាមដែលកំពុងតែបោះជំហានទៅមុខ ។ ថ្នាក់ដឹកនាំនៃប្រទេសកុម្មុយនិស្តទាំងពីរនេះបានមើលឃើញការគាំទ្រខាងផ្លូវទូតរបស់អាស៊ាន ថាជាកត្តាសំខាន់នៃការផ្ទុះឡើងក្នុងពេលដ៏ខ្លី នៃមហាអគ្គីភ័យមួយ ។

ថ្ងៃ៦សីហា១៩៧៨ វិទ្យុភ្នំពេញបានប្រកាសថា រដ្ឋាភិបាលក.ប.និងរដ្ឋាភិបាលសាធារណរដ្ឋឥណ្ឌូណេស៊ីបានព្រមព្រៀងភ្ជាប់ចំណងទូតនៅថ្ងៃ៧សីហា ។ ការទទួលស្គាល់ដ៏យឺតយ៉ាវនេះ (ពីរឆ្នាំក្រោយក.ប.បានដាក់ទូតជាមួយសមាជិកអាស៊ានឯទៀតរួចអស់ហើយ) មានន័យថា មេដឹកនាំខ.ក.នៅពេលនេះបានចង់មិត្តភាពជាមួយនឹងប្រទេសដែលប្រឆាំងនឹងចិនខ្លាំងជាងគេនៅអាស៊ី ហើយនិងជាប្រទេសមួយដែលប្រយុទ្ធនឹងពួកទ័ពព្រៃនៅកោះទីម័រខាងកើត ដែលក.ប.បានគាំទ្រក្នុងអតីតកាល ។ថ្ងៃ១៧តុលា អៀង_សារីបានទៅដល់ប្រទេសហ្វីលីពីនក្នុងដំណើរទស្សនកិច្ចផ្លូវទូតបីប្រទេស ។ ទស្សនកិច្ចបីថ្ងៃនៃមេដឹកនាំខ.ក. ដែលប្រទះគ្នានឹងទស្សនកិច្ចរបស់នាយករដ្ឋមន្ត្រីផាំវ៉ាន់ដុងនៃវៀតណាមដែរ ជាដំណើរទៅដាន់ទឹកដីនៃប្រទេសអាស៊ីអាគ្នេយ៍មួយដែលនិយមស.រ.អ.ជាងគេ និងជាប្រទេសតែមួយគត់ដែលនៅអនុញ្ញាតឲ្យមានមូលដ្ឋានទ័ពអាមេរិកាំង ។

មិនតែប៉ុណ្ណោះសោត ហ្វីលីពិនក៏ជាប្រទេសមួយដែលរដ្ឋាភិបាលកំពុងប្រយុទ្ធជាមួយទ័ពព្រៃម៉ៅនិយម ចលនាមួយដែលខ.ក.ចាត់ទុកជាបងប្អូន ។ ប៉ុន្តែ មានហេតុផលជាក់ស្តែងនៅក្នុងការសម្របសម្រួលផ្នែកមនោ-គមន៍វិជ្ជានេះ ។ នៅក្នុងសន្និសីទកាសែតមួយ អៀងសារីបានបញ្ជាក់ថា ទស្សនកិច្ចរបស់គាត់នៅទីនោះនិងនៅប្រទេសសមាជិកអាស៊ានផ្សេងទៀតអាចចាត់ទុកថាមានជោគជ័យបាន លុះណាតែវាបានទទួលនូវសមានចិត្ត និងការគាំទ្រខាងផ្លូវសីលធម៌សម្រាប់ប្រទេសគាត់ ដែលកំពុងតែប្រឈមមុខចំពោះគ្រោះថ្នាក់ដ៏ធំនៃ "ការលេបត្របាក់របស់វៀតណាម" ។

ចេញពីហ្វីលីពិន គណៈប្រតិភូខ្មែរបានបន្តដំណើរទៅទីក្រុងហ្សាការតា ជាទីដែលពួកគេត្រូវជួបប្រជុំជាមួយមន្ត្រីជាន់ខ្ពស់ឥណ្ឌូណេស៊ី ដោយរួមទាំងប្រធានាធិបតីស៊ូហារតូផងដែរ ។ ភាគីឥណ្ឌូណេស៊ីមិនមានអត្ថា-ធិប្បាយអ្វីជាសាធារណៈទេ ។ តែការដែលឥណ្ឌូណេស៊ីព្រមទទួលគណៈប្រតិភូក.ប.នេះ ក៏ជាសញ្ញានៃជោគជ័យការទូតរបស់ខ្មែរក្រហមរួចទៅហើយ ។ រឿងនេះក៏បានបង្ហាញឲ្យឃើញផងដែរនូវកាផ្លាស់ប្តូរដ៏ខ្លាំងក្លានៃនយោបាយក្រៅប្រទេសរបស់ខ.ក. ដែលបានឈានមួយជំហានចេញពីមនោគមន៍វិជ្ជា "ស្អប់បរទេស" ងាកទៅរក "ការទូតសាមញ្ញ"ដោយផ្អែកលើមូលដ្ឋានទំនាក់ទំនងធម្មតារវាង **ប្រទេសនិងប្រទេស** ។ ការដែលខ្មែរក្រហមប្តូរនយោបាយទំនងជាមានការណែនាំពីចិន ។ តែការណែនាំរបស់ចិនគ្រាន់តែលើកឡើងដើម្បីរំលឹកអំពីការគំរាមកំហែង ក្បួនក ដែលទើបកន្លងទៅថ្មីៗនេះ ។

## ៩_ឥទ្ធិពលរបស់ចិនទៅលើនយោបាយក្រៅប្រទេសរបស់ខ្មែរក្រហមៈ

ខ.ក.បានទទួលឥទ្ធិពលពីចិនមែន ប៉ុន្តែមិនមែនជាអាយ៉ងរបស់ចិនឡើយ ។ មានប្រភពពីរដែលបញ្ជាក់អំពីឥទ្ធិពលចិនទៅលើខ.ក. ។

ប្រភពទីមួយ គឺជំនួយសម្ភារៈរបស់ចិន ។ តែខ.ក.បានចាត់ទុកជោគជ័យទាំងឡាយថាជាការខំប្រឹងប្រែងរបស់គេនិងជានយោបាយឯករាជ្យរបស់គេ ។ ខែមករា១៩៧៨ នៅពេលដែល **ដេងយិងចាវ** *(ភរិយាមេម៉ាយរបស់ជូអេនឡាយ)* បានមកកម្ពុជាដើម្បីទទូចសុំឲ្យភ្នំពេញចរចាជាមួយវៀតណាម *(តែមិនបានសម្រេច)* វិទ្យុភ្នំពេញបានផ្សាយថាៈ

> **"យើងធ្វើការកត់ចំណាំរវាងមិត្តល្អនិងមិត្តអាក្រក់ ។ យើងគោរពនិងស្រឡាញ់មិត្តទាំងឡាយណាដែលល្អជាមួយយើង ដែលគោរពឯករាជ្យ អធិបតេយ្យភាព និងបូរណភាពទឹកដីកម្ពុជា ហើយដែលទាក់ទងជា-មួយយើង លើមូលដ្ឋានស្មើភាពគ្នា ។ ប៉ុន្តែលក្ខណៈវិនិច្ឆ័យមិត្តភាពរបស់យើងមិនមែនផ្អែកទៅលើមិត្តនេះ**

**ឬមិត្តនោះផ្តល់ជំនួយនោះទេ តែគឺផ្អែកទៅលើគោលការណ៍សមភាព គោរពគ្នាទៅវិញទៅមក ផល ប្រយោជន៍ទៅវិញទៅមកក្នុងស្មារតីសាមគ្គីភាព ស្របទៅតាមគោលការណ៍គោរពនិងការពារសិទ្ធិនៃ ប្រទេសនីមួយៗ ទោះជាប្រទេសនោះតូចក្តីធំក្តី ក្នុងការចាត់ចែងវាសនារបស់ខ្លួនដោយខ្លួនឯង "។**

ដោយបេសកជនជាន់ខ្ពស់ចិនមានបញ្ហាជាមួយមេដឹកនាំខ.ក.នេះហើយ បានជាក.ប.មិនព្រមឱ្យចិនចូល ជួបសម្តេចសីហនុ ដែលកាលនោះទ្រង់ជាប់នៅក្នុងមន្ទីរឃុំឃាំង ។

ប្រភពទីពីរនៃឥទ្ធិពលចិនទៅលើខ្មែរក្រហម គឺមនោគមវិជ្ជាម៉ៅសេទុង ។ តែមនោគមវិជ្ជាម៉ៅបាន ចុះថយឥទ្ធិពលក្រោយមរណភាពរបស់គាត់នៅខែកញ្ញា១៩៧៦ ។ សូម្បីតែមុនមរណភាពរបស់ម៉ៅក៏ដោយ នយោ-បាយការបរទេសរបស់ខ.ក.មានសភាពដូចគ្នានឹងចិនតិចតួចណាស់ ។ ជាមួយនឹងការធ្លាក់ឥទ្ធិពលរបស់ម៉ៅនៅឆ្នាំ ចុងក្រោយ ជំនួយតែមួយគត់ដែលពួកជ្រុលនិយមប.ក.ក.បានទទួលគឺបានពីក្រុមដែលគេហៅថា "ពួកអ្នកលេង បួននាក់" (Gang of four) ដែលត្រូវគេចាប់ខ្លួននៅខែតុលា១៩៧៦ ។

សក្ខីភាពនៃការមិនសប្បាយចិត្តរបស់ចិនជាមួយនយោបាយជ្រុលនិយមក្នុងស្រុករបស់ ខ.ក. ដែលជាប់ ទាក់ទិននឹងនយោបាយក្រៅប្រទេស ត្រូវបានគេរកឃើញនៅក្នុងរបាយការណ៍សម្ងាត់នៃមជ្ឈិមបក្សកុម្មុយនិស្តចិននៅ ខែមករា១៩៧៩ ។ ក្រោយពីបានកត់សម្គាល់ឃើញថាខ.ក.បែកបាក់គ្នាតាំងពីឆ្នាំជ័យជំនះ១៩៧៥ មេដឹកនាំចិនបាន រិះគន់មេខ.ក.ថា: "បើខ្មែរទាំងបីក្រុមស្រុះស្រួលគ្នាតាំងពីពេលកងទ័ពបដិវត្តកម្ពុជាបានខំបង្រួបបង្រួមកាលពីឆ្នាំ ១៩៧៦នោះ ម្ល៉េះសមស្ថានភាពបានល្អប្រសើរស្រេចទៅហើយ ។ ប៉ុន្តែ ប.ក.ក.មិនបានប្រើវិធីសមស្របក្នុងការ ដោះស្រាយឡើយ ដែលបណ្តាលឱ្យទំនាស់កាន់តែរីកធំឡើង" ។

សក្ខីភាពរបស់អ្នកស្រី **ឡូរ៉ង់_ពិជ** (ស្ត្រីបារាំងដែលរៀបការជាមួយមន្ត្រីការបរទេសខ.ក.ម្នាក់ ហើយដែល បានធ្វើការនៅក្រសួងការបរទេសក.ប.នៅភ្នំពេញ) បានផ្តល់ភស្តុតាងដោយផ្ទាល់ថា ខ.ក.មានការសង្ស័យ មិន ទុកចិត្តចិន ហើយជំទាស់នឹងចិនដែលប៉ុនប៉ងគ្រប់គ្រងរបបរបស់ខ្លួន ។ ដូចយ៉ាងនៅខែមករា១៩៧៦ កម្មាភិបាល ក្រសួងការបរទេសម្នាក់បានថ្លែងថា: "យើងត្រូវប្រុងប្រយ័តជាមួយចិន...។ យើងជំពាក់បំណុលចិនច្រើនណាស់ ។ ចិនជាមហាប្រទេសមួយ ដែលគេចង់យកយើងធ្វើរណបគេ" ។

ក្នុងពាក់កណ្តាលឆ្នាំ១៩៧៧ នៅពេលប្រជុំរៀនសូត្រធ្វើការរិះគន់និងស្វ័យរិះគន់មួយនៅក្រសួងការ បរទេស អ្នកស្រី **ពិជ**ត្រូវគេរិះគន់ថា: **"អ្នកឯងចូលចិត្តចិន ហើយនិយាយរួតតែពីចិន ។ ចិនមិនមែនជាមិត្តពិត ប្រាកដទេ ។ គេចង់ដាក់អាណានិគមលើយើង" ។**

នៅក្នុងកិច្ចប្រជុំរៀនសូត្រមួយនៃបុគ្គលិកក្រសួងការបរទេស ក្នុងខែកក្កដា១៩៧៨ អ្នកស្រីពិដបានរ៉ាយរ៉ាប់ពីរឿងមួយដែលអៀងសារីបានលើកឡើងអំពីស្ថានការណ៍អន្តរជាតិ ។ សារីនិយាយថា "រុស្សីកំពុងតែធ្លាក់ខ្លួនកប់ភក់ជ្រៅរើមិនរួច ឯចិនក៏ដូច្នោះដែរ" ។

ពាក់កណ្តាលឆ្នាំ១៩៧៨ ចិនហាក់ដូចជាបន្ថយឥទ្ធិពលរបស់ខ្លួនខ្លះ ទៅលើនយោបាយការបរទេសជ្រុលនិយមរបស់ក.ប. ។ ចិនត្រូវការនូវ**កម្ពុជាឯកភាពមួយ** សម្រាប់ប្រើជាយុទ្ធភូមិសាស្ត្រដើម្បីទប់ទល់នឹងការឡាមព័ទ្ធរបស់សហភាពសូវៀត ។ នេះមិនមែនបានន័យថា ចិនប្រគល់នយោបាយក្នុងប្រទេសនិងក្រៅប្រទេសទៅឲ្យ ខ.ក.នោះទេ ។ ផ្ទុយទៅវិញ ជាពិសេសក្រោយមរណភាពរបស់ម៉ៅសេទុង ចិនប្រហែលជាបានឃើញនូវនយោ-បាយបំផ្លាញខ្លួនឯងយ៉ាងគ្រោះថ្នាក់របស់ខ.ក. ដោយហេតុថារបបភ្នំពេញកំពុងតែប្រឈមមុខនឹងចក្រពត្តិខាងកើតហើយដែលអាចនឹងប្រើប្រជាជនខ្លួនទាំងអស់ដើម្បីទប់ទល់នឹងការឈ្លានពាន ។ ចិនក៏ទំនងជាបានមើលឃើញផងដែរថា នយោបាយក្រៅប្រទេសរបស់ខ.ក.ជានយោបាយបង្ករឿងយ៉ាងគ្រោះថ្នាក់ ជាពិសេសបើគេគិតទៅលើកម្លាំងដែលមិនសមគ្នាខាងភាគីមាណូយ ហើយនិង **ការប្រុងប្រៀបរៀបខ្លួនជាស្រេចខាងកម្លាំងយោធារបស់យួនកុម.ដើម្បីបានចំណេញខាងផ្នែកនយោបាយ** ។ បន្ទាប់ពីមរណភាពរបស់ម៉ៅ ឥរិយាបទចិនចំពោះខ្មែរក្រហម ជាឥរិយាបទតឹងរ៉ឹងមួយនៃ **ភាពប្រាកដនិយមនយោបាយ** (នយោបាយដែលផ្អែកលើអំណាចច្រើនជាងឧត្តមគតិ) ដែលចិនចាត់ទុកភាពជ្រុលនិយមនៃកូនដីងរបស់គេថាជាភាពអាម៉ាស់មុខមួយ និងជាឧបសគ្គមួយនៃគោលដៅយុទ្ធ-សាស្ត្រដ៏ធំធេងរបស់ចិន ។

## ១០_សេចក្តីសន្និដ្ឋានៈ

## ពន្យល់អំពីនយោបាយក្រៅប្រទេសរបស់ខ្មែរក្រហម

ដំណោះស្រាយនយោបាយក្រៅប្រទេសរបស់ខ.ក.ទីមួយគឺ សេចក្តីសម្រេចចិត្តរបស់គេក្នុងការប្រឈមមុខនឹងវៀតណាម ។ ដំណោះស្រាយទីពីរដែលជាប់ទាក់ទិននឹងទីមួយដែរគឺ ការប្រឈមមុខនឹងប្រទេសថៃ ។

ការដែលក.ប.ចាត់ទុករដ្ឋាភិបាលសេរីរបស់ថៃជាសត្រូវនឹងមនោគមន៍វិជ្ជារបស់ខ្លួននោះគ្មានអ្វីគួរឲ្យអស្ចារ្យទេ ។ តែថៃមិនមែនជាអ្នកគំរាមកំហែងខាងផ្នែកសន្តិសុខឡើយ ។ អ្វីដែលយើងត្រូវការពន្យល់នោះគឺថា ហេតុដូចម្តេចបានជាកម្ពុជាចេះតែបន្តការវាយប្រហារតាមបែបយោធាទៅលើថៃ បើទោះជាតិចតួចក្តី ក្នុងពេលដែលប្រទេសខ្លួនកំពុងប្រឈមមុខនឹងការវាយប្រហារស្លាប់រស់ពីអ្នកជិតខាងម្ខាងទៀតនោះ ។ ការវាយប្រហារទៅលើថៃមិនមែនជាការបង្ខិតបង្ខំពីចៅហ្វាយចិនឡើយ ។

ទម្ងន់នៃសក្ខីភាពបានពន្យល់ប្រាប់ថា ភាពជ្រុលនិយមរបស់ខ.ក. ទាំងនយោបាយក្រៅប្រទេស ទាំងនយោបាយក្នុងប្រទេស គឺជាលទ្ធផលដែលបានមកពីការសម្រេចចិត្តដោយខ្លួនឯងរបស់មេដឹកនាំខ.ក.។ បើតាមទំហំនៃឥទ្ធិពលរបស់រដ្ឋាភិបាលចិនដែលបានដាក់ វាអាចនឹងសមល្មមក្នុងការចង្អុលទិសប្រាប់មេខ.ក. ចំពោះនយោបាយក្នុងក្រៅប្រទេស និងល្មមគ្រប់គ្រាន់ដើម្បីរបបនេះធ្វើដំណើរឆ្ពោះទៅកាន់ **ភាពប្រាកដនិយមនយោបាយបុរាណ** នៃនយោបាយក្រៅស្រុកមួយ ។ តែតាមការប្រមើលមើលទៅលើផលប្រយោជន៍គោលដៅសន្តិសុខនៃចិននិងខ.ក. ឥទ្ធិពលនោះវាហាក់ដូចជាតូចតាចហួស ហើយវាហាក់ដូចជាយឺតពេលពេកទៅហើយ ។

ការគាំទ្របដិវត្តកុម្មុយនិស្តថៃជាផ្នែកមួយនៃតម្រូវការចាំបាច់នៃមនោគមន៍វិជ្ជា ។ គេមិនគួរភ្ញាក់ផ្អើលទេថារបបមួយដែលកំពុងតែជឿជ្ជាប់មុខក្នុងការតាមរកភាពបរិសុទ្ធនៃមនោគមន៍វិជ្ជារបស់ខ្លួន អាចនឹងទទួលយកមនោគមន៍វិជ្ជាបរទេសបាននោះ ។

ប៉ុន្តែ អាកប្បកិរិយារបស់ខ.ក.អាចយល់បានតាមជំនឿច្រូតផ្តេសផ្តាសរបស់គេ ដែលថាប្រទេសថៃចេះតែវាយប្រហារនិងបុករុកកម្ពុជា និងគំរាមវាយយកកម្ពុជាថែមទៀត ។ ប៉ុលពតប្រហែលជឿថា មានតែការសម្តែងរិទ្ធិប៉ុណ្ណោះដែលអាចធ្វើឲ្យ“អាខ្មាំងទិសខាងលិច”ខកខានមិនបានសម្រេចផែនការ ។ ម្យ៉ាងទៀត ពួកខ្មែរក្រហមត្រូវបានជ្រួតជ្រាបដោយមនោគមន៍វិជ្ជាម៉ៅ ដោយជឿថាពួកគេអាចយកជ័យជំនះបានលើអ្នកជិតខាង **ខ្លាំង** របស់ខ្លួន ។ បើទោះជាខ.ក.មិនដែលភ្ជាប់ខ្លួនទៅនឹងទ្រឹស្តី“ខ្លួនទីពឹងខ្លួន”របស់ម៉ៅក៏ដោយ ពួកគេបានអនុវត្តទ្រឹស្តីនោះហួសពីកម្លាំងសម្ភារៈ ។

គេគួរកត់ចំណាំនូវភាពស្រដៀងគ្នានៃនយោបាយក្រៅប្រទេសរបស់ចិនក្នុងកំលុងឆ្នាំ១៩៦០ ។ ចន្លោះឆ្នាំ១៩៦៣និង១៩៦៩ ម៉ៅសេទុងអនុវត្តនយោបាយប្រឈមមុខទល់នឹងមហាអំណាចទាំងពីរ ។ ម៉ៅបានចាត់ទុកស.រ.អ.និងសហភាពសូវៀតជាសត្រូវដូចគ្នា ។ គ្រាន់តែក្រោយពីសូវៀតចូលឈ្លានពានចេកូស្លូវ៉ាគីនៅខែសីហា ១៩៦៨ និងជាពិសេស ក្រោយពីសូវៀតគំរាមថានឹងបាញ់ប្រហារទៅលើទីតាំងអាវុធបរមាណូរបស់ចិនភ្លាម ចិនបានប្តូរទស្សនវិស័យយុទ្ធសាស្ត្ររបស់គេ ហើយងាកមកអែបនឹងលោកខាងលិចវិញ ។ ដូច្នេះជំហរយុទ្ធសាស្ត្រ “មុខពីរ”របស់ម៉ៅនៅឆ្នាំ១៩៦៣_៦៩ជាសេចក្តី សង្ឃឹមនៃជំហរយុទ្ធសាស្ត្ររបស់ប៉ុលពតនៅឆ្នាំ១៩៧៥_១៩៧៨ ។

# ជំពូកបួន

## ១_ការបែកបាក់"យុទ្ធសាមគ្គីភាព"នៅឥណ្ឌូចិនៈវៀតណាមនិងកម្ពុជា,១៩៧៥_៧៨

ការរៀបចំតម្រែតម្រង់ឡើងវិញនៃកងទ័ពបដិវត្តឥណ្ឌូចិន បានប្រព្រឹត្តទៅតាំងតែពីមុនការដួលរលំនៃរដ្ឋាភិបាលដែលមាននិន្នាការអាមេរិកាំងនៅវៀតណាមខាងត្បូងនិងកម្ពុជាម្ល៉េះ ។

យួនកុម.បានបង្ហាញថាខ្លួនមានការជាប់ចិត្តជាមួយសហភាពសូវៀត ឯខ្មែរកុម.វិញបង្ហាញថាខ្លួនចូលចិត្តចិន ដែលជាហេតុធ្វើឲ្យអ្នកទាំងពីរធ្លាក់ទៅក្នុងមាត់មហាអំណាចទាំងពីរដែលមានវិវាទនឹងគ្នា ។ ការកាន់បក្សពួកមានភាពមិនដូចគ្នាទេ ។ ទោះជាយ៉ាងណា យួននៅតែមានទំនាក់ទំនងល្អជាមួយចិន ។ ឯខ្មែរវិញផ្ដាច់អស់នូវចំណងទូត និងថែមទាំងបង្ករឿងអាស្រូវជាមួយសហភាពសូវៀតទៀតផង ។ (លាវកុម.បានធ្លាក់ចូល ទៅក្នុងកណ្ដាប់ដៃយួនកុម.រួចទៅហើយ) ។

ដោយវិវាទចិននិងសូវៀតលេចរូបរាងឡើងសាជាថ្មីក្នុងរង្វង់បក្សកុម្មុយនិស្តនៅឥណ្ឌូចិន សង្គ្រាមត្រូវតែផ្ទុះដែលមិនអាចគេចរួចឡើយ ហើយផលវិបាកច្រើនផ្សេងទៀតក៏អាចនឹងមានផងដែរ ។ គេគួរពិចារណាលើមូល_ហេតុមួយចំនួនថាហេតុអ្វីបានជាគ្មានបក្សកុម្មុយនិស្តក្នុងស្រុកដែលជាគូប្រជែងណាមួយគិតគូរដោះស្រាយ ហើយបណ្ដោយឲ្យទំនាក់ទំនងរបស់ខ្លួនធ្លាក់ចុះដុនដាបរហូតដល់ថ្នាក់ជ្រើសរើសយកសង្គ្រាមជាដំណោះស្រាយយ៉ាងនេះ ។

ចំពោះយួនកុម. ដោតវាសនារបស់គេក្នុងការកសាងប្រទេសឡើងវិញ បន្ទាប់ពីបានឆ្លងកាត់សង្គ្រាមចំនួនសាមសិបឆ្នាំ ពឹងផ្អែកទាំងស្រុងទៅលើបរិយាកាសសន្តិភាព ដែលជាប្រភពនៃការកាត់បន្ថយចំណាយលើកងទ័ព ហើយនិងទាក់ទាញយកជំនួយនិងពាណិជ្ជកម្មពីបរទេស ។ ការកសាងប្រទេសជាថ្មីរបស់វៀតណាម និងវឌ្ឍនកម្មសេដ្ឋកិច្ចប្រាកដជាអាចសម្រួលបានតាមការបន្តបង្ហូរជំនួយពីចិន ក្នុងផ្នែកបុគ្គលិកបច្ចេកទេស គ្រឿងបរិក្ខា និងជំនួយហិរញ្ញវត្ថុ ។ ជំនួយពីរដ្ឋាភិបាលចិនខាងផ្នែកនយោបាយយោធា និងសេដ្ឋកិច្ចដល់ខ្មែរក្រហមមានន័យថា បើវៀតណាមហ៊ានប៉ះពាល់របបថ្មីរបស់ខ្មែរ ជំនួយសេដ្ឋកិច្ចពីចិនដល់វៀតណាមនឹងត្រូវខូចខាត មិនតែប៉ុណ្ណោះថែមទាំងអាចមានការវាយបកវិញយ៉ាងដំណាំទៀតផង ។

ប៉ុន្តែ ផែនការកាន់កាប់កម្ពុជាជាផែនការមួយដែលវៀតណាមតាមព្យាយាមឈោងចាប់ យកអស់រាប់ទស_វត្សមកហើយ ។ បើយកប.ក.ក.តាមផ្លូវនយោបាយដូចលាវមិនបានទេ ហើយបើយុទ្ធសាស្ត្រខែមេសា១៩៧៥មិនជាទីសង្ឃឹមទេនោះ យួនមានតែជម្រើសមួយគត់ដើម្បីបានសម្រេចផែនការ គឺដំណោះស្រាយតាមផ្លូវយោធា ។ តែបញ្ហានៅត្រង់ថា បើសិនវៀតណាមហ៊ានប្រើកម្លាំងយោធា តើវានឹងអាចប៉ះពាល់ដល់ជំនួយសេដ្ឋកិច្ច និងការ

វាយបកពីចិនដែរឬទេ ។

ចំណែកខាងខ្មែរកុម្មុយនិស្តវិញ ដែលទ្រឹស្តី"ខ្លួនទីពឹងខ្លួន"របស់ម៉ៅបានប្រានចោលជំនួយបរទេសរួចទៅហើយនោះ គេក៏នៅមានមូលហេតុល្អៗខ្លះដែរថា ហេតុអ្វីបានជាគេគួរតែចៀសវាងជម្លោះជាមួយវៀតណាម ។ ការពិតជាក់ស្តែងសំខាន់មួយគឺ ភាពខុសគ្នារវាងកម្លាំងទ័ពរបស់ខ្លួននិងទ័ពអ្នកជិតខាង ។ កងទ័ពវៀតណាមមិនមែនគ្រាន់តែមានគ្រឿងអាវុធទំនើបជាងកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះទេ តែកងទ័ពនេះក៏មានចំនួនដប់ដងលើសខ្មែរក្រហមដែរ ។ ពិសេសជាងនោះទៅទៀត ដោយបដិវត្តន៍ខ្មែរក្រហមមានការលោតផ្លោះលឿនជ្រុលនោះ បានធ្វើឲ្យប្រជាជនខ្លួនឯងហេវហត់ខ្សោះខ្សល់ សល់តែស្បែកដណ្តប់ឆ្អឹងដែលធ្វើឲ្យខ្មែរក្រហមបាត់បង់ប្រជាប្រិយភាពនិងការគាំទ្រមូលហេតុរបស់ខ្លួន ។ ក្នុងចំណោមអ្នកដើរតួទាំងអស់នៃសង្គ្រាមនៅឥណ្ឌូចិន តាមការវាយតម្លៃទៅលើស្ថានភាពជាក់ស្តែង ពួកខ្មែរក្រហមបានធ្វើសង្គ្រាមមួយដែលស្ទើរតែគ្មានន័យអ្វីទាំងអស់ ។

បើទោះជាយួនក្តី ឬខ្មែរក្តីដែលប្រាថ្នាមិនចង់ឲ្យមានសង្គ្រាមជាមួយគ្នាយ៉ាងណាក៏ដោយ ក៏សង្គ្រាមបានផ្ទុះរួចជាស្រេចទៅហើយ ។ សង្គ្រាមផ្ទុះឡើងរវាងជនកុម្មុយនិស្តនៅឥណ្ឌូចិនមិនមែនបណ្តាលមកពីឧបាយទុច្ចរិតរបស់មហាអំណាចខាងក្រៅណា ដូចដែលខ្មែរកុម.និងយួនកុម.បានអះអាងនោះទេ តែគឺបណ្តាលមកពីទិសដៅនយោ-បាយមិនស៊ីគ្នានៃបក្សកុម្មុយនិស្តដែលជាអ្នកឈ្នះទាំងពីរ និងដោយសារអ្នកដែលខ្សោយជាងគេក្នុងចំណោមអ្នកទាំងពីរ (ខ្មែរក្រហម) **មានការយល់ដឹងស្ទើរ** អំពីបច្ចុប្បន្នភាពនៃគោលដៅសង្គមនយោបាយ និងស្ថានភាពយោធាដែលគេកំពុងប្រឡូក ។

យើងបានពិនិត្យរួចហើយអំពីភារកិច្ចវប្បធម៌នយោបាយខ្មែរក្រហម នៅក្នុងនយោបាយក្រៅប្រទេសរបស់កម្ពុជា ។ ឥឡូវ យើងងាកមកពិនិត្យដោយយ៉ាៗអំពីទំនាក់ទំនងនៃវចនាសម្ពន្ធ និងវប្បធម៌នយោបាយក្នុងស្រុករបស់វៀតណាមវិញម្តង ។

## ២_ព្រឹត្តិការណ៍ផ្ទៃក្នុងនៃនយោបាយក្រៅប្រទេសរបស់វៀតណាម៖

ក្នុងការយកបានវៀតណាមខាងត្បូងនៅចុងខែមេសា១៩៧៥ យួនកុម.មានបញ្ហាជាច្រើនដែលត្រូវប្រឈមមុខ ។ ក្នុងកិច្ចចាត់ចែងគ្រប់គ្រងការចុះចូលនៃទាហានខ្មាំងចំនួនមួយលាននាក់ និងការត្រួតត្រាសង្គមមួយដែលមនុស្សជាង២០លាននាក់ស្អប់កុម្មុយនិស្ត ហើយដែលអ្នកខ្លះជាអ្នកនយោបាយផងនោះ គឺជាការទទួលយកមួយដ៏មានទំហំធំធេងពន់ពេកណាស់ ។

ក្រោយលទ្ធផលជ័យជំនះទៅលើបារាំងនៅឆ្នាំ១៩៥៤ យួនកុម.បានពើបប្រទះនូវការសងសឹកបង្ហូរឈាម

និងយុទ្ធនាការកែវកម្មជាច្រើនប្រឆាំងនឹងសត្រូវចាស់របស់គេ ប្រឆាំងនឹងប្រជាជនដែលមានភ័ព្វសំណាងជាង និងប្រឆាំងនឹងពួកបញ្ញវន្តវៀតណាមខាងជើង ។ យុទ្ធនាការនេះ ដែលពាក្យពេញលេញគេហៅថា "**យុទ្ធនាការប្រឆាំងនឹងប្រតិបជិវត្តន៍និងយុទ្ធនាការកែទម្រង់ដីធ្លី**" មិនមែនគ្រាន់តែយកតាមគំរូដែលបានធ្វើហើយនៅប្រទេសចិនប៉ុណ្ណោះទេ តែគឺថែមទាំងបានប្រព្រឹត្តទៅក្រោមការឃ្លាំមើលរបស់កម្មាភិបាលកុម្មុយនិស្តចិនទៀតផង ។ យួនរាប់ម៉ឺននាក់បានត្រូវប្រហារជីវិតនៅក្នុងយុទ្ធនាការនោះ ។

ក្នុងរយៈពេលពីរទសវត្សបន្ទាប់ ឥទ្ធិពលនៃ"ការស្ថាបនាសង្គមនិយមជាគំរូរបស់ចិន"ទៅលើនយោបាយក្នុងស្រុករបស់យួនចេះតែប្រែប្រួលឥតឈប់ឈរ ។ តែនៅឆ្នាំ១៩៧៥ ឥទ្ធិពលរបស់ចិនកុម.ទៅលើយួនកុម. បើ-ទោះជាមិនទាន់រលាយបាត់អស់ក៏ដោយ ក៏ឥទ្ធិពលនេះបានធ្លាក់ចុះដល់កម្រិតទាបបំផុតទៅហើយ ។ ឥឡូវ ដោយងាយទទួលយកឥទ្ធិពលពីសហភាពសូវៀតជាង និងដោយទំហំនៃភាពងាយប្រែក្រឡាប់នៃមតិរបស់សហគមន៍នយោបាយអន្តរជាតិមេដឹកនាំយួនជ្រើសរើសយកកម្មវិធីមួយដែលមានការបង្ហូរឈាមតិចជាងកាលពីឆ្នាំ១៩៥០ ។

មេដឹកនាំហាណូយបានចោតបញ្ជាតអតីតនាយទាហាន និងមន្ត្រីរដ្ឋការរបស់វៀតណាមខាងត្បូងដែលចុះចាញ់ប្រហែលពីរយពាន់នាក់យកទៅដាក់គុក ដោយបង្ខំឱ្យធ្វើការធ្ងន់ជាច្រើនឆ្នាំ ។ បន្ទាប់មក មេដឹកនាំហា-ណូយបានរំលាយចោលនូវអង្គការសង្គមកិច្ចឯករាជ្យទាំងឡាយមានសាលារៀន សមាគមកីឡា និងអង្គការសប្បុរសធម៌ផ្នែកសាសនានៅវៀតណាមខាងត្បូងដែលទើបដណ្តើមបាន ហើយដាក់សង្គមថ្មីទាំងមូលឱ្យនៅក្រោមការត្រួតត្រារបស់អង្គការបក្ស ។ អ្នកណាដែលប្រឆាំងនឹងផែនការនេះត្រូវគេចាប់ចង និងត្រូវគេចោទថាជា សេអ៊ីអា (ភ្នាក់ងារសម្ងាត់អាមេរិកាំង) ។ ជនជាតិយួន ដែលគេចាប់ចងពីបទប្រឆាំងនយោបាយ ត្រូវបានអ្នកសួរចម្លើយនិងទីភ្នាក់ងារពត៌មានរដ្ឋចោទប្រកាន់ថាជា"ភ្នាក់ងារចក្រពត្តិនិយម" និងជាពិសេស"ភ្នាក់ងារ សេអ៊ីអា ។

នៅក្នុងនយោបាយនេះ យើងអាចមើលឃើញឥទ្ធិពលទាំងខាងមនោគមន៍វិជ្ជាម៉ាក់_ឡេនីន និងទាំងខាងការបេកស្រាយផ្ដេសផ្ដាសខ្លះនៃជីវិតនយោបាយ ។ ប៉ុន្តែដំណោះស្រាយរបស់យួនកុម.ទៅលើបញ្ហានយោបាយ បើទោះជាត្រឹមត្រូវផងនិងមិនត្រឹមត្រូវផងក៏ដោយ ក៏ដំណោះស្រាយនោះធ្វើឡើងដោយបានគន់គូរ និងថ្លឹងថ្លែង ។ គឺព្រឹត្តិការណ៍ឆ្នាំ១៩៧៥ដែលប្រព្រឹត្តទៅដោយគ្មានការរំជើបរំជួល និងដោយអហិង្សានោះហើយដែលជាលក្ខណៈសំគាល់នៃមាគ៌ានយោបាយរបស់ ហ្សូសេហ្វ ស្តាលីន ( Joseph Stalin) និងម៉ៅសេទុងដែលជាគ្រូដើមរបស់យួនកុម. ហើយដែលវៀតណាមបានទំប្រើងរត់តាមឱ្យទាន់កាលពីឆ្នាំ១៩៥០ ។ ដំណោះស្រាយរបស់វៀតណាមជាដំ-ណោះស្រាយដែលមិនសូវផ្តាប់មុខជ្រុល និងមិនសូវហិង្សាដូចសមមិត្តប្អូន*ខ្មែរ* របស់គេឡើយ ។

## ៣_មហន្តរាយនៅជិតមាត់ជ្រោះ

## ទំនាក់ទំនងរវាងសាធារណរដ្ឋសង្គមនិយមវៀតណាមនិងកម្ពុជាប្រជាធិបតេយ្យ, ខែមេសា_សីហា១៩៧៥

នៅពេលទីក្រុងភ្នំពេញចុះចាញ់ពួកទ័ពព្រៃ ថ្ងៃ១៧មេសា១៩៧៥ ក្រុមអ្នកឈ្នះខ្មែរក្រហមបានទទួលការអបអរសាទរសើរយ៉ាងកក់ក្តៅពីយួនកុម. ។ ពីរអាទិត្យក្រោយមក វៀតណាមខាងជើងយកព្រៃនគរបាន ។ គឺក្នុងរយៈពេលនោះដែរដែលខ្មែរក្រហមបានបណ្តេញប្រជាជនខ្មែរចេញពីទីប្រជុំជនធំៗទាំងឡាយនៃកម្ពុជា ។ ពេលនោះកម្ពុជាដែលទទួលឈ្មោះថ្មីថា កម្ពុជាប្រជាធិបតេយ្យ ក៏បានចាប់ផ្តើមដំណើរយ៉ាងវែងឆ្ពោះទៅកាន់ សុក្រឹតសង្គមនិយមម៉ៅ (MaoistUtopia) ។ ប៉ុន្តែបើទោះជាមានភាពខុសគ្នាដូចមេឃនិងដីនៅក្នុងដំណោះស្រាយបដិវត្តិរវាងវៀតណាមនិងកម្ពុជាក៏ដោយ ក៏នៅមានសញ្ញាជាសាធារណៈខ្លះទៀតដែលបង្ហាញអំពីការមិនពេញចិត្តរបស់វៀត_ណាមចំពោះ សង្គមពិសោធន៍ថ្មី នៃអ្នកជិតខាងរបស់គេ ។

អ្នកដឹកនាំថ្មីនៃកម្ពុជាប្រជាធិបតេយ្យកំពុងតែពុលច្អកឡប់នឹងជ័យជំនះទៅលើសាធារណរដ្ឋខ្មែរ ។ គេថែមទាំងបានសង្កត់ធ្ងន់ថា សង្គ្រាមនេះឈ្នះដោយគ្មានបរទេសណាជួយទេ គឺពួកគេម្នាក់ឯងគត់ដែលបានផ្តួល "ចក្រ_ពត្តិអាមេរិក" ។

មុនខែកញ្ញា១៩៧៧ កម្ពុជាប្រជាធិបតេយ្យធ្វើទំនាក់ទំនងផ្លូវទូតជាអន្តរជាតិដោយមានកំណត់ ។ មិត្តបរទេសសំខាន់របស់គេគឺ ចិនដីគោកនិងកូរ៉េខាងជើង ។ តែទោះម្តេចម្តា នៅពេលដែលខ្មែរក្រហមមានទំនាស់ជាអន្តរជាតិខ្លះ ដូចជាការប៉ះទង្គិចជាមួយ ស.រ.អ. អំពីការចាប់នាវាអាមេរិកាំង ម៉ាយ៉ាគ្វេស (Mayaguez) ខ្មែរក្រហមក៏បានទទួលការគាំទ្រពីហាណូយដែរ ។

ដោយលាក់បំបាំងពីភ្នែកអន្តរជាតិ ភាពតានតឹងដែលកើតមានឡើងក្នុងសម័យសង្គ្រាមមិនបានធូរស្រាលទេ តែវាបែរជាធ្ងន់ឡើងៗទៅវិញ ។ បញ្ហានៅពីក្រោយរាំងនន គឺជម្លោះទល់ដែនរវាងខ្មែរនិងយួន ។ ដូចយើងបានជម្រាបជូនរួចហើយក្នុងជំពូកមួយ នៅចន្លោះឆ្នាំ១៨៧០និង១៩១៤ រដ្ឋបាលអាណានិគមបារាំងបានគូសវាសសាជាថ្មីនូវព្រំប្រទល់រវាងកម្ពុជានិងវៀតណាម ដោយបានកាត់ទឹកដីខ្មែរទៅឱ្យយួនដែលស្ថិតនៅក្រោមអាណា_ព្យាបាលរបស់ខ្លួន ។ នៅក្នុងកិច្ចព្រមព្រៀងចកសមុទ្រអាឡុង **ខែមិថុនា១៩៤៨ បារាំងបានទទួលស្គាល់ថា ទឹកដីកូសាំងស៊ីន ឬកម្ពុជាក្រោមជាទឹកដីរបស់យួន** ។

កំហឹងក្រេវក្រោធរបស់ខ្មែរភាគច្រើនចំពោះភាពដ៏អាម៉ាស់ រួមជាមួយនឹងស្មារតីវីជ័យភាពដែលបាន

ជ្រួតជ្រាបពេញខ្មែរក្រហមហើយនោះ ក៏បានបង្កវដាមហិច្ឆតាយ៉ាងខ្លាំងក្លាមួយ ក្នុងការដណ្ដើមយកទឹកដីដែលបាត់បង់មកវិញ ។ សម្ដេចសីហនុបានរាយការណ៍ថា នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានប្រាប់ទ្រង់ថា "**ពួកយើងនឹងរំដោះយកកម្ពុជាក្រោមមកវិញ**" ។ តែមហិច្ឆតានោះបានត្រូវស្រុតស្រកអន់ថយមកវិញដោយកត្តាប្រាកដនិយមខាងផ្នែកយោធា ។

នៅថ្ងៃជោគជ័យខែមេសា១៩៧៥របស់គេ ទ័ពខ្មែរក្រហមមាន២៣០កងវរសេនាតូចដែលមិនសូវសម្បូណ៌អាវុធ ហើយដែលសាច់ទ័ពទាំងអស់មានប្រមាណពី៥៥ពាន់ទៅ៦០ពាន់នាក់ ។ យួនខាងជើងមានទ័ព៦៨៥ពាន់នាក់ ប្រដាប់ដោយអាវុធទំនើប គាំទ្រដោយកងទ័ពជើងទឹក៣ពាន់នាក់ និងកងទ័ពអាកាស១២ពាន់នាក់ ជាមួយនឹងយន្តហោះចម្បាំង២៦៨គ្រឿង ដោយបូកបញ្ចូលអាកាសយានទម្លាក់គ្រាប់បែកធុនតូចមួយកង និងយន្តហោះប្រដេញទម្លាក់គ្រាប់បែក៦កងផង ។

ដើមខែឧសភា ខ្មែរក្រហមបានវាយប្រហារទៅលើកោះកាន់កាប់ដោយវៀតណាមនៅក្នុងឈូងសមុទ្រថៃដោយទាមទារយកកោះខ្មែរដែលបារាំងបានប្រគល់ទៅឱ្យយួន ហើយដែលយួនយកធ្វើជាសម្បត្តិរបស់គេ ។ ដោយភ្ញាក់នឹងទង្វើទាំងនោះ យួនកុម.បានវាយបកដោយឥតរួញរា ។ នៅចុងខែឧសភា យួនបានវាយយកកោះជាច្រើនទៅវិញ ចាប់ខ្មែរក្រហមជាឈ្លើយ៣០០នាក់ ។ ដើមខែមិថុនា យួនបានបើកការវាយលុកបន្តទៅមុខទៀតដើម្បីដណ្ដើមយកកោះត្រល់ (បារាំងហៅ ពូលូវ៉ៃ) ។ ទង្វើនេះហាក់ដូចជាបានរារាំងខ្មែរក្រហមឱ្យឈប់ប្រឈមមុខនឹងយួនតទៅទៀត ។

តាមប្រភពវៀតណាមនៅថ្ងៃ២ធ្នូ១៩៧៥ ប៉ុល_ពតបានទទួល **ង្វៀន_វ៉ាន់លិញ** តំណាងបក្សពលករវៀត_ណាម ។ ប៉ុលពតបានប្រាប់**លិញ**ថា ការវាយប្រហារបណ្ដាលមកពីយោធាខ្មែរក្រហម "មិនស្គាល់ភូមិសាស្ត្រ" ។ ខែមិថុនា១៩៧៥ ប៉ុលពត, នួនជា, និងអៀងសារីបានដឹកនាំគណៈប្រតិភូមួយទៅហាណូយជាសម្ងាត់ដើម្បីធ្វើការចរចា ។ ខែកក្កដា១៩៧៥ គណៈប្រតិភូជាន់ខ្ពស់មួយពីវៀតណាមដឹកនាំដោយលេខាធិការបក្សកុម្មុយនិស្តទីមួយ **ឡេយន់** បានធ្វើទស្សនកិច្ចជាមិត្តភាពមួយនៅកម្ពុជា ។ គោលបំណងពិតប្រាកដនៃទស្សនកិច្ចនៅពេលនោះគេមិនបានឱ្យដឹងទេ តែក្រោយមកគេបានដឹងថា គឺដើម្បីផ្ដោតទៅលើជម្លោះព្រំប្រទល់ និងទឹកដីរវាងប្រទេសទាំងពីរ ។ (កោះត្រល់ដែលយួនបានយក ត្រូវបានប្រគល់មកវិញនៅខែសីហា) ។

ជាសាធារណៈ យួនកុម.តែងតែថាគ្មានអ្វីជាបញ្ហាទេ ។ព្រឹត្តិប័ត្រប្រចាំខែរបស់ហាណូយឈ្មោះអ្នកនាំសារវៀតណាមនិយាយថា កិច្ចចរចាបានប្រព្រឹត្តទៅ"ក្នុងបរិយាកាសស្និទស្នាល ពោរពេញទៅដោយស្មារតីជាភាតរភាព។

បញ្ហាពិភាក្សាទាំងឡាយបានត្រូវសម្រេចជាឯកច្ឆន្ទ" ។ សេចក្តីសង្ខេបនៃអត្ថបទបានបន្តទៅទៀត: ថ្វីបើមានភាពមិនស្របគ្នាក្នុងទស្សនៈនៃរបបទាំងពីរចំពោះ"ការកសាងសង្គមនិយម"ក៏ដោយ ព្រឹត្តិប័ត្រវៀតណាមក៏នៅបានសរសើរខ្មែរក្រហម ដែលបានបណ្តេញប្រជាជនចេញពីទីក្រុង ។ គេបានសរសើរសង្គមកម្ពុជាថ្មីដោយគ្មានកំណត់ព្រំដែន: "រំដោះកម្ពុជាបាន គឺបានរស់នៅក្នុងបរិយាកាសសុខសាន្តថ្មីមួយ" ។

## ៤_បង្កើតទំនាក់ទំនងធម្មតាជាចំហៈ ខែសីហា១៩៧៥_ខែធ្នូ១៩៧៦

វៀតណាមនៅមានសល់ទ័ពខ្លះលើទឹកដីខ្មែរ ក្រោយជ័យជំនះរួមរបស់ពួកកុម្មុយនិស្តឆ្នាំ១៩៧៥ ។ ចិនទំព្រើងប្រែងតាមផ្លូវនយោបាយខ្លះដើម្បីបញ្ចុះបញ្ចូលមេដឹកនាំហាណូយ ថាគួរតែដកកងទ័ពខ្លួនទៅវៀតណាមវិញ ។ យើងគ្រាន់តែអាចសន្និដ្ឋានបានថា **វៀតណាមបានចាត់ទុកកងទ័ពនេះជាជាមធ្យោបាយដ៏មានថាមពលមួយសម្រាប់ទិសដៅនយោបាយអនាគតនៅក្នុងកម្ពុជា** ។ ម្យ៉ាងទៀតមេដឹកនាំហាណូយជឿថា ទិសដៅនយោបាយដែលកម្ពុជាប្រុងធ្វើនោះជាទិសដៅរយៈពេលវែង មិនមែនជាទិសដៅដែលគេត្រូវគិតគូរជាបន្ទាន់ទេ ។

ក្នុងកំលុងឆ្នាំ១៩៧៦ មានការទទួលអបអរជាសាធារណៈ ប្តូរគ្នាទៅវិញទៅមកតាមរយៈពិធីការពិសេសជាច្រើន ។ ការប្រកាសរដ្ឋធម្មនុញ្ញដោយប្រជាជនខ្មែរបានត្រូវទទួលស្វាគមន៍ដោយប្រជាជនវៀតណាមនៅខែមករា១៩៧៦ ។ វិចារណកថារបស់ **ញ៉ាន់ដាន់** (ទិន្នានុប្បវត្តិផ្លូវការរបស់បក្សវៀតណាម) បានអះអាងថា រដ្ឋធម្មនុញ្ញបានត្រូវ"អនុមតិជាឯកច្ឆន្ទ"ដោយសមាជជាតិទីបីនៃតំណាងប្រជាជនកម្ពុជា "តាមការពិភាក្សាដ៏ទូលំទូលាយនិងប្រកបដោយប្រជាធិបតេយ្យ ក្នុងចំណោមគ្រប់ស្រទាប់ប្រជាជនទូទាំងប្រទេស" ។ កាសែតបានបញ្ជាក់នូវឥរិយាបទជាវិជ្ជមានមួយចំពោះការសម្រេចជោគជ័យនៃអ្នកជិតខាងរបស់ខ្លួន: "ថ្វីបើបានជួបប្រទះនូវការលំបាកគ្រប់បែបយ៉ាងក៏ដោយ បដិវត្តន៍កម្ពុជាចេះតែធ្វើដំណើរទៅមុខជាដរាប" ។

នៅខែមេសា១៩៧៦ បុណ្យខួបទីមួយនៃជ័យជំនះខ្មែរក្រហមបានត្រូវស្វាគមន៍ដោយបក្សវៀតណាមនិងមេដឹកនាំរដ្ឋាភិបាល ។ ឡេយន់, តុងឌឹកថាំង, ត្រឿងជិញ និងផាំវ៉ាន់ដុងបានផ្ញើសារលិខិតសរសើរខៀវសំផន, នួនជា, និងប៉ុលពត ក្នុងការដែលអ្នកទាំងបីត្រូវបានជ្រើសតាំងជាគណៈប្រធានរដ្ឋ ជាប្រធានរដ្ឋសភា និងជានាយករដ្ឋមន្ត្រី ។ សារលិខិតបានដៅទៅលើ "មហាជ័យជំនះនៃការតស៊ូប្រឆាំងនឹងចក្រពត្តិអាមេរិកាំងនិងខ្ញុំបំរើក្នុងការរំដោះប្រទេសបានទាំងស្រុង" ។ បណ្តាញផ្សាយពត៌មានវៀតណាមបានពោលដោយត្រេកត្រអាលអំពី"ស្នាដៃនៃកម្មករ កសិករនិងកងទ័ពបដិវត្តិកម្ពុជា" ។ គេក៏បានថ្កោលទោសផងដែរចំពោះការទម្លាក់គ្រាប់បែកនៅសៀមរាប

ខែកុម្ភៈ១៩៧៦ ដោយយន្តហោះស.រ.អ. ដែលជាការពាលអះអាងដោយគ្មានភស្តុតាងដដែលៗរបស់ពួកខ្មែរក្រហម ។ វិទ្យុហាណូយបានស្រែកបន្ទរបន្ថែមទៀតដើម្បីការពារខ្មែរក្រហមៈ

**"ចក្រពត្តិអាមេរិកបានជួយឧបត្ថម្ភ និងជួយពន្យុះពួកប្រតិកិរិយាថៃឲ្យបង្ករឿង និងបង្ករហិង្សានៅតាមទល់ដែនកម្ពុជា ដោយបញ្ជូននាវាចម្បាំងទៅក្នុងដែនសមុទ្រខ្មែរ ចាប់អ្នកនេសាទស្លូតត្រង់ ញុះញង់ប្រជាជនឲ្យរត់ទៅប្រទេសថៃ ហើយនិយាយបង្កាច់បង្ខូចរបបថ្មីនៃកម្ពុជា ។"**

ខែមិថុនា១៩៧៦ នៅពេលបុណ្យខួបទី៧នៃកំណើតរដ្ឋាភិបាលបដិវត្តិបណ្តោះអាសន្នសាធារណរដ្ឋវៀតណាមខាងត្បូង (របទាសម្តន្ទរដ្ឋបាលតំណាងយួនកុម.នៅវៀតណាមខាងត្បូង) មេខ្មែរក្រហមបានផ្ញើសារមួយដើម្បីសម្តែងការកោតសរសើរ ។ ទង្វើនេះបានត្រូវថ្លើយតបវិញយ៉ាងកក់ក្តៅពីមេដឹកនាំរដ្ឋាភិបាលបដិវត្តបណ្តោះអាសន្ន ។ មួយខែក្រោយមក នៅក្នុងឱកាសបង្រួបបង្រួមវៀតណាមជាផ្លូវការដែលមានឈ្មោះថា សាធារណរដ្ឋសង្គមនិយមវៀតណាម (ស.ស.វ.) វិទ្យុភ្នំពេញបានផ្សាយអត្ថាធិប្បាយមួយមានចំណងជើងថា "យុទ្ធសាមគ្គីភាពនិងមិត្តភាពរវាងប្រជាជននៃកម្ពុជាប្រជាធិបតេយ្យ និងស.ស.វ. រីកដុះដាលឡើងជានិច្ច កាន់តែបៃតងឡើង និងរឹងប៉ឹងឡើង" ។

គណៈប្រតិភូផ្លូវការផ្សេងៗគ្នាជាច្រើនបានមកទស្សនាកម្ពុជានាឆ្នាំ១៩៧៦ ។ គណៈប្រតិភូពត៌មាន វៀតណាមបានត្រូវទទួលនៅខែកក្កដា ។ នៅក្នុងសុន្ទរកថាលាគ្នា ផ្សាយតាមវិទ្យុភ្នំពេញ ប្រធានគណៈប្រតិភូបានសរសើរ "ស្នាដៃដ៏ធំធេងនៃប្រជាជននិងបដិវត្តន៍កម្ពុជា" និងបាននិយាយអំពី"វីរភាពនៃប្រជាជនកម្ពុជា ក្រោមការដឹកនាំដ៏ភ្លឺស្វាងរបស់អង្គការបដិវត្ត" ។ តំណាងគណៈប្រតិភូបានថ្លែងអំណរគុណចំពោះសមមិត្តប្រធាននៃបដិវត្តន៍កម្ពុជា ។

ខែកក្កដា កិច្ចព្រមព្រៀងមួយបានត្រូវចុះហត្ថលេខាដោយតំណាងនៃរដ្ឋាភិបាលទាំងពីរ ដើម្បីបើកផ្លូវអាកាសរវាងហាណូយនិងភ្នំពេញ ។ ប៉ុន្តែនៅខែដដែលនោះ សញ្ញានៃភាពតានតឹងដំបូងជាទូទៅរវាងអ្នកដឹកខាងទាំងពីរក៏លេចរូបរាងឡើង ។ នៅក្នុងសម្ភាសន៍មួយជាមួយតំណាងសារពត៌មានវៀតណាម និងគណៈប្រតិភូទូរទស្សន៍ដែលបានមកធ្វើទស្សកិច្ចនៅកម្ពុជា ប៉ុលពតបាននិយាយអំពីមិត្តភាព និងឯកភាពកម្ពុជា-វៀតណាមថាជា "បញ្ហាយុទ្ធសាស្ត្រមួយនិងជាមតិពិសិដ្ឋមួយ...។ ដរាបណាមិត្តភាពនិងសាមគ្គីភាពនេះរឹងមាំ ដរាបនោះទើបបដិវត្តន៍នៃប្រទេសយើងទាំងពីរបានរីកចម្រើនគួរជាទីពេញចិត្ត" ។ គាត់បានសារភាពថា"ឧបសគ្គនិងការលំបាកទាំងឡាយអាចនឹងកើតឡើងបាន ។ ហេតុនេះ កម្ពុជាមានបំណងចង់ប្រកាន់យកជំហរនេះយ៉ាងខ្ជាប់ខ្ជួន" ។

ថ្ងៃ២១កញ្ញា១៩៧៦ សេវាកាស (air service) រវាងហាណូយនិងភ្នំពេញ កាត់តាមព្រៃនគរ បានចាប់ផ្តើមបើក ។ គណៈប្រតិភូស្ត្រីកម្ពុជាបានធ្វើទស្សនកិច្ចនៅវៀតណាម ក្នុងខែសីហានិងកញ្ញា១៩៧៦ ។ បន្ទាប់មកនៅខែធ្នូ១៩៧៦ អង្គការបដិវត្ត (ដែលបក្សកុម្មុយនិស្តកម្ពុជាដាក់ឈ្មោះឲ្យខ្លួនឯង) បានផ្ញើរទូនបណ្ណ (Greeting card) ទៅបក្សពលករវៀតណាមនៅក្នុងឱកាសសមាជទីបួនរបស់គេ ។

ដូច្នេះមកដល់ចុងឆ្នាំ១៩៧៦ សភាពខាងក្រៅនៅតែបង្ហាញចំណងជិតស្និទ្ធរវាងបក្សកុម្មុយនិស្តនិងរដ្ឋាភិបាលវៀតណាមនិងកម្ពុជានៅឡើយ ។ តែសញ្ញាខាងក្រៅនេះបានបិទបាំងនូវចំណងពិតប្រាកដរបស់បក្សទាំងសងខាង ។ មេដឹកនាំយួនសង្ឃឹមថា **គេអាចនឹងបញ្ចូលភ្នាក់ងាររបស់គេទៅក្នុងថ្នាក់ដឹកនាំនៃបក្សកុម្មុយនិស្តកម្ពុជាបាន** ។ នៅពេលជាមួយគ្នានោះដែរ មេដឹកនាំកម្ពុជាប្រជាធិបតេយ្យក៏កំពុងចេះក្តៅងំដោយភ្លើងកំហឹង និងការភ័យខ្លាចពីវៀតណាមដែលអាចពុះកញ្ជ្រោលឡើង ហើយបង្កទៅជាមានការប្រឈមគ្នាខាងផ្លូវអាវុធ ។

## ៥_កម្ពុជានៅក្នុងបរិបទនៃទស្សនវិស័យយុទ្ធសាស្ត្រទៅរបស់ហាណូយៈ

ដូចយើងបានឃើញរួចមកហើយ មេយួនកុម.តែងតែសង្ឃឹមជានិច្ចថាចលនាកុម្មុយនិស្តកម្ពុជា ដែលគេបានបង្កើតនិងជួយឧបត្ថម្ភជាច្រើនទសវត្សមកហើយនោះ នៅពេលដណ្តើមអំណាចរដ្ឋបាន អាចនឹងដើរតាមមាគ៌ានយោបាយងាកទៅខាងយួនដូចលាវកុម្មុយនិស្តដែរ ។ តែក្តីសង្ឃឹមរបស់វៀតណាមត្រូវរលាយបាត់សូន្យ ។ ចាប់ពីដើមឆ្នាំ១៩៧៣រហូតដល់ឆ្នាំ១៩៧៥ វៀតណាមជាចំណុចដែលត្រូវរងការវាយប្រហារពីយោធាខ្មែរក្រហមសំខាន់បំផុតនៅក្នុងទឹកដីខ្មែរ ហើយនៅពេលចប់សង្គ្រាម នឹងវាយចូលទៅក្នុងទឹកដីវៀតណាមទៀត ។ មានតែការវាយបកផ្តាច់ព្រ័ត្រទៅលើទ័ពខ្មែរក្រហមដែលកាន់កាប់កោះនៅក្នុងឈូងសមុទ្រថៃ ពីខែឧសភាដល់ខែមិថុនា១៩៧៥ប៉ុណ្ណោះទេ ដែលបានបង្ក្រាបការវាយលុករបស់ខ្មែរក្រហមប្រចាំងនឹងសម្ពន្ធមិត្តចាស់របស់គេ ។

បើទោះជាជំហរនយោបាយរបស់គេទន់ខ្សោយនៅក្នុងកម្ពុជាក៏ដោយ មេដឹកនាំយួននៅតែចិញ្ចឹមក្តីសង្ឃឹមជានិច្ច ចំពោះការរៀបចំដាក់ឡើងវិញនូវឥទ្ធិពលរបស់គេនៅក្នុងជួរដឹកនាំខ្មែរក្រហម ។ ជាពិសេស ការលាលែងពីមុខតំណែងនាយករដ្ឋមន្ត្រីរបស់ប៉ុលពត ដែលបានប្រកាសជាសាធារណៈតាមវិទ្យុភ្នំពេញ ក្នុងខែកញ្ញា១៩៧៦ បានត្រូវផាំវ៉ាន់ដុង និងឡេយន់យកចិត្តទុកដាក់ពិចារណាជាទីបំផុត ។

នៅក្នុងកិច្ចសន្ទនាជាមួយឯកអគ្គរដ្ឋទូតសូវៀតប្រចាំវៀតណាម ថ្ងៃ៦វិច្ឆិកា១៩៧៦ ផាំវ៉ាន់ដុងបានចាត់ទុកស្ថានការណ៍នៅកម្ពុជាថាជាបញ្ហាស្មុគស្មាញ "ដែលជាហេតុធ្វើឲ្យគាត់ពិបាកនិយាយឲ្យបានច្បាស់លាស់" ។ ផាំវ៉ាន់ដុងគិតថាប្រហែលប៉ុលពតឈឺ ។ គាត់បានដៅបញ្ជាក់ថា ចំពោះមេដឹកនាំហាណូយ ការលាលែងពីតំណែង

របស់ប្អូនថ្លៃប៉ុលពត (រដ្ឋមន្ត្រីការបរទេសអៀងសារី) មិនអាចកើតមានឡើងបានទេ ។ ផ.វ.ដុងនិយាយថា: គេដឹងច្បាស់ណាស់ថាអៀងសារីជាអ្នកនិយមចិន ។ **នួនជា នាយករដ្ឋមន្ត្រីថ្មី "យើងងាយធ្វើការជាមួយជាង យើងស្គាល់គាត់គ្រាន់បើជាងមេដឹកនាំកម្ពុជាឯទៀត"** ។

ក្នុងជំនួបជាមួយទូតសូវៀត ថ្ងៃ១៦វិច្ឆិកា១៩៧៦ ឡេយន់បានស្មានថា ប៉ុលពតនិងអៀងសារីទំនងជាត្រូវគេដកចេញពីមុខតំណែង ។ ការនេះ វៀតណាមនឹងទទួលស្វាគមន៍ពីព្រោះខ្មែរពីររូបនេះត្រូវបានគេនិយាយថាបានបង្កើត"និកាយនិន្នាការចិន ដែលដឹកនាំទៅរកនយោបាយគ្រោតគ្រាតនិងតឹងរ៉ឹង" ។ គាត់បន្ថែមទៀតថា "ពួកនេះជាមនុស្សអាក្រក់" ។ **ឡេយន់បានអះអាងថា: នួនជា សមាជិកម្នាក់នៃគណៈកម្មាធិការអចិន្ត្រៃយ៍និងលេខាធិការដ្ឋាន ដែលត្រូវជាក់ជំនួសប៉ុលពតជានាយករដ្ឋមន្ត្រីនៅខែកញ្ញា គឺជាមនុស្សម្នាក់ដែលមាននិន្នាការទៅខាងយួន ។ ឡេយន់និយាយថា: "នួនជា ជាមនុស្សរបស់យើង និងជាមិត្តផ្ទាល់ខ្លួនរបស់ខ្ញុំ"** ។

ក្នុងការបញ្ចេញយោបល់អំពីនួនជានេះ មេដឹកនាំយួនកុម.ទាំងពីរយល់ថាជាការភាន់ច្រឡំធំណាស់ ។ ប៉ុន្តែការភាន់ច្រឡំនេះមិនមែនជាការវេរីវាយសម្រាប់ពេលនោះទេ ។ ដូចយើងនឹងបានឃើញថា **ឡេយន់** រំលឹកមតិនេះឡើងវិញនៅពេលពីរឆ្នាំបន្ទាប់មក ។

ឡេយន់ក៏បានបញ្ជាក់ផងដែរ នូវសេចក្តីទុកចិត្តរបស់គាត់ថា បើទោះជាពេលនេះមានឧបសគ្គក៏ដោយ ទំនាក់ទំនងអាចរីកចំរើនទៅតាមវិធីមួយដែលគាត់ចូលចិត្ត: **"ខ្ញុំអាចធានាថា អ្វីៗទាំងអស់នៅកម្ពុជានឹងត្រូវមានរបៀបរៀបរយ ។ មិនយូរមិនឆាប់ កម្ពុជាគង់នឹងនៅជាមួយវៀតណាម ។ ខ្មែរគ្មានច្រកណាចេញទេ ។ យើងចេះធ្វើការជាមួយពួកគេ ហើយដឹងថាកន្លែងណាត្រូវធ្វើរឹង កន្លែងណាត្រូវធ្វើទន់"** ។ ឡេយន់បានបញ្ជាក់ថា ក្នុងទំនាក់ទំនងចំពោះកម្ពុជា មេដឹកនាំវៀតណាមបានធ្វើការសម្របសម្រួលជាមួយលាវ ។ កៃសនផុមវិហាន អគ្គលេខាធិការនៃបក្សប្រជាជនលាវ "ជាមនុស្សល្អណាស់ ដែលឈរខាងវៀតណាមនិងសហភាពសូវៀត" ។

ប៉ុន្តែ ទំនាក់ទំនងរបស់ហាណូយជាមួយលាវមិនគ្រាន់តែទាក់ទិននឹងកម្ពុជាប៉ុណ្ណោះទេ ។ ក្នុងការវាយតម្លៃស្ថានការណ៍នៅប្រទេសថៃ ឡេយន់បានពោលអំពីការខកចិត្តរបស់គាត់ចំពោះមុខងាររបស់បក្សកុម្មុយនិស្តថៃ (ប.ក.ថ.) ។ បើទោះជាមានចលនាបដិវត្តនៅប្រទេសថៃក៏ដោយ ក៏ប.ក.ថ.គ្មានសមត្ថភាពក្នុងការដឹកនាំចលនានេះឡើយ ។ ឡេយន់បានភ្ជាប់បញ្ហានេះទៅនឹងហេតុដែលប.ក.ថ.ស្ថិតនៅក្រោមឥទ្ធិពលរបស់ប៉េកាំង ។ តែគាត់បានបញ្ជាក់ថា បក្សពលករវៀតណាមបានចាត់វិធានការដើម្បីពង្រឹងឥទ្ធិពលខ្លួនជាមួយប.ក.ថ. ។គាត់គិតថា: បើសមាជិកម្នាក់នៃការិយាល័យនយោបាយប.ក.ថ.ជាជនជាតិវៀតណាម រីឯលេខាធិការបក្សជាជាតិវៀតណាមពាក់

កណ្តាល គឺជាការល្អម៉្យាង ។ ប៉ុន្តែ សកម្មភាពរបស់យួនកុម.ត្រូវរាំងរំខានដោយមូលហេតុភូមិសាស្ត្រដែលផ្តាច់ប្រទេសថៃពីវៀតណាម ។ ហេតុនេះហើយបានជាវៀតណាមត្រូវដើរតួយ៉ាងសំខាន់តាមរយៈប្រទេសលាវ និងតាមរយៈបក្សប្រជាជនលាវ ។ ការយកប្រជាជនលាវធ្វើជាឈ្នាន់ បានផលចំណេញធំធេងពេកក្រៃ ដោយហេតុថា តាមសំដីឡេយន់ ប្រជាជនមានកំណើតលាវដប់លាននាក់កំពុងរស់នៅប្រទេសថៃ ។

កិច្ចសន្ទនាវាំងឡេយន់និងទូតសូវៀត ផ្តល់ដល់យើងនូវន័យខ្លឹមសារនៃប្រយោជន៍យុទ្ធសាស្ត្រដ៏ទូលំទូលាយមួយរបស់មេដឹកនាំយួនកុម.នៅក្នុងតំបន់ ។ មិនខ្វល់ពីការប្រព្រឹត្តិរបស់ខ្មែរក្រហម យួនបានគិតគូរដាក់ឥទ្ធិពលរបស់ខ្លួនទៅលើចលនាកុម្មុយនិស្តនៅប្រទេសថៃ ដែលមិនមែនជាអ្នកជិតខាងរបស់ខ្លួន ។ ការដែលយួនធ្វើនេះគឺដើម្បីប្រកួតជាមួយចិន ។ តែការប្រកួតនេះមិនមែនជាយុទ្ធសាស្ត្រនៃ**ភាពប្រាកដនិយមនយោបាយ** ដែលអាចនឹងរុញហាណូយឱ្យគាំទ្ររដ្ឋាភិបាលថៃទាល់តែសោះ (ដូចដែលសូវៀតធ្លាប់បានធ្វើនៅទីនោះនិងនៅកន្លែងផ្សេងទៀតនៃប្រទេសសមាគមអាស៊ាន ដែលរដ្ឋប្រឆាំងនឹងកុម្មុយនិស្តត្រូវបានប្រកួតជាមួយក្រុមបះបោរម៉ៅនិយម) ។ មេដឹកនាំយួនក៏បានអនុវត្តទៅតាមសេចក្តីត្រូវការចាំបាច់នៃមនោគមន៍វិជ្ជាដែរ ។ ក្នុងការខំប្រឹងប្រែងដាក់ឥទ្ធិពលរបស់ខ្លួនទៅលើប.ក.ថ. ហើយសំខាន់បំផុតទៅលើចលនាបដិវត្តថៃក៏ដូចជាទៅលើលាវនិងកម្ពុជាដែរ មេដឹកនាំវៀត-ណាមបានចាត់ទុកហាណូយថាជាចៅហ្វាយនៃបដិវត្តន៍ម៉ាក់ឡេនីនដ៏"បរិសុទ្ធ"នៅអាស៊ីអគ្នេយ៍ ។

## ៦_វិបល្លាសទិដ្ឋិរបស់ខ្មែរក្រហមៈពីសប្បុរិសភ័យ (ការភ័យស្លន់ស្លោ) ក្នុងស្រុកទៅសង្គ្រាមក្រៅស្រុក

ដូចយើងបានឃើញស្រាប់ហើយថា ខ្មែរកុម.មានមូលហេតុត្រឹមត្រូវចំពោះមហិច្ឆតារបស់វៀតណាមមកលើកម្ពុជាក្នុងអនាគតដ៏វែង ។ ប៉ុន្តែ គ្រោះថ្នាក់របស់ខ្មែរក្រហមនឹងកើតមានឡើងក្នុងពេលចាប់ៗពីមហិច្ឆតារបស់វៀតណាមក្នុងកំឡុងពាក់កណ្តាលឆ្នាំ១៩៧០ ។ តើការចាប់ស្មានរបស់ប៉ុលពតអំពីចេតនាជាបន្ទាន់ និងផែនការប្រាកដនិយមរបស់ហាណូយជាការបំផ្លើស ឬជាការចោទដោយគ្មានមូលដ្ឋាន ?

យើងទើបនឹងបានពិភាក្សាហើយ ថាវៀតណាមបានប្តូរយុទ្ធសាស្ត្រក្នុងការត្រួតត្រាចលនាកុម្មុយនិស្តនៅលាវនិងកម្ពុជា ។កត្តាសំខាន់នៃយុទ្ធសាស្ត្រនេះ គឺបញ្ចូលមកក្នុងបក្សកុម្មុយនិស្តកម្ពុជានូវមនុស្សដែលគេបានបង្វឹកនិងបានលាងខួររួចហើយ ។ នៅក្នុងករណីកម្ពុជា ហាណូយបានហ្វឹកហ្វឺននិងផ្គត់ផ្គង់នូវរបស់ដែលគេហៅថា ខ្មែរវៀតមិញ ដែលគេសន្មត់ថាជាភ្នាក់ងាររបស់គេ ។ ធ្វើដូច្នេះ ដើម្បីឱ្យមេខ្មែរក្រហមមានសត្រូវពិតប្រាកដនៅហា-ណូយ ។ ប៉ុន្តែប៉ុលពតនិងបក្សពួក ដោយបានដឹងកលល្បិចវៀតណាមរួចហើយនោះ ក៏បានចាត់ការមុនដោយចាប់ខ្មែរវៀតមិញទាំងអស់ដែលទើបមកពីហាណូយ ជាមួយនឹងកងទ័ពវៀតណាមខាងជើង នៅដើមឆ្នាំ១៩៧០ និង

មួយលើកទៀតបន្ទាប់ពីជ័យជំនះឆ្នាំ១៩៧៥ ។ តែទោះជាយ៉ាងណាក៏ដោយ ប៉ុលពតនិងបនគាត់នៅតែភ័យខ្លាចជានិច្ច ថាភ្នាក់ងារហាណូយអាចលួចបង្កប់ខ្លួននៅក្នុងបក្សរបស់គាត់ ។ នៅក្នុងសុន្ទរកថា ថ្ងៃ២៧កញ្ញា១៩៧៧ ប៉ុលពតបានពន្យល់ជាសាធារណៈ អំពីខ្សែរយៈរវាងនយោបាយក្រៅប្រទេសដ៏ប្រុងប្រយ័តរបស់គាត់ និងភេវកម្មផ្ទៃក្នុងដូច្នេះ:

**"នៅក្នុងសង្គមថ្មីនៃកម្ពុជារបស់យើង ទំនាស់ស្លាប់រស់នៅមាននៅឡើយ ដោយបណ្ដាញចារកម្មខ្មាំងដែលធ្វើការឲ្យពួកចក្រពត្តិនិយមនិងប្រតិកិរិយាអន្តរជាតិកំពុងតែរស់នៅជាមួយយើង ដើម្បីធ្វើវិទ្ធង្សនាប្រឆាំងនឹងបដិវត្តន៍យើង ។"**

ជាសម្ងាត់ ប៉ុលពតបានធ្វើការបោសសំអាតមួយទៀតនៅក្នុងបក្សនិងរដ្ឋាភិបាលរបស់គាត់ ដើម្បីកំចាត់ចោលនូវអ្វីដែលគាត់ជឿថាជាផែនការក្បត់ធ្វើរដ្ឋប្រហាររបស់ភ្នាក់ងារសូវៀតឬវៀតណាម ។ ដូច្នេះ បើសិនជាមានអំពើក្បត់ផ្ទៃក្នុងដែលមានខ្សែញាក់ពីបរទេស វាជាការធម្មតាទេដែលថាអាចមានមហាអំណាចបរទេសណាមួយដែលទទួលខុសត្រូវជាខ្មាំងសកម្ម ។ ដោយមោទនភាពជ្រួតជ្រាបជាកជាំក្នុងជ័យជំនះរបស់ខ្លួនក្រោយឆ្នាំ១៩៧៥ វាជាការពិតហើយថាខ្មែរក្រហមគួរតែគិតគូរចាត់ការពីផែនការក្បត់របស់ខ្មាំងទាំងខាងក្នុង ទាំងខាងក្រៅ ។ ម្យ៉ាងទៀត មេដឹកនាំខ្មែរក្រហមជឿហើយតែងនិយាយជារឿយៗដោយចំហថា "នៅឆ្នាំ១៩៧៥គឺកងទ័ពបដិវត្តកម្ពុជាតែម្នាក់ឯងគត់ដែលបានធ្វើឲ្យចក្រពត្តិអាមេរិកបរាជ័យ ។ ឯបច្ចាមិត្តសព្វថ្ងៃរបស់គេ (វៀតណាម) មិនមែនខ្លាំងដូចស.រ.អ.ឡើយ" ។

ខែមេសា១៩៧៧ នៅឱកាសបុណ្យខួបលើកទីពីរនៃការរំដោះទីក្រុងភ្នំពេញ រដ្ឋាភិបាលវៀតណាមនិងបណ្ដាញពត៌មានជាតិនៅហាណូយបានអបអរសាទរ និងកោតសរសើរចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្នុងកាយវិការជាសាធារណៈ រដ្ឋាភិបាលវៀតណាមមិនបានសំដែងនូវសញ្ញានៃភាពតានតឹង ឬពិរោធនឹងជាមួយអ្នកជិតខាងរបស់គេឡើយ ។ កាសែតញ៉ាន់ដាន់បានចេញផ្សាយរាយរ៉ាប់រឿងដ៏ក្បោះក្បាយយ៉ាងសប្បាយមួយរបស់គណៈប្រតិភូស្ត្រីវៀតណាមម្នាក់ ដែលទើបនឹងបានវិលត្រឡប់មកពីកម្ពុជាវិញថា: "ប្រជាជនកម្ពុជាបានវាយសម្រុកយ៉ាងសស្រាក់សស្រាំក្នុងការលើកទំនប់ប្រឡាយ... ។ ស្ត្រីៗក៏បានប្រយុទ្ធយ៉ាងអង់អាចក្លៀវក្លាជាមួយបុរសដែរ ដើម្បីក្លាយខ្លួនជាម្ចាស់ប្រទេស" ។ រីឯបក្សវៀតណាមនិងរដ្ឋបុរសទាំងឡាយក៏បានផ្ញើសារអបអរសាទរដល់យុទ្ធមិត្តរបស់គេនៅថ្ងៃខួបជ័យជំនះនោះដែរ ។ ប៉ុន្តែ កាយវិការសុចន្ទៈនេះមិនបានឲ្យផលអ្វីដល់វៀតណាមឡើយ ។ ខ្មែរក្រហមមានបំណងជ្រើសរើសយកខួបទីពីរនៃសញ្ជ័យ (ការដណ្ដើមយកបាន) របស់វៀតណាមកុម្មុយនិស្តទៅលើ

វៀតណាមខាងត្បូង ដើម្បីទុកជានលោហិតដ៏ពិតប្រាកដមួយ ។ ថ្ងៃ៣០មេសា១៩៧៧ កងឯកភាពខ្មែរក្រហម បានវាយប្រហារទៅលើភូមិនិងទីប្រជុំជនខេត្តអានយ៉ាង និងខេត្តចូដុក (វៀតណាមខាងត្បូង) ដុតផ្ទះនិងសម្លាប់ជនស៊ីវិលរាប់រយនាក់ ។ មេដឹកនាំវៀតណាមភ្ញាក់ផ្អើលស្រឡាំងកាំង ដោយគេមិនអាចយល់បាននូវយុទ្ធសាស្ត្រ សមហេតុផលណាមួយដែលនៅពីក្រោយការវាយប្រហារនោះ ។ ហេតុនេះ គេបានសម្រេចចិត្តធ្វើការវាយបកតាមកម្លាំងយោធា ។

យោងតាមមេបញ្ជាការទ័ពរងរបស់ខេត្តតាយនិញ វៀតណាមខាងត្បូង ក្នុងខែមេសានិងឧសភា១៩៧៧ កងទ័ពខ្មែរក្រហមបានវាយលុកដោយត្រង់ទៅលើភូមិវៀតណាមនៅតាមទល់ដែន ដែលធ្វើឱ្យប្រជាជនយួនរកស៊ីប្រកបការងារមិនបាន ។ ខាងវៀតណាមបានអះអាងថា គេបានស្នើឱ្យមានការសម្រុះសម្រួលដោយសន្តិវិធីអំពីបញ្ហាព្រំដែន តែត្រូវខ្មែរក្រហមជំទាស់ ។ កាលណោះ ខាងវៀតណាមថាខ្មែរក្រហមបានប្រមូលផ្តុំទ័ពពីរកងពលនៅតាមព្រំដែនជាប់នឹងខេត្តតាយនិញ ហើយនៅពាក់កណ្តាលខែឧសភា កងទ័ពនេះក៏បើកការវាយសំរុកទៅលើទឹកដីវៀតណាម ។

ដំណឹងពីការប្រយុទ្ធគ្នាដ៏ធំរវាងទ័ពកុម្មុយនិស្តនេះ ត្រូវប្រើពេលរាប់ខែទម្រាំនឹងបានលេចឮដល់ពួកបរទេស ។ នៅចុងខែមិថុនា វិទ្យុទីក្រុងដាការតាបានផ្សាយថា មានការប្រយុទ្ធគ្នាតាមផ្លូវអាវុធនៅក្នុងខេត្តវៀត-ណាមពីរ ។ ចុងខែកក្កដា វិទ្យុភ្នំពេញបានចាប់ឱ្យតំរុយពីវិបត្តិនៅទល់ដែន ។ ពីរបីថ្ងៃកន្លងមក វិទ្យុភ្នំពេញបានផ្សាយជាលើកទីមួយនូវអ្វីដែលគេចាត់ថា ជាគ្រោះថ្នាក់របស់កម្ពុជាដែលត្រូវ **ត្រូវបាក់លេចដោយកម្លាំងខាងក្រៅជំតឈ្មោះមួយ ។**

ក្នុងកំឡុងចុងខែសីហា១៩៧៧ វិទ្យុភ្នំពេញបានចាប់ផ្តើមលើកសរសើរ"ការប្រុងប្រយ័ត្នបដិវត្តខ្ពស់"នៃកងទ័ពបដិវត្តតំបន់ភ្លៀសាន ក្នុងការបង្ក្រាបជោគជ័យដើម្បីការពារព្រំប្រទល់ ។ សេចក្តីរាយការណ៍ផ្សេងៗទៀតបានបញ្ជាក់ថា កម្ពុជានិងវៀតណាមកំពុងប្រយុទ្ធគ្នានៅសមរភូមិជួរមុខជាច្រើនតាមបណ្តោយព្រំដែន ។ កងទ័ពទាំងសងខាងត្រូវបានគេនិយាយថា មានចំនួនពី៤០០០ទៅ៥០០០នាក់ ។ វិទ្យុភ្នំពេញ នៅពេលដែលកំពុងតែកោតសរសើរពលិកម្មរបស់កងទ័ព ក៏បានពន្យល់ផងដែរថាពួកគេកំពុងតែប្រឈមមុខនឹងការប្រុងប្រៀបប្រទាក់ក្រឡាជាស្រេចនៃបច្ចាមិត្ត ។ មិនត្រឹមតែចក្រពត្តិអាមេរិក ខ្ញុំកញ្ជះ និងបនក្បត់របស់គេប៉ុណ្ណោះទេ គឺមានខ្មាំងគ្រប់ធន់ទាំងជិតទាំងឆ្ងាយ ទាំងធំទាំងតូច ។ ការផ្សាយបានបន្តថា:

**"ប្រទេសយើងតូច មានមនុស្សតិច ។ ស្ថានភាពភូមិសាស្ត្រនិងរបបនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ**

**យើង មិនអនុញ្ញាតឲ្យយើងមានលទ្ធភាពឈ្លានពានប្រទេសណាឡើយ ។ ប្រទេសមួយដែលតូចហើយខ្សោយ មិនអាចលេបប្រទេសធំបានទេ...។ តែទោះជាយ៉ាងណា ក៏ប្រជាជនកម្ពុជានិងកងទ័ពបដិវត្តបានប្តេជ្ញាការពារឯករាជ្យអធិបតេយ្យភាព និងបូរណភាពទឹកដីនៅក្នុងព្រំប្រទល់សព្វថ្ងៃរបស់យើង ។"**

ថ្ងៃ២៧កញ្ញា១៩៧៧ ពេលដែលប៉ុលពតបានប្រកាសជាចំហអំពីវត្តមានរបស់បក្សកុម្មុយនិស្តកម្ពុជា គណៈកម្មាធិការកណ្តាលនៃបក្សវៀតណាមបានផ្ញើសារកោតសរសើរនិងសំដែងសេចក្តីរីករាយ ។ ការដែលគួរចាប់អារម្មណ៍មែនទែននោះគឺ សារលិខិតនេះបានផ្ញើបន្ទាប់ពីជនស៊ីវិលវៀតណាមរាប់រយនាក់ បានត្រូវសម្លាប់រង្គាលដោយខ្មែរក្រហមកាលពីថ្ងៃ២៤កញ្ញា ។ គេក៏គួរតែពិចារណាផងដែរ អំពីព្រឹត្តិការណ៍ជុំវិញសារលិខិតដ៏ចម្លែកប្លែកខុសគេនេះ ។ មេបញ្ជាការវៀតណាមនៅកន្លែងកើតហេតុ បានអញ្ជើញអ្នកសារពត៌មានប្រទេសហុងគ្រី កាន់ដឺរដូរ៉ាមកមើលជាសាក្សីនៃអំពើព្រៃផ្សៃរបស់ខ្មែរក្រហមក្នុងពេលវាយប្រហារនោះ ។ គាត់ត្រូវបានគេជូនទៅខេត្តតាយនិញ អមដំណើរដោយកងការពារមួយកងធំ ។ នៅតាយនិញ ដូរ៉ាបានឃើញអគារបាក់បែកនិងសាកសពប្រជាជន ព្រមទាំងជនរងគ្រោះដែលត្រូវលាករពេលរាល ជាពិសេសស្ត្រីនិងកុមារ ។ គាត់បានត្រូវគេរាយការណ៍ជូនយ៉ាងអំពីស្ថានភាពយោធានៅតាមបណ្តោយព្រំប្រទល់ដ៏វែង រួមទាំងការចោទប្រកាន់ទៅលើការវាយប្រហារប៉ុស្តិ៍ការពារវៀតណាមលេខ៧៣៧, ការបំផ្លាញភូមិជាច្រើន និងការស្លាប់ជនស៊ីវិលរាប់រយនាក់ ។ ដូរ៉ាបានឃើញការជម្លៀសប្រជាជនឲ្យទៅឆ្ងាយពីព្រំដែន ។

មន្ត្រីវៀតណាមនៅទីកន្លែងបានស្នើអ្នកកាសែតហុងគ្រីឲ្យសរសេរអំពីព្រឹត្តិការណ៍នោះ ដោយបញ្ជាក់ថាមិនយូរមិនឆាប់ យុទ្ធនាការប្រឆាំងខ្មែរក្រហមអាចនឹងត្រូវលាតត្រដាង ។ នៅក្នុងបរិបទនេះ វៀតណាមបានដៅទៅលើអង្គមីទិងពិសេសមួយរបស់ការិយាល័យនយោបាយបក្សកុម្មុយនិស្តវៀតណាមនៅព្រៃនគរថ្ងៃ៣០កញ្ញា ក្រោមការដឹកនាំរបស់ឡេយន់ ។ នាកិច្ចប្រជុំនៃមន្ត្រីក្នុងតំបន់ជាមួយ ដូរ៉ាបានជេរប្រទេចចិនយ៉ាងចំហ តែមន្ត្រីខ្លះទៀតបាននិយាយដោយប្រុងប្រយ័តថា "មានមហាអំណាចខ្លះបានលូកដៃកក្ករកកាយកិច្ចការផ្ទៃក្នុងរបស់គេ ហើយបានធ្វើស្ថានការណ៍ឲ្យមិនប្រក្រតី" ។ មន្ត្រីវៀតណាមម្នាក់ ផ្នែកឃោសនាបំផុសបំផុលបានអះអាងថា វៀតណាមចាប់បានអ្នកទោសចិនជាច្រើនក្នុងពេលប្រយុទ្ធជាមួយខ្មែរក្រហម នៅខែមេសា និងឧសភា ។

មកដល់ថ្ងៃ១ខែតុលា ស្ថានការណ៍បានប្រែប្រួលទាំងស្រុង ។ វៀតណាមបានស្នើដូរ៉ា ឲ្យប្រគល់ទៅគេវិញទាំងអស់នូវភស្តុតាង (រូបថត សៀវភៅកំណត់ហេតុ) ទាំងឡាយដែលគាត់មាន ហើយសុំកុំឲ្យគាត់ពិភាក្សាជាមួយអ្នកណាឲ្យសោះនូវអ្វីដែលគាត់បានឃើញនិងបានឮ ។ គេបានប្រាប់គាត់ថា កិច្ចការទាំងនេះត្រូវបានសម្រេប

ដោយអង្គការថ្នាក់ខ្ពស់បំផុតនៅហាណូយ ។ វៀតណាមបានរំឭកគាត់ម្តងទៀតនៅពេលមុនគាត់ឡើងយន្តហោះនៅអាកាសយានដ្ឋាន **សៀឡាំ** នៅហាណូយ ។ វៀតណាមបានលាក់ភស្តុតាងរហូតដល់ចុងឆ្នាំ១៩៧៧ នៅពេលដែលវត្ថុតាងទាំងឡាយត្រូវប្រគល់ទៅឲ្យអ្នកការសែតវិញ ។

តាមមើលទៅ មេដឹកនាំហាណូយហាក់ដូចជាមានការកៀបសង្កត់ពីអាជ្ញាធរតំបន់ក្នុងការតប_តជាមួយខ្មែរក្រហម ។ តែនៅខែកញ្ញា គេក៏នៅតែមានសង្ឃឹមថាជម្លោះអាចនឹងដោះស្រាយបានដោយមិនបាច់ធ្វើសង្គ្រាម។ វៀតណាមខ្វល់ខ្វាយនឹងបញ្ហាផ្ទៃក្នុង ហើយរារែកនឹងបង្ករឿងជាមួយភ្នំពេញ ដោយខ្លាចប៉ះពាល់ដល់ទំនាក់ទំនងរបស់ហាណូយជាមួយប៉េកាំង ។

នៅក្នុងកិច្ចសន្ទនាមួយជាមួយឯកអគ្គរដ្ឋទូតសូវៀតប្រចាំទីក្រុងហាណូយ ថ្ងៃ៦តុលា១៩៧៧ ឡេយន់បានខំពុះពារក្នុងការផ្តល់សេចក្តីពន្យល់ឲ្យបានក្បោះក្បាយអំពីចរិតរបស់ខ្មែរក្រហម ។ គាត់ពិពណ៌នាការដឹកនាំរបស់កម្ពុជាថា "មានលក្ខណៈជាតិនិយមខ្លាំងហួស និងស្ថិតនៅក្រោមឥទ្ធិពលប៉េកាំង" ។ ប៉ុន្តែ បើរៀបរាប់ពីបុគ្គលិកលក្ខណៈរបស់មេដឹកនាំនីមួយៗវិញ លេខាធិការបក្សវៀតណាមបានបញ្ជាក់ថា "ប៉ុលពតជាអ្នកត្រុតស្គីនិយម (Trotskyist) ឯអៀងសារីវិញជាអ្នកជាតិនិយមសាហាវ មាននិន្នាការចិន" ។ ងាកទៅនិយាយពីមេខ្មែរក្រហមឯទៀត ឡេយន់បញ្ចេញទស្សនៈថា "នួនជានិងសុនសេនមានឥរិយាបថស្របនឹងវៀតណាម"។ គេថាមានតែពីរនាក់នេះគត់ជាអ្នកមាននិន្នាការវៀតណាម ដែលបានរួចខ្លួនពីអំពីអំពើឃោរឃៅរបស់ប៉ុលពត ចាប់តាំងពីអ្នកមានទេព្យកោសល្យភាគច្រើនដែលចូលចិត្តចងមិត្តជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាមត្រូវគេបំបាត់ចោលអស់មក ។ ឡេយន់បានបន្ថែមថា នួនជានិងសុនសេនដែលបានរស់រានមានជីវិតក៏ដោយសារគាត់មានអំណាចខ្លាំងនៅក្នុងប្រទេស ។

ក្រោយពីបានកត់សម្គាល់អំពីការកាប់សម្លាប់ស្ត្រីនិងកុមារវៀតណាមមក ឡេយន់បានបញ្ជាក់ថា កងទ័ពវៀតណាមមានសមត្ថភាពអាចកម្ទេចទ័ពខ្មែរបានមួយរំពេច ។ តែកម្ពុជាបានខំប្រឹងអូសទាញវៀតណាមឲ្យធ្លាក់ទៅក្នុងជម្លោះដ៏ធំមួយដើម្បីដុតបញ្ឆេះស្មារតីជាតិនិយម និងស្មារតីប្រឆាំងវៀតណាមនៅក្នុងកម្ពុជា ។ យោងតាមឡេយន់ ការឆ្លើយតបរបស់វៀតណាមគឺការបង្ហាញខន្តី និងការប៉ុនប៉ងរកដំណោះស្រាយសន្តិភាពនូវគ្រប់បញ្ហាទាំងឡាយដែលមានជាមួយកម្ពុជា ។ មេដឹកនាំវៀតណាមជឿថា បើគ្មានប៉ុលពតនិងអៀងសារីទេ កម្ពុជាអាចនឹងត្រូវគ្នាជាមួយវៀតណាម ។

នៅខែតុលា វៀតណាមបានចាប់ផ្តើមជ្រើសរើសកងទ័ពនិងរណសិរ្សនយោបាយក្នុងចំណោមជនភៀសខ្លួន

ខ្មែរនៅវៀតណាមខាងត្បូង និងនៅឯនាយសមុទ្រ ។ **គោលបំណងគឺដកប៉ុលពតចេញពីអំណាច** ។ មើលទៅហាក់ដូចជាហាណូយប្រុងប្រៀបបន្ថយុទ្ធសាស្ត្ររបស់គេនៅក្នុងដំណាក់ការដំបូងនៃសង្គ្រាមប្រឆាំងនឹងអតីតសាធារណ-រដ្ឋវៀតណាមខាងត្បូង **គឺការបង្កើតទ័ពព្រៃដែលគេអាចបញ្ជាបាន ហើយនិងឧបត្ថម្ភផ្នែកពស្ដុភានិងទ័ពដោយ វៀត-ណាមកុម្មុយនិស្ត** ។

ខែវិច្ឆិកា គណៈប្រតិភូជាន់ខ្ពស់វៀតណាមមួយដឹកនាំដោយឡេយន់ បានធ្វើទស្សនកិច្ចនៅទីក្រុងប៉េកាំង។ កម្មវត្ថុនៃការពិភាក្សាមិនត្រូវបានគេប្រកាសឲ្យដឹងទេ ។ ដោយប្រមើលឃើញថា ទស្សនកិច្ចអាចនឹងមានផលដល់កម្ពុជាប្រជាធិបតេយ្យ វិទ្យុភ្នំពេញមិនបានធ្វើការកត់សម្គាល់អ្វីឲ្យជាក់លាក់ទេ គ្រាន់តែថាជាទស្សនកិច្ចក្នុងន័យមិត្តភាពប៉ុណ្ណោះ ។ តែយោងតាមពត៌មានសម្ងាត់វៀតណាម គ្មានភាគីណាមួយលើកបញ្ហាជម្លោះរវាងវៀតណាម-កម្ពុជាទៅដាក់ក្នុងអង្គប្រជុំឡើយ ។

ខែធ្នូ១៩៧៧ ការប្រយុទ្ធគ្នានៅតាមព្រំដែនរវាងវៀតណាមនិងកម្ពុជា មានសន្ទុះកាន់តែខ្លាំងក្លាឡើង ។ ហាណូយប្រើយន្តហោះចម្បាំង កុងកាំភ្លើងធំ និងទ័ពប្រហែល២០ពាន់នាក់ក្នុងការវាយសន្ទាប់ដ៏ធំមួយនៅតំបន់ចំពុះសេក ខេត្តស្វាយរៀង (កម្ពុជា) ចម្ងាយតែ៤៨គ.ម.ពីទីក្រុងហូជីមិញ (ព្រៃនគរ) ប៉ុណ្ណោះ ។ ការវាយសន្ទាប់មួយប្រាវនេះគឺគ្រាន់តែចង់សម្ដែងឫទ្ធិដើម្បីឲ្យខ្មែរសុំចរចា ។ តែផ្ទុយទៅវិញ ខ្មែរក្រហមឥតរាថយ ។ ទីលានប្រ-យុទ្ធនេះបង្កើតបានជាចាកមួយក្នុងការបែកបាក់រវាងរដ្ឋាភិបាលវៀតណាមនិងកម្ពុជា ។

## ៧-កម្ពុជាប្រជាធិបតេយ្យប្រកួតនឹងវៀតណាមៈ

នៅថ្ងៃ៣១ធ្នូ១៩៧៧ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបានប្រកាសកាត់ចំណងទូតជាបណ្ដោះអាសន្នជា-មួយសាធារណរដ្ឋសង្គមនិយមវៀតណាម ដោយរង់ចាំនូវការដកថយរបស់កងកម្លាំងឈ្លានពាននៃស.ស.វ.ចេញពីទឹកដីពិសិដ្ឋរបស់ក.ប. ហើយនិងការរៀបចំឡើងវិញនូវបរិយាកាសជាមិត្តភាពរវាងប្រទេសទាំងពីរ ។ ក្នុងនាមនៃរដ្ឋាភិបាលកម្ពុជា ខៀវសំផនបានអានសុន្ទរកថាមួយស្ដីពីការឈ្លានពានរបស់វៀតណាម ។ គាត់បានពន្យល់អំពីគំនិតវៀតណាមក្នុងហេតុពីរយ៉ាង: "ហេតុជាបន្ទាន់ គឺការប៉ុនប៉ងបង្អត់ស្រូវអង្ករ គោក្របីប្រជាជនខ្មែរដើម្បីដោះស្រាយបញ្ហាអត់ឃ្លានទៅវៀតណាម ។ ប៉ុន្តែ មូលហេតុគ្រឹះបានត្រូវគេនិយាយថា បំណងដ៏យូរអង្វែងរបស់វៀត-ណាមគឺចង់បញ្ចូលកម្ពុជាទៅក្នុងសមាជិកនៃសហភាពឥណ្ឌូចិនគ្រប់គ្រងដោយវៀតណាម ។

នៅក្នុងការឆ្លើយតបដំបូងទៅភាគីកម្ពុជា រដ្ឋាភិបាលវៀតណាមបានបញ្ជាក់ថា មានការខ្វែងគំនិតគ្នាលើបញ្ហាទឹកដីនិងព្រំប្រទល់រវាងប្រទេសទាំងពីរ ។ ប៉ុន្តែវៀតណាមបានចោទកម្ពុជាថាបានលើកទ័ពចូលបង្ករជម្លោះ

នៅខែឧសភា១៩៧៥ ហើយនិងបានលុកលុយចូលទឹកដីវៀតណាមជាច្រើនលើក ។ ស.ស.វ.អះអាងថាបានសាកល្បងជាច្រើនដងដើម្បីដោះស្រាយជម្លោះ តែត្រូវបានគេទាត់ចោលរាល់តែដង ។ នៅចំពោះមុខគេឯង មេដឹកនាំហាណូយយល់ឃើញថា មានភ័ព្វវាសនាស្ទួចស្ទើងណាស់ក្នុងការសម្របសម្រួលរវាងពួកគេនិងអតីតៈសម្ពន្ធមិត្ត ។

ការវាយផ្តាច់ព្រាត់ចូលតំបន់ចំពុះសេកនៃប្រទេសកម្ពុជាដោយកងទ័ពវៀតណាម បានត្រូវផ្អាកមុនពេលកំណត់នៅទីក្រុងស្វាយរៀង ក្រោយពីវៀតណាមបានសំពងដាដំណាំទៅលើសត្រូវរបស់គេ ។ នៅដើមខែមករា ១៩៧៨ វៀតណាមបានដកថយពីកម្ពុជាដោយនាំទៅជាមួយនូវអ្នកទោសរាប់ពាន់នាក់ព្រមទាំងជនភៀសខ្លួនផងដែរ ។ ដោយកងទ័ពរបស់គេស្ថិតនៅចម្ងាយតែ៣៨គ.ម.ពីភ្នំពេញប៉ុណ្ណោះ វៀតណាមអាចវាយចូលយកទីក្រុងបានយ៉ាងងាយ ហើយកាន់កាប់កម្ពុជាទាំងមូលផង ។ ប៉ុន្តែ ដូចគេបានប្រាប់អ្នកកាសែតប៊ុលហ្គារីក្រោយមក ថាគេមិនអាចធ្វើដូច្នោះបានតាមផ្លូវនយោបាយ ។ បំណងនៃការវាយលុករបស់គេ គឺគ្រាន់តែចង់ដាក់ទណ្ឌកម្មនិងបង្អន់ដំណើរឈ្លានពានរបស់ខ្មែរក្រហមតែប៉ុណ្ណោះ ។ ទង្វើដូចនេះមិនបានផលឡើយ ។ តែផ្ទុយទៅវិញ កម្ពុជាប្រជាធិបតេយ្យបានប្រកាសថា ការដកថយរបស់វៀតណាមគឺជាជ័យជំនះដ៏ធំមួយរបស់បដិវត្តកម្ពុជា ដែលមានសារសំខាន់ជាប្រវត្តិសាស្ត្រ ស្មើនឹងបរាជ័យរបស់ចក្រពត្តិអាមេរិកនៅថ្ងៃ១៧មេសា១៩៧៥ ។ ថ្នាក់ដឹកនាំបានអះអាងថា "ជ័យជំនះថ្ងៃ៦មករារបស់យើងទៅលើពួកអ្នកដណ្តើមទឹកដី អ្នកវាតទីនិយម និងខ្មាំងយួនឈ្លានពានបានធ្វើឱ្យយើងមានការទុកចិត្តយ៉ាងកក់ក្តៅទៅលើប្រជាជននិងប្រទេសយើង នៅក្នុងបក្សកុម្មុយនិស្តកម្ពុជា និងកងទ័ពបដិវត្តកម្ពុជា និងនៅក្នុងមាគ៌ាបក្សនៃសង្គ្រាមប្រជាជន" ។ ដោយមិនរវល់ឆ្លើយតបនឹងសេចក្តីស្នើរបស់វៀតណាម ខ្មែរក្រហមបានបន្តការវាយប្រហារចូលក្នុងទឹកដីយួនតទៅទៀត ។

មានដំណើរហេតុខាងគោលដៅយោធាពិតប្រាកដដែលបានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើការសម្រេចរបស់មេដឹកនាំទាំងសងខាង ។ ទីមួយ គឺភាពខុសគ្នាស្រឡះនៃទំហំកងទ័ពរបស់ប្រទេសទាំងពីរ ។ នៅឆ្នាំ១៩៧៧ កងទ័ពក.ប.មានប្រហែល៧០ពាន់ ឯកងទ័ពស.ស.វ.មាន៦១៥ពាន់ ។ ទីពីរ គឺភាពខុសគ្នាខាងផ្នែកគុណភាពនៃគ្រឿងអាវុធយុទ្ធភ័ណ្ឌ ។ កងទ័ពថ្មើរជើងខាងក.ប.មានៈ រថក្រោះធុនស្រាលបន្តិចបន្តួចជាមួយនឹងអ្នកបើកបរប្រហែល២០០នាក់ ហើយគ្មានទ័ពអាកាសទេ ។ ឯចំណែកខាងស.ស.វ.មានរថក្រោះធុនស្រាលនិងធុនកណ្តាល ៩០០គ្រឿង កងទ័ពអាកាសមាន១២ពាន់នាក់ ប្រដាប់ដោយយន្តហោះចម្បាំង៣០០គ្រឿង ។ ទីបី គឺភាពខុសគ្នានៃចំនួនប្រជាជនៈ ក.ប.មានប្រជាជនមិនដល់៧លាននាក់ទេ ឯស.ស.វ.វិញមានជិត៥០លាននាក់ ។ កត្តាសំខាន់ចុងក្រោយ គឺភាពមិនស៊ីគ្នាក្នុងលក្ខណ័ណ្ឌប្រជាជនៈ ប្រជាជនវៀតណាមភាគច្រើន បើទោះជាក្រីក្រក្តីក៏នៅមាន

សុខភាពសមរម្យ ។ ឯចំណែកប្រជាជនខ្មែរវិញ ពាក់កណ្ដាលស្ថិតនៅក្នុងភាពហេវហត់ស្គមស្គាំង ទាំងខាងផ្លូវកាយ ទាំងខាងផ្លូវសតិអារម្មណ៍ ដែលបណ្ដាលមកពីការអត់ឃ្លាននិងជម្ងឺ ។

ប៉ុន្តែ ថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យធ្វើហាក់ដូចជាមិនដឹងមិនឮ ថាគ្មានគុណវិប្បត្តិនៃកត្តាសម្ភារៈនិងកត្តាមនុស្សទេ ឬក៏ថាកត្តាទាំងនោះមិនជាបញ្ហាអ្វីឡើយ ។ លើសពីនោះទៅទៀត តាមអ្នកនិពន្ធអង់គ្លេស Orwell ពួកគេនៅតែបន្តអួតអាងថាការដកថយរបស់វៀតណាមពីទឹកដីកម្ពុជា បន្ទាប់ពីបានធ្វើឱ្យពួកខ្មែរក្រហមខូចខាតយ៉ាងដំណំ ថាជាជោគជ័យរបស់កម្ពុជា ។ សំណួរតែមួយគត់របស់គេគឺថា តើហេតុអ្វីបានជាកម្ពុជាឈ្នះ ? ចម្លើយត្រូវបានឆ្លើយនៅក្នុងការឃោសនារបស់បក្សមួយតាមវិទ្យុភ្នំពេញថា :

**"ទាំងបក្ស ទាំងកងទ័ព ទាំងប្រជាជន យើងមានចំណែករួមគ្នាក្នុងការយកជ័យជំនះលើវៀតណាម ពីព្រោះថ្មីៗនេះ យើងទើបនឹងបានធ្វើឲ្យចក្រពត្តិអាមេរិកបរាជ័យ ហើយយួនមិនមែនខ្លាំងជាងអាមេរិកទេ ។ បើទោះជាយ៉ាងនេះក៏ដោយ ក៏នៅមានអ្នកខ្លះនិយាយថា វៀតណាមជាប្រទេសធំ មានប្រជាជន៥០លាននាក់ ហេតុអ្វីបានជាចាញ់កម្ពុជាដែលមានប្រជាជនតែ៨លាននាក់នោះ ? យើងឈ្នះយួន ពីព្រោះយើងត្រូវតែឈ្នះយួន ។ នេះគឺជាចំណុចសំខាន់ ។"**

ម្យ៉ាងទៀត រឿងយោធាក៏ដូចជារឿងនយោបាយក្នុងស្រុកដែរ ។ យើងអាចយកជ័យជំនះបានលើកម្លាំងមួយដែលគ្មានតុល្យភាពជាមួយនឹងយើង ។ កិច្ចការនេះតម្រូវឱ្យយើងធ្វើការគន់គូររៀបចំផែនការឱ្យបានហ្មត់ចត់ :

**"យើងមានគ្នាតិច ហើយយើងត្រូវប្រឈមមុខនឹងកម្លាំងដែលមានគ្នាច្រើន ។ ដូច្នេះ យើងត្រូវត្រៀមកម្លាំងឲ្យបានជាអតិបរមា ដើម្បីសម្លាប់ខ្មាំងឲ្យបានយ៉ាងច្រើនបំផុត , នេះជាពាក្យស្លោករបស់យើង ។ បើនិយាយពីចំនួន ខ្មែរម្នាក់ត្រូវសម្លាប់យួន៣០នាក់ ។ បើយើងអនុវត្តផែនការនេះបាន យើងពិតជាឈ្នះ ។ យើងអាចនឹងឈ្នះយួន បើទោះជាគេមានគ្នាប៉ុន្មានក៏ដោយ... ។ មកទល់នឹងពេលនេះ យើងមានជោគជ័យក្នុងការអនុវត្តពាក្យស្លោក"មួយទល់សាមសិប"របស់យើង... បានសេចក្ដីថា យើងងាប់មួយ យួនងាប់សាមសិប ។"**

ការពោលអះអាងនេះគឺជាការប្រឌិតសុទ្ធសាធ ។ បើគិតតាមភាពសមទំនងនៃរូបមន្តនេះ កម្ពុជាប្រជាធិបតេយ្យមានសង្ឃឹមជានិច្ចក្នុងការធ្វើសង្គ្រាមជាមួយវៀតណាមក្នុងអនាគត :

**"ក្នុងរូបមន្តនេះ យោធាខ្មែរម្នាក់ស្មើនឹងយោធាយួនសាមសិបនាក់ ... ។ បើយើងមានកងទ័ពពីរលាននាក់ យួនត្រូវមានកងទ័ពហុកសិបលាន ។ ដូច្នេះ ទ័ពពីរលានវាលើសពីគ្រប់គ្រាន់ទៅហើយ ព្រោះយួនមានប្រជាជនតែ៥០លានប៉ុណ្ណោះ ។ យើងមិនត្រូវការមានប្រជាជន៨លាននាក់ទេ ។ យើងត្រូវការកងទ័ពតែ**

**ពីរលានប៉ុណ្ណោះ ដើម្បីកម្ទេចយួន៥០លាននាក់ , ហើយយើងនៅសល់ប្រជាជន៦លានទៀត ។ យើងត្រូវតែអនុវត្តវិធានការសឹកបែបនេះ ដើម្បីបានសម្រេចជ័យជំនះ ។"**

យើងឃើញហើយថា ខ្មែរក្រហមអួតជាន់លើអួត ។ គេថា "គេបានកម្ទេចវៀតណាម គេបានទិងបន្តដាក់ទណ្ឌកម្មសត្រូវរបស់គេតទៅទៀត និងថារើសកងទ័ពឲ្យបានពីរលាន ពីក្នុងចំណោមប្រជាជនដែលកំពុងខ្សោះខ្សល់ ស្គមស្គាំងស្លាំងស្លក់ដើម្បីកម្ទេចវៀតណាម៥០លាន"។

ដោយពិចារណាអំពីទស្សនៈមិនសមរម្យរបស់ខ្មែរក្រហម (ជំនឿរបស់មេដឹកនាំខ្មែរក្រហមទៅលើឧត្តមភាពនៃភាពកម្សោយរបស់គេ) យើងបានរកឃើញនូវជំនឿអរូបិយជាទូទៅនៅក្នុងប្រវត្តិសង្គ្រាមពីអតីតកាល ។យើងនឹងលើកឧទាហរណ៍មួយអំពីការបះបោរប្រឆាំងនឹងវៀតណាមកាលពីឆ្នាំ១៨២០ ដឹកនាំដោយព្រះសង្ឃទាម **៩៦** (១) :

**"នៅពេលដែលដឹងថាយួនលើកទ័ពចូលមកហើយ ភិក្ខុកែសូត្រសែកមន្តអាគម ប្រោះព្រំលាស់ទឹកលើក្បាលពលទាហាន ដើម្បីកុំឲ្យយួនកម្ទេចនៅក្នុងសមរភូមិ ។ បើយួនបាញ់មក មន្តអាគមនោះអាចបញ្ចៀសគ្រាប់បាន ។ ពេលភិក្ខុកែប្រោះព្រំរួចហើយ ពលទាហានលែងខ្វល់ពីអ្វីទាំងអស់ រួចហើយចេញទៅប្រយុទ្ធជាមួយយួន ។"**

នេះជាការពិសោធន៍មួយដែលខ្មែរក្រហមយកជាជំបូន្មាន ក្នុងរូបមន្ត"មួយទល់នឹងសាមសិប" ។ តែខុសគ្នាត្រង់ថា ខ្មែរក្រហមមិនយកមន្តអាគមប្រោះព្រំមកប្រើ គឺគេយកមនោគមន៍វិជ្ជាម៉ាក់_ឡេនីនទិងគំនិតម៉ៅ រួមផ្សំនឹងកងទ័ពបដិវត្តខ្មែរដែលធ្វើ"សង្គ្រាមប្រជាជន"សុទ្ធសាធដើម្បីប្រយុទ្ធតទល់ជាមួយនឹងពួក"ប្រតិកិរិយា" បរទេសឈ្លានពាន ។ ទ្រឹស្តីជ្រុលនិយមម៉ៅដែលខ្មែរក្រហមអនុវត្តក្នុងការសម្រេចគោលដៅណាមួយនោះ គឺជាកិច្ចការលំបាកមួយដែលទំនងជាមិនអាច និងពិតជាមិនអាចទៅរួចសោះឡើយ ។

## ៨_វៀតណាមប៉ុនប៉ងធ្វើការផ្សាយរកក្រុមខ្មែរបះបោរ

បន្ទាប់ពីមានការផ្តាច់ទំនាក់ទំនងទូតជាមួយកម្ពុជាប្រជាធិបតេយ្យមក វៀតណាមបានចាប់ផ្តើមធ្វើការឃោសនាប្រឆាំងនឹងសប្បដិភ័យ (ការភ័យខ្លាំង) ដែលកើតមាននៅក្នុងស្រុកដោយពួកខ្មែរក្រហម ។ ចន្លោះខែមករានិងមិថុនា១៩៧៨ ហាណូយប្តូរឈ្មោះខ្មែរក្រហមជាបន្តបន្ទាប់ ពី "រដ្ឋអំណាចកម្ពុជា" ទៅ "រដ្ឋអំណាចភ្នំពេញ" , ពី"រដ្ឋអំណាចភ្នំពេញ"ទៅ "បនប៉ុលពត_អៀងសារី" ។ កាសែតញ៉ាន់ដាន់បានសរសេរថា :

**"បនប៉ុលពត_អៀងសារីបានបង្ហាញខ្លួនគេឲ្យឃើញយ៉ាងច្បាស់ថា ពួកខ្លួនជាឃាតករដ៏គួរឲ្យខ្ពើមរអើមជាងគេក្នុងពាក់កណ្តាលទីពីរនៃសតវត្សនេះ ។ តើអ្នកណានៅពីក្រោយខ្នងឃាតករដែលដៃប្រឡាក់ដោយ**

**ឈាមប្រជាជនកម្ពុជា រួមទាំងជនជាតិចាម ជនជាតិវៀត និងជនជាតិហ្វា ? គ្មានអ្វីគួរឲ្យអស្ចារ្យដល់ពិភពលោកឡើយ ។ បនប៉ុលពត_អៀងសារីគ្រាន់តែជាឧបករណ៍ដ៏ថោកទាបនៃសត្រូវដែលប្រឆាំងនិងសន្តិភាពនិងមនុស្សជាតិតែប៉ុណ្ណោះ ។ អំពើរបស់ពួកគេកំពុងតែធ្វើដំណើរឆ្ពោះទៅរកការសម្លាប់ជាតិឯង ។ នេះគឺជាការសម្លាប់ពូជសាសន៍ដ៏ពិសេសមួយ ។ យើងត្រូវបញ្ឈប់ការប្រល័យជាតិឯងនេះ ។ យើងត្រូវបញ្ឈប់ការប្រល័យពូជសាសន៍ពីកណ្តាប់ដៃនៃបនប៉ុលពត_អៀងសារី !"**

ការអំពាវនាវឲ្យជួយសង្គ្រោះប្រជាជនកម្ពុជាពីរបបប្រល័យពូជសាសន៍មិនមែនគ្រាន់តែនិយាយឲ្យពិរោះស្តាប់ប៉ុណ្ណោះទេ ។ នៅក្នុងបរិបទនៃការឃោសនាជាអន្តរជាតិដ៏ទូលំទូលាយមួយដែលធ្វើឡើងដោយទីក្រុងហាណូយ **នេះគឺជាការប៉ុនប៉ងស្របច្បាប់មួយដើម្បីផ្តួលរំលំរបបកុម្មុយនិស្តកម្ពុជា** ដែលនឹងកើតមានឡើងក្នុងពេលឆាប់ៗ ។ សំណួរមិនមែនស្ថិតនៅត្រង់"ប្រសិនបើ"ទេ តែគឺស្ថិតនៅត្រង់ថា "តើពេលណា ហើយរបៀបណា" ។

នៅក្នុងបួនខែដំបូងនៃឆ្នាំ១៩៧៨ វៀតណាមបានបង្កើតបណ្តាញជំរំសម្ងាត់មួយ ដើម្បីបង្កើត"កងទ័ពរំដោះខ្មែរ"ពីក្នុងចំណោមជនភៀសខ្លួន និងជនស៊ីវិលខ្លះទៀតដែលត្រូវគេកៀរពីកម្ពុជាទៅវៀតណាម ។

ប៉ុលពតបានជួយពង្រីក"កងទ័ពរំដោះ"នេះ ដោយបានបន្ថែមសប្បដិភ័យទៅលើតំបន់បូព៌ានៃកម្ពុជាក្នុងឆ្នាំ ១៩៧៨ ។ ដោយមិនយល់អំពីការចំណេញទៅលើវៀតណាមដែលបណ្តាលពីអំពើរបស់ខ្លួន ប៉ុលពតបានសន្និដ្ឋានថា ភូមិភាគបូព៌ាជាសំបុកនៃពួកក្បត់ ។ ហេតុនេះហើយបានជាយោធាភូមិភាគនិរតី និងកងកម្លាំងសន្តិសុខមជ្ឈិមបក្ស បានលើកទ័ពទៅភូមិភាគបូព៌ាដើម្បីកម្ទេច"ពួកក្បត់លាក់ខ្លួន" ។

គ្មានភស្តុតាងណាមួយបានបញ្ជាក់ថា ជនដែលពួកប៉ុលពតសម្លាប់នោះជាភ្នាក់ងាររបស់វៀតណាមឡើយ។ **តាមពិត រឿងនេះធ្វើឲ្យហាណូយយល់ស្របទាំងស្រុង ពីព្រោះវាបានបម្រើនូវឆន្ទៈនយោបាយរបស់ហាណូយ** ក្នុងការធ្វើឲ្យពិភពលោកជឿថា សម្ពន្ធមិត្តខ្មែរក្រហមថ្មីរបស់គេគឺជាអ្នកប្រឆាំងដាច់ខាតនឹងបដិវត្តប៉ុលពត ។ ផ្ទុយទៅវិញពួកអ្នកដែលប៉ុលពតប៉ុនប៉ងសម្លាប់នោះ គឺសុទ្ធតែជាអ្នកដែលមានភក្តីភាពទទួលបញ្ជាពីថ្នាក់ដឹកនាំខ្មែរក្រហមកាលពីបីឆ្នាំមុន ។ បញ្ហាទាំងនោះមានទាក់ទិននឹងការវាយប្រហារជនជាតិវៀតណាម និងអាណិកជនខ្មែរក្នុងទឹកដីយួន ហើយដែលត្រូវបានទទួលនូវការតដៃវិញយ៉ាងសាហាវពីវៀតណាម ។ ជនក្បត់ប៉ុលពតដ៏សំខាន់ម្នាក់ឈ្មោះ**សោភឹម** ដែលបានធ្វើអត្តឃាត គឺជាលេខាធិការអចិន្ត្រៃយ៍នៃការិយាល័យនយោបាយប.ក.ក. នៃភូមិភាគបូព៌ា ។ គាត់ជាអ្នកគាំទ្រដ៏ប្តូរផ្តាច់ម្នាក់ក្នុងការប្រឆាំងនឹងវៀតណាម ។ អ្នកដឹកនាំវៀតណាមជឿថា គេអាចដោះស្រាយបញ្ហាជាមួយកម្ពុជាប្រជាធិបតេយ្យបានយ៉ាងងាយ ដោយលើកទ័ពចូលកម្ទេចកម្ពុជាតែក្នុងរយៈពេលម្ភៃបួន

ម៉ោង ។ ប៉ុន្តែ ហាណូយបានគ្រោងផែនការឱ្យបានសមហេតុសមផល ទាំងខាងទ្រឹស្តី ទាំងខាងនយោបាយដើម្បីឈោងទៅចាប់គោលដៅ ។ នៅក្នុងពេលពិភាក្សាគ្នាអំពីជំហររបស់វៀតណាម ក្នុងខែមីនា១៩៧៨ **ត្រាន់គ្វាន** សមាជិកម្នាក់នៃគណៈកម្មាធិការកណ្តាលប.ក.វ.បានផ្តល់គំនិតខ្លះអំពីទស្សនៈរបស់យួនកុម្មុយនិស្ត ។ គាត់បានប្រៀបធៀបកម្ពុជាឆ្នាំ១៩៧៨ទៅនឹងឆេកូស្លូវ៉ាគីឆ្នាំ១៩៦៨ ។ នៅឆេកូស្លូវ៉ាគី **ប្រតិបដិវត្ត**បានផ្តួលរំលំអំណាចបដិវត្ត។ ដោយហេតុនេះ ជាការចាំបាច់គេត្រូវតែបញ្ចូលទ័ពមកពីខាងក្រៅ ។ ផ្ទុយទៅវិញក្នុងករណីកម្ពុជា តាំងពីជ័យជំនះរបស់បដិវត្តន៍១៩៧៥មក អំណាចមិនបានផ្លាស់ប្តូរទេ ។ហាណូយយល់ថា កងទ័ពប.ក.ក.រឹងមាំល្អណាស់ ប៉ុន្តែកងទ័ពនេះរលេះរលួយក៏ដោយសារប៉ុលពត និងអៀងសារីនេះឯង ។

ក៏ប៉ុន្តែ នៅមានភាពសមរម្យមួយទៀតដែរជាយមិនបាច់ឈ្លានពាន ។ ចាប់តាំងពីឆ្នាំ១៩៧៥មក ចិនតែងចោទប្រកាន់វៀតណាមថាជាអ្នកវាតទីនិយមនិងជាអ្នកអនុត្តរភាពនិយម ។ គេបានចោទរួចទៅហើយថាការឈ្លានពានរបស់វៀតណាមចូលកម្ពុជា ជាការបណ្តាលឱ្យខាតបង់ដល់អាជ្ញាធរវៀតណាម ជាពិសេសនៅអាស៊ីអគ្នេយ៍និងនៅក្នុងចលនាបដិវត្តនៃតំបន់ ។ បើសិនជាសាធារណរដ្ឋសង្គមនិយមវៀតណាមឈ្លានពានកម្ពុជា អំពើនេះនឹងអាចធ្វើឱ្យលាវមានការព្រួយបារម្ភ ដែលមិនមែនជាផលប្រយោជន៍របស់វៀតណាម ។ ម្យ៉ាងទៀតត្រាន់គ្វានយល់ឃើញថា ចិនអាចនឹងចូលកាន់កាប់លាវ ។

នៅពេលជាមួយគ្នានោះដែរ ត្រាន់គ្វានបានកត់សម្គាល់ថា "គោលបំណងធំបំផុតរបស់វៀតណាមគឺចងមិត្តភាពជាមួយកម្ពុជាឡើងវិញ" ។ តែទោះជាយ៉ាងណាក៏ដោយ គាត់គ្មានសង្ឃឹមថាបំណងនោះនឹងបានសម្រេចតាមការចរចាសន្តិភាពក្នុងអនាគតឡើយ ។ ការប្រែប្រួលនៅកម្ពុជាត្រូវតែមាន ហើយកិច្ចការនេះត្រូវស៊ីពេលច្រើន ។ នយោបាយផ្តាច់ការឃោរឃៅនៃរបបប៉ុលពត បានធ្វើឱ្យប្រជាជនស្ថិតនៅក្នុងស្ថានភាពមួយដ៏ពិបាក ជាទីបំផុត ។ ឡេយន់បានហៅប្រព័ន្ធដែលកំពុងមាននៅកម្ពុជាថា "គុកអ្នកទោសកុម្មុយនិស្ត" ។ ប៉ុន្តែ បើទោះជាមានចលនាតស៊ូរើបំរះនៅខាងក្នុងក៏ដោយ ក៏ចលនានោះនៅខ្វះរចនាសម្ពន្ធឱ្យបានត្រឹមត្រូវ ។

ដូច្នេះ ដើម្បីឱ្យនយោបាយនេះមានន័យ គេត្រូវមានការឧបត្ថម្ភនយោបាយពីវៀតណាម និងរៀបចំធ្វើការបះបោរបដិវត្តនៅក្នុងកម្ពុជា ។ ដោយសម្លឹងឃើញថាមានអ្នកដែលស្មោះត្រង់នឹងវៀតណាមនៅក្នុងជួរដឹកនាំខ្មែរក្រហម យួនសង្ឃឹមថាគេអាចនឹងរៀបចំដាក់ក្រុមកុម្មុយនិស្តនិយមវៀតណាមឡើងវិញនៅកម្ពុជា ។ ប៉ុន្តែ បញ្ហានៅត្រង់ថា តើយុទ្ធវិធីឧបត្ថម្ភ"សង្គ្រាមប្រជាជន"នេះបានជោគជ័យដែរឬទេ ?

ចុងខែឧសភា១៩៧៨ ការប្រយុទ្ធគ្នាបានចាប់កើតឡើងនៅតាមព្រំដែននៃប្រទេសទាំងពីរ ។ ការទម្លាក់

គ្រាប់បែកពីទ័ពអាកាសវៀតណាមជិតសាមសិបដងក្នុងមួយថ្ងៃ ធ្វើឱ្យខ្មែរក្រហមទទួលការខូចខាតយ៉ាងដំណំ ។ នៅពាក់កណ្ដាលឆ្នាំ " កងទ័ពរំដោះ" ប្រជាជនកម្ពុជាស្ថិតនៅក្រោមអតីតកម្មាភិបាលខ្មែរក្រហមនៃតំបន់ ២០៣ (ភូមិភាគបូព៌ា) ដែលអ្នកខ្លះបានចូលរួមក្នុងការបះបោរខែមេសានិងឧសភា ហើយដែលអ្នកទាំងអស់នោះបានភៀសខ្លួនទៅវៀតណាមដើម្បីគេចពីការបោសសម្អាតរបស់ប៉ុលពត ។

## ៩_ការសម្រេចចិត្តរបស់វៀតណាមក្នុងការឈ្លានពានកម្ពុជា៖

នៅវាងពាក់កណ្ដាលឆ្នាំ១៩៧៨ វៀតណាមយល់ឃើញថា កុប្បកម្មពិសោធមួយកាលពីមុនដែលគេបានយកគំរូតាម"សង្គ្រាមប្រជាជន"របស់ប្រធានម៉ៅនោះមិនបានជោគជ័យទេ ។ អង្គភាពយោធាដែលស្មោះត្រង់នឹងប៉ុលពត និងនគរបាលមជ្ឈិមបក្សមានអំណាចខ្លាំងណាស់ ។ ដំណោះស្រាយតែមួយគត់គឺ លើកទ័ពចូលឈ្លានពានតាមធម្មតា ដូចដែលសហភាពសូវៀតធ្លាប់បានធ្វើនៅចេកូកាលពីឆ្នាំ១៩៦៨ដូច្នោះដែរ ។

ថ្ងៃ២១មិថុនា ការិយាល័យនយោបាយបក្សកុម្មុយនិស្តវៀតណាមបានបញ្ជូនគណៈប្រតិភូមួយ ដឹកនាំដោយឡេយន់ ទៅធ្វើទស្សកិច្ចនៅម៉ូស្គូដែលមានរយៈពេលពីប្រាំពីរទៅប្រាំបួនថ្ងៃ ។ គោលបំណងនៃទស្សនកិច្ចនេះ គឺដើម្បីជួបជាមួយ ឡេអូនិដ ប្រេសណូវ និងអ្នកដឹកនាំសូវៀតផ្សេងទៀត ដើម្បីប្តូរយោបល់គ្នាអំពីស្ថានការណ៍នៅវៀតណាម និងបញ្ហាអន្តរជាតិសំខាន់ៗមួយចំនួន ។ សេចក្តីស្នើរបស់មេដឹកនាំគណៈប្រតិភូវៀតណាម (រដ្ឋមន្ត្រីក្រសួងការបរទេសង្វៀនឌុយទ្រិញ) បានបញ្ជាក់ថា ស្ថានការណ៍នៅវៀតណាមបានត្រូវកំណត់ក្នុងទិដ្ឋភាពច្រើនយ៉ាង ដោយ "សង្គ្រាមរបស់កម្ពុជាប្រឆាំងនឹងស.ស.វ." និងដោយអាកប្បកិរិយារបស់ជនជាតិចិននៅវៀតណាមដែលមេដឹកនាំហាណូយជឿថាមានការទាក់ទងគ្នាយ៉ាងជិតស្និទ្ធ ។ ប.ក.វ.បានទស្សន៍ទាយទុកជាមុនថា "ស្ថានការណ៍នឹងរឹតតែធ្ងន់ឡើង ដែលយើងត្រូវកាពិគ្រោះយោបល់ជាបន្ទាន់ឱ្យបានទាន់ពេលជាមួយសមមិត្តសូវៀត" ។ ទ្រិញបានបញ្ជាក់ថា ឡេយន់"មានបំណងចង់ធ្វើទូវសម្ពើរជាច្រើនដល់ថ្នាក់ដឹកនាំប.ក.ស.ស.(បក្សកុម្មុយនិស្តសហភាពសូវៀត)នៅម៉ូស្គូ" ។ ចំណែកឯមន្ត្រីការបរទេសវៀតណាមវិញមិនបានឱ្យអ្នកណាដឹងអំពីទស្សនកិច្ចនេះឡើយ។

គួរឱ្យស្តាយ ដោយយើងគ្មានឯកសារកំណត់ហេតុនៃអង្គប្រជុំសម្ងាត់នៅម៉ូស្គូនោះ ។ ប៉ុន្តែ មន្ត្រីដើងចាស់វៀតណាមមួយរូបបានឱ្យដឹងថា នៅខែមិថុនា១៩៧៨ កម្មាភិបាលនយោបាយយួនកុម.បានត្រូវគេប្រាប់ឱ្យដឹងថាគេកំពុងរៀបចំចូលឈ្លានពានកម្ពុជាហើយ ។ បើទោះជាគេមិនពិភាក្សាគ្នាជាចំហក៏ដោយ គោលបំណងនៃការប្រជុំគឺ វៀតណាមចង់បានការគាំទ្រខាងផ្នែកនយោបាយនិងយោធាពីសូវៀត ក្នុងករណីដែលស្ថានការណ៍រឹតតែតឹងតែងឡើងនាអនាគត ឬក៏យ៉ាងហោចណាស់ វៀតណាមចង់បានការធានាពីសូវៀតនៅពេលដែលមានការវាយបកពី

យោធាចិន ។ សូវៀតគ្មានបំណងធ្វើសង្គ្រាមជាមួយចិនដោយសាររឿងវៀតណាមនិងកម្ពុជានោះទេ តែគេមិនបានបញ្ជាក់ពីបំណងនោះឡើយ ។ ប៉ុន្តែ កតិកាសញ្ញាមិត្តភាពនិងសហប្រតិបត្តិការមួយបានត្រូវចុះហត្ថលេខាជាសាធារណៈនៅម៉ូស្គូ ក្នុងខែវិច្ឆិកា ។

នៅក្នុងសន្និសីទកាសែតថ្ងៃ២៥កក្កដា១៩៧៨ មន្ត្រីការបរទេសវៀតណាមម្នាក់បានប្រាប់ភារៈធារីសូវៀតប្រចាំហាណូយថា ខ្មែរក្រហមបានប្រមូលផ្តុំ១៤កងពល ក្នុងចំណោម១៧កងពលនៃយោធាកម្ពុជា និង១៦កងវរៈសេនាធំនៅទល់ដែនវៀតណាម ។

នៅក្នុងអង្គប្រជុំមួយជាមួយទូតសូវៀតប្រចាំហាណូយ ដើមខែកញ្ញា១៩៧៨ ឡេឌួនបានបញ្ជាក់ថា ការិយាល័យនយោបាយនៃប.ក.វ.បានដាក់កម្មវិធីយ៉ាងល្អិតល្អន់"ដើម្បីចាត់ការរឿងកម្ពុជាឲ្យបាននៅដើមឆ្នាំ១៩៧៩" ។ គាត់បានកត់សម្គាល់ថា តាមការគន់គូរបស់វៀតណាមប្រតិកម្មរបស់ចិនអាចនឹងត្រូវផ្លាស់ប្តូរ ។

ឡេឌួនបាននិយាយថាៈ បើចិនមិនចង់ឲ្យមានការផ្លាស់ប្តូរនៅកម្ពុជាដែលខ្លួនមិនចូលចិត្តដែរនោះ ចិនគួរបញ្ជូនទ័ព១០កងពលទៅកម្ពុជា ។ តែគាត់គិតថា ចិនមិនអាចធ្វើដូច្នោះបានឡើយ ព្រោះការដឹកនាំទ័ពតាមផ្លូវសមុទ្រទៅកម្ពុជាពិបាកណាស់ ។ បើចង់វាយតាមដើងគោកពីទិសខាងជើងវិញក៏រឹតតែយ៉ាប់ទៅទៀត ហើយមកទល់នឹងពេលនេះ ចិនក៏នៅមិនទាន់ចាត់ចែងធ្វើអ្វីនៅឡើយទេ ។ ជាបន្ថែម ឡេឌួនបានសង្កត់ធ្ងន់ថា វៀតណាមមិនអាចរើចាំទាល់តែចិនពង្រីងជំហររបស់គេនៅកម្ពុជាឡើយ ។

ឡេឌួនក៏បាននិយាយផងដែរអំពីការខំប្រឹងប្រែងរបស់វៀតណាម ក្នុងការជ្រើសរើសក្រុមអ្នកតស៊ូបះបោរនៅកម្ពុជា ។ គាត់បានអះអាងថា មានទ័ពខ្មែរ៩កងវរៈសេនាតូចកំពុងហ្វឹកហ្វឺនដោយវៀតណាម ។ ហើយក៏បានព្រមកដែរថាមានគណៈតំបន់ម្តែនាក់ ដែលមានសមានចិត្តជាមួយវៀតណាម បានងើបឡើងបះបោរប្រឆាំងនឹងរបបភ្នំពេញ ។ ឡេឌួនបានអះអាងថា វៀតណាមព្យាយាមភ្ជាប់ទំនាក់ទំនងជាមួយ **សោភឹម**ហៅ **ស៊ុវណ្ណ** ។ មេដឹកនាំយួនបានបញ្ជាក់ថា"គាត់(សោភឹម)ជាមនុស្សរបស់យើង" ហើយថាហាណូយមានបំណងឲ្យ **សោភឹម**"ដឹកនាំចលនាតស៊ូនៅក្នុងកម្ពុជា" ។ ជាថ្មីម្តងទៀត ឡេឌួនបានបញ្ជាក់អំពីជំនឿរបស់គាត់ក្នុងថ្នាក់ទន្លងទៅថានួនជាសមាជិកនៃថ្នាក់ដឹកនាំជាន់ខ្ពស់ខ្មែរក្រហម"ជាមនុស្សម្នាក់ដែលមានសមានចិត្តជាមួយវៀតណាម" ។ ក្នុងពេលធ្វើទស្សនកិច្ចនៅប្រទេសចិន បើទោះជា **នួនជា** បានថ្លែងសុន្ទរកថាប្រឆាំងនឹងវៀតណាមក៏ដោយ ឡេឌួននៅតែអះអាងថា "នេះមិនមែនជាលក្ខណៈទស្សនៈនយោបាយរបស់នួនជាទេ តែវាជាការបង្ខិតបង្ខំពីអាជ្ញាធរភ្នំពេញ ឲ្យនួនជាធ្វើដូច្នោះ ។ យើងយល់ច្បាស់ណាស់ពីស្ថានភាពរបស់គាត់" ។

ក្នុងចំណោមខ្មែរកុម្មុយនិស្តដែលសហការជាមួយវៀតណាម ឡេយន់ទុកចិត្តទៅលើពួកខ្មែរដែលជាអតីតសមាជិកប.ក.ឥ.តែប៉ុណ្ណោះ ។ ហេតុការណ៍នេះ រួមផ្សំជាមួយនឹងអត្តសញ្ញាណនៃអាណិកជនវៀតណាមផងជាមូលដ្ឋានដ៏សមរម្យដើម្បីសម្គាល់បុគ្គលដែលស័ក្តិសមនឹងទទួលឥទ្ធិពលនយោបាយពីយួនកុម. ។ ទស្សនៈនយោ_បាយរបស់ឡេយន់នៅតែស្មានខុស ចំពោះអាកប្បកិរិយាជាហូរហែរបស់ខ្លួនជានិងសុនសេន ។ មេខ្មែរក្រហមទាំងពីរនាក់នៅតែស្មោះត្រង់ជាមួយប៉ុលពត ។ សុនសេនទើបតែឈប់ត្រូវរ៉ូវជាមួយប៉ុលពតនៅខែមិថុនា១៩៩៧នេះទេដោយសារមានការបែកបាក់គ្នានៅក្នុងចលនាខ្មែរក្រហម ។ ស្រដៀងគ្នានោះដែរ នៅពេលដែលអៀងសារីផ្តាច់ខ្លួនពីប៉ុលពតដែលរឹបូតអំណាច ហើយដែលត្រូវចាប់ឃុំឃាំងដោយអតីតសមមិត្តក្បាលរឹង ទើបខ្លួនជាក្លាយខ្លួនជាអ្នកប្រឆាំងនឹងប៉ុលពត ។ ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះ នាំឱ្យយើងចង់ដេញដោលសួរឡេយន់ អំពីការវាយតម្លៃរបស់គាត់ទៅលើគណៈភូមិភាគបូព៌ា **សោភិម** ផងដែរ ។ កាលនោះ ឡេយន់អះអាងថា ប.ក.វ.ព្យាយាមទាក់ទង **សោភិម** ដែលជននេះបានស្លាប់បាត់តាំងពីបីខែទៅហើយ ។

តើការភាន់ច្រឡំរបស់ឡេយន់នេះ គ្រាន់តែជាលទ្ធផលដែលគាត់ខំព្យាយាមបញ្ចុះបញ្ចូលគូរសន្ទនាសូវៀតជាមួយនឹងសុទិដ្ឋិនិយមខាងផ្នែកនយោបាយរបស់គាត់ឬ ? វាអាចដូច្នោះមែន ។ ប៉ុន្តែ វាជាការខ្មាស់គេជំណាស់បើគេដឹងថា ទស្សនវិស័យរបស់វៀតណាមមានការជាប់ទាក់ទិនមួយផ្នែក ជាមួយនឹងមនុស្សដែលស្លាប់បីខែហើយនោះ ។ ដូច្នេះ គេត្រូវសន្និដ្ឋានអំពីកម្រិតនៃការយល់ដឹងរបស់ឡេយន់ ។ មេដឹកនាំវៀតណាមចេះតែហក់លោតដោយគ្មានមូលហេតុសមរម្យអំពីទស្សននយោបាយរបស់មេដឹកនាំខ្មែរ នៅលើមូលដ្ឋានដែលកត្តាមិនទាក់ទងគ្នា ។

នៅខែតុលា វិទ្យុវៀតណាមបានចាប់ផ្តើមផ្សាយនូវអត្ថបទរបស់កាសែតវៀតណាម ដែលនិយាយថាអាចនឹងមានការបះបោរនៅកម្ពុជា ដើម្បីឆ្លើយតបទៅនឹងវិសុទ្ធិកម្ម *(ការធ្វើឱ្យសុទ្ធ)* សមាជិកនៅក្នុងបក្សកុម្មុយនិស្តកម្ពុជា និងកម្មាភិបាលយោធាក្នុងកងទ័ព ។ **វិទ្យុក៏បានផ្សាយផងដែរនូវសេចក្តីអំពាវនាវរបស់ជនជាតិខ្មែរ ដែលអះអាងថាជាអតីតសមាជិកនៃកងទ័ពប.ក.ក.ឲ្យងើបឡើងប្រឆាំងនឹងបនក្សត់ប៉ុលពត_អៀងសារី ឬរត់ចោលជួរចូលព្រៃជាមួយប្រជាជន ឬរត់ទៅប្រទេសវៀតណាម ។ ទាំងអស់នេះ សុទ្ធតែជាផែនការនយោបាយរៀបចំឡើងដើម្បីការវាយលុកផ្តាច់ព្រ័ត្ររបស់កងយោធាវៀតណាមទៅលើរបបកម្ពុជាប្រជាធិបតេយ្យ ។**

ទីភ្នាក់ងារពត៌មានបារាំងបានរាយការណ៍ថា សហភាពសូវៀតបានដឹកមកដាក់នៅកំពង់ផែវៀតណាមនូវរថក្រោះធុនធំល្មមមួយចំនួន យន្តហោះចម្បាំង កាំភ្លើងធ្លោង និងគ្រាប់រំសេវ ។

ថ្ងៃ៣ធ្នូ វិទ្យុហាណូយបានប្រកាសអំពីការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជាដើម្បីសង្គ្រោះជាតិ នៅក្នុង

តំបន់រំដោះនៃប្រទេសកម្ពុជា ។ គេនិយាយថា រណសិរ្សនេះបានត្រូវបង្កើតឡើងនៅក្នុងអង្គប្រជុំមួយដែលមាន "មនុស្ស២០០នាក់តំណាងប្រជាជនខ្មែរគ្រប់ស្រទាប់វណ្ណៈ" ។ គេមិនដឹងពីកាលបរិច្ឆេទនៃអង្គប្រជុំនោះទេ ប៉ុន្តែគេថាគណៈកម្មាធិការកណ្តាលមួយមាន សមាជិកដប់បួននាក់បានត្រូវជ្រើសតាំងឡើង ដោយមាន **ហេងសំរិន** ជាប្រធាន ។ ហេងសំរិនជាអតីតសមាជិកបក្សក្នុងអង្គការនយោបាយភូមិភាគបូព៌ា និងជាអតីតស្នងការនយោបាយនិងជាមេបញ្ជាការកងពលលេខ៤ ។ វិទ្យុហាណូយនិយាយថា:

> **"អង្គប្រជុំក៏បានសម្រេចជាឯកច្ឆន្ទផងដែរនូវគោលការណ៍១១ចំណុច ស្តីអំពីភារកិច្ចនិងទិសដៅរបស់បដិវត្តន៍កម្ពុជា និងអំពាវនាវដល់ប្រជាជនខ្មែរឲ្យងើបឡើងតស៊ូ ដើម្បីផ្តួលរំលំបនបក្សពួកនិយមប៉ុលពត-អៀងសារី ហើយនិងដើម្បីកសាងនូវកម្ពុជាមួយដែលមានសន្តិភាព ឯករាជ្យ ប្រជាធិបតេយ្យ អព្យាក្រឹត មិនចូលបក្សសម្ព័ន្ធ ដើម្បីឈានទៅកាន់សង្គមនិយម ។"**

វៀតណាមបានបង្កើតគ្រឹះនៃរដ្ឋាភិបាលអាយ៉ង ដែលគេមានបំណងលើកបន្តុបនៅភ្នំពេញ ។ **ការធ្វើយ៉ាងនេះគឺដើម្បីយកលេសសម្រាប់ការឈ្លានពានរបស់គេ ។**

ក្នុងពីរអាទិត្យដំបូងនៃខែធ្នូ ទ័ពវៀតណាមពីរកងពលបានធ្វើដំណើរចូលភូមិភាគបូព៌ា ដោយប្រុងប្រយ័តបានចម្ងាយ១១២គ.ម.នៅក្នុងដីខ្មែរ ។ បន្ទាប់មក នៅថ្ងៃ២៥ធ្នូ ហាណូយបើកការវាយលុកគ្រប់មុខព្រួញដោយប្រើទ័ព៣០កងពល មានទាហានជាង១៥០ពាន់នាក់ ។ កងទ័ពនេះយកបានភ្នំពេញ ថ្ងៃ៧មករា១៩៧៩ ។ សាធារណរដ្ឋប្រជាមានិតកម្ពុជាក៏ត្រូវបានបង្កើតឡើងបន្តិចក្រោយមក ដោយមានហេងសំរិនជាប្រធានរដ្ឋ និង **ប៉ែនសុវណ្ណ**ជាអគ្គលេខាធិការនៃ**បក្សប្រជាជនបដិវត្តកម្ពុជា** *(ប.ប.ប.ក.)* ។ *(ប៉ែនសុវណ្ណ និងហេងសំរិន ក្រោយមកត្រូវគេកម្ចាត់ចេញ)* ។ ឈ្មោះប.ប.ប.ក.នេះជាឈ្មោះដែលហាណូយបានបង្កើតនៅខែកញ្ញា១៩៥១ ទុកឲ្យសមាសភាគខ្មែរដែលជាអ្នកស្នងបន្តនៅក្នុងបក្សកុម្មុយនិស្តឥណ្ឌូចិន ។

ពួកខ្មែរក្រហម ដែលកងទ័ពត្រូវកម្ទេចអស់ជាងពាក់កណ្តាល បាននាំគ្នារត់ទៅតំបន់ខាងលិចនៃប្រទេស។ មុនដំបូង ពួកគេសាកប្រឈមតទល់ជាមួយកងទ័ពវៀតណាម ។ តែយុទ្ធសាស្ត្រជ្រុលនិយមរបស់ពួកគេបានធ្វើឲ្យបាត់បង់នូវអាយុជីវិតមនុស្សដ៏ច្រើនឥតគណនា ។ ក្រោយៗមក ខ្មែរក្រហមក៏ងាកមកធ្វើសង្គ្រាមទ័ពព្រៃវិញ ។

## ១១-សេចក្តីសន្និដ្ឋាន

គេអាចយល់បានចំពោះការសម្រេចចិត្តរបស់វៀតណាម ក្នុងការវាយបកទៅលើកម្ពុជាប្រជាធិបតេយ្យដែលបានរុករានទន្ទ្រានទៅលើទឹកដីនិងប្រជាពលរដ្ឋរបស់គេ ។ ពិតហើយ ពួកយួនកុម.ជាអ្នកទទួលខុសត្រូវចំពោះ

អំរិភាពនៃខ្មែរភាគច្រើនទៅលើពួកគេ ដោយការប៉ុនប៉ងមិនបានសម្រេចរបស់វៀតណាម ដើម្បីត្រួតត្រាចលនាកុម្មុយនិស្តខ្មែរក្នុងសម័យបដិវត្ត និងសង្គ្រាមអស់ជាច្រើនទសវត្សរ៍ ។ ប៉ុន្តែ ការទំរើងប្រែងធ្វើវិទ្ធង្សនាដោយផ្ទាល់របស់វៀតណាមហាក់ដូចជាត្រូវគេបោះបង់ចោលក្រោយឆ្នាំ១៩៧៥ ។ តាមពិត រហូតមកដល់ដើមឆ្នាំ១៩៧៨ មេដឹកនាំវៀតណាមបានឆ្លើយតបចំពោះការវាយប្រហាររបស់ខ្មែរក្នុងបែបការពារខ្លួន រួមជាមួយនឹងន័យនយោបាយនិងយោធា ។ ដរាបណាកម្ពុជាប្រជាធិបតេយ្យនៅតែបន្តវិខានអុកឡុកវៀតណាម ដរាបនោះវៀតណាមនៅតែយល់ថា ការសម្រេចចិត្តរបស់គេក្នុងការគាំទ្រចលនាបះបោរក្នុងស្រុកប្រឆាំងនឹងខ្មែរក្រហម មិនមែនជាការហួសវិស័យឬជាការចម្លែកឡើយ ។ ការសម្រេចចិត្តនេះបានឆ្លុះបញ្ចាំងពីការសម្របសម្រួលមួយរវាងកិច្ចការពារសន្តិសុខជាតិរបស់វៀតណាមនៅចំពោះមុខកម្ពុជា និងចន្ទះដ៏ប្រុងប្រយ័តរបស់គេក្នុងការធ្វើ **មិនឲ្យចិនអន់ចិត្ត** ។

ប៉ុន្តែ ការសម្រេចចិត្តដោយថាហេតុរបស់មេដឹកនាំវៀតណាមក្នុងការឈ្លានពានទ្រង់ទ្រាយធំ និងការកាន់កាប់ទឹកដីគឺជា **ជម្រើស** មិនមែនជា**ការចាំបាច់**ឡើយ ។ វៀតណាមអាចចេះតែបន្តដាក់ទណ្ឌកម្ម ដោយធ្វើឲ្យវិនាសហិនហោចទៅលើខ្មែរនៅក្នុងទឹកដីខ្មែរ ។ កម្លាំងទ័ពនិងកម្លាំងអាវុធដ៏សម្បើមអស្ចារ្យរបស់វៀតណាមអាចធ្វើឲ្យសត្រូវរបស់គេចុះទន់ខ្សោយនៅក្នុងកាលដ៏យូរអង្វែង ដោយទុកឲ្យកម្ពុជាទុំជ្រុះហើយធ្លាក់ទៅក្នុងកណ្តាប់ដៃនៃក្រុមបះបោរ គាំទ្រដោយវៀតណាម ។ ប៉ុន្តែ កលល្បិចនេះមិនធានាថារបបក្រោយៗមកទៀត បើទោះជាស្ម័គ្រស្មោះនឹងវៀតណាមក៏ដោយ អាចនឹងស្ថិតនៅក្រោមការត្រួតត្រារបស់វៀតណាមនោះឡើយ ។ មានតែការចូលឈ្លានពានដោយផ្ទាល់ទេ ដែលវៀតណាមអាចសម្រេចកលល្បិចនោះបាន ។ បើសិនដូច្នោះមែន វានឹងវិលទៅករឿងចាស់ ដែលជាមហិច្ឆតារបស់ចក្រពត្តិវៀតណាមនោះឯង ។ ដូចយើងបានឃើញរួចមកហើយ មហិច្ឆតានេះបានចាក់ឬសយ៉ាងជ្រៅទៅក្នុងវប្បធម៌នយោបាយនៃវជនវៀតណាម ។ ដោយហេតុនេះ គេត្រូវការធ្វើនូវសេចក្តីពន្យល់ដ៏វែងអន្លាយមួយ ស្តីពីជម្រើសនយោបាយដែលបានធ្វើឡើងដោយថាហេតុ ។

ទិដ្ឋភាពនៃការពន្យល់មួយបែបទៀត ស្ថិតនៅលើទំនាក់ទំនងមិនប្រក្រតីរវាងវៀតណាមនិងចិន ហើយនិងគំនិតជ្រួលច្របល់របស់ហាណូយទៅលើទំនាក់ទំនងចិន_ខ្មែរ ដែលបានធ្វើឲ្យយួនវាយតម្លៃខុសទៅលើបញ្ហាខ្មែរក្រហម ។ នៅសម័យឆ្នាំ១៩៧៥_៧៧ ការតប_តរបស់វៀតណាមទៅលើខ្មែរក្រហមត្រូវបានធ្វើឡើងដោយវាស់វែងត្រឹមត្រូវ ព្រមទាំងអត់អោនថែមទៀតផង ។ តែនៅឆ្នាំ១៩៧៨ ទំនាក់ទំនងត្រឡប់ត្រឡិនរវាងចិននិងយួន រួមផ្សំជាមួយនឹងឬកពារចម្លែកផ្លែកពីធម្មតារបស់របបកម្ពុជាផង បានធ្វើឲ្យយួនកុម.សន្និដ្ឋានថា ខ្មែរក្រហមពិតជានៅក្រោមបញ្ជារបស់ចិន ។ ហេតុនេះ ដំណោះស្រាយដោយស្ងប់ស្ងាត់និងដោយពិចារណាមួយមុននេះបន្តិច

ហាក់ដូចជាដាក់បញ្ហាទាំឲ្យរំជួលចិត្តបន្ថែម ដែលហាណូយមើលឃើញថាកម្ពុជា ជាដាវដ៏មុតស្រួចរបស់ចិន កំពុងតែភ្ជង់ទៅលើវៀតណាម ។ មេដឹកនាំវៀតណាមមិនអាចរង់ចាំឲ្យ "បនប្រល័យពូជសាសន៍ ប៉ុលពត_អៀងសារី" កម្ទេចពួកគេមុនបានឡើយ ។ គេត្រូវតែកម្ទេចខ្មែរក្រហមឲ្យខ្ទេចហ្មត់ និងឲ្យបានដាច់រហ័ស ។ ចំណែកឯអាណិក_ជនចិន"ជួរទី៥" (អង្គការភិទ្ធផ្ស្រទាល្ងចលាក់) នៅក្នុងប្រទេសវៀតណាមវិញ បានត្រូវហាណូយមើលឃើញថាជាទិដ្ឋភាពទីពីរ ដែលជាប់ទាក់ទងគ្នាទៅវិញទៅមក ក្នុងការដែលចិនប៉ុនប៉ងធ្វើឲ្យវៀតណាមទន់ខ្សោយ និងរារាំងកុំឲ្យយួនមានការរីកចម្រើនឆ្ពោះទៅរកប្រទេសសង្គមនិយមដ៏ខ្លាំងមួយបាន ។

ម្យ៉ាងទៀត នៅក្នុងព្រឹត្តិហេតុនេះ បើទោះជាវៀតណាមគិតប្រឃុកប្រឃល់ដែលបណ្ដាលឲ្យគេនិយាយបំផ្លើសអំពីទំហំនៃការគំរាមកំហែងពីពួកខ្មែរក្រហម ហើយដែលបណ្ដាលឲ្យគេជ្រើសរើសយកមធ្យោបាយឈ្លានពាននិងកាន់កាប់ ដើម្បីតាមបំផ្លាញខ្មែរក្រហមទាំងស្រុងនោះ ក៏ភាពតក់ក្រហល់ប្រឃុកប្រឃល់នោះមិនបានធ្វើឲ្យវៀតណាមប្រព្រឹត្តផ្ដេសផ្ដាសនៅក្នុងទង្វើរបស់គេនោះដែរ ។ តាមការរីតចំណងមិត្តភាព និងតាមការធានាផ្ដល់ពស្តុភាពីសហភាពសូវៀត បើទោះជាមិនមែនអន្តរាគមន៍ផ្ទាល់ក៏ដោយ មេដឹកនាំវៀតណាមបានចាត់វិធានការចាំបាច់តាមផ្លូវយោធា ដើម្បីឈានទៅដល់លទ្ធផលនយោបាយមួយ ទោះមិនច្បាស់លាស់ក៏ដោយ ។ ហើយថ្វីបើការសម្រេចឈ្លានពានរបស់គេអាចប៉ះពាល់ដល់ដំណឹងគ្រោតគ្រាតអំពីស្ថានការណ៍នយោបាយនៅកម្ពុជា (ដូចជាថាទួនជា សុនសេន និងខ្មែរក្រហមជាន់ខ្ពស់ឯទៀតជាដៃជើងរបស់យួន) នេះមិនមែនមានន័យថាទស្សនៈនិងឥ_រិយាបថរបស់វៀតណាមចំពោះកម្ពុជាមិនសមហេតុមិនសមផលនោះទេ ។

ដូចគ្នាដែរ គេក៏មិនត្រូវនិយាយអំពីការសម្រេចចិត្តរបស់ខ្មែរក្រហមក្នុងការប្រឈមមុខជាមួយវៀតណាមតាមផ្លូវយោធាឡើយ ។ គឺគ្មានន័យអ្វីទាំងអស់ ចំពោះទស្សនៈទាំងឡាយណាដែលសន្មត់អំពីសកលភាពនៃសនិទា_នីយៈ *(ភាពសមហេតុសមផល)* ដោយការពិនិត្យពិច័យទៅលើឥរិយាបថនៃប្រទេស ជាពិសេសទាក់ទង នឹងបញ្ហាសង្គ្រាមនិងសន្តិភាព ។

ពិតហើយ ប្រវត្តិសាស្ត្របានផ្ដល់ដល់ប្រជាជនខ្មែរនូវគ្រឹះដ៏ជ្រៅនិងបរិសុទ្ធនៃគំនុំចាបចេះប្រចាំងនឹងជនជាតិវៀតណាម ។ ការគំរាមកំហែងយកទឹកដី ដែលវៀតណាមធ្វើបានសម្រេចក្នុងរយៈពេលជាងពីរសតវត្សរ៍កន្លងទៅ ទោះជាតាមរយៈការខិតខំរបស់គេក្ដី ឬតាមរយៈការសម្រេចចិត្តដ៏ភ្លើតភ្លើនរបស់រដ្ឋការអាណានិគមបារាំងក្ដី បានធ្វើឲ្យកម្ពុជាបាត់បង់នូវទឹកដីដ៏ធំធេង នូវកោតផលសេដ្ឋកិច្ច និងតម្លៃនៃការគោរពចំពោះពូជសាសន៍ខ្មែរ ។ ហួសពីនេះទៅទៀត មេដឹកនាំកុម្មុយនិស្ត ដែលត្រួតត្រាកម្ពុជាពីថ្ងៃ១៧មេសា១៩៧៥ មានមូលហេតុពិសេស

ផ្ទាល់ខ្លួនរបស់គេ ដែលបានដក់ជាប់នៅក្នុងការពិសោធន៍ជាប្រវត្តិសាស្ត្រថ្មីៗនេះ ទៅលើការមិនទុកចិត្តវៀតណាម ដែលមានបំណងចង់ត្រួតត្រាប្រជាជាតិខ្មែរ ។

មេខ្មែរក្រហមមានសិទ្ធិក្នុងការក្រេវក្រោធប្រចាំងនឹងវៀតណាម និងមិនទុកចិត្តវៀតណាម ។ តែនៅឆ្នាំ១៩៧៥_៧៧ គេមិនឃើញមានមូលហេតុត្រឹមត្រូវណាមួយគួរឱ្យជឿថា កម្ពុជាស្ថិតនៅក្នុងគ្រោះថ្នាក់ដ៏ធំនៃការធ្លាក់ទៅក្នុងកណ្តាប់ដៃវៀតណាមឡើយ ដោយនៅពេលនោះ វៀតណាមរវល់តែជាប់ដៃនៅក្នុងបញ្ហាផ្ទាល់ខ្លួនរបស់គេ ហើយណាមួយ គេមិនចង់រំខានចិនឱ្យលើសពីការដែលគេបានធ្វើរួចហើយនោះដែរ ។

ខាងផ្នែកទស្សននយោបាយ ថ្នាក់ដឹកនាំខ្មែរក្រហមមិនបានយកឧត្តមគតិមកប្រើក្នុងការកែលម្អឡើងវិញនូវអំពើក្រេវក្រោធ និងក្នុងការសម្រាលកង្វល់ភ័យខ្លាចឡើយ ។ គេបែរជាប្រើកម្លាំងទ័ពតទល់ជាមួយសត្រូវដ៏ខ្លាំងមួយដែលមិនអាចប្រៀបផ្ទឹមបាន ។ ដូចយើងបានឃើញហើយ សកម្មភាពរបស់ខ្មែរក្រហមបានត្រឹមតែ ជួយជម្រុញនិងកម្លាវៀតណាមឱ្យធ្វើនូវអ្វីដែលខ្មែរក្រហមភ័យខ្លាច គឺការឈ្លានពាននិងការផ្តួលរំលំរបបរបស់គេតែប៉ុណ្ណោះ ។

ដូច្នេះ តើយើងពន្យល់ជំនឿឥតមូលដ្ឋាន និងអំពើមិនសមហេតុផលទាំងពីរនេះយ៉ាងដូចម្តេច ? ចម្លើយស្ថិតនៅលើទស្សនសាកលដែលចាកភាពដើមរបស់មេដឹកនាំខ្មែរក្រហម ។

ជំនឿរបស់ប៉ុលពតនិងបក្សពួកក្រោយឆ្នាំ១៩៧៥ ដែលជឿថាពួកគេស្ថិតនៅក្នុងគ្រោះអាសន្ននៃការលេបត្របាក់ដោយវៀតណាម គឺជាការស្រមើស្រមៃមួយដែលដូចគ្នានឹងការជឿថារបបរបស់គាត់ស្ថិតនៅក្នុងគ្រោះថ្នាក់ដ៏ធំនៃវិទ្ធង្សនាផ្ទៃក្នុង ។ យុទ្ធសាស្ត្រជ្រៀតចូលដាយថាហេតុរបស់ហាណូយ បានត្រូវប្រចាំងដោយការបោសសម្អាតផ្ទៃក្នុងរបស់ប៉ុលពតក្នុងឆ្នាំ១៩៧៣_៧៥ ។ លើកនេះ វិទ្ធង្សនាផ្ទៃក្នុងត្រូវបានគេស្មានថា បក្សកំពុងត្រូវ "ខ្មាំងគ្រប់ស្រទាប់ជ្រៀតចូល" ។ ម្យ៉ាងទៀត ធម្មជាតិស្រមើស្រមៃនៃការភ័យខ្លាចនេះធ្វើឱ្យគេនឹកឃើញដល់ជនរងគ្រោះដែលត្រូវគេបោសសម្អាតកាលពីឆ្នាំ១៩៧៧_៧៨ ដោយរួមទាំងអតីតសមមិត្តរបស់ប៉ុលពតផង, ធ្វើឱ្យគេនឹកឃើញដល់ការគាបយកចម្លើយសារភាពពីជនរងគ្រោះ តាមរយៈការធ្វើទណ្ឌកម្ម, ហើយនិងធ្វើឱ្យគេនឹកឃើញជាពិសេស នូវការចោទប្រកាន់ផ្តេសផ្តាសថាជាភ្នាក់ងារវៀតណាម, ភ្នាក់ងារសូវៀត ឬសេអ៊ីអាក្នុងបែបផែនជាខ្សែរយៈ ។ ច្បាស់ណាស់ថា ក្នុងការស្ថាបនាដោយខ្លួនឯងនូវឧទាហរណ៍នៃ"សហគមន៍ច្របូកច្របល់"មួយ ថ្នាក់ដឹកនាំខ្មែរក្រហមបានសម្តែងឱ្យឃើញនូវវប្បធម៌មួយដែលជ្រួតជ្រាបជាកជាំទៅដោយ "ភាពច្របូកច្របល់ខ្វល់ខ្វាយ" ។

ស្របគ្នានឹងការគិតស្រមើស្រមៃអំពីវិទ្ធង្សនាផ្ទៃក្នុងនេះ យើងក៏បានរកឃើញដែរនូវគំនិតស្រមើស្រមៃអំពី "ភាពជ្រុលនិយមម៉ៅ"ដែលជាមនោគមន៍វិជ្ជាក្នុងស្រុករបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ ។ ខ្មែរក្រហមបានអូត

អាងថា "ការកសាងសង្គមនិយម"របស់គេបានដើរលឿន និងទៅឆ្ងាយជាងប្រទេសសង្គមនិយមឯទៀត (ដែលនៅក្នុងនោះមានប្រទេសជាមិត្តផងដែរ) ។ ពួកគេជឿថា **សង្គមនិយមនិងសមូហភាពនិយមច្រើន** និង **មូលធននិយមនិងបុគ្គលនិយមតិច** ទាំងពីរនេះរួមគ្នាជាមួយនឹងភេរវកម្មប្រចាំងនឹងខ្មាំងថែមទៀត អាចធ្វើឲ្យប្រជាជនខ្មែររួបរួមគ្នាបាន ។ មេខ្មែរក្រហមជឿថា ការកែប្រែសង្គមនិយមដ៏ចាប់រហ័សនៃរចនាសម្ពន្ធសង្គម និងសេដ្ឋកិច្ចរបស់កម្ពុជា អាចធ្វើឲ្យកម្ពុជារឹងមាំក្នុងការប្រយុទ្ធតទល់នឹងការគំរាមកំហែងរបស់វៀតណាម ។

តាមការណ៍ពិត ល្បឿននៃការកែប្រែសង្គមនិយមបានធ្វើឲ្យប្រជាជនខ្មែរហេវហត់ខ្សោះខ្សល់ សល់តែស្បែកដណ្តប់ឆ្អឹង ។ ទាំងអស់រួមផ្សំគ្នាជាមួយនឹងភេរវកម្មបានធ្វើឲ្យប្រជាជនភាគច្រើន ដែលប្រចាំងនឹងយួនជាប្រពៃណីដែរនោះ ខូចទឹកចិត្តឈប់គាំទ្ររដ្ឋាភិបាលខ្លួន ។ ដូច្នេះ គំនិតស្រមើស្រមៃរបស់បដិវត្តកម្ពុជា ដែលជាឫសគល់របស់មនោគមន៍វិជ្ជាខ្មែរក្រហម ជាបច្ច័យនៃមហន្តរាយដល់កម្ពុជាប្រជាធិបតេយ្យរបស់ខ្មែរក្រហម ។

ទីបំផុត ដោយបានពិចារណាទៅលើមូលហេតុមិនសមស្របនៃសកម្មភាពយោធារបស់ខ្មែរក្រហមប្រចាំងនឹងវៀតណាម និងជំនឿមេខ្មែរក្រហមទៅលើឧត្តមភាពនៃភាពទន់ខ្សោយរបស់ខ្លួន យើងក៏បានរកឃើញឡើងវិញនូវជំនឿអរូបិយជាទូទៅដែលធ្លាប់មានរាប់ពាន់ឆ្នាំមកហើយនៅក្នុងចលនាតស៊ូខ្មែរ ។

ដូចយើងបានឃើញស្រាប់ ភាពច្របូកច្របល់ក្រពុលមុខនិងនិន្នាការមនោគមន៍វិជ្ជាអរូបិយរបស់ខ្មែរក្រហមទៅលើវៀតណាម បានត្រូវគេមើលឃើញទាំងស្រុងនៅក្នុងនយោបាយការបរទេសរបស់ពួកគេ ។ គឺកត្តាទាំងនេះហើយ មិនមែនការបង្ខិតបង្ខំពីចៅហ្វាយចិនទេ ដែលពន្យល់អំពីអាកប្បកិរិយារបស់ខ្មែរក្រហម ។

♥

# ជំពូក៥

## ១- យុទ្ធសាស្ត្របែកផ្លូវគ្នារបស់សូវៀតនិងវៀតណាមចំពោះកម្ពុជា: ១៩៧០-៧៥ ៖

ហេតុការណ៍ដ៏ចម្លែកអស្ចារ្យមួយនៃវិវាទនៅឥណ្ឌូចិនមុនឆ្នាំ១៩៧៥គឺថា នៅពេលដែលយួនកុម្មុយនិស្តកំពុងតែល្អូកល្អឺនជាមួយសហភាពសូវៀត ប្រទេសទាំងពីរនេះបែរជាអនុវត្តនយោបាយផ្សេងគ្នាទៅវិញចំពោះកម្ពុជា ។ ក្រោយពីកម្ពុជាធ្វើរដ្ឋប្រហារប្រឆាំងនឹងវត្តមានយួនវៀតកុងនៅលើទឹកដីខ្មែរ នៅខែមីនា១៩៧០ភ្លាម ទ័ពយួនកុម.វាយប្រាវមកលើកងទ័ពសាធារណរដ្ឋថ្មី ហើយក៏បានជួយផ្គុំផ្ដើមបង្កើតទ័ពព្រៃកុម.ខ្មែរដែលដឹកនាំដោយសម្ដេចសីហនុ ។ ប៉ុន្តែ សម្ពន្ធមិត្តរបស់ហាណូយ (ស.ស.ស.ស.) ឈរនៅឆ្ងាយ ឥតមានធ្វើអត្ថាធិប្បាយអ្វីទេអំពីរឿងទ័ពព្រៃខ្មែរ ហើយនៅតែរក្សាចំណងផ្លូវទូតជាមួយរដ្ឋាភិបាលប្រឆាំងកុម្មុយនិស្តនៅភ្នំពេញ រហូតដល់ពេលជិតចប់សង្គ្រាម ។

បើទោះជាមានការអះអាងថាគាំទ្រក៏ដោយ ក៏ស.ស.ស.ស.មិនដែលទទួលស្គាល់ជាផ្លូវការនូវរដ្ឋាភិបាល គ្រុង (GRUNK=Gouvernement Royal d'Union Nationale du Kampuchea= រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា) ដែលជារដ្ឋាភិបាលនិរទេសរបស់សម្ដេចសីហនុឡើយ។ សហភាពសូវៀតនៅតែបន្តទទួលស្គាល់រដ្ឋាភិបាលលន់ណុលតទៅទៀត ។

ហេតុអ្វីបានជាសហភាពសូវៀតទទួលស្គាល់ ហ៊្វុង ( FUNK = Front Uni National du Kampuchea រណសិរ្សរួបរួមជាតិកម្ពុជា ) ហើយបែរជាមិនទទួលស្គាល់ គ្រុង ទៅវិញ ? ចម្លើយគឺច្បាស់ជាប្រហែលស្ថិតនៅលើភាពស្មុគស្មាញនយោបាយរបស់ក្រុមខ្មែរបះបោរនាសម័យនោះ ដោយហេតុថា ក្នុងរយៈពីរឆ្នាំដំបូងនៃសង្គ្រាម ហ៊្វុង ទំនងហាក់ដូចជាស្ថិតនៅក្រោមបញ្ជាផ្ទាល់របស់យួនកុម្មុយនិស្ត នៅពេលដែល គ្រុង ស្ថិតនៅក្នុងអង្គភាពទូតរបស់សម្ដេចសីហនុនៅទីក្រុងប៉េកាំង ក្រោមឥទ្ធិពលប្រទេសចិន ។ការបកស្រាយរបស់សហភាពសូវៀតនេះស៊ីគ្នានឹងការបញ្ជាក់បន្ថែមរបស់សម្ដេចសីហនុ នៅក្នុងការរំលឹកជាហូរហែរបស់ទ្រង់ចាប់ពីខែមីនា ១៩៧០ រហូតដល់ខែកុម្ភៈ ១៩៧៣ ៖

"កាលនោះ ខ្ញុំតែងតែទៅហាណូយជារឿយៗ ហើយទូតសូវៀតក៏បានសុំជួបខ្ញុំ ។ ដោយឥតលាក់លៀម អ្នកការទូតនោះបានប្រាប់ខ្ញុំថា រដ្ឋាភិបាលរបស់គាត់ទទួចសុំចង់ឱ្យខ្ញុំចេញពីប៉េកាំង ហើយវិលទៅកម្ពុជាវិញដើម្បីដឹកនាំការតស៊ូរំដោះជាតិ ។"

ស្ទើរតែពេញមួយរយៈពេលនៃសង្គ្រាម សហភាពសូវៀតនិងសម្ព័ន្ធមិត្តនៃកតិកាសញ្ញា វ៉ារសូវី របស់គេបន្តទទួលស្គាល់រដ្ឋាភិបាលលន់ណុល ទទួលអ្នកការទូតរបស់សាធារណរដ្ឋខ្មែរនៅអឺរ៉ុបខាងកើត ហើយរក្សាទុកស្ថានទូតសូវៀតនៅភ្នំពេញ ។ ហេតុការណ៍ទាំងនេះបានបណ្តាលឱ្យមានឧប្បត្តិហេតុដ៏អាម៉ាស់មួយៈ នៅទីក្រុងប្រាក ក្នុងខែសីហា ១៩៧០ មន្ត្រីការទូតនិងនិស្សិតខ្មែរជាច្រើននាក់ តំណាង គ្រុង បានដណ្តើមយកស្ថានទូតខ្មែរពីពួកសាធារណរដ្ឋ ។ អាជ្ញាធរ ឆេកូស្លូវ៉ាគី បានហ៊ុំព័ទ្ធស្ថានទូត ហើយបានបង្ខំអ្នកដណ្តើមឱ្យដើរចេញ ។

យោងតាមអ្នកធ្វើវិភាគនយោបាយសូវៀតដើងចាស់ម្នាក់អំពីបញ្ហាខ្មែរបានឱ្យដឹងថា មានការមិនចុះសម្រុងគ្នា ក្នុងសេចក្តីសម្រេចចិត្តនៃបញ្ញវន្តសូវៀតអំពីនយោបាយកម្ពុជា ។ ចំណុចសំខាន់នៃការមិនចុះសម្រុងគ្នាគឺស្ថិតនៅត្រង់ថា តើក្រុមបះបោរខ្មែរឈ្នះឬមិនឈ្នះ ? ក្រុម អ្នកសំអាងលើហេតុការណ៍ ជឿថាពួកខ្មែរកុម.និងសម្តេចសីហនុមិនអាចឈ្នះឡើយ ។ ក្រុម អ្នកជ្រុលនិយម ជឿថាក្រុមខ្មែរបះបោរនឹងឈ្នះ ដូចវៀតណាមនិងលាវកុម.ដែរ ។

តាមរយៈសង្គ្រាមប៉ាកាជាចំហជាមួយសម្តេចសីហនុ នៅដើមឆ្នាំ១៩៧២ សូវៀតយល់ឃើញថា គេគួរតែរិះរកដំណោះស្រាយនយោបាយផ្សេងទៀត ។ នៅដើមឆ្នាំ១៩៧២ សូវៀតចាប់ផ្តើមទាក់ទងជាមួយរដ្ឋាភិបាលលន់ណុល ក្នុងបំណងបង្កើតកម្លាំងទីបី មួយដែលអនុញ្ញាតឱ្យបក្សកុម.មានសិទ្ធិអាចចូលរួមបោះឆ្នោតបាន ។ សូវៀតចង់ឱ្យ ហង់ ធុនហាក់ សាកលវិទ្យាធិការនៃមហាវិទ្យាល័យវិចិត្រសិល្បៈជាអ្នកដឹកនាំបក្ស ។ គេបានរាយការណ៍មកថាកម្មាភិបាលបក្សនឹងត្រូវជ្រើសរើសចេញពីមហាវិទ្យាល័យនេះខ្លះ ពីវិជ្ជាស្ថានបច្ចេកទេសសូវៀតនៅភ្នំពេញខ្លះ និងពីក្នុងចំណោមខ្មែរដែលបានទៅហ្វឹកហ្វឺននៅសាកលវិទ្យាល័យ ប៉ាទ្រីស លូមុមបា នៅទីក្រុងម៉ូស្គូខ្លះ ។ សូវៀតក៏បានស្នើរសុំផងដែរឱ្យកម្ពុជាអនុញ្ញាតឱ្យ

យួនហាណូយ ដែលកំពុងនៅលើទឹកដីខ្មែរ ប្រើទឹកដីទាំងឡាយដែលនៅខាងកើតទន្លេមេគង្គជាទីជម្រកផង ។ ប៉ុន្តែ សេចក្តីស្នើរបានត្រូវទាត់ចោលដោយរដ្ឋាភិបាលលន់ណុល ដោយហេតុថា គេមិនអាចអនុញ្ញាតឱ្យទ័ពយួនហាណូយរស់នៅលើទឹកដីខ្មែរឡើយ ។ ហើយផែនការណ៍នេះ ក៏ត្រូវបានជំទាស់ទាំងស្រុងពីសម្តេចសីហនុនិងចិន ដោយគេយល់ថានេះជាមូលហេតុដ៏ច្បាស់ក្រឡែតមួយក្នុងការទប់ស្កាត់ឥទ្ធិពលរបស់ចិន ។ ទោះយ៉ាងណា សេចក្តីស្នើរនោះមិនអាចចេញរួចឡើយ ពីព្រោះខ្មែរក្រហមនិន្នាការចិនដែលកំពុងត្រួតត្រាក្រុមខ្មែរបះបោរក៏ប្រឆាំងដាច់ខាតនឹងសម្នើរនោះដែរ ។

ទិដ្ឋភាពនៃនយោបាយសូវៀតមួយទៀតដែលគួរឱ្យកត់សម្គាល់គឺ មូលហេតុដែលគេបន្តមិនទទួលស្គាល់រដ្ឋាភិបាល គ្រុង ដែលគ្រាន់តែជារាំងននយោបាយ ផ្តល់ការគាំទ្រមិនពេញលេញដល់រណសិរ្ស ហ៊្វុង ដែលគ្រប់គ្រងដោយពួកជ្រុលនិយមម៉ៅ ( ពួកប្រឆាំងសូ-វៀត) តាំងពីឆ្នាំ១៩៧២មក ។ ហេតុអ្វីបានជាពួកសូវៀតវិនិច្ឆ័យស្មានការណ៍ខុស ? សូវៀតដែលមានចារបុរស នៅក្នុងក្រុមខ្មែរបះបោរ តិចជាងយួនហាណូយនោះ មិនបានចាប់អា - រម្មណ៍ចំពោះអាកប្បកិរិយារបស់ខ្មែរក្រហមនិយមម៉ៅ និងប៉ាន់ស្មានខុសអំពីកម្លាំងពួកនិ - យមសូវៀត និងនិយមហាណូយ នៅក្នុងក្រុមបះបោរខ្មែរ ។

ប៉ុន្តែ នយោបាយសូវៀតបានត្រូវប្តូរទិសនៅពេលដែលស.រ.អ.ឈប់ទម្លាក់គ្រាប់បែកនៅខែសីហា ១៩៧៣ ។ សារពត៌មានសូវៀតបានខំប្រឹងយកចិត្តទុកដាក់ទៅលើឥទ្ធិពលនៃការទម្លាក់គ្រាប់បែកអាមេរិកាំង ក្នុងរដូវផ្ការីកនិងរដូវប្រាំង នាឆ្នាំ១៩៧៣ រួមជាមួយនឹងការប៉ុនប៉ងរបស់សភាអាមេរិកាំង ដើម្បីឱ្យបញ្ឈប់ការទម្លាក់គ្រាប់បែក ។ នៅពេលដឹងច្បាស់ថាការទម្លាក់គ្រាប់បែកត្រូវបានបញ្ចប់ហើយ សហភាពសូវៀតបានរៀបចំចាត់វិធានការបន្ថែមខ្លះ ដើម្បីរកភាពស្របច្បាប់ដល់សម្តេចសីហនុ និងរដ្ឋាភិបាលរបស់ទ្រង់ ។ ចុងខែកក្កដា កាសែត ប្រាវ៉ដា បានផ្សាយអំពីទស្សនកិច្ចរបស់សម្តេចសីហនុនៅកូរ៉េខាងជើង ក្នុងឋានៈជាប្រធាន ហ៊្វុង (ឋានន្តរសក្តិបន្ទាប់បន្សំរបស់ទ្រង់ខាងផ្នែកការទូត) ។ ខែសីហា បន្ទាប់ពីថ្ងៃអា-មេរិកាំងឈប់ទម្លាក់គ្រាប់បែក ប្រាវ៉ដា បានរាយការណ៍អំពីសេចក្តីថ្លែងការណ៍របស់សម្តេច

សីហនុ អានដោយប៉ែននុត ដោយបានបញ្ជាក់ថា រូបលោកទាំងពីរជាអ្នកដឹកនាំរដ្ឋាភិបាលនិរទេស ។ បីថ្ងៃបន្ទាប់មក ប្រាវដាបានរាយការណ៍អំពីសេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាល ។ ខែតុលា ទូតសូវៀតបានជួបសម្តេចសីហនុនៅប៉េកាំង ។

ក្នុងសម័យប្រជុំជជែកដេញដោលគ្នាអំពីបញ្ហាអាសនៈខ្មែរនៅអង្គការសហប្រជាជាតិ ឆ្នាំ១៩៧៣ សហភាពសូវៀតបានឱ្យកៅអីទៅរដ្ឋាភិបាលគ្រុង ។ កាលពីមួយខែមុន សូវៀតបានបញ្ជាឱ្យភារធារី និងអ្នកការទូតភាគច្រើនដកចេញពីភ្នំពេញ ដោយទុកតែបុគ្គលិកមួយចំនួនតូចសម្រាប់យាមស្ថានទូត ដែលសភាពការណ៍នេះ មើលទៅទំនងដូចជាចង់ទទួលស្គាល់ទាំងសងខាង ។

ការបញ្ឈប់ទម្លាក់គ្រាប់បែករបស់អាមេរិកាំង ហាក់ដូចជាបានធ្វើឱ្យសហភាពសូវៀតសម្លឹងឆាកមកមើលស្ថានការណ៍ក្រុមខ្មែរបះបោរឡើងវិញ ។ ប៉ុន្តែក្នុងលក្ខណៈប្រុងជើងការ សហភាពសូវៀតមិនទាន់កាត់ផ្តាច់ចំណងទូតទាំងស្រុងពីភ្នំពេញនៅឡើយទេ ។ គេរង់ចាំរហូតដល់ថ្ងៃ២៨មីនា ១៩៧៥ ទើបសហភាពសូវៀតសម្រេចឱ្យដកអ្នកការទូតទាំងអស់និងមន្ត្រីផ្សេងទៀត ដែលតំណាងរដ្ឋាភិបាលលន់ណុល ចេញពីទីក្រុងម៉ូស្គូ ហើយប្រកាសទទួលស្គាល់រដ្ឋាភិបាលគ្រុងថាជារដ្ឋាភិបាលស្របច្បាប់របស់កម្ពុជា ។ ទោះជាយ៉ាងណាក៏ស្ថានទូតសូវៀតនៅភ្នំពេញមិនដែលបិទឡើយ ។

ការផ្លាស់ប្តូរនយោបាយរបស់រដ្ឋាភិបាលលន់ណុលក្នុងអាទិត្យចុងក្រោយបង្អស់នេះ មិនបានធ្វើឱ្យមេដឹកនាំក្រុមបះបោររីករាយឡើយ ។ ពេលខ្មែរក្រហមយកភ្នំពេញបាននៅខែមេសា១៩៧៥ គេបានចាប់ចងបុគ្គលិកទូតសូវៀតដែលនៅសេសសល់ បញ្ជូនទៅស្ថានទូតបារាំង រង់ចាំការនិរទេសខ្លួនចេញពីកម្ពុជាប្រជាធិបតេយ្យ ។

យោងតាមសម្តេចសីហនុ៖

"នៅពេលខ្មែរក្រហមបានចូលដល់ទីក្រុងភ្នំពេញ ក្រុមខ្មែរក្រហមមួយកងឯកតាព បាននាំគ្នាដើរសំដៅទៅស្ថានទូតសូវៀត ទម្លាក់ទង់ជាតិសូវៀតចុះ ហើយដុតចោលដើម្បីសងសឹក ។ ពួកគេបានប្រាប់ពួករុស្ស៊ីថា: ពួកអ្នកឯងចូលជាមួយបនលន់ណុល ចូលជាមួយចក្រពត្តិអាមេរិក ។ ឥឡូវយើងត្រូវដាក់ទោសអ្នកឯង ដើម្បីធ្វើឱ្យអ្នកឯងអាម៉ាស់

មុខ ។ ថាហើយ ពួកគេចាប់អ្នកការទូតសូវៀតចង ដាក់លើឡានបាំប្រ៊ុប ហើយបើកសំដៅទៅស្ថានទូតបារាំង... ។ នេះគឺជាការអាម៉ាស់មុខមួយដ៏សម្បើមរបស់ពួករុស្ស៊ី ។"

ហេតុអ្វីបានជាសហភាពសូវៀតមិនបានផ្តល់ការគាំទ្រផ្លូវទូតឱ្យបានពេញលេញដល់ពួកក្រុមបះបោរនៅកម្ពុជា ដោយរង់ចាំរហូតទាល់តែដល់អាទិត្យចុងក្រោយបង្អស់នៃសង្គ្រាមនោះ? តាមការណ៍ពិត សូវៀតបានស្គាល់នូវឧត្តមានុភាព (អានុភាពដ៏ឧត្តម) នៃប្រទេសចិន ទាំងទៅលើខ្មែរក្រហម ទាំងទៅលើសម្តេចសីហនុ ។ គេទំនងជាមិនចង់ឱ្យខ្លួនគេក្លាយទៅជាអតិថិជនរបស់ចិនឡើយ ។

ប៉ុន្តែ ការពន្យល់នេះមិនគួរជាទីពេញចិត្តទេ ដោយហេតុថា សហភាពសូវៀតបានជួយវៀតណាមខាងជើង ហើយវៀតណាមខាងជើងបានគាំទ្រយ៉ាងពេញបន្ទុកផ្នែកការទូតដល់ពួកទ័ពព្រៃខ្មែរ ហើយថែមទាំងផ្តល់គ្រឿងអាវុធរបស់ចិន ដល់ពួកគេរហូតដល់ឆ្នាំ១៩៧៥ទៀតផង ។ ហេតុអ្វីបានជាសហភាពសូវៀតនិយាយមិនស៊ីចង្វាក់គ្នាជាមួយនឹងសម្ពន្ធមិត្តរបស់ខ្លួន? យោងតាមអតីតមន្ត្រីម្នាក់ ដែលធ្លាប់បានចូលរួមក្នុងការពិភាក្សាតទល់បញ្ហានយោបាយរបស់សូវៀតបានឱ្យដឹងថា មេដឹកនាំវៀតណាមមិនដែលបានបញ្ជាក់ថាសហភាពសូវៀតទទួលស្គាល់រដ្ឋាភិបាលសម្តេចសីហនុឡើយ ។ បើសិនជាគេទទួលស្គាល់មែននោះ គេនឹងអនុវត្តតាមមិនខាន ។

ពួកសូវៀតបានកំពុងលេងល្បែងនយោបាយដោយប្រុងប្រយ័ត ។ គេរង់ចាំមើលទាល់តែស្ថានការណ៍យោធាបានត្រូវដោះស្រាយរួចជ្រះស្រឡះ ទើបគេបណ្តោយឱ្យវៀតណាមធ្វើការសម្រេចចិត្តដោយឥតរារែកចូលកម្ពុជា ដោយគេមើលឃើញថា បើយួនឈ្នះយួនបានចំណេញ តែបើយួនចាញ់ យួនក៏មិនខាត ។

ជាការពិតណាស់ហើយថា នៅមានមូលហេតុច្រើនទៀតក្នុងបញ្ហាបែកផ្លូវគ្នារបស់ម៉ូស្គូ-ហាណូយស្តីអំពីរឿងកម្ពុជា ។ ប៉ុន្តែ អាកប្បកិរិយាផ្សេងគ្នារបស់សហភាពសូវៀតនិងវៀតណាមខាងជើងចំពោះប្រទេសចិន ក៏ជាកត្តាចម្បងមួយទៀតដែរ ។ ដូចយើងបានឃើញក្នុងជំពូកមុនរួចមកហើយថា នៅឆ្នាំ១៩៧០ នយោបាយនិងមនោគមន៍វិជ្ជារបស់

យួនកុម្មុយនិស្តមានភាពខុសគ្នាឆ្ងាយពីចិន គឺជាភាពខុសគ្នាមួយដែលកើតមានឡើងតាំងតែពីជប់ឆ្នាំមុនម្ល៉េះ ។ ប៉ុន្តែ នៅចុងឆ្នាំ១៩៧៥ បើទោះជាមានភាពតានតឹងរវាងសូវៀតនិងចិនក៏ដោយ ក៏វៀតណាមនៅតែមិនទាន់អើពើអ្វីដែរ ។ ហើយម្យ៉ាងទៀត យួនក៏មិនទាន់យកទំនាស់ដែលគេកំពុងមានជាមួយនឹងចិនទៅធ្វើជាបញ្ហាសំខាន់ នៅក្នុងនយោបាយកម្ពុជារបស់គេឡើយ ។

កិច្ចប្រជុំខែមិថុនា ១៩៧៨ នៅម៉ូស្គូ ពិតជាមានទាក់ទិននឹងរឿងផ្សេងទៀតក្រៅពីរឿងសេដ្ឋកិច្ច ។ រឿងនេះបានត្រូវបញ្ជាក់ឱ្យកាន់តែច្បាស់ថែមទៀតដោយវត្តមានរបស់ឡេ ឡៀងគាន់ ដែលជាគណៈប្រតិភូកងទ័ពប្រជាជនវៀតណាមរបស់ឡេយន់ ។ ម្យ៉ាងទៀតដូចយើងបាននិយាយរួចមកហើយថា កម្មាភិបាលយួនទាំងឡាយបានត្រូវគេប្រាប់ឱ្យប្រុងប្រៀបរៀបចំខ្លួនចូលឈ្លានពានកម្ពុជា នៅខែមិថុនា១៩៧៨ ។ វៀតណាមយល់ឃើញថា ជំនួយយោធារបស់សូវៀតអាចចាត់ទុកបានថាជាជំនួយដ៏មានប្រសិទ្ធិភាពនៅក្នុងប្រតិបត្តិការបែបនេះ ។ ការផ្តល់នូវការគាំទ្រនេះទំនងជាមានចែងនៅក្នុងរបៀបវារៈ បើទោះជាចេតនាទាំងឡាយរបស់វៀត-ណាមមិនបានបញ្ជាក់ក៏ដោយ ។

នៅថ្ងៃ៣ខែវិច្ឆិកា សហភាពសូវៀត (ស.ស.) និងវៀតណាមបានចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាពនិងសហប្រតិបត្តិការមួយ ។ គន្លឹះសំខាន់នៃសន្ធិសញ្ញានេះត្រូវបានគេរកឃើញនៅក្នុងបីមាត្រា ៖

មាត្រា២

- **ភាគីទាំងពីរនឹងបន្តសម្របសម្រួលផែនការសេដ្ឋកិច្ចជាតិរយៈពេលវែង ព្រមព្រៀងគ្នាក្នុងរយៈពេលវែងដោយផ្តោតទៅលើការអភិវឌ្ឍន៍ផ្នែកដ៏សំខាន់ជាងគេក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រនិងបច្ចេកទេស និងការប្តូរចំណេះដឹងនិងការពិសោធន៍ ដើម្បីរួមចំណែកក្នុងការកសាងសង្គមនិយមនិងកុម្មុយនិស្តនិយម ។**

មាត្រា៤

- **ភាគីទាំងពីរនឹងប្រឹងប្រែងឱ្យអស់ពីសមត្ថភាពដើម្បីពង្រឹងប្រព័ន្ធសង្គមនិយមក្នុងពិភពលោក និងរួមចំណែកក្នុងការអភិវឌ្ឍន៍ និងការការពារផលប្រយោជន៍សង្គមនិយម ។**

មាត្រា៦

- ក្នុងករណីដែលភាគីណាមួយត្រូវគេវាយប្រហារ ឬត្រូវគេគំរាមថានឹងវាយប្រហារ ភាគីហត្ថលេខីទាំងពីរត្រូវពិភាក្សាគ្នាជាបន្ទាន់ដើម្បីចាត់វិធានការបង្ក្រាបការគំរាមកំហែង និងត្រូវចាត់វិធានការឱ្យបានត្រឹមត្រូវនិងមានប្រសិទ្ធិភាព ដើម្បីរក្សាសន្តិភាពនិងសន្តិសុខនៃប្រទេសទាំងពីរ ។

*សន្ធិសញ្ញានេះមានតម្លៃដូចគ្នានឹងសេចក្តីថ្លែងការសម្ពន្ធភាពខាងផ្នែកសេដ្ឋកិច្ច និងនយោបាយ ហើយដែលស្រដៀងគ្នានឹងសម្ពន្ធភាពយោធាដែរ ។ នេះគឺជាសម័យកាលមួយដែលស្ថានការណ៍ឡើងដល់កម្រិតខ្ពស់បំផុត ចាប់តាំងពីឆ្នាំ១៩៧០មក ។ ម៉្យាងទៀត វៀតណាមបានគូសបញ្ជាក់ថា* ការចុះហត្ថលេខាលើសន្ធិសញ្ញា បានបើកនូវទំព័រថ្មីមួយ ក្នុងទំនាក់ទំនងរវាងបក្សនិងប្រទេសនៃប្រជាជនវៀតណាម និងប្រជាជនសូវៀត ។

*តើអ្វីទៅដែលជាគោលបំណងរបស់សន្ធិសញ្ញា? អត្ថបទមួយនៅក្នុងទិន្នានុប្បវត្ត* តាប់ជីកុងសាន *របស់បក្សកុម្មុយនិស្តវៀតណាម បានរៀបរាប់អំពីការបំផុសគំនិត លើកទឹកចិត្តដ៏មានប្រសិទ្ធិភាពរបស់សហភាពសូវៀត តាំងពីឆ្នាំ១៩១៧៖*

ក្នុងពេលបច្ចុប្បន្ននេះ មានហេតុការណ៍មួយដែលគ្មានអ្នកណាម្នាក់អាចបដិសេធបាន ៖ នៅចំពោះមុខកម្លាំងដែលមិនចេះចាញ់នៃសាធារណរដ្ឋសង្គមនិយមសហភាពសូវៀត និងប្រទេសសង្គមនិយមជាបងប្អូន សូមពួកចក្រពត្តិនិយមនិងពួកប្រតិកិរិយាអន្តរជាតិទាំងឡាយ បើទោះជាអ្នកនោះល្ងោតសង្គ្រាមតិចក្តីច្រើនក្តី គឺតឱ្យបានពីរដងមុននឹងបង្កសង្គ្រាមរាយមាយជាមួយនឹងប្រព័ន្ធសង្គមនិយមពិភពលោក ។ គេត្រូវយល់ថា ការវាយប្រហារតាមផ្លូវយោធាទៅលើសាធារណរដ្ឋសង្គមនិយមសហភាពសូវៀត (ស.ស.ស.ស.) និងប្រទេសសង្គមនិយមជាបងប្អូនដែលមានចំណងយ៉ាងជិតស្និទ្ធិជាមួយគ្នា តាមរយៈមិត្តភាពដ៏ស្អិតរមួត នឹងពិតជាត្រូវទទួលនូវការវាយបកតបវិញមិនខានឡើយ ។ ស្ថានការណ៍នេះបានបង្កើននូវភាពអង់អាចក្លាហាន និងទំនុកចិត្តរបស់យុទ្ធមិត្តនៃបដិវត្តនិងសន្តិភាពក្នុងពិភពលោក ។

*អត្ថបទនេះចង់បញ្ជាក់ថា៖ យួនកុម.គិតថា បើគេចូលរួមដោយស្របច្បាប់ជាមួយ*ប្រព័ន្ធសង្គមនិយមពិភពលោក *ដែលដឹកនាំដោយ ស.ស. គេអាចនឹងបង្ខំស.ស.ឱ្យធ្វើជាខែលការពាររបស់វៀតណាម ទល់នឹងការវាយប្រហារដោយថាហេតុពី* ពួកចក្រពត្តិនិយមនិងពួកប្រតិកិរិយាអន្តរជាតិ ។ *សេចក្តីត្រូវការនូវរបាំងខែលបែបនេះបានបង្ហាញឱ្យឃើញកាន់តែច្បាស់*

ទៀតនៅពេលដែលការតានតឹងជាមួយចិនមានភាពកាន់តែធ្ងន់ឡើង ទាក់ទងនឹងបញ្ហាជនជាតិហ្វា និងឯកភាពផ្សភាពរបស់កម្ពុជា ។ ហេតុនេះ សន្ធិសញ្ញាបានត្រូវយួនកុម.គិតថាជាលក្ខន្តិក:នៃការធានាកាប់រងដ៏តូចស្តួចស្តើងមួយ ដែលគេបានសម្រេចចិត្តរួចទៅហើយក្នុងការវាយលុកទ្រង់ទ្រាយធំចូលឈ្លានពានកម្ពុជា នៅដើមរដូវប្រាំងខាងមុខនេះ គឺជានៅតែពីរឬបីអាទិត្យទៀតតែប៉ុណ្ណោះ ។

ប៉ុន្តែ សូវៀតយល់ឃើញផ្សេងទៅវិញចំពោះសន្ធិសញ្ញា ។ យោងតាមមាត្រា៦ ប្រតិកម្មចាំបាច់សម្រាប់ភាគីនីមួយៗ ចំពោះការវាយប្រហារតាមផ្លូវយោធាទៅលើភាគីណាមួយគឺស្ថិតនៅលើម្នាក់ៗពិភាក្សាប្តូរយោបល់គ្នា ក្នុងដំណើរឆ្ពោះទៅរកវិធានការសន្តិសិទ្ធិដើម្បីបង្ក្រាបការគំរាមកំហែង ។ គេមិនចាំបាច់តម្រូវឱ្យមានអន្តរាគមន៍យោធាផ្ទាល់ឡើយ ។ មន្ត្រីជើងចាស់សូវៀតម្នាក់ឈ្មោះ មីឃែល កាពិតសា (Mikhail Kapitsa) ថា នេះគ្រាន់តែជាសន្ធិសញ្ញានយោបាយតែប៉ុណ្ណោះ ។ វៀតណាមចង់បានការបញ្ជាក់មួយឱ្យបានច្បាស់លាស់អំពីជំនួយយោធា តែត្រូវសូវៀតជំទាស់ ។ ស.ស. មិនចង់ច្បាំងជាមួយចិនព្រោះតែរឿងវៀតណាមឡើយ។

## ២-ការសម្រេចចិត្តរបស់សហភាពសូវៀតនិងវៀតណាម ក្នុងការឈ្លានពានកម្ពុជា ៖

រដ្ឋាភិបាលចិន និងមេដឹកនាំបញ្ចិមប្រទេស រួមទាំងអ្នកវិភាគនយោបាយ តែងតែសន្និដ្ឋានថា ការឈ្លានពានរបស់វៀតណាមចូលកម្ពុជាបណ្តាលមកពីការរុញច្រានរបស់ ស.ស. ។ ប៉ុន្តែគ្មានភស្តុតាងជាក់លាក់ណាមួយដែលបញ្ជាក់អំពីការកិច្ចរបស់សូវៀតនៅក្នុងរឿងនេះឡើយ ។ ផ្ទុយទៅវិញ បើទោះជាយើងមានភស្តុតាងមិនគ្រប់គ្រាន់ក៏ដោយ ក៏ភស្តុតាងនោះបានឱ្យដឹងថា មេដឹកនាំសូវៀតមិនបានដឹងពីផែនការឈ្លានពានរបស់វៀតណាមទេ គឺទាល់តែព្រឹត្តិការណ៍កើតឡើងហើយ ទើបគេដឹង ។

ឯកសារសម្ងាត់ស្តីពីការសន្ទនាគ្នារវាងមេដឹកនាំស.ស.និងវៀតណាម នៅម៉ូស្គូ នាខែមិថុនានិងវិច្ឆិកា ឆ្នាំ១៩៧៨ មិនដែលត្រូវបានផ្សព្វផ្សាយឱ្យនរណាដឹងក្រៅពីអតីត:ថ្នាក់ដឹកនាំសូវៀតឡើយ ។ ប៉ុន្តែ អ្នកជំនាញការចិនម្នាក់នៅក្នុងក្រសួងការបរទេសនៃអតីត: ស.ស. និងអ្នកជំនាញការពិសេសពីរនាក់ទៀតលើបញ្ហាវៀតណាមនិងកម្ពុជា នៅក្នុង

អតីតៈគណៈកម្មាធិការកណ្តាលសូវៀត បានបដិសេធដាច់អហង្ការថា វៀតណាមបានឱ្យដំណឹងជាមុនដល់សូវៀតអំពីផែនការឈ្លានពានរបស់គេ ។

មានភស្តុតាងពីរដែលបញ្ជាក់អំពីរឿងនេះ ។ ភស្តុតាងផ្លូវការទីមួយ គឺខ្សែអាត់ថតសម្ភាសការសន្ទនាជាសម្ងាត់ នៅហាណូយក្នុងខែកញ្ញា១៩៧៨ រវាងអគ្គលេខាធិការវៀតណាម ឡេយន់ និងឯកអគ្គរដ្ឋទូតសូវៀត អ៊ីគ័រ ស៊ែរបាកូវ (Igor Sherbakov) ។ នៅក្នុងអង្គប្រជុំ ឡេយន់បានរៀបរាប់យ៉ាងវែងអន្លាយអំពីថា តើមជ្ឈិមបក្សកុម.វៀតណាមបានរៀបចំផែនការយ៉ាងណាខ្លះ ដើម្បីចាត់ការអំពីបញ្ហាកម្ពុជាឱ្យបានចប់សព្វគ្រប់នៅដើមឆ្នាំ១៩៧៩ ។ គាត់ក៏បានធ្វើការកត់សម្គាល់ផងដែរថា៖ ការដែលវៀតណាមគិតថាអាចនឹងមានប្រតិកម្មតាមផ្លូវយោធាពីចិននោះ ឥឡូវនេះបានផ្លាស់ប្តូរហើយ ។ ឡេយន់បានសង្កត់បន្ថែមថា ការគំរាមកំហែងដ៏ធ្ងន់យ៉ាងនេះ វៀតណាមមិនអាចរង់ចាំទាល់តែ ប៉េកាំងពង្រឹងជំហរខ្លួននៅកម្ពុជាបានឡើយ ។ នៅក្នុងន័យមួយ ដើម្បីធ្វើដំណោះស្រាយមិនឱ្យសាំញ៉ាំនិងមានប្រយោជន៍ ឡេយន់បាននិយាយតែអំពីការខំប្រឹងប្រែងជួយបង្កើតកម្លាំងតស៊ូខ្មែរតែប៉ុណ្ណោះ ដោយបានបញ្ជាក់ថា មានទ័ពខ្មែរចំនួនប្រាំបួនកងវរសេនាតូចកំពុងទទួលការហ្វឹកហ្វឺនពីវៀតណាម និងគណៈតំបន់ម្តៃនាក់បានរត់មកចុះចូលជាមួយវៀតណាម ។ ចំពោះសំដីឡេយន់ដែលបាននិយាយថា នឹងគិតគូរដោះស្រាយបញ្ហាខ្មែរឱ្យបានរួចរាល់នៅដើមឆ្នាំ១៩៧៩ រួមផ្សំនឹងភស្តុតាងផ្សេងទៀតដែលយើងសន្និដ្ឋានថាជាភស្តុតាងនៃផែនការឈ្លានពានរបស់ហាណូយ សូវៀតក៏នៅស្រពិចស្រពិលមិនច្បាស់លាស់ដែរកាលពេលនោះថា វៀតណាមនឹងបោះបង់ផែនការរំលំខ្មែរក្រហម បើសិនជាខ្លះមធ្យោបាយជួយគាំទ្រក្រុមខ្មែរបះបោរនៅក្នុងស្រុក ។ នៅក្នុងរបាយការណ៍ជាផ្លូវការរបស់ទូតសូវៀត មិនបានបញ្ជាក់អំពីកិច្ចសន្ទនាគ្នាស្តីអំពី ផែនការឈ្លានពាននិងកាន់កាប់កម្ពុជារបស់វៀតណាមឡើយ ។

ភស្តុតាងទីពីរ ដែលបញ្ជាក់ពីដំណើររឿងរបស់អតីតៈមន្ត្រីសូវៀត ដែលគួរជឿបាននោះគឺ មេដឹកយួនកុម.ខកខានមិនបានប្រាប់សូវៀតឱ្យដឹងមុន អំពីផែនការវាយលុករបស់ខ្លួននៅឆ្នាំ១៩៧២ ដែលជាការវាយលុកដ៏ធំជាងគេបង្អស់ នៅក្នុងសង្គ្រាមវៀតណាម ។

នេះគឺជាការបំភាន់មតិមួយដោយហេតុថា នៅក្នុងទស្សនកិច្ចមួយរបស់គណៈប្រតិភូសូវៀត នៅហាណូយ ដឹកនាំដោយមេទ័ពជើងអាកាស ម៉ារសាល់ បាទីតស្គី (Marshall Batitski) វៀតណាមបានសុំជំនួយជាគ្រឿងអាវុធថ្មីៗ នៅមុនពេលបើកការវាយលុកបន្តិចតែប៉ុណ្ណោះ ។

ជាការពិតហើយថា គេមិនអាចមានអ្វីបញ្ជាក់ចំពោះការបដិសេធនោះឡើយ ។ ប៉ុន្តែគេអាចស្មានបានថា ឡេយន់ប្រហែលបានប្រាប់ជាសម្ងាត់ដល់ ប្រេសណែវ (Brezhnev) ឬកូស៊ីហ្គិន (Kosygin) រួចទៅហើយនៅក្នុងការពិភាក្សាដែលគេមិនបានថតសម្លេងទុក( Unrecorded conversation) ស្តីអំពីផែនការចូលឈ្លានពានកម្ពុជារបស់វៀតណាម ។ ប៉ុន្តែឧបមាថាបើសិនជាមានកិច្ចពិភាក្សានោះមែន វាជាការមិនសមទេដែលថា ប្រេសណែវ កូស៊ីហ្គិន ឬ សមាជិកណាមួយនៃមជ្ឈិមបក្ស មានគំនិតចង់លាក់ការណ៍សំខាន់បែបនេះ ពីសមាជិកមជ្ឈិមបក្សសូវៀតឯទៀត ដែលជាហេតុបណ្តាលឱ្យមានការលាក់លៀមពត៌មានពីអ្នកឯកទេសនយោបាយការបរទេស នៃគណៈកម្មាធិការកណ្តាល ។

បើសិនជាផែនការឈ្លានពានមិនត្រូវបានលើកយកមកពិភាក្សាទេ តើរបៀបវារៈក្នុងអង្គប្រជុំ នៅខែមិថុនានិងវិច្ឆិកា ១៩៧៨ ជាមួយនឹងមេដឹកនាំសូវៀត និយាយពីអ្វីទៅវិញ ? ជារឿយៗ មេដឹកនាំហាណូយតែងតែពិពណ៌នាថាជាការគំរាមកំហែងរបស់ចិនចំពោះឯករាជ្យភាពវៀតណាម ។ ដូចយើងបានឃើញរួចមកហើយ សង្គ្រាមប៉ាការវាងចិននិងវៀតណាមពីរឿងដែលវៀតណាមបណ្តេញក្រុមជាតិពន្ធុសញ្ជាតិចិន និងពីរឿងដែលចិនកាត់ជំនួយពីវៀតណាម គឺជាបញ្ហាសាធារណៈដ៏សំខាន់ រវាងប្រទេសជិតខាងគ្នាទាំងពីរនេះ ។ យើងដឹងថា វៀតណាមត្រូវការជាចាំបាច់បំផុតនូវជំនួយសេដ្ឋកិច្ចពីប្លុកសូវៀត ដើម្បីជំនួសជំនួយចិន ។ ដោយមិនបាច់ឆ្ងល់ឡើយ វៀតណាមនឹងនិយាយឱ្យសូវៀតទន់ត្រចៀកក្នុងការរកជំនួយ ដើម្បីទប់ទល់នឹងការគំរាមសម្ភុតរបស់ចិន តែមិនមែនការគំរាមកំហែងរបស់កម្ពុជាឡើយ។

អតីតៈមន្ត្រីសូវៀតម្នាក់សាកល្បងពន្យល់អំពីឥរិយាបទរបស់វៀតណាម ៖

ហាណូយជឿថាទីក្រុងម៉ូស្គូចង់ជំទាស់នឹងផែនការឈ្លានពានរបស់ខ្លួន ។ បើទោះជា

យ៉ាងនេះក៏ដោយ បទដ្ឋានគ្រឹះនៃគោលការណ៍សម្ពន្ធមិត្តបានពន្យល់ថា វៀតណាមឱ្យដំណឹងសូវៀតកៀកពេលណាស់ទៅហើយ គឺមុនព្រឹត្តិការណ៍តែបន្តិចប៉ុណ្ណោះ ដែលធ្វើឱ្យម៉ូស្គូគ្មានពេលគ្រប់គ្រាន់ក្នុងកាប្រុងប្រៀបសម្ភារៈជួយហាណូយ ។ សូវៀតគ្មានពេលគ្រប់គ្រាន់ក្នុងការរៀបចំសម្ភារៈ តែគេមានពេលគ្រប់គ្រាន់ក្នុងការប្រុងប្រៀបរៀបចំខ្លួនខាងផ្លូវនយោបាយនិងផ្លូវទូត ។ បើទោះជាចំណងមិត្តភាពសូវៀត-វៀតណាមឡើងដល់ផុតកំពូលក៏ដោយ ក៏គំនិតក្រឡិកក្រឡុករបស់ហាណូយបានបង្ហាញនូវព្រំដែននៃមិត្តភាពនោះដែរ ។ ដើម្បីបានសម្រេចផែនការផ្សងព្រេងរបស់ខ្លួននៅក្នុងតំបន់ វៀតណាមត្រូវការជំនួយគាំទ្រខាងផ្លូវសម្ភារៈ និងខាងផ្លូវទូតពីសូវៀត និងត្រូវការនូវកិច្ចការពាររបស់សូវៀតទល់នឹងការវាយបកជាយថាហេតុណាមួយពីចិន ។ មេដឹកនាំយួនកុម.មិនចង់សំដែងការស្មោះត្រង់ជាមួយចៅហ្វាយខ្លួនអំពីផែនការនយោបាយ និងយោធាសំខាន់ៗរបស់គេឡើយ បើទោះជាគេបានចូលជាសម្ពន្ធមិត្តនយោបាយពេញលេញជាមួយសូវៀតហើយក៏ដោយ ។ ម្យ៉ាងទៀត ទស្សនៈអន្តរជាតិស្តីអំពីការទទួលខុសត្រូវរបស់សូវៀត ចំពោះនយោបាយការបរទេសរបស់វៀតណាម យល់ឃើញថាការបោកប្រាស់របស់ហាណូយនឹងបណ្តាលឱ្យមានផលវិបាកផ្នែកនយោបាយដ៏ធ្ងន់ទៅលើកិត្តិសព្ទអន្តរជាតិរបស់ ស.ស. ព្រមទាំងប៉ះពាល់ដល់សន្តិសុខជាតិសូវៀតផងដែរ ។

## ៣-សេចក្តីសន្និដ្ឋាន

ជម្លោះជាអន្តរជាតិអំពីរឿងខ្មែរ មិនមែនជាលទ្ធផលនៃព្រឹត្តិការណ៍ដែលបង្ករឡើងដោយមហាអំណាចកុម្មុយនិស្តធំៗពីរ គឺស.ស. និងចិនឡើយ ។ មហាអំណាចទាំងពីរបានត្រូវជាប់ជាប់ទាក់ទិននៅក្នុងជម្លោះក៏ដោយសារកូនជើងរបស់គេដែលជាអ្នកនាំភ្លើង ។

ក៏ប៉ុន្តែ នៅមានអសមប្បមាណ (ភាពខ្វះលំនឹង) មួយចំនួនទៀតដែររបស់សូវៀតនិងចិននៅក្នុងវិវាទ ។ មានតែចិនទេដែលបានចូលរួមដោយផ្ទាល់នៅក្នុងសង្គ្រាម ។ ឯស.ស. វិញមានសំណាងបានធ្វើត្រឹមតែជាអ្នកជួយផ្តល់គ្រឿងអាវុធនិងជំនួយសេដ្ឋកិច្ចតែប៉ុណ្ណោះ ដោយហេតុថា កូនជើងគេបានទទួលរ៉ាប់រងធ្វើសង្គ្រាមដោយខ្លួនឯង ។ ផ្ទុយពីចិន ស.ស.

គ្មានការគំរាមកំហែងខាងផ្លូវសន្តិសុខផ្ទាល់ពីកម្ពុជាទេ ប៉ុន្តែ ប្រទេសនេះត្រូវប្រឈមមុខចំពោះការបង់ខាតខាងផ្លូវនយោបាយនិងផ្លូវទូត ។

គេគួរកត់សម្គាល់ដែរថា មុនពេលចប់សង្គ្រាមនៅវៀតណាម យួនកុម្មុយនិស្តមិនសូវទុកចិត្ត ស.ស. ប៉ុន្មានទេ ។ សូម្បីតែការវាយលុកទ្រង់ទ្រាយធំក្នុងរដូវចូលឆ្នាំចិន-យួន ឆ្នាំ ១៩៧២ ក៏យួនមិនបានឱ្យសូវៀតដឹងមុនដែរ ។ នេះគឺមកពីគេអាងលើជំនួយដ៏ស្តុកស្តម្ភរបស់ ស.ស. និងការដែលគេបានដោះដៃពីចិន ហើយងាកទៅចាប់ដៃស.ស.ស.ស.វិញនៅពេលសូវៀតនិងចិនឈ្លោះគ្នា ។

ការដែលហាណូយខកខានមិនបានប្រាប់ទីក្រុងម៉ូស្គូឱ្យដឹងពីការអនុវត្តផែនការឈ្លានពានកម្ពុជា គឺជាការសម្តែងឱ្យឃើញនូវភាពមន្ទិលសង្ស័យមួយ ដែលគេមានតាំងពីដើមទីមក ។

ហាណូយយល់ថា ម៉ូស្គូជាប់ទ្រង់ហើយ នឹងធ្វើយថាមិនជួយវៀតណាមក៏មិនកើត ព្រោះអ្នកទាំងពីរបានរួមគ្នាចងកំហឹងជាមួយប៉េកាំងរួចទៅហើយ ។បើសិនជារឿងនោះពិតដូច្នោះមែន ហាណូយពិតជានិយាយត្រឹមត្រូវ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ការបោកប្រាស់របស់វៀតណាមពេលនេះ មិនអាចជៀសវាងការពង្រឹងទំនាក់ទំនងមិត្តភាពសូវៀត-វៀតណាមបានឡើយ ។ បើសិនការភ័យខ្លាចឬការក្បត់ជាឫសគល់នៃអំពើបោកប្រាស់របស់ហាណូយមែននោះ អំពើទាំងនេះពិតជាការប្រមាថមើលងាយចំពោះសូវៀត ។ដូច្នេះនៅពេលអនាគត បើសិនប្រទេសទាំងពីរ (សូវៀតនិងវៀតណាម) ជួបប្រទះនឹងវិបត្តិ ស.ស. មានសង្ឃឹមតិចណាស់ក្នុងការងាកទៅចាប់ដៃជាមួយវៀតណាម ៕

♥

# ជំពូក៦

## ១-ផលវិបាកនៃការឈ្លានពានរបស់វៀតណាម ៖

ការឈ្លានពានរបស់វៀតណាម និងការកាន់កាប់ប្រទេសកម្ពុជាតាមផ្លូវយោធាក្នុងរយៈពេលដប់ឆ្នាំជាបន្តបន្ទាប់ បាននាំមកនូវមហន្តរាយដល់ប្រទេសជាសត្រូវទាំងពីរ និងទាំងប្រជាជនក្នុងស្រុកផង ។ មិនមានប្រទេសណាមួយក្នុងចំណោមប្រទេសទាំងពីរបានសម្រេចគោលដៅរបស់ខ្លួនទាំងស្រុងឡើយ ។ ពួកខ្មែរក្រហម ជាពិសេសប៉ុលពតនិងបក្សពួកគឺជាអ្នកខាតបង់ធំជាងគេ ។ ពួកគេសង្ឃឹមថាគេអាចនឹងយកជ័យជំនះបានទៅលើកងទ័ពវៀតណាម ។ តែផ្ទុយទៅវិញ ពួកគេបានបាត់បង់អស់នូវកម្លាំងនយោបាយនិងកម្លាំងយោធា ។ ជាយថាហេតុ ក្រោយពីគេបានចំណាយពេលអស់ដប់ប្រាំឆ្នាំ តស៊ូរស់នៅក្នុងព្រៃ ពួកគេបានទទួលរងនូវការបាក់បែកគ្នាខាងផ្លូវនយោបាយនិងយោធា តាមរយៈការរត់ចោលជួរ ។

ផលវិបាកនៃការឈ្លានពានរបស់យួនកុម. គឺជាផលវិបាកចម្រុះ ។ ជាអាទិ៍ គេបានសម្រេចនូវគោលបំណងបឋមរបស់គេ គឺការកម្ទេចរបបខ្មែរក្រហម ក្នុងក្តីសង្ឃឹមថានឹងបានជ័យជំនះភ្លាមៗ ជាមួយនឹងការទទួលយល់ព្រមដោយឥតប្រែប្រួលពីសហគមន៍អន្តរជាតិផង ។ តែផ្ទុយទៅវិញ វៀតណាមឥតបានទទួលជ័យជំនះភ្លាមៗឡើយ ហើយវៀតណាមត្រូវទទួលរងនូវការកៀបសង្កត់អស់រយៈពេលជាងដប់ឆ្នាំពីកម្លាំងយោធាចិននិងត្រូវដាក់ឱ្យនៅឯកោជាអន្តរជាតិខាងផ្លូវទូតនិងផ្លូវសេដ្ឋកិច្ច ដែលជាហេតុបណ្តាលឱ្យមានការយឺតយ៉ាវក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេស ។ វៀតណាមបានត្រូវបង្ខំឱ្យដកទ័ពចេញពីកម្ពុជា និងឱ្យព្រមទទួលលក្ខខណ្ឌជាបណ្តោះអាសន្ន ក្នុងការរៀបចំរដ្ឋាភិបាលខ្មែរឡើងវិញ ក្រោមការត្រួតពិនិត្យរបស់អង្គការសហប្រជាជាតិ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក្រុមខ្មែរ ដែលជាសម្ពន្ធមិត្តរបស់វៀតណាម បានក្តាប់អំណាចជាប់ ។

កាលចាប់ផ្តើមដំបូង ស.ស. បានទទួលផលប្រយោជន៍ដ៏ស្មុកស្មាញពីអំពើឈ្លានពាន

របស់វៀតណាម ។ គឺជាលើកទីមួយហើយដែលសូវៀតបានកាន់កាប់មូលដ្ឋានទ័ពជើងទឹក និងជើងអាកាសរបស់វៀតណាម ។ នៅពេល ស.ស. រលំរលាយក្នុងឆ្នាំ១៩៩១ អ្នកដឹកនាំរដ្ឋរុស្ស៊ីបានបង្ហាញនូវការមិនសូវយកចិត្តទុកដាក់ប៉ុន្មានឡើយក្នុងការចងសម្ពន្ធមិត្តជាមួយវៀតណាម ។ កន្លង់ចម្បងរបស់រុស្ស៊ីពេលនេះគឺការប្រើងស្តារឡើងវិញនូវការបាត់បង់ថវិការាប់ពាន់លានដុល្លា ដែលគេបានចាយវាយខ្ជះខ្ជាយទៅលើជំនួយវៀតណាម ។

ក្នុងចំណោមប្រទេសដែលជាប់ទាក់ទិនទាំងអស់ក្នុងសង្គ្រាម គឺមានតែប្រទេសចិនមួយទេដែលហាក់ដូចជាបានជោគជ័យធំធេងជាងគេ ក្រោយពេលចេញពីសង្គ្រាម ។ ក្នុងទឹកដំបូង ចិនបានចំណាយទ័ពនិងកិត្យានុភាព ចូលវាយលុកវៀតណាមដោយមិនបានសម្រេចផល នៅខែកុម្ភៈ១៩៧៩ ដើម្បីកៀបសង្កត់យួនឱ្យដកថយចេញពីកម្ពុជា ។ ទីបំផុតចិនក៏បានសម្រេចគោលដៅរបស់គេ ដោយវៀតណាមដកចេញពីកម្ពុជាមែន ។ ពេលនេះចិនបានក្លាយជាមហាអំណាចយោធានិងនយោបាយនៅក្នុងតំបន់ ។ ឯចំណែកការខាតបង់ខាងផ្លូវនយោបាយ និងផ្លូវទ័ពព្រោះតែរឿងកាន់ជើងខ្មែរនោះ ក៏មិនសូវជាមានសារៈសំខាន់អ្វីទៅលើការរីកចំរើននៃសេដ្ឋកិច្ចដ៏មានថាមពល និងឥទ្ធិពលនយោបាយទាំងមូលរបស់ចិនឡើយ ។

## ២-ការបាត់បង់អំណាចនៃថ្នាក់ដឹកនាំខ្មែរក្រហម ៖

វិបាកភ្លាមៗនិងដំបូងគេបំផុតរបស់ការឈ្លានពាន គឺការផ្តួលរំលំរបបប៉ុលពតនៅភ្នំពេញ និងស្ទើរតែពេញផ្ទៃប្រទេស ។ ក្នុងសប្តាហ៍ដំបូងនៃការឈ្លានពាន ប៉ុលពតនិងបក្សពួកបានបើកការវាយ តប-តដ៏ខ្លាំងក្លា ក្នុងទ្រង់ទ្រាយធំតទល់នឹងទ័ពឈ្លានពាន ។ យុទ្ធសាស្ត្រនេះជាយុទ្ធសាស្ត្រដែលមេដឹកនាំខ្មែរក្រហមផ្អែកទៅលើទ្រឹស្តី "សង្គ្រាមប្រជាជន" ដែលផ្ទុយគ្នានឹង "ក្រុមសេរីនិយម" របស់វៀតណាម ។ ក្រោយការឈ្លានពានរបស់វៀតណាម ការសន្និដ្ឋានបែបនេះគឺជាការសន្និដ្ឋានខុសដូចលើកមុនៗដែរ ។ ប្រឈមមុខទល់នឹងកងទ័ពមួយដែលមានគ្នាច្រើនដូចស្រមោច បំពាក់ដោយអាវុធទំនើបៗ យុទ្ធសាស្ត្របែបនេះគឺជាស្នៀតមួយនៃមហន្តរាយខាងផ្លូវយោធា ។ កងទ័ពវៀតណាម កម្ទេចទាំង

ស្រុងនូវកងឯកភាពនៃកងទ័ពបដិវត្តកម្ពុជាប្រជាធិបតេយ្យ វាយផ្តាច់ខ្សែការពារអស់ជាង ពាក់កណ្តាល ហើយទីបំផុត កងទ័ពស្ទួលក៏ត្រូវបែកជាដុំតូចៗ ដែលក្រោយមកប្រមូលផ្តុំគ្នាឡើងវិញដើម្បីបង្កើតជាទ័ពព្រៃ ។ពួកគេបាននាំគ្នាដកថយទៅមូលដ្ឋានក្នុងព្រៃជ្រៅ នៅភាគខាងលិចនិងខាងជើងនៃកម្ពុជា ជាប់ទល់ដែនថៃនិងលាវ ហើយបើកការវាយប្រហារតទល់នឹងកងទ័ពយួនចេញពីទីនោះមកវិញ ។

នៅថ្ងៃ៧មករា ១៩៧៩ កងទ័ពវៀតណាមចូលដល់ទីក្រុងភ្នំពេញ លើកបន្តុបអ្នកដឹកនាំនៃ រណសិរ្សសង្គ្រោះជាតិកម្ពុជា ឱ្យកាន់អំណាច ហើយបង្កើតស្ថាប័នរដ្ឋមួយឱ្យឈ្មោះថា សាធារណរដ្ឋប្រជាមានិតកម្ពុជា (ស.ប.ក.) ។ អ្នកដឹកនាំមួយចំនួនតូចនៃរដ្ឋាភិបាល ស.ប.ក. គឺជាអតីតៈខ្មែរវៀតមិញ ដែលបានទទួលការហ្វឹកហ្វឺនយ៉ាងត្រឹមត្រូវ រាប់សិបឆ្នាំនៅហាណូយ។ ប៉ុន្តែ ភាគច្រើននៃអ្នកដឹកនាំនៅក្នុងរដ្ឋាភិបាល ជាអតីតៈមេបញ្ជាការខ្មែរក្រហមពីភូមិភាគបូព៌ានៃប្រទេសកម្ពុជា ដែលមានជាអាទិ៍ ហេងសំរិន ជាស៊ីម និង ហ៊ុនសែន ។ ពួកអ្នកទាំងនេះបាននាំគ្នារត់គេចទៅវៀតណាម ដើម្បីឱ្យរួចផុតពីអំពើកាប់សម្លាប់របស់ប៉ុលពត ។ រដ្ឋាភិបាលនេះបានត្រូវតែងតាំងឡើងដោយ បក្សបដិវត្តប្រជាជនកម្ពុជា ដែលបង្កើតដោយយួនកុម. កាលពីឆ្នាំ១៩៥១ ។

## ៣-សង្គ្រាមវៀតណាមជាមួយចិន ៖

ក្នុងសេចក្តីថ្លែងការណ៍មួយនៅចំពោះមុខក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ខែមករា១៩៧៩ រដ្ឋាភិបាលចិនបានថ្កោលទោសចំពោះអំពើឈ្លានពានរបស់វៀតណាមទៅលើកម្ពុជា ថាជាជំហានមួយដ៏ធំ ក្នុងការពង្រីកអនុត្តរភាពរបស់ខ្លួននៅក្នុងតំបន់ ហើយនិងជាផ្នែកមួយដ៏សំខាន់របស់មហិច្ឆតាសូវៀតដើម្បីវាតអំណាចនៅអាស៊ីនិងនៅចុងបូព៌ា។ ចិនជឿច្បាស់ណាស់ ហើយក៏ព្រួយណាស់ដែរចំពោះរឿងនេះ ។ ប៉ុន្តែ ចិនក៏មានការព្រួយបារម្ភម្យ៉ាងទៀតដែរ ចំពោះជ័យជំនះរបស់វៀតណាមទៅលើមិត្តកម្ពុជារបស់គេ ដោយគេយល់ថា នេះជាភាពអាម៉ាស់មុខមួយរបស់ចិន ។ ដូច្នេះ ជាការជៀសមិនរួច ដើម្បីកុំឱ្យបាក់មុខ ចិនត្រូវតែវាយបកទៅវៀតណាមវិញតាមផ្លូវយោធា ។

ថ្ងៃ១៧កុម្ភៈ ១៩៧៩ កងទ័ពចិនបានវាយលុកចូលភាគខាងជើងវៀតណាម ដើម្បីឱ្យមេរៀនដល់ពួកគេ ។ ក្រោយពីប្រយុទ្ធគ្នាដ៏ខ្លាំងក្លាអស់រយៈពេលបីសប្តាហ៍នៅក្នុងខេត្តភាគខាងជើងជាប់នឹងប្រទេសចិន កងទ័ពចិនបានដកថយ ជាមួយនឹងការបាត់បង់ជីវិតពលទាហានរាប់ម៉ឺននាក់ ។ ចំណែកខាងវៀតណាមវិញ ក៏បានទទួលរងនូវការខូចខាតមិនតិចដែរ ។ តាមរបាយការណ៍របស់អ្នកធ្វើយុទ្ធពត៌មានបញ្ចិមប្រទេសបានឱ្យដឹងថា មានការខូចខាតខ្ទេចខ្ទាំជាដំណំនៅតាមទីប្រជុំជនធំៗរបស់វៀតណាម នៅតាមទល់ដែន ដូចជា ឡាវកៃ ឡាងសឺន និង កាវបាង ។

ការឈ្លានពានរបស់ចិនមិនបានធ្វើឱ្យវៀតណាមដកទ័ពចេញពីកម្ពុជាក៏ពិតមែន ។ ប៉ុន្តែវាបានបង្ខំហាណូយឱ្យរក្សាទុកនូវកងទ័ពមួយភាគធំនៅព្រំប្រទល់ខាងជើងនៃប្រទេសវៀតណាម ដើម្បីកុំឱ្យវៀតណាមយកទ័ពនោះទៅដាក់នៅកម្ពុជា ។ ការគំរាមឈ្លានពានជាលើកទីពីររបស់ចិនមានន័យថា វៀតណាមត្រូវតែរក្សាទុកនូវកងទ័ពមួយចំនួនធំនៅទីនោះជារៀងរហូត ។

ចិនបានឆ្លើយតបទៅនឹងការឈ្លានពានរបស់វៀតណាម តាមមធ្យោបាយសំខាន់ទីពីរ ៖ គឺគេនៅតែផ្តល់ជំនួយឱ្យពួកខ្មែរក្រហមដែលបានបោះបង់ចោលទីក្រុងភ្នំពេញហើយដកថយទៅភាគខាងលិចនិងខាងជើងនៃប្រទេស ដើម្បីឱ្យពួកគេមានលទ្ធភាព ក្នុងការធ្វើសង្គ្រាមវាយឆ្មក់ ។ មិនតែប៉ុណ្ណោះ ចិនក៏បានផ្តល់ជំនួយយោធាផងដែរដល់ទ័ពព្រៃខ្មែរមិនមែនកុម្មុយនិស្ត ដឹកនាំដោយសម្តេចសីហនុ និងអតីតៈនាយករដ្ឋមន្ត្រីសឺនសាន ។ អសមត្ថភាពរបស់វៀតណាមក្នុងការកម្ចាត់កងទ័ពតស៊ូខ្មែរ រួមជាមួយនឹងការរីងខះជំនួយពីស.ស.ផង បានបង្ខំវៀតណាមឱ្យបញ្ចប់នូវវត្តមានផ្ទាល់នៃកងទ័ពរបស់ខ្លួននៅកម្ពុជា ។នេះហើយជាចំណុចដែល ចិនឈ្នះក្នុងការប្រឈមមុខជាមួយនឹងវៀតណាម ។

### ៤-អវិចាពនៃការគាំទ្រជាអន្តរជាតិចំពោះវៀតណាម ៖

មុនការឈ្លានពានចូលកម្ពុជា ហាណូយបានខំប្រឹងប្រែងអស់ពីសមត្ថភាព ដើម្បីយកប្រៀបលើ ស.រ.អ. ចំពោះទំនាក់ទំនងជាប្រក្រតីឡើងវិញខាងផ្នែកនយោបាយ ដោយ

គេសង្ឃឹមថានឹងបាន ជំនួយកសាង ប្រទេសឡើងវិញពី ស.រ.អ. និងពីទីភ្នាក់ងារខ្ចីប្រាក់អន្តរ-ជាតិ ។គោលបំណងរបស់វៀតណាមត្រូវខកខានមិនបានសម្រេចមុនឆ្នាំ១៩៧៨ ដោយហាណូយទទូចទាមទារថា ជំនួយដែលជួយនោះគ្រាន់តែជាជំនួយជួសជុលប៉ុណ្ណោះ ។ លក្ខ-ខណ្ឌដំបូងបែបនេះ គឺពិតជាការប្រមាថមួយចំពោះមោទនភាពរបស់អាមេរិកាំង ដែលគេមិនអាចទទួលយកបាន ហើយមន្ត្រី ស.រ.អ.មិនអាចធ្វើតាមលក្ខខណ្ឌនោះបានឡើយ ។

មេដឹកនាំយួនជឿប្រាកដថា ការឈ្លានពានរបស់គេ និងការបន្តកាន់កាប់កម្ពុជាយូរៗទៅ គង់តែនឹងធ្វើឱ្យគេឯងបំភ្លេចចោលលែងនឹកនាដាមិនខាន ។ យួនយល់នេះខុសស្រឡះ ។ សកម្មភាពទាំងឡាយរបស់គេបានធ្វើឱ្យរលាយនូវប្រក្រតីភាវូបនីយកម្ម (ការធ្វើឱ្យមានភាពប្រក្រតី ) ជាមួយ ស.រ.អ. ដែលគេសង្ឃឹមថា អាចនឹងកើតមានឡើងនៅពេលខាងមុខ ។ ម្យ៉ាងទៀត បញ្ចីមប្រទេសភាគច្រើន និងប្រទេសតតិយលោកមួយចំនួនក៏បានប្រឆាំង មិនធ្វើសហប្រតិបត្តិការជាមួយយួនដែរ ។ សហគមន៍អឺរ៉ុបបានកាត់ជំនួយស្បៀងអាហារពីវៀតណាម ។ នៅសល់តែប្រទេសស៊ុយអែដ និងប្រទេសបារាំងប៉ុណ្ណោះដែលជាប្រទេសផ្តល់ជំនួយ ។

លើសពីនេះទៅទៀត សហគមន៍អន្តរជាតិ តាមរយៈកិច្ចប្រជុំប្រចាំឆ្នាំនៃមហាសន្និ-បាតនៅអង្គការសហប្រជាជាតិ (អ.ស.ប.) បានសម្តែងនូវការ មិនទទួលស្គាល់រដ្ឋាភិបាលដែលលើកបន្តុបដោយវៀតណាមឡើយ ។ ផ្ទុយទៅវិញ មុនដំបូង ភាគច្រើនទទួលស្គាល់រដ្ឋាភិបាលខ្មែរក្រ-ហមរបស់កម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់មក ក្រោយពីបានបង្កើតរដ្ឋាភិបាលចម្រុះនៅឆ្នាំ១៩៨២ ( រដ្ឋាភិបាលចម្រុះនៃកម្ពុជាប្រជាធិបតេយ្យ : រ.ច.ក.ប. ) រវាងខ្មែរក្រហម និងខ្មែរមិនមែនកុម្មុយនិស្តពីរក្រុមទៀត ដឹកនាំដោយសម្តេចសីហនុនិងសឺនសាន រដ្ឋាភិបាលថ្មីនេះ (រ.ច.ក.ប. )ក៏ត្រូវបានគេទទួលស្គាល់កាន់តែច្រើនឡើងៗ នៅក្នុងសម័យប្រជុំប្រចាំឆ្នាំរបស់ អ.ស.ប. ។ នៅពេលវៀតណាមនិងប្លុកសូវៀតដណ្តើមកៅអីគ្នាជាមួយ រ.ច.ក.ប. នៅ អ.ស.ប. នៅឆ្នាំ១៩៨៣ ប្រទេសចំនួន៩០បានទទួលស្គាល់ រ.ច.ក.ប. ។

នៅក្នុងមហាសន្និបាតប្រចាំឆ្នាំនៃ អ.ស.ប.ស្តីពីដំណោះស្រាយដកទ័ពបរទេសចេញ

ពីកម្ពុជា សម្លេងឆ្នោតគាំទ្របានកើនឡើងជាលំដាប់ គឺនៅឆ្នាំ១៩៧៩ មាន៩១សម្លេង ; ១៩៨០ មាន៩៧សម្លេង ; ១៩៨១ មាន១០០សម្លេង ។ នៅឆ្នាំ១៩៨២និង១៩៨៣ សម្លេងគាំទ្រឡើងដល់ ១០៥ទល់នឹងសម្លេងប្រឆាំង២៣ ; ហើយនៅឆ្នាំ១៩៨៤ ប្រទេសចំនួន១១០ បានបោះឆ្នោតឱ្យវៀតណាមដកទ័ពចេញពីកម្ពុជា ។

ដូច្នេះ ផលវិបាកដ៏ធំធេងរបស់ហាណូយក្នុងការសម្រេចចិត្តឈ្លានពានកម្ពុជា គឺភាពឯកោរបស់វៀតណាម ពីសហគមន៍អន្តរជាតិក្នុងផ្នែកទូតនិងផ្នែកសេដ្ឋកិច្ច ។ មានតែប្រទេសក្នុងប្លុកសូវៀត និងប្រទេសឥណ្ឌាប៉ុណ្ណោះ ដែលទទួលស្គាល់រដ្ឋាភិបាលទីក្រុងភ្នំ-ពេញ ដែលលើកបន្តុបដោយវៀតណាម ហើយគឺប្រទេសទាំងអស់នេះឯងហើយដែលផ្តល់ជំនួយស្ទើរតែទាំងអស់ដល់វៀតណាមរហូតដល់ឆ្នាំ១៩៩១ ។ ជាមួយនឹងការឡើងកាន់អំ-ណាចរបស់ មីខែល ហ្គ័របាឆូវ (Mikhail Gorbachew) នៅស.ស. និងការលេចឡើងនូវ ទស្សនៈថ្មីក្នុងនយោបាយការបរទេសសូវៀត វៀតណាមបានត្រូវទទួលនូវការកៀបសង្កត់ឱ្យដកកងទ័ពឈ្លានពានទាំងអស់ចេញពីកម្ពុជា ។ ទីបំផុត នៅឆ្នាំ១៩៩១ បន្ទាប់ពីការរលំរលាយនៃរបបកុម្មុយនិស្តនៅអឺរ៉ុបខាងកើតនិងនៅ ស.ស. រួមនឹងការបញ្ចប់ជំនួយសេដ្ឋកិច្ចសូវៀតដល់វៀតណាមផងនោះ វៀតណាមបានត្រូវគេបង្ខំឱ្យទទួលយកនូវផែនការសន្តិភាពមួយរៀបចំដោយ អ.ស.ប. ដែលនាំទៅរកការបោះឆ្នោតដោយសេរី និងការបង្កើតរដ្ឋាភិបាលឯករាជ្យមួយនៅកម្ពុជា ។

សូម្បីតែក្រោយការឈ្លានពានក៏ដោយ ដោយឃើញផលវិបាកជាអន្តរជាតិនៃការសម្រេចចិត្តរបស់ខ្លួន មេដឹកនាំវៀតណាមនៅតែមានផ្លូវរកច្រកចេញជានិច្ច ។ គេសុំឱ្យមានតាពអព្យាក្រឹតខាងដំណោះស្រាយនយោបាយមួយ ដែលទាក់ទងនឹងក្រុមខ្មែរតស៊ូមិនមែនកុម. ដោយមិនឱ្យមានក្រុមខ្មែរក្រហមចូលលាយឡំ ។ សមាគមនៃប្រជាជាតិអាស៊ីអគ្នេយ៍ ( Association of the South-East Asian Nations = ASEAN ) ឬ អាស៊ាន និង ស.រ.អ. យល់ស្របចំពោះសម្នើរនោះ ។ ប៉ុន្តែចំពោះចិនវិញ ដែលពឹងផ្អែកលើប្រទេសថៃ (ដែលជាសមាជិកអាស៊ាន) ក្នុងការជួយដឹកជញ្ជូនគ្រឿងអាវុធទៅឱ្យខ្មែរក្រហមនោះ ច្បាស់ជាប្រកែកមិនព្រមទទួលយក

នូវសម្នើរនោះឡើយ ។ នេះជាជម្រើសយុទ្ធសាស្ត្រផ្សេងទៀតរបស់វៀតណាម តាមទស្សនៈរបស់អ្នកវិភាគនយោបាយបញ្ចិមប្រទេស ។ វាជាការច្បាស់ណាស់ទៅហើយថា នេះគឺពិតជាទស្សនៈរបស់មេដឹកនាំហាណូយ ។ (យោងតាមអតីតៈមន្ត្រីយួនកុម.ឈ្មោះ ប៊ូយទិនបាន ឱ្យដឹងថា សម្នើរនេះគឺពិតជាត្រូវបានស្នើរដោយរដ្ឋមន្ត្រីការពារជាតិវៀតណាម វ៉ាន់ធៀនយ៉ាប់ នៅឆ្នាំ១៩៨២ ។) ប៉ុន្តែ ថ្នាក់ដឹកនាំវៀតណាមបានជ្រើសរើសយកវិធីផ្សេងទៅវិញ ។

**៥-វត្តមាននយោបាយនិងយោធារបស់សូវៀត នៅវៀតណាម ៖**

វត្តមានយោធាសូវៀតនៅវៀតណាម បានកើនឡើងយ៉ាងគំហុក ដែលជាលទ្ធផលនៃព្រឹត្តការណ៍ជាច្រើន បណ្ដាលមកពីអំពើឈ្លានពានរបស់វៀតណាមនៅកម្ពុជា ។ក្រោយពីចិនបានឈ្លានពានចូលវៀតណាម កងទ័ពនាវាសូវៀតក៏បានចាប់ផ្ដើមធ្វើដំណើរមកកាន់កំពង់ផែវៀតណាមជាលើកដំបូង ។ យោងតាមក្រសួងស៊ើបការសម្ងាត់សឹង្ហបូរី នាវាចម្បាំងសូវៀតបានចូលចតនៅឆកសមុទ្រ កាំរ៉ាញ់ ក្នុងខែមីនា ១៩៧៩ នៅពេលដែលនាវាចម្បាំងប្រហែល១៥គ្រឿងទៀតកំពុងប្រតិបត្តិការក្នុងសមុទ្រចិនខាងត្បូង ជាមួយនឹងនាវាមុជទឹកចំនួន២គ្រឿងផង ។ នៅពាក់កណ្ដាលខែមេសា យន្តហោះស៊ើបការណ៍ ធីយូ-៩៥ (TU-95) បានត្រូវយកមកដាក់ពង្រាយនៅវៀតណាម ។ គេជឿថាកងទាហានសូវៀតដំបូងគេ បានចូលចតនៅឆកសមុទ្រ កាំរ៉ាញ់ នៅខែកញ្ញា១៩៧៩ ។ នៅដើមឆ្នាំ១៩៨០ កងទ័ពវៀតណាមទាំងអស់បានរើចេញពី កាំរ៉ាញ់ ដោយទុកតែមួយចំនួនតូចខាងផ្នែកការពារសន្តិសុខ ។ ពេញមួយឆ្នាំ១៩៨០ មូលដ្ឋានកាំរ៉ាញ់បានត្រូវប្រគល់ផ្ដាច់មុខទៅឱ្យ ស.ស. ប្រើប្រាស់ ។

ប៉ុន្តែ នយោបាយកែទម្រង់ខាងផ្នែកការបរទេសនិងការពារជាតិ រៀបចំនិងអនុវត្តដោយ មីខែលហ្គ័របាឆូវ នៅចុងឆ្នាំ១៩៨០ មានឥទ្ធិពលដ៏ខ្លាំងក្លាទៅលើទំនាក់ទំនងមិត្តភាពសូវៀត-វៀតណាម ។ ជាមួយនឹងការកាត់បន្ថយជំនួយសូវៀតខាងទ័ពអាកាសនិងទ័ពជើងទឹក ចាប់ពីដើមឆ្នាំ១៩៨៩មក សូវៀតលែងសូវប្រើមូលដ្ឋានសឹកកាំរ៉ាញ់ហើយ ។ ឯវៀតណាមសោត ក៏អស់មានអ្វីជាសំខាន់សម្រាប់ ស.ស.ស.ស. ទៀតឡើយ ។

## ៦-វៀតណាមូបនីយកម្មនៅកម្ពុជា ៖

មុនកិច្ចព្រមព្រៀងទទួលយកផែនការសន្តិភាពរបស់ អ.ស.ប. យួនកុម្មុយនិស្តបាន ខំឆ្មៀតបូមយកផលប្រយោជន៍យ៉ាងអស់ដៃ ពីអំពើឈ្លានពានរបស់ខ្លួននៅកម្ពុជា ។ ពួកគេ បានលើកបន្តុបរបបដ៏ផុយស្រួយមួយនៅភ្នំពេញ គ្រប់គ្រងជាបែបអាណានិគម តាមទម្រង់ វៀតណាមូបនីយកម្មកម្ពុជា ( ការធ្វើកម្ពុជាឱ្យទៅជាវៀតណាម ) ។

អាណានិគមកិច្ចនេះមានទ្រង់ទ្រាយធំពីរ ៖

ទីមួយ ការត្រួតត្រាដោយផ្ទាល់ទៅលើរដ្ឋាភិបាលភ្នំពេញ (សាធារណរដ្ឋប្រជាមានិត កម្ពុជា : ស.ប.ក.) ដែលក្រោយមក នៅឆ្នាំ១៩៨៩ ត្រូវយួនដូរឈ្មោះឱ្យទៅជា រដ្ឋកម្ពុជា (រ.ក.) វិញ ។ ពួកអ្នករត់ចោលជួរជាច្រើនបានរាយការណ៍ថា ស.ប.ក. បានត្រូវដំណើរការទៅ ក្រោមបង្គាប់ទីប្រឹក្សាយួន នៅគ្រប់មន្ទីរក្រសួង ។ អ្នកធ្វើការក្នុងអង្គការជំនួយមនុស្សធម៌ បញ្ចិមប្រទេសក៏យល់ស្របដែរថាទីប្រឹក្សាវៀតណាមសំខាន់ជាងគេ គឺទូតវៀតណាមប្រចាំ ស.ប.ក. នេះតែម្តង ។ យោងតាមអតីតៈមន្ត្រីផ្តាច់ខ្លួនពីរនាក់ ក្នុងក្រសួងការបរទេសនៃ ស.ប.ក.បានឱ្យដឹងថា៖ រៀងរាល់ព្រឹកទូតវៀតណាមត្រូវជួបហ៊ុនសែន (រដ្ឋមន្ត្រីការបរទេស ស.ប.ក. ) និងមន្ត្រីក្រោមបង្គាប់ហ៊ុនសែន ដើម្បីដាក់ផែនការអនុវត្តឱ្យបានសមស្របក្នុងថ្ងៃ នោះ។ ទូតយួនខ្លួនឯងក៏ត្រូវបានទទួលបញ្ជាមួយជាន់ទៀត ជាប្រចាំថ្ងៃតាមទូរលេខ ពីទី ក្រុងហាណូយ ។ បញ្ជារបស់ទូតយួនបានត្រូវបញ្ជូនទៅឱ្យហ៊ុនសែន ហើយហ៊ុនសែនត្រូវ បញ្ជូនបន្តទៅ ផ្នែកទាំងដប់បួនទៀតនៃក្រសួងការបរទេស ។ នៅក្នុង ផ្នែកទាំងដប់បួននោះ មានទី ប្រឹក្សាយួន១៥ឬ១៧នាក់ផ្សេងទៀត នៅត្រួតមើលសកម្មភាពប្រចាំថ្ងៃរបស់ក្រសួង ។ ទីប្រឹ-ក្សាយួនទាំងអស់ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ការិយាល័យមួយនៅហាណូយ ដែល ជាផ្នែកមួយរបស់មជ្ឈិមបក្ស ហើយដែលមានឈ្មោះថា បី-៦៨ (B-68) ។នៅពេលដែលមន្ត្រី ក្រសួងការបរទេសខ្មែរណាម្នាក់ធ្វើដំណើរទៅក្រៅប្រទេស គេត្រូវមានលិខិតអនុញ្ញាតពីទី ប្រឹក្សាវៀតណាម សរសេរជាភាសាបារាំងឬអង់គ្លេស ។ ម៉ុន សេកយ៉េន អតីតៈនាយកផ្នែក អប់រំនយោបាយ នៃគណៈកម្មាធិការកណ្តាល បក្សបដិវត្តប្រជាជនកម្ពុជា បានអះអាងថា

នេះគឺជាគំរូបែបបទទៅគ្រប់មន្ទីរក្រសួងទាំងអស់នៃរដ្ឋាភិបាល ។ ពួកអ្នកផ្តាច់ខ្លួនជាច្រើន ពី ស.ប.ក.ក៏បានបញ្ជាក់ដូច្នេះដែរ ។ សេកយ៉េនបានឱ្យដឹងទៀតថា មន្ត្រីខ្មែរជាច្រើនបានរៀបការជាមួយស្រីយួន ដែលត្រូវស្រីយួនទាំងនោះរាយការណ៍ទៅឱ្យមន្ត្រីយួនជាទៀងទាត់អំពីសកម្មភាពប្តីរបស់ខ្លួន ។

មន្ត្រីខ្មែរទាំងអស់នៃ ស.ប.ក. បានត្រូវបង្ខំឱ្យរៀនភាសាវៀតណាម ។ តំណែងខ្ពង់ខ្ពស់ជាងគេត្រូវបានទៅអ្នកណាដែលចេះភាសាយួនជ្រៅជ្រះ ។ មន្ត្រីជាន់ខ្ពស់ត្រូវគេបញ្ជូនឱ្យទៅ អប់រំនយោបាយ រាប់ខែនៅវៀតណាម ។ ទំនាក់ទំនងនយោបាយទាំងមូលបានត្រូវបកប្រែជាភាសាខ្មែរ ជាមួយនឹងការចុះហត្ថលេខាលើសន្ធិសញ្ញាសន្តិភាពនិងមិត្តភាពរវាងសាធារណរដ្ឋសង្គមវៀតណាម និងសាធារណរដ្ឋប្រជាមានិតកម្ពុជា ក្នុងខែកុម្ភៈ១៩៧៩ ។ សន្ធិសញ្ញានេះអនុញ្ញាតឱ្យវៀតណាមមានសិទ្ធិដាក់ទីប្រឹក្សារបស់ខ្លួននៅកម្ពុជា ។

ទ្រង់ទ្រាយទីពីរនៃអាណានិគមកម្ម គឺការវិលត្រឡប់មកកម្ពុជាវិញនៃជនស៊ីវិលយួនរាប់ម៉ឺនសែននាក់ចាប់តាំងពីឆ្នាំ១៩៧៩មក ។ រដ្ឋាភិបាលយួនទាមទារថា ជនជាតិវៀតណាមទាំងនោះ សុទ្ធតែជានិគមជនវៀតណាមធ្លាប់រស់នៅប្រទេសកម្ពុជា មុនឆ្នាំ១៩៧៥ ហើយដែល ឬមួយបានរត់ភៀសខ្លួនទៅស្រុកយួន នៅសម័យកាប់សម្លាប់របស់លន់ណុលឆ្នាំ១៩៧០ ឬមួយត្រូវចាប់បញ្ជូនទៅស្រុកយួនវិញដោយខ្មែរក្រហម ក្រោយឆ្នាំ១៩៧៥ ។ ប៉ុន្តែ បើតាមការសង្កេតរបស់អ្នកឆ្លងឆ្លើយព័ត៌មានបរទេសនៅកម្ពុជា និងតាមកិច្ចសម្ភាសជាមួយជនភៀសខ្លួននៅតាមព្រំដែនខ្មែរ-ថៃបានឱ្យដឹងថា ជនជាតិយួនទាំងនោះភាគច្រើនជាអ្នកចំណូលថ្មី ។ ជាតិពន្ធុវិទូបារាំង ម៉ារី អាឡិចសង់ឌ្រីន ម៉ារតាំង( Marie Alexandrine Martin) បានវាយតម្លៃថា ចាប់តាំងពីឆ្នាំ១៩៧៩មក និគមជនយួនរស់នៅប្រទេសកម្ពុជាមានចំនួនពី ៤០០ពាន់ទៅ៦០០ពាន់នាក់ ។ ក្រិត្យមួយ ចុះខែកញ្ញា១៩៨៣ បានចែងថា៖ ខ្មែរត្រូវចែកដីឱ្យប្រជាជនវៀតណាមនៅ ; ត្រូវជួយសម្រួលជីវភាពដល់ពួកគេ និងជួយសង់ផ្ទះឱ្យពួកគេផង ។ ជាមួយគ្នានោះដែរ ភូមិឃុំនៅតាមជនបទនីមួយៗមានភារកិច្ចត្រូវទទួលយកគ្រួសារវៀតណាមមួយចំនួនទៀត ។ ដើម្បីជាសញ្ញានៃអំណាចអាណានិគមរបស់ខ្លួន កងទ័ពវៀតណាមបានកេណ្ឌប្រជាជនខ្មែរឱ្យបំពេញគម្រោងការយោធា ដូច

**ជា ការរាយគ្រាប់មីន និងការជីកប្រឡាយនៅតាមព្រំដែនខ្មែរ-ថៃជាដើម ( ផែនការ ក៥ )។**

ថ្វីបើគេអះអាងថា មករំដោះប្រជាជនខ្មែរពីអំពើឃោរឃៅរបស់ប៉ុលពតក៏ដោយ ប៉ុន្តែអស់រយៈដប់ពីរឆ្នាំហើយ យួននៅតែចចេសទាមទារថា ដាច់ខាត កម្ពុជាមិនអាចមានរដ្ឋាភិបាលណាទៀតក្រៅពីរដ្ឋាភិបាលកុម្មុយនិស្តដែលគេតម្រូវដាក់ឱ្យនេះទេ ។ ផលវិបាកនយោបាយនៃអំពើឈ្លានពានរបស់យួននាសម័យនោះ បានត្រូវគេមើលឃើញថាជា "ស្ថានការណ៍មិនងាកបកក្រោយវិញឡើយ" ។ នេះមានន័យថា មេដឹកនាំនយោបាយមិនមែនកុម្មុយនិស្តសុទ្ធសាធណាក៏ដោយ ( ជាអាទិ៍សម្តេចនរោត្តមសីហនុ សឺនសាននិងមន្ត្រីជាន់ខ្ពស់ ) មិនអាចដើរតួដោយឯករាជក្នុងឆាកនយោបាយនៅកម្ពុជាបានឡើយ ។ ចំពោះការទទួលយកផែនការសន្តិភាពរបស់ អ.ស.ប.នៅឆ្នាំ១៩៩១ វៀតណាមបានបញ្ជាក់ចំពោះសម្តេចសីហនុនិងសឺនសានថា បើមេខ្មែរតស៊ូទាំងពីរនេះមិនចូលរួមជាមួយនឹងប៉ុលពត និង"បនប្រល័យពូជសាសន៍ "ទេនោះ ពួកគេអាចដើរតួជាតំណាងបាននៅក្នុងរដ្ឋកម្ពុជា ។

ថ្វីបើវៀតណាមត្រូវបង្ខំចិត្តបោះបង់ការកាន់កាប់ផ្ទាល់នៅកម្ពុជាក៏ដោយ ក៏បក្សកុម.ដែលគេលើកបន្តុប ដឹកនាំដោយ ហ៊ុនសែន មានលទ្ធភាពអាចក្តាប់អំណាចនៅក្នុងប្រទេសបានជាច្រើនឆ្នាំ តាមរយៈរដ្ឋប្រហាររបស់ ហ៊ុនសែន ខែកក្កដា១៩៩៧ ។ ការក្តោបអំណាចនយោបាយរបស់ហ៊ុនសែន បានបន្តជានាទូវឥទ្ធិពលវៀតណាមមកលើកម្ពុជា។

## ៧-បរាជ័យរបស់ខ្មែរក្រហម ក្នុងយុទ្ធសាស្ត្រដើម្បីរស់ ៖

នៅឆ្នាំ១៩៨២ ក្រោមការទូន្មាន (បើសិនមិនមែនជាការកៀបសង្កត់ ) ពីអ្នកជួយសង្គ្រោះ ចិននិងថៃ ក្នុងផ្នែកយោធានិងការទូត ពួកខ្មែរក្រហមបានចូលរួមសម្ពន្ធភាពជាមួយក្រុមខ្មែរមិនមែនកុម.ពីរទៀត ( រណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរដឹកនាំដោយអតីតៈនាយករដ្ឋមន្ត្រីសឺនសាន និង រណសិរ្សរួបរួមជាតិដើម្បី កម្ពុជាឯករាជ្យ អព្យាក្រឹត សន្តិភាព និងសហប្រតិបត្តិការ : រ.រ.ជ.ក.ឯ.អ.ស.ស. ត្រូវនឹងភាសាបារាំងថា Front Uni National pour un Cambodge Indépendant, Neutre, Pacifique, Et Coopératif : FUNCINPEC ហើយដែលត្រូវគេហៅជាទូទៅថា ហ្វ៊ុនស៊ិនប៉ិច ដឹកនាំដោយអ្នកសីហនុនិយមមួយចំនួន ) ។ ខ្មែរទាំងបីក្រុមបាន

រួមគ្នាបង្កើតរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ( រ.ច.ក.ប. ) ដែលមានតំណាងនៅ អ.ស.ប. ។ ពីទីតាំងជម្រកក្នុងទឹកដីថៃ និងពីមូលដ្ឋានសឹកដែលតាំងក្នុងព្រៃជ្រៅនៅតំបន់ទល់ដែនខ្មែរថៃ ក្រុមខ្មែរក្រហមនិងសម្ព័ន្ធមិត្តបានធ្វើសង្គ្រាមទ័ពព្រៃអស់មួយទសវត្សរ៍ ជាមួយនឹងកងទ័ពវៀតណាមនិងក្រុមខ្មែរកុម្មុ.ដែលយួនលើកបន្តុបនៅភ្នំពេញ ។

សង្គ្រាមទ័ពព្រៃចេះតែប្រព្រឹត្តទៅដោយបានជោគជ័យតិចតួចស្តួចស្តើង រហូតទាល់តែដល់ពេលនៃការរលំរលាយរបបកុម្មុ. នៅអឺរ៉ុបខាងកើត និងនៅ ស.ស.ស.ស. ។ ការបន្ថយជំនួយសូវៀតពីវៀតណាម បានជម្រុញឱ្យមានការដកកងទ័ពវៀតណាមចេញពីកម្ពុជា ហើយបានបង្ខំក្រុមវិវាទខ្មែរទាំងអស់ឱ្យព្រមទទួលយកនូវដំណោះស្រាយសន្តិភាពជាមួយនឹងការរៀបចំបោះឆ្នោតជាសាកលមួយ ក្រោមការត្រួតពិនិត្យរបស់តំណាងអ.ស.ប. ដែលមានឈ្មោះថា **អាជ្ញាធរអន្តរកាលនៃអង្គការសហប្រជាជាតិនៅកម្ពុជា** ( United Nations Transitional Authority in Cambodia : UNTAC ) ដែលត្រូវគេស្គាល់ជាទូទៅថា **អ៊ុនតាក់** ។ មុនដំបូង ខ្មែរក្រហមយល់ព្រមតាមផែនការរបស់ អ.ស.ប. ដែលមេដឹកនាំរបស់គេបានចុះហត្ថលេខានៅទីក្រុងប៉ារីស ក្នុងខែតុលា ១៩៩១ ។ នៅពេលអ៊ុនតាក់ចាប់ផ្តើមដំណើរការនៅកម្ពុជា និងដោយជឿថា ទង្វើទាំងនេះជាការផ្អៀងទៅរកវៀតណាមនិងរបប**រដ្ឋកម្ពុជា** ខ្មែរក្រហមក៏សម្រេចឈប់ធ្វើសហប្រតិបត្តិការជាមួយអ៊ុនតាក់ ។

ការបោះឆ្នោតបានប្រព្រឹត្តទៅដោយគ្មានការចូលរួមពីខ្មែរក្រហម ។ អ្នកបោះឆ្នោតភាគច្រើនបានជ្រើសរើសយកគណបក្សរាជានិយម **ហ្វ៊ុនស៊ិនប៉ិច** ដែលដឹកនាំដោយ នរោត្តម រ៉ាណារិទ្ធ កូនរបស់សម្តេចសីហនុ ។ បើទោះជាមានការបំភិតបំភ័យយ៉ាងសម្បើមពីអាយ៉ងហាណូយនៅភ្នំពេញ ក៏ពួកគេបានសន្ទឹកឆ្នោតត្រឹមតែ៣៨%ប៉ុណ្ណោះ ។ ថ្វីបើ អ.ស.ប.ដាក់ក្រុមជម្លោះទាំងអស់ឱ្យនៅក្នុងភាពអព្យាក្រឹតក៏ដោយ ក៏ពួកអ្នកចាញ់ដែលមានកម្លាំងប៉ូលីសនិងទាហាន មិនព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតឡើយ ។ **ហ៊ុនសែន** គំរាមថានឹងមានសង្គ្រាមស៊ីវិល ។ ដើម្បីចៀសវាងសង្គ្រាមសាជាថ្មី សម្តេចសីហនុសុខចិត្តអនុញ្ញាតឱ្យក្បាលម៉ាស៊ីននៃ **បក្សប្រជាជនបដិវត្តកម្ពុជា / រដ្ឋកម្ពុជា** កាន់ក្រសួងសំខាន់ៗ រួមទាំងក្រសួងនគរ

បាលនិងក្រសួងការពារជាតិផង ចំណែកឯមេដឹកនាំរបស់គេក៏ត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងការបង្កើតរដ្ឋាភិបាល "បង្រួបបង្រួមជាតិ" មួយ ជាមួយពួកអ្នកឈ្នះទៀត ។

ថ្វីបើរដ្ឋាភិបាលថ្មីនេះបានចេញរួចពីការរាំងស្ទះ និងមិនបានធ្វើឱ្យទ័ពខ្មែរក្រហមបរាជ័យក៏ដោយ ក៏វាបានបញ្ចុះបញ្ចូលខ្មែរក្រហមមួយចំនួនធំឱ្យរត់ចោលជួរដែរ ។ ក្នុងន័យនេះ ដំណើរការបោះឆ្នោតជាគោលការមួយដែលជួយរំលាយកងទ័ពខ្មែរក្រហមក្រោមការដឹកនាំរបស់ប៉ុលពត ។ ចន្លោះឆ្នាំ១៩៩៣ និង១៩៩៦ យោធាខ្មែរក្រហមរាប់ពាន់នាក់បាននាំគ្នារត់ផ្តាច់ខ្លួនជាបន្តបន្ទាប់ ។ លុះមកដល់ឆ្នាំ១៩៩៦ ទើបសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និងអតីតៈរដ្ឋមន្ត្រីក្រសួងការបរទេស **អៀងសារី** បាននាំគ្នាចុះចូលជាមួយរដ្ឋាភិបាល ។

នៅចុងឆ្នាំ១៩៩៦ កងទ័ពខ្មែរក្រហមនៅសល់តែស្រមោលប៉ុណ្ណោះ ហើយគ្មានលទ្ធភាពអាចនឹងដណ្តើមយកអំណាចបានវិញឡើយ ។ ទំនាស់ផ្ទៃក្នុង និងការមិនទុកចិត្តគ្នាឯងនៅក្នុងបក្ស បណ្តាលឱ្យប៉ុលពតបញ្ជាឱ្យគេធ្វើឃាតកូឈួយរបស់ឯង **សុនសេន** (អតីតៈរដ្ឋមន្ត្រីការពារជាតិ) និងក្រុមគ្រួសារទាំងមូល ។ ទីបំផុត ប៉ុលពតបានត្រូវចាប់ខ្លួន និងត្រូវដកអំណាចចេញដោយបក្សពួករបស់គាត់ ។

ប៉ុលពតត្រូវចាប់ឃុំឃាំងជាងមួយឆ្នាំ ដោយអតីតៈយុទ្ធមិត្ត **ម៉ុក**(តាម៉ុក)និង **នួនជា** ក្នុងមូលដ្ឋានមួយ នាតំបន់ព្រៃជ្រៅឆ្ងាយដាច់ស្រយាល ។ ចលនាខ្មែរក្រហមបានត្រូវបាក់បែកឯការសុំចុះចូលជាមួយរបបភ្នំពេញចេះតែមានជាបន្ត ។ ក្រោយពេលបានឮពត៌មានតាមវិទ្យុថា ស.រ.អ. មានផែនការរកចាប់ខ្លួនគាត់ ដើម្បីបញ្ជូនទៅកាត់ទោសនៅតុលាការអន្តរជាតិ ប៉ុលពតក៏បានចូលមរណភាព នៅថ្ងៃ១៥មេសា ១៩៩៨ ។ ព្រឹត្តិការណ៍នេះ បានធ្វើឱ្យប៉ុលពត ដែលជាអ្នកផ្តើមរឿងជាមួយវៀតណាម ដកខ្លួនផុតពីឆាកនយោបាយខ្មែរ ។

**៨-សេចក្តីសន្និដ្ឋាន ៖**

ផលវិបាកនយោបាយចុងក្រោយ នៃការឈ្លានពានរបស់វៀតណាមនៅកម្ពុជា មិនទាន់បានសម្រេចចប់សព្វគ្រប់នៅឡើយទេ ដូច្នេះ វាដូចជារហ័សពេកក្នុងការវាយតម្លៃឱ្យ

បានជាក់លាក់ចំពោះអំពើឈ្លានពាននេះ ។ ប៉ុន្តែ គេអាចនិយាយបានថា មេដឹកនាំខ្មែរក្រ-ហមធំៗ ជាពិសេសប៉ុលពត ត្រូវទទួលការខាតបង់ស្ទើរតែទាំងស្រុង ។ អ្នកដែលខ្សោយជាងគេ ក្នុងចំណោមគូវិវាទទាំងបួនក្រុម បានទទួលនូវការឈឺចាប់ជាអតិបរមា ។

គេមិនបាច់ឆ្ងល់ឡើយថា យួនកុម.ពេញចិត្តនឹងកូនជឹងកម្ពុជារបស់គេ (ដែលក្រោយឆ្នាំ១៩៩១បានងាកទៅរកជំនួយយុទ្ធសាស្ត្រពីប្រទេសកុម្មុយនិស្តនៅអឺរ៉ុបខាងកើត) ដែលបានសម្រេចក្នុងការដណ្តើមអំណាចនយោបាយ ។ ប៉ុន្តែ គេក៏មិនប្រាកដដែរទេ ថាតើការដណ្តើមបានអំណាចទាំងពីរលើកគឺ **រដ្ឋប្រហារបិទមុខ** ឆ្នាំ១៩៩៣-៩៧ **និង រដ្ឋប្រហារបើកមុខ** ខែកក្កដា ឆ្នាំ១៩៩៧ អាចនឹងមានភាពរឹងមាំក្នុងរយៈពេលវែងដែរឬទេ ។ នៅក្នុងបរិបទនៃលទ្ធផលការបោះឆ្នោតឆ្នាំ១៩៩៣ និងការបន្លំសន្លឹកឆ្នោតឆ្នាំ១៩៩៨ សកម្មភាពទាំងនេះបានបង្ហាញយ៉ាងច្បាស់នូវភាពមិនស្របច្បាប់របស់ **របបហ៊ុនសែន** ។

ជាតុពិតបានបញ្ជាក់ថា ការឈ្លានពាននិងការកាន់កាប់កម្ពុជា បានធ្វើឱ្យវៀតណាមបាត់បង់ជីវិតមនុស្ស និងធនធានដ៏ច្រើន ហើយនិងបានធ្វើឱ្យមានការយឺតយ៉ាវក្នុងវិស័យអភិវឌ្ឍន៍សេដ្ឋកិច្ចអស់ជាងមួយទសវត្សរ៍ ។ ជាពិសេស ក្រោយការដួលរលំនៃរបបកុម្មុយ-និស្តនៅអឺរ៉ុបខាងកើត និងក្រោយពេលដែលសូវៀតបានជម្រុញមេដឹកនាំវៀតណាមឱ្យធ្វើការសម្រុះសម្រួលជាមួយចិនមក ភាពតានតឹងរវាងប្រទេសជិតខាងទាំងពីរ ក៏បានថយចុះយ៉ាងសម្បើម ។ ប៉ុន្តែការសម្រុះសម្រួលត្រូវបានសម្រេចទៅតាមលក្ខខណ្ឌរបស់ចិន ហើយនិងការបាក់មុខមាត់ខ្លះត្រូវបានទៅលើ នាគ (Dragon) ណាដែលតូចជាងគេ ៕

**ចប់**

******

♥

# កំណត់សម្គាល់

១-(ទំព័រ៨៥): តាមឯកសារប្រវត្តិសាស្ត្រខ្មែររបស់លោកត្រឹងងា ទំព័រ១៤៧និយាយថា:

នៅគ.ស.១៨២០ មានភិក្ខុមួយអង្គនាម កែគង់ បួសនៅវត្តសំបួរ ក្នុងខេត្តភ្នំពេញ បានតាំងខ្លួនជាអ្នកសិល្ប៍ក្លូវិសេស ទៅបញ្ចុះបញ្ចូលអស់រាស្ត្រនៅខេត្តបាភ្នំ រួចទៅរួបរួមនឹងសម្តេចចៅពញាតី ឧកញ្ញានវេន្ទគល់ និងនាយកែព្រាលលើកទ័ពទៅកាប់សម្លាប់យួនអស់ជាច្រើន ។ ពេលនោះ មេទ័ពយួននៅព្រៃនគរប្រើឱ្យនាំពល៣០០០នាក់ លើកមកភ្នំពេញរួមជាមួយនឹងព្រះឧទ័យរាជា ហើយបានចាប់ភិក្ខុកែគង់យកទៅសម្លាប់ចោល ៕